ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ
អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន

# របាយការណ៍
# ស្តីពី
# ការសិក្សាវាយតម្លៃសមត្ថភាពគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់
# និង
# យុទ្ធសាស្ត្រអភិវឌ្ឍន៍សមត្ថភាព

ខែធ្នូ ឆ្នាំ២០០៩

រៀបចំដោយក្រុមការងារកម្មវិធីសិទ្ធិកុមារ ក្រសួងមហាផ្ទៃ, UNICEF និង VBNK

# អារម្ភកថា

នៅក្នុងការគាំទ្រ និងកសាងសមត្ថភាពក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីឱ្យពួកគាត់អាចបំពេញតួនាទី និងភារកិច្ចរបស់ខ្លួនដែលបានកំណត់ក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ បានទទួលការគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុជាច្រើនពីបណ្តាគម្រោង នៃដៃគូរអភិវឌ្ឍន៍នានា។ ដោយឡែក កម្មវិធីសិទ្ធិកុមារនៃអង្គការយូនីសេហ្វ ក៏បានជួយគាំទ្រការកសាងសមត្ថភាពក្រុមប្រឹក្សាឃុំ សង្កាត់នៅក្នុងខេត្ត ៦ (ខេត្តព្រៃវែង, ខេត្តស្វាយរៀង, ខេត្តកំពង់ស្ពឺ, ខេត្តកំពង់ធំ, ខេត្តឧត្តរមានជ័យ, និងខេត្តស្ទឹងត្រែង) ដោយបានសាកល្បងបង្កើតគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ ចំនួន១៣០ឃុំ នៅក្នុងខេត្តទាំង៦ នៅឆ្នាំ២០០៤ ក្នុងគោលបំណងជួយដល់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការបំពេញតួនាទី និងភារកិច្ចរបស់ខ្លួនដែលពាក់ព័ន្ធនឹងបញ្ហានារី និងកុមារ។

ផ្អែកតាមបទពិសោធន៍នេះ គណៈកម្មាធិការជាតិដឹកនាំកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ បានទទួលស្គាល់ភាពសំខាន់នៃគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ ហើយបានសម្រេចឱ្យបង្កើតនូវគណៈកម្មាធិការនេះជាផ្លូវការនៅទូទាំងប្រទេសនៅឆ្នាំ២០០៧ តាមរយៈសេចក្តីណែនាំ លេខ ០៨២ សណន/គ.ជ.វ.វ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០០៧។

ដោយមានគាំទ្របច្ចេកទេស និងថវិកាពីអង្គការយូនីសេហ្វ(UNICEF) និងវិទ្យាស្ថានបំរើអ្នកសំរបសំរួលការងារអភិវឌ្ឍន៍ (VBNK) ក្រុមការងារកម្មវិធីសិទ្ធិកុមារ ក្រសួងមហាផ្ទៃ បានរៀបចំការសិក្សាមួយដើម្បីធ្វើការវាយតម្លៃសមត្ថភាពគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ដែលបានបង្កើតសាកល្បងនៅឆ្នាំ២០០៤រហូតដល់មានការបង្កើតជាផ្លូវការនៅទូទាំងប្រទេសក្នុងគោលបំណងដើម្បីវាស់វែងនូវសមត្ថភាពរបស់គណៈកម្មាធិការនេះដោយបានរៀបចំជារបាយការណ៍នេះឡើង ដែលបង្ហាញពីបទពិសោធន៍ល្អៗ និងគម្លាតរវាងសមត្ថភាព ចំណេះដឹងជំនាញ និងបទពិសោធន៍ក្នុងការអនុវត្តមុខងារ ព្រមទាំងលើកឡើងជាយុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍន៍សមត្ថភាពគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់។

អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ សង្ឃឹមថា ឯកសាររបាយការណ៍នេះ នឹងជួយឱ្យអ្នកសិក្សា អ្នកពាក់ព័ន្ធក្នុងការគាំទ្រ និងកសាងសមត្ថភាពក្រុមប្រឹក្សាឃុំ សង្កាត់ និងគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ នឹងធ្វើជាមូលដ្ឋានសម្រាប់ការរៀនសូត្រ និងធ្វើជាបទពិសោធន៍ ចំណេះដឹងសម្រាប់ការគាំទ្រ និងការរៀបចំពង្រឹងសមត្ថភាពគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ក្នុងបំពេញតួនាទីរបស់ខ្លួន ដើម្បីដោះស្រាយបញ្ហានារី និងកុមារ ឱ្យកាន់តែមានប្រសិទ្ធភាព។

**អគ្គនាយក**

# ការសិក្សាវាយតម្លៃសមត្ថភាព

## គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់

ខែធ្នូ ឆ្នាំ២០០៩




unicef VBNK

## សេចក្ដីថ្លែងអំណរគុណ

ការសិក្សាវាយតម្លៃសមត្ថភាពគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ (គ.ក.ន.ក) នេះ អាចសម្រេចទៅបានអាស្រ័យដោយមានការចូលរួមយ៉ាងសកម្មពីមន្ត្រី នៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ មន្ត្រីអង្គការយូនីសេហ្វ (**UNICEF**) និងបុគ្គលិកវិទ្យាស្ថានបំរើអ្នកសំរបសំរួលការងារអភិវឌ្ឍន៍ (**VBNK**) ដូចមានរាយនាមដូចខាងក្រោម:

- លោក សេង សីលា — ប្រធានការិយាល័យផែនការ ស្ថិតិ និងព័ត៌មាន, DoLA/MoI
- លោក ជេដ្ឋ គីមជុង — អនុប្រធានការិយាល័យតាមដានត្រួតពិនិត្យ និងគាំទ្រឃុំសង្កាត់,**DoLA/MoI**
- លោក ហឿន ប្រណិត — អនុប្រធានការិយាល័យស្រាវជ្រាវបច្ចេកទេស, DoLA/MoI
- លោក គយ ប៊ួយ — អនុប្រធានការិយាល័យហិរញ្ញវត្ថុ, DoLA/MoI
- លោក ថេង កន្និ — អនុប្រធានការិយាល័យអគ្រានុកូលដ្ឋាន, DoGA/MoI
- លោក សាយ ស៊ីនួន — មន្ត្រីការិយាល័យអប់រំ និងកសាងសមត្ថភាព, DoLA/MoI
- លោក ហួ បូ — មន្ត្រីការិយាល័យផែនការ ស្ថិតិ និងព័ត៌មាន, DoLA/MoI
- លោក ខៀវ ណាវ៉ា — មន្ត្រីការិយាល័យផែនការ ស្ថិតិ និងព័ត៌មាន, DoLA/MoI
- លោក អ៊ុក សុត្ថា — មន្ត្រីការិយាល័យតាមដានត្រួតពិនិត្យ និងគាំទ្រឃុំ សង្កាត់ , DoLA/MoI
- លោក ព្រំ ប៊ុនធឿន — មន្ត្រីការិយាល័យអប់រំ និងកសាងសមត្ថភាព, DoLA/MoI
- អ្នកស្រី រស់ ស៊ីវណ្ណា — មន្ត្រីគម្រោងអភិបាលកិច្ចមូលដ្ឋានដើម្បីសិទ្ធិកុមារ, កម្មវិធីសិទ្ធិកុមារ នៃអង្គការយូនីសេហ្វ
- លោក យី កុសលវឌ្ឍនៈ — មន្ត្រីគម្រោងអភិបាលកិច្ចមូលដ្ឋានដើម្បីសិទ្ធិកុមារ, កម្មវិធីសិទ្ធិកុមារ នៃអង្គការយូនីសេហ្វ
- Ms. Marija De winj — មន្ត្រីកម្មវិធីកិច្ចការពារកុមារ នៃអង្គការយូនីសេហ្វ
- Mr. Graeme Storer — នាយកវិទ្យាស្ថានបំរើអ្នកសំរបសំរួលការងារអភិវឌ្ឍន៍ (**VBNK**)
- Mr. Arthur DelVecchio — ទីប្រឹក្សាបច្ចេកទេស, **VBNK**
- អ្នកស្រី ម៉ូវ លាន — ប្រធានក្រុមសម្របសម្រួល, **VBNK**
- អ្នកស្រី ម៉ែ ស្រីលន់ — អ្នកសម្របសម្រួល, **VBNK**
- ក. សង់ ប៉ែរណាឌីន — អ្នកសម្របសម្រួល, **VBNK**
- លោក ជី សុធី — ប្រធានក្រុមសម្របសម្រួល, **VBNK**

ក្រុមសិក្សាវាយតម្លៃ សូមថ្លែងអំណរគុណចំពោះមន្ត្រីរាជការ និងបុគ្គលិកទាំងអស់ដែលបានរួមចំណែកក្នុងការសិក្សានេះ ជាពិសេសសូមថ្លែងអំណរគុណចំពោះអ្នកពាក់ព័ន្ធ ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការចូលរួមពិភាក្សា ផ្តល់បទសម្ភាសន៍ និងកិច្ចប្រជុំពិគ្រោះយោបល់នានា នៅក្នុងខេត្តកំពង់ស្ពឺ ខេត្តកំពង់ធំ ខេត្តឧត្តរមានជ័យ ខេត្តកំពង់ចាម និងខេត្តរតនគិរី ព្រមទាំងដៃគូអភិវឌ្ឍន៍មួយចំនួននៅរាជធានីភ្នំពេញ ដែលក្នុងនោះរួមមាន តំណាងមកពីសហគមន៍ សមាជិក គ.ក.ន.ក អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ អង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត មន្ត្រីសម្របសម្រួលថ្នាក់ខេត្ត ស្រុក និងមន្ត្រីបង្គោលកម្មវិធីសិទ្ធិកុមារថ្នាក់ខេត្ត ស្រុក មន្ទីរវិស័យពាក់ព័ន្ធ ដែលបានចូលរួមនៅក្នុងការអភិវឌ្ឍសមត្ថភាពរបស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ព្រមទាំងអង្គការសង្គមស៊ីវិលនានាដែលបាន និងកំពុងធ្វើការពាក់ព័ន្ធទៅនឹងបញ្ហាស្ត្រី និងកុមារនៅតាមឃុំ សង្កាត់។

# សេចក្តីសង្ខេប

អនុលោមតាមមាត្រា២៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងសេចក្តីណែនាំលេខ ០៨២ សណន/គ.ជ.វ.វ ចុះថ្ងៃទី ០៨ ខែសីហា ឆ្នាំ២០០៧ ស្តីពីការរៀបចំ និងបង្កើតគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារនៅគ្រប់ឃុំ សង្កាត់ទូទាំងប្រទេស ឃុំ សង្កាត់បានបង្កើតគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ ឃុំ សង្កាត់(គ.ក.ន.ក) ក្នុងគោលបំណងដើម្បីផ្តល់យោបល់ និងជួយកិច្ចការជូនក្រុមប្រឹក្សាឃុំ សង្កាត់ ពាក់ព័ន្ធបញ្ហាស្ត្រី និងកុមារ នៅក្នុងឃុំ សង្កាត់របស់ខ្លួន។ គ.ក.ន.ក នេះ មានសមាសភាព មេឃុំ ចៅសង្កាត់ ជំទប់ទី២ ចៅសង្កាត់រងទី២ ស្មៀនឃុំ សង្កាត់ អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ជាសមាជិកស្ត្រីដែលជ្រើសចេញពីសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ឬជាស្ត្រីដែលជ្រើសរើសចេញក្រៅពីសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ នាយប៉ុស្តិ៍នគរបាលរដ្ឋបាល នាយកសាលា ប្រធានមណ្ឌលសុខភាព និងមេភូមិ ឬអនុប្រធានភូមិគ្រប់ភូមិ។

គ.ក.ន.ក មានតួនាទីសម្របសម្រួល តាមដានត្រួតពិនិត្យ រាយការណ៍ និងដោះស្រាយបញ្ហាពាក់ព័ន្ធស្ត្រី និងកុមារ ដើម្បីឱ្យស្ត្រី និងកុមារទទួលបាននូវសេវាសង្គមដ៏សមស្រប និងប្រកបដោយគុណភាព។

តាមរយៈការសិក្សាស្រាវជ្រាវជាច្រើនបានបង្ហាញថា គ.ក.ន.ក កំពុងទទួលបានផលជាវិជ្ជមាន ទីមួយ គ.ក.ន.ក ដែលបានបង្កើតចាប់តាំងពីឆ្នាំ២០០៥បានផ្តល់អាទិភាពខ្ពស់ទៅលើបញ្ហាពាក់ព័ន្ធស្ត្រី និងកុមារច្រើនជាង គ.ក.ន.ក ដែលបានបង្កើតក្រោយឆ្នាំ២០០៧។ ទីពីរ សកម្មភាពរបស់ គ.ក.ន.ក បានក្លាយជាកត្តាកំណត់ដ៏សំខាន់មួយក្នុងការបញ្ចូលបញ្ហារបស់ស្ត្រី និងកុមារទៅក្នុងរបៀបវារៈនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ព្រមទាំងបញ្ចូលបញ្ហារបស់ស្ត្រី និងកុមារទៅក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរបស់ឃុំ សង្កាត់ផងដែរ។ ទីបី គ.ក.ន.ក បាន និងកំពុងបំពេញតួនាទីយ៉ាងសំខាន់ក្នុងការជួយពង្រឹងអាណត្តិរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ដើម្បីបង្កើនការទទួលបាននូវសេវាសង្គមនានានៅមូលដ្ឋាន។ ទីបួន សមាជិក គ.ក.ន.ក បានដើរតួនាទីក្នុងការទាក់ទាញការគាំទ្រពាក់ព័ន្ធនឹងបញ្ហាស្ត្រី និងកុមារនៅក្នុងសហគមន៍។ ទីប្រាំ គ.ក.ន.ក បានធ្វើកិច្ចសហការជាមួយអ្នកផ្តល់ សេវាផ្សេងៗ ដូចជា សាលារៀន មណ្ឌលសុខភាព ប៉ុស្តិ៍នគរបាលរដ្ឋបាល ។ល។

គ.ក.ន.ក បានរៀបចំចាត់ចែងអនុវត្តសកម្មភាពជាច្រើនដូចជា ៖

- ជំរុញឱ្យមានតម្រូវការក្នុងការប្រើប្រាស់សេវា និងបង្កើនការអនុវត្តថែទាំសុខភាពគ្រួសារ ដូចជា លើកទឹកចិត្តឱ្យកុមារបានទទួលការចាក់វ៉ាក់សាំងឱ្យបានគ្រប់ចំនួន ជំរុញការចុះសំបុត្រកំណើតរបស់កុមារឱ្យទាន់ពេលវេលា រៀបចំយុទ្ធនាការចុះឈ្មោះចូលរៀន គាំទ្រការបង្កើតថ្នាក់មត្តេយ្យសិក្សាសហគមន៍ និងជ្រើសរើសគ្រូមត្តេយ្យសិក្សាសហគមន៍ លើកកម្ពស់ការយល់ដឹងពីអំពើហិង្សាក្នុងគ្រួសារ និងជំរុញឱ្យមានការបំបៅកូនដោយទឹកដោះម្តាយ។
- បានអនុវត្តសាកល្បងនូវសកម្មភាពមួយចំនួនក្នុងការដោះស្រាយគម្លាត នៃការទទួលបានសេវានានារបស់គ្រួសារងាយរងគ្រោះ ដូចជា ការផ្តល់មធ្យោបាយ ឬសោហ៊ុយធ្វើដំណើរសម្រាប់បញ្ជូនស្ត្រីមានផ្ទៃពោះទៅ

សម្រាលកូន និងទៅពិនិត្យផ្ទៃពោះនៅមណ្ឌលសុខភាព ផ្តល់អាហារបំប៉នសម្រាប់ស្ត្រីមានផ្ទៃពោះ និងផ្តល់កង់ឱ្យកុមារដែលរស់នៅភូមិដាច់ស្រយាលសម្រាប់ជាមធ្យោបាយទៅសាលារៀន។

- គាំទ្រសេវានានា ដូចជា ការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យនៅក្នុងសាលារៀន និងមណ្ឌលសុខភាព
- គាំទ្រផែនការសកម្មភាព និងត្រួតពិនិត្យលើគុណភាពសេវានៅក្នុងមូលដ្ឋាន ដូចជា ការត្រួតពិនិត្យលើការងាររបស់ក្រុមទ្រទ្រង់សុខភាពភូមិ ការតាមដានត្រួតពិនិត្យវត្តមានរបស់គ្រូមត្តេយ្យសិក្សាសហគមន៍ និងការជំរុញឱ្យមានសមធម៌យេនឌ័រក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ សង្កាត់។

ទោះជាយ៉ាងណាក៏ដោយសមត្ថភាពរបស់សមាជិក គ.ក.ន.ក គឺនៅមិនទាន់មានភាពស្មើគ្នាទេពីឃុំ សង្កាត់មួយទៅឃុំ សង្កាត់មួយ ពីខេត្តមួយទៅខេត្តមួយ។ មូលហេតុទីមួយ គឺ គ.ក.ន.ក មួយចំនួនបានបង្កើតឡើងជាយូរឆ្នាំមកហើយ រីឯ គ.ក.ន.ក មួយចំនួនផ្សេងទៀតទើបតែបានបង្កើត។ មូលហេតុទីពីរ គឺ គ.ក.ន.ក មានការអភិវឌ្ឍខ្លួនអាស្រ័យលើកត្តាមួយចំនួន ដូចជា បទពិសោធន៍ ការប្តេជ្ញាចិត្តខ្ពស់ និងភាពជឿជាក់របស់សមាជិកនីមួយៗ ព្រមទាំងកត្តាបរិយាកាសផងដែរ (ការទទួលស្គាល់ ការផ្តល់តម្លៃ និងការទទួលយកយោបល់ ដើម្បីផ្សារភ្ជាប់ជាមួយ គ.ក.ន.ក/អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារនៅក្នុងឃុំ សង្កាត់ ឬពីអ្នកពាក់ព័ន្ធផ្សេងទៀត)។ លើសពីនេះទៅទៀតមាន គ.ក.ន.ក ខ្លះទទួលបានការគាំទ្រពីភ្នាក់ងាររាជរដ្ឋាភិបាល ភ្នាក់ងារអន្តរជាតិ ឬអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ហើយ គ.ក.ន.ក មួយចំនួនទៀតបានទទួលការគាំទ្រតិចតួច។

ការសិក្សាវាយតម្លៃនេះ ផ្តល់ឱកាសឱ្យយើងទទួលបានទិន្នន័យ និងព័ត៌មានដែលអាចធ្វើការប្រៀបធៀបអំពីសមិទ្ធផល និងបញ្ហាប្រឈមក្នុងការបំពេញការងាររបស់ គ.ក.ន.ក នៃឃុំ សង្កាត់នីមួយៗ និងកំណត់បាននូវកត្តាជោគជ័យសំខាន់ៗដែលធ្វើឱ្យ គ.ក.ន.ក នេះមានការរីកចម្រើន និងឧបសគ្គដែលរារាំងដល់ការរីកចម្រើនរបស់ គ.ក.ន.ក ផងដែរ។

គោលបំណង នៃការសិក្សាមានពីរគឺ:

- ទីមួយ សិក្សាវាយតម្លៃសមត្ថភាពបច្ចុប្បន្ន និងរចនាសម្ព័ន្ធគាំទ្រក្នុងការបំពេញភារកិច្ចរបស់ គ.ក.ន.ក និងបង្កើតជាឯកសារបែបផែនសមត្ថកិច្ចរយៈពេលវែងដែលបង្ហាញពីរបៀបនៃការបង្កើនសមត្ថកិច្ច និងការផ្តល់ទំនុកចិត្តថែមទៀតចាប់តាំងពីការបង្កើតរហូតដល់ គ.ក.ន.ក នេះបំពេញមុខងាររបស់ខ្លួនបានពេញលេញ
- ទីពីរ បង្កើតយុទ្ធសាស្ត្រអភិវឌ្ឍសមត្ថភាពគ្រប់ជ្រុងជ្រោយមួយ ដើម្បីគាំទ្រ គ.ក.ន.ក ឱ្យបំពេញមុខងារបានពេញលេញ និងល្អប្រសើរនៅក្នុងអាណត្តិរបស់ខ្លួន។

របាយការណ៍នេះ រៀបចំតាមផ្នែកដូចខាងក្រោម:

១. ផ្នែកទី១ ផ្តល់នូវទិដ្ឋភាពទូទៅនៃដំណើរការវិមជ្ឈការ និងអាណត្តិរបស់ គ.ក.ន.ក។ ក្នុងផ្នែកនេះក៏បានកំណត់អត្ថន័យនៃពាក្យ "ការអភិវឌ្ឍសមត្ថភាព" ដែលប្រើក្នុងការសិក្សានេះសម្រាប់រៀបចំចងក្រងនូវគំនិតរបស់បុគ្គលនីមួយៗដើម្បីឆ្លើយតបទៅនឹងគំនិតផ្តួចផ្តើមនៃការអភិវឌ្ឍសមត្ថភាពដោយផ្តោតទៅលើវប្បធម៌ និងសង្គម។ ហេតុដូចនេះតម្រូវឱ្យមានការបង្ហាញឡើងនូវភាពមិនស៊ីសង្វាក់គ្នារវាងវប្បធម៌ និងការឱ្យតម្លៃនៅក្នុងសង្គមសម្រាប់ធ្វើជាដំណោះស្រាយនៅក្នុងកម្មវិធីកសាងសមត្ថភាព។

២. ផ្នែកទី២ សង្ខេបពីរបកគំហើញសំខាន់ៗ ពីការសិក្សាស្រាវជ្រាវបែបគុណភាពចំនួនបី ។ ការសិក្សាទាំងនេះមាន (១).ការសិក្សាវាយតម្លៃ គ.ក.ន.ក/អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ដែលធ្វើដោយក្រសួងមហាផ្ទៃ ក្រសួងកិច្ចការនារី និងអង្គការយូនីសេហ្វ (ក្នុងឆ្នាំ២០០៦ និង២០០៨) ។ (២).នៅឆ្នាំ២០០៩ អង្គការ UNFPA បានធ្វើការពិនិត្យឡើងវិញលើបញ្ហាប្រជាជន សុខភាពបន្តពូជ និងយេនឌ័រ ដែលបានឆ្លុះបញ្ចាំងនៅក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរបស់ឃុំ សង្កាត់ និង(៣).ការបង្ហាញពីរបកគំហើញពីការសិក្សាវាយតម្លៃបែបគុណភាពនៅក្នុងឆ្នាំ២០០៩នេះដែលបានធ្វើនៅខេត្តចំនួនប្រាំ (កំពង់ស្ពឺ, កំពង់ចាម, កំពង់ធំ, ឧត្តរមានជ័យ និងរតនគិរី ) ។

ផ្នែកទី២នេះបានរំលេចចេញនូវកត្តាជោគជ័យសំខាន់ៗចំនួនបួនរបស់ គ.ក.ន.ក: (១).ការលូតលាស់តាមដំណាក់កាលៗ និងការវិវត្តន៍ដោយខ្លួនឯង (២).ការបង្កើតទំនាក់ទំនងការងារ (៣).ការយកចិត្តទុកដាក់ក្នុងការធ្វើការងារជាក្រុម (៤).ការបង្កើតភាពជឿទុកចិត្តជាមួយសហគមន៍ និងអ្នកពាក់ព័ន្ធ។ បន្ទាប់មកធ្វើការប្រៀបធៀប និងបង្ហាញពីភាពខុសគ្នានៃរបកគំហើញនៅក្នុងការសិក្សាទាំងបួនខាងលើដើម្បីកំណត់ទម្រង់គំរូ និងសង្ខេបអំពីអ្វីដែលរំពឹងទុកក្នុងការវិវត្តន៍ចាប់តាំងពីការបង្កើតរហូតទៅដល់ គ.ក.ន.ក អាចបំពេញមុខងារបានពេញលេញ។ បន្ទាប់មក លើកយកបញ្ហាជាក់លាក់ដែលទាក់ទងទៅនឹងការអភិវឌ្ឍសមត្ថភាពមកធ្វើការពិភាក្សាសម្រាប់ជាមូលដ្ឋាន ក្នុងការរៀបចំវិធីសាស្ត្ររៀនសូត្រតាមបែបសិស្សមជ្ឈមណ្ឌល ដើម្បីអភិវឌ្ឍសមត្ថភាព ដែលនឹងរៀបរាប់នៅក្នុងផ្នែកទី៤។

នៅក្នុងផ្នែកនេះ បញ្ចប់ដោយការសន្និដ្ឋានថា ការឱ្យតម្លៃពិតប្រាកដចំពោះ គ.ក.ន.ក និងអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ គឺការបំពេញការងារដោយមានកិច្ចសហការយ៉ាងជិតស្និទ្ធ និងទូលំទូលាយជាមួយអ្នកផ្តល់សេវានានាដើម្បីបំពេញមុខងារផ្សេងៗដូចជា ការត្រួតពិនិត្យវត្តមានសិស្សនៅតាមសាលារៀន ការសម្របសម្រួលឱ្យស្ត្រីមានផ្ទៃពោះ នៃគ្រួសារក្រីក្រទៅទទួលសេវាថែទាំសុខភាពនៅមណ្ឌលសុខភាព ឬក៏គាំទ្រដល់ការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យនៅក្នុងមណ្ឌលសុខភាព។ ដូចនេះ គ.ក.ន.ក និងអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ បានជួយជំរុញឱ្យមានតម្រូវការក្នុងការទទួលបាន និងប្រើប្រាស់សេវាសង្គមនានា និងដោះស្រាយនូវបញ្ហាគម្លាតមួយចំនួន។ ទន្ទឹមនឹងនេះដែរ ពួកគាត់ក៏បានពង្រឹងបណ្តាញការងារសង្គម ដើម្បីចូលរួមចំណែកក្នុងការអនុវត្តគោលដៅអភិវឌ្ឍន៍ ដែលមានភាពជិតស្និទ្ធ និងមាននិរន្តរភាពក្នុងសង្គម ។

៣. ផ្នែកទី៣ ផ្តល់អត្ថន័យនៃពាក្យ"បែបផែនសមត្ថកិច្ច"សម្រាប់ គ.ក.ន.ក/អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់។ ក្នុងផ្នែកនេះចាប់ផ្តើមរៀបរាប់ថាតើសមត្ថកិច្ចមានន័យ និងត្រូវបានគេប្រើប្រាស់យ៉ាងដូចម្តេច។ ជារួមសមត្ថកិច្ចចំនួន១២ត្រូវបានគេកំណត់ជាក់លាក់ ហើយដាក់បញ្ចូលជា៣ក្រុម: ស្វ័យគ្រប់គ្រង ការគ្រប់គ្រងការងារទំនាក់ទំនង និងការគ្រប់គ្រងលទ្ធផលការងារ ។

ផ្នែកទី៣នេះដែរ ផ្តល់ពីរបៀបអនុវត្តជាក់ស្តែង នៃបែបផែនសមត្ថកិច្ចនៅក្នុងដំណាក់កាលរៀនសូត្រ និងការអភិវឌ្ឍ គ.ក.ន.ក ។ ឧទាហរណ៍ ការប្រាស្រ័យទាក់ទង និងការគោរព គឺជាជំនាញមូលដ្ឋានគ្រឹះ សម្រាប់ការសម្របសម្រួលដ៏មានប្រសិទ្ធភាពដែលអាចគាំទ្រដល់ការចរចារ និងការធ្វើឱ្យមានឥទ្ធិពលលើអ្នកដ៏ទៃ ។

លើសពីនេះទៀត ជំនាញវិភាគ ការចរចារ និងការធ្វើឱ្យមានឥទ្ធិពលលើអ្នកដ៏ទៃ គឺជាតម្រូវការសម្រាប់ការទាក់ទាញមតិគាំទ្រ ។ នៅផ្នែកទីបីនេះបញ្ចប់ដោយមានការបង្ហាញពីរបៀប ដែល គ.ក.ន.ក អាចប្រើប្រាស់សមត្ថកិច្ច ដូចជា ឧបករណ៍វាយតម្លៃខ្លួនឯង ដើម្បីវាស់វែងការរីកចម្រើនរបស់ខ្លួន និងកំណត់កង្វះចន្លោះសមត្ថភាព ។

៤. ផ្នែកទី៤ ផ្តល់អនុសាសន៍សម្រាប់យុទ្ធសាស្ត្រអភិវឌ្ឍសមត្ថភាពរយៈពេលវែង ។ ផ្នែកនេះចាប់ផ្តើមដោយរៀបរាប់ឡើងវិញនូវសារៈសំខាន់នៃវិធីសាស្ត្ររៀនសូត្រតាមបែបសិស្សមជ្ឈមណ្ឌលមុននឹងកំណត់បាននូវការអនុវត្តល្អៗដែលមាននាពេលបច្ចុប្បន្ននៅក្នុងប្រទេសកម្ពុជា។ ឧទាហរណ៍ វេទិកា កិច្ចសន្ទនាសហគមន៍ វគ្គបណ្តុះបណ្តាលដល់ស្ត្រីជាក្រុមប្រឹក្សាឃុំ សង្កាត់ កិច្ចការពារសង្គម ការបង្កើតផែនទីសេវាសង្គម និងវិធីសាស្ត្ររៀនសូត្រដែលបានបង្កើតឡើងក្រោមការគ្រប់គ្រង នៃកម្មវិធីសិលា ។

នៅក្នុងផ្នែកនេះដែរ កំណត់គោលការណ៍ណែនាំអំពីយុទ្ធសាស្ត្រអភិវឌ្ឍសមត្ថភាព មុននឹងលើកឡើងនូវអនុសាសន៍សម្រាប់ការបង្កើតយុទ្ធសាស្ត្រ ។ យុទ្ធសាស្ត្រសំខាន់ៗ រួមមានដូចខាងក្រោម ៖

**ក.** ការសិក្សាឱ្យបានស៊ីជម្រៅតាមរយៈការគាំទ្រ ការតាមដាន និងការឆ្លុះបញ្ចាំង គឺជាការលើកទឹកចិត្តឱ្យប្រើប្រាស់ជំនាញ ឥរិយាបថ និងអាកប្បកិរិយាក្នុងការអនុវត្តការងារជាក់ស្តែង

**ខ.** ការពង្រីកវគ្គបណ្តុះបណ្តាលដល់ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងកិច្ចសហការជាមួយក្រុមសម្របសម្រួលពហុវិស័យ

**គ.** បង្កើតក្រុមសម្របសម្រួលស្នូលមួយ ដើម្បីសម្របសម្រួលការរៀបចំឯកសារមេរៀន និងវិធីសាស្ត្របណ្តុះបណ្តាលឱ្យមានការឯកភាពគ្នា និងថាតើស្ថាប័នណាជាអ្នកទទួលខុសត្រូវក្នុងការបណ្តុះបណ្តាលដល់ក្រុមសម្របសម្រួលថ្នាក់ខេត្ត និងថ្នាក់ស្រុក ។

ផ្នែកទីបួន បញ្ចប់ដោយមានការគូសបញ្ជាក់ពីសារៈសំខាន់នៃការកសាងសមត្ថភាព និងទំនុកចិត្ត ។ ជំនាញទំនាក់ទំនង ជំនាញសម្របសម្រួល និងជំនាញប្រាស្រ័យទាក់ទង នៅតែជាមូលដ្ឋានគ្រឹះដ៏សំខាន់ សម្រាប់អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ។ ម្យ៉ាងទៀត អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ក៏នៅតែត្រូវការឱ្យមានសមត្ថភាពក្នុងការតស៊ូមតិ ការចរចារ ការធ្វើឱ្យមានឥទ្ធិពលទៅលើអ្នកដទៃ និងការទាក់ទាញមតិគាំទ្រ ដោយមានហេតុផលត្រឹមត្រូវ ។ ចំពោះសមាជិក គ.ក.ន.ក ទាំងអស់ប្រើប្រាស់ទិន្នន័យសម្រាប់វិភាគរកបញ្ហា និងដំណោះស្រាយដើម្បីបង្កើតជាសកម្មភាព និងចាត់អាទិភាព សម្រាប់ការអន្តរាគមន៍នានា នៅពេលអនាគត ។

| តារាងមាតិកា | ទំព័រ |
| --- | --- |
| អារម្ភកថា | |
| សេចក្ដីថ្លែងអំណរគុណ | ១ |
| សេចក្ដីសង្ខេប | ៣ |
| តារាងមាតិកា | ៧ |
| បញ្ជីអក្សរបំព្រួញ | ១០ |
| **ផ្នែកទី១.សាវតារ** | ១១ |
| ១.១. ទិដ្ឋភាពទូទៅ និងសនិទានភាពនៃការសិក្សាវាយតម្លៃ | ១១ |
| ១.២. គោលបំណងនៃការសិក្សាវាយតម្លៃ | ១៣ |
| ១.៣. ទំហំ និងដែនកំណត់នៃការសិក្សាវាយតម្លៃ | ១៤ |
| ១.៤. អត្ថន័យនៃការអភិវឌ្ឍសមត្ថភាព | ១៧ |
| ១.៤.១. ការយល់ឃើញជាលក្ខណៈប្រព័ន្ធ | ១៧ |
| ១.៤.២. ការអភិវឌ្ឍសមត្ថភាពក្នុងបរិបថវិមជ្ឈការ | ១៨ |
| **ផ្នែកទី២.ការសិក្សាវាយតម្លៃសមត្ថភាពគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់** | ២០ |
| ២.១. របកគំហើញចម្បងៗពីការសិក្សាវាយតម្លៃបែបគុណភាព | ២០ |
| ២.១.១. ការសិក្សាវាយតម្លៃបែបគុណភាពលើ គ.ក.ន.ក/អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ដែលគាំទ្រដោយកម្មវិធីសិទ្ធិកុមារ | ២០ |
| ២.១.២. ការសិក្សាវាយតម្លៃអំពីចំណេះដឹង អាកប្បកិរិយា និងការអនុវត្តការងាររបស់អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ | ២២ |
| ២.១.៣. ការពិនិត្យមើលរបស់ UNFPA ទៅលើផែនការខេត្ត និងកម្មវិធីវិនិយោគឃុំ | ២៤ |
| ២.១.៤. ការសិក្សាវាយតម្លៃសមត្ថភាព គ.ក.ន.ក/អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ដោយ MOI-DOLA/UNICEF | ២៧ |
| ២.២. តើ គ.ក.ន.ក/អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់មានការអភិវឌ្ឍយ៉ាងដូចម្ដេច? ហើយថាតើយើងអាចទទួលបានអ្វីខ្លះ? | ៣៣ |
| ២.៣. បញ្ហាជាក់លាក់ពាក់ព័ន្ធនឹងការអភិវឌ្ឍសមត្ថភាព | ៣៨ |

| | |
|---|---|
| ២.៣.១. ផ្តល់ការរៀនសូត្រ និងការអភិវឌ្ឍសមត្ថភាពរួមគ្នា | ៣៨ |
| ២.៣.២. ការប្រើប្រាស់វិធីសាស្ត្ររៀនសូត្រដែលលើកទឹកចិត្តឱ្យមានកិច្ចសន្ទនាងាយៗ | ៤០ |
| ២.៣.៣. កុំធ្វើឱ្យមានភាពស្មុគស្មាញ | ៤០ |
| ២.៣.៤. ការអភិវឌ្ឍសមត្ថភាពជាជំហានៗ | ៤១ |
| ២.៤. តម្រូវការអភិវឌ្ឍសមត្ថភាពរបស់ គ.ក.ន.ក/អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ វិវត្តតាមពេលវេលាដោយរបៀបណា | ៤២ |
| ២.៥. កំណត់សំគាល់លើសេចក្តីសន្និដ្ឋានដែលជាការឱ្យតម្លៃបន្ថែមដល់ គ.ក.ន.ក/អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ | ៤៥ |
| **ផ្នែកទី៣: ការធ្វើការងារដោយសមត្ថភាព** | ៤៨ |
| ៣.១. តើអ្វីជាសមត្ថភាព និងហេតុអ្វីត្រូវមានសមត្ថភាព? | ៤៨ |
| ៣.២.កម្រងសមត្ថភាពសម្រាប់ គ.ក.ន.ក/អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំសង្កាត់ | ៤៨ |
| ៣.៣. ឧបករណ៍សិក្សាវាយតម្លៃខ្លួនឯង | ៥៤ |
| **ផ្នែកទី៤: យុទ្ធសាស្ត្រអភិវឌ្ឍន៍សមត្ថភាពដែលបានស្នើឡើង** | ៥៦ |
| ៤.១. វិធីសាស្ត្ររៀនសូត្រតាមបែបសិស្សមជ្ឈមណ្ឌល | ៥៦ |
| ៤.២. ការអនុវត្តល្អនាពេលបច្ចុប្បន្ន | ៥៧ |
| ៤.២.១. វេទិការៀនសូត្រ | ៥៧ |
| ៤.២.២. ការអភិវឌ្ឍជំនាញសម្របសម្រួលសម្រាប់ស្ត្រីជាក្រុមប្រឹក្សាឃុំ សង្កាត់ | ៥៨ |
| ៤.២.៣. កិច្ចសន្ទនាសហគមន៍ | ៥៩ |
| ៤.២.៤. ការបង្កើតផែនទីសេវាសង្គម និងកិច្ចការពារសង្គម | ៦០ |
| ៤.២.៥. ការបណ្តុះបណ្តាលដល់អ្នកធ្វើការងារសង្គម | ៦១ |
| ៤.២.៦. កម្មវិធីសិលាជាករណីសិក្សាមួយក្នុងការផ្លាស់ប្តូរឱ្យមានការអភិវឌ្ឍប្រកបដោយនិរន្តរភាព | ៦២ |
| ៤.៣. គោលការណ៍ណែនាំអំពីយុទ្ធសាស្ត្រអភិវឌ្ឍន៍សមត្ថភាព | ៦៣ |
| ៤.៤. អនុសាសន៍សម្រាប់ការយុទ្ធសាស្ត្រអភិវឌ្ឍសមត្ថភាពរយៈពេលវែង | ៦៤ |

| | |
|---|---|
| ឯកសារពិគ្រោះ | ៧៥ |
| ឧបសម្ព័ន្ធ | ៧៨ |
| ឧបសម្ព័ន្ធ១: លក្ខខណ្ឌការងារ | ៧៨ |
| ឧបសម្ព័ន្ធ២: បញ្ជីឈ្មោះអ្នកចូលរួមសម្ភាសន៍សំខាន់ៗ | ៨៦ |
| ឧបសម្ព័ន្ធ៣: អត្ថន័យនៃពាក្យសមត្ថភាព | ៩៨ |
| តារាង និងគំនូសតាង | |
| តារាងទី១: របៀបដែល គ.ក.ន.ក/អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ មានការអភិវឌ្ឍ តាមដំណាក់កាល | ៣៣ |
| តារាងទី២: តម្រូវការអភិវឌ្ឍសមត្ថភាពទៅតាមពេលវេលា | ៤៣ |
| តារាងទី៣: សមត្ថភាពផ្នែកឥរិយាបថ ចំណេះដឹងផ្នែកបច្ចេកទេស និងផ្នែកជំនាញរបស់ គ.ក.ន.ក/ អ្នកទទួលបន្ទុកកិច្ចការនារី និង កុមារឃុំ សង្កាត់ | ៤៩ |
| តារាងទី៤: សមត្ថភាពដែលទាក់ទងទៅនឹងតួនាទី និងការទទួលខុសត្រូវរបស់ គ.ក.ន.ក | ៥២ |
| គំនូសតាងទី១: ទំនាក់ទំនងរវាងសមាសធាតុស្រាវជ្រាវនានា | ១៦ |
| គំនូសតាងទី២: កម្រងសមត្ថភាព | ៥១ |
| គំនូសតាងទី៣: ក្រុមសម្របសម្រួលពហុវិស័យ និងការបណ្តុះបណ្តាលបន្ត | ៦៥ |
| គំនូសតាងទី៤: ការអនុវត្តមុខងាររបស់ គ.ក.ន.ក និងការគាំទ្ររបស់អ្នកផ្តល់សេវា | ៦៧ |

# <u>បញ្ជីអក្សរបំព្រួញ</u>

| | |
|---|---|
| CCWC | គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ (គ.ក.ន.ក) |
| CPWP | គណៈកម្មាធិការលើកកម្ពស់ស្ត្រីក្នុងវិស័យនយោបាយ |
| CWPD | អង្គការស្ត្រីកម្ពុជាដើម្បីសន្តិភាព និងការអភិវឌ្ឍ |
| D&D | វិមជ្ឈការ និង វិសហមជ្ឈការ |
| DCWC | គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារក្រុង/ស្រុក/ខណ្ឌ |
| DoLA | នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន |
| GAD/C | អង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា |
| MDG | គោលដៅអភិវឌ្ឍន៍សហសវត្ស |
| CMDG | គោលដៅអភិវឌ្ឍន៍សហសវត្សកម្ពុជា |
| MoEF | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| MoI | ក្រសួងមហាផ្ទៃ |
| MoP | ក្រសួងផែនការ |
| MoSAVY | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| MoWA | ក្រសួងកិច្ចការនារី |
| MSC | រឿងរ៉ាវផ្លាស់ប្តូរសំខាន់ៗ |
| NAA | អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងនឹងជំងឺអេដស៍ |
| NCDD | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) |
| PCWC | គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមាររាជធានី/ខេត្ត |
| PLAU | អង្គភាពរដ្ឋបាលមូលដ្ឋានរាជធានី/ខេត្ត |
| PRA | ការសិក្សាវាយតម្លៃដោយមានការចូលរួម |
| PSDD | គម្រោងគាំទ្រការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យតាមរយៈវិមជ្ឈការ និងវិសហមជ្ឈការ |
| VBNK | វិទ្យាស្ថានបំរើអ្នកសំរបសំរួលការងារអភិវឌ្ឍន៍ |
| WCFP | អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ |
| WfP | អង្គការចំរើនស្ត្រី |
| WGPDD | ក្រុមការងារសម្រាប់ភាពជាដៃគូក្នុងវិមជ្ឈការ និងវិសហមជ្ឈការ |

## ផ្នែកទី១.សាវតារ

## ១.១.និន្នាការទូទៅ និងសនិទានភាពនៃការសិក្សាវាយតម្លៃ

យុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាលកម្ពុជា កំពុងធ្វើឱ្យប្រជាពលរដ្ឋមានសម្លេងនៅក្នុងអភិបាលកិច្ច និងបានផ្តល់សេវាសាធារណៈដល់ប្រជាពលរដ្ឋនៅមូលដ្ឋានកាន់តែមានលក្ខណៈល្អប្រសើរឡើងតាមរយៈការផ្ទេរសិទ្ធិអំណាច ការទទួលខុសត្រូវ និងធនធានពីរដ្ឋបាលថ្នាក់កណ្តាលទៅរដ្ឋបាលថ្នាក់ខេត្ត និងឃុំ សង្កាត់។ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នៅក្នុងឆ្នាំ២០០២ បានធ្វើឱ្យឃុំ សង្កាត់ក្លាយជាស្ថាប័នសំខាន់មួយនៅក្នុងអភិបាលកិច្ចមូលដ្ឋាន ដោយបានផ្តល់ឱកាសឱ្យសហគមន៍ជនបទមានតួនាទីក្នុងការធ្វើសេចក្តីសម្រេចនានាដែលប៉ះពាល់ដល់ការរស់នៅរបស់ពួកគេ។ លើសពីនេះ ឃុំ សង្កាត់ បានបង្កើនឱ្យមានការចូលរួមក្នុងការបំពេញកិច្ចការនានានៅក្នុងក្របខ័ណ្ឌនៃអាណត្តិរបស់ខ្លួនដើម្បីឱ្យប្រជាពលរដ្ឋទទួលបានសុខុមាលភាពល្អ។

ដំណើរការកំណែទម្រង់នេះ ក៏បានផ្តល់ឱកាសផងដែរក្នុងការធ្វើសមាហរណកម្មបញ្ហាចម្បងៗដែលពាក់ព័ន្ធនឹងស្ត្រី និងកុមារនៅក្នុងដំណើរការរៀបចំគោលនយោបាយ និងរដ្ឋបាល។ អង្គការយូនីសេហ្វ និងអង្គការមិនមែនរដ្ឋាភិបាលផ្សេងៗទៀត កំពុងធ្វើការជាមួយរាជរដ្ឋាភិបាលដើម្បីធានាឱ្យស្ត្រី និងកុមារមានតំណាងនៅក្នុងដំណើរការកំណែទម្រង់នេះ និងកំណត់ឱ្យបានជាក់លាក់នូវតួនាទី និងមុខងារសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្តល់សេវាសាធារណៈជាមូលដ្ឋាន និងប្រែក្លាយមុខងារទាំងនេះទៅជាសកម្មភាពសម្រាប់អនុវត្ត។ ដើម្បីសម្រេចបាននូវកិច្ចការទាំងនេះ អង្គការយូនីសេហ្វ និងអង្គការមិនមែនរដ្ឋាភិបាលផ្សេងទៀត បាន និងកំពុងធ្វើការងារ ដើម្បីពង្រឹងសមត្ថភាពមន្ត្រីថ្នាក់ក្រោមជាតិ ជាពិសេសនៅថ្នាក់ឃុំ សង្កាត់លើផ្នែកកសាងផែនការតាមបែបវិមជ្ឈការ ការងារគ្រប់គ្រង ការផ្តល់សេវាសាធារណៈ និងការផ្តល់ជាសម្ភារៈផ្សេងៗដល់ស្ត្រី និងកុមារ។

គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ (គ.ក.ន.ក) បានបង្កើតឡើងដើម្បីផ្តល់យោបល់ និងជួយកិច្ចការពាក់ព័ន្ធបញ្ហាស្ត្រី និងកុមារនៅក្នុងឃុំ សង្កាត់។ គណៈកម្មាធិការនេះ មានតួនាទីសម្របសម្រួល តាមដានត្រួតពិនិត្យ ទាក់ទាញការគាំទ្រមតិ រាយការណ៍ និងផ្តល់អនុសាសន៍ដើម្បីឱ្យប្រាកដថា សេវា និងអ្នកផ្តល់សេវាផ្នែកសេដ្ឋកិច្ច និងសង្គម ផ្តល់ប្រយោជន៍ និងសិទ្ធិអំណាចដល់ស្ត្រី និងកុមារ ហើយស្ត្រី និងកុមារទាំងនេះទទួលបានសេវានានាដោយគ្មានការរើសអើង។

សមាជិក គ.ក.ន.ក រួមមាន មេឃុំ ចៅសង្កាត់ និងជំទប់២ ចៅសង្កាត់រងទី២ (ជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលទទួលខុសត្រូវការងារសង្គមកិច្ច និងសេវាសាធារណៈក្នុងឃុំ សង្កាត់) អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ជាស្ត្រីជ្រើសចេញពីសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ឬជាស្ត្រីជ្រើសរើសក្រៅពីសមាជិកក្រុមប្រឹក្សាឃុំសង្កាត់ដែលបានទទួលប្រាក់ឧបត្ថមពីក្រុមប្រឹក្សាឃុំ សង្កាត់ តំណាងមួយរូបមកពីមណ្ឌលសុខភាព តំណាងមួយរូបមកពីសាលារៀន នាយប៉ុស្តិ៍នគរបាលរដ្ឋបាល ស្មៀនឃុំ សង្កាត់ មេភូមិ ឬអនុប្រធានភូមិគ្រប់ភូមិ។ ហើយគណៈកម្មាធិការនេះ ត្រូវមានសមាជិកស្ត្រីយ៉ាងតិចចំនួន៤០%។

នៅឆ្នាំ២០០៤ គ.ក.ន.ក ត្រូវបានបង្កើតឡើងដំបូងតាមសេចក្តីណែនាំលេខ ០០៥សណន ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៤ របស់ក្រសួងមហាផ្ទៃ នៅក្នុងឃុំចំនួន១២២ ក្នុងស្រុកចំនួន២០ ក្នុងខេត្តចំនួន៦ (កំពង់ស្ពឺ កំពង់ធំ ព្រៃវែង ស្វាយរៀង ស្ទឹងត្រែង និងឧត្តរមានជ័យ)ដែលគាំទ្រដោយកម្មវិធីសិទ្ធិកុមារនៃអង្គការយូនីសេហ្វ។ ផ្អែកតាមបទពិសោធន៍នេះ នៅឆ្នាំ២០០៧ គ.ក.ន.ក បានបង្កើតនៅទូទាំងប្រទេស(១៦២១ឃុំ សង្កាត់)តាមរយៈសេចក្តីណែនាំលេខ ០៨២ សណន/គ.ជ.វ.វ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០០៧ របស់គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ(គ.ជ.វ.វ )។ នៅដើមឆ្នាំ២០០៨ គ.ជ.វ.វ បានរៀបចំសៀវភៅណែនាំស្តីពីការអនុវត្តមុខងារ គ.ក.ន.ក និងបានធ្វើសិក្ខាសាលាតម្រង់ទិសដល់គ្រូបង្គោលមកពីគ្រប់ខេត្ត ក្រុង។

កម្មវិធីសិទ្ធិកុមារ នៃអង្គការយូនីសេហ្វ បានសហការជាមួយក្រសួងមហាផ្ទៃ (នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន) ដើម្បីគាំទ្រដល់ គ.ក.ន.ក/អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់នៅក្នុងខេត្តទាំង៦ចាប់តាំងពីឆ្នាំ២០០៤ មកម្ល៉េះ។ គោលបំណងនៃកម្មវិធីសិទ្ធិកុមារ គឺធ្វើការងារដើម្បីការពារសិទ្ធិរបស់ស្ត្រី និងកុមារ ព្រមទាំងជួយលើកកម្ពស់ជីវភាពរស់នៅរបស់ពួកគេបានប្រសើរឡើងតាមរយៈការអនុវត្តសកម្មភាពនៅតាមសហគមន៍។ ពិសេសជាងនេះទៀត កម្មវិធីនេះជួយពង្រឹងគំនិតផ្តួចផ្តើមរបស់សហគមន៍ដើម្បីធ្វើឱ្យសេវាសុខភាព អាហារូបត្ថម្ភ ការអប់រំ ទឹកស្អាត និងអនាម័យកាន់តែប្រសើរឡើង។ កម្មវិធីនេះ ក៏បានផ្តល់ឱកាសផងដែរក្នុងការបង្កើតមុខរបរថ្មីដល់គ្រួសារងាយរងគ្រោះ និងសហគមន៍ ព្រមទាំងផ្តល់នូវការបង្ការ និងការគាំពារសង្គម។

កម្មវិធីសិទ្ធិកុមារ ទទួលស្គាល់ថា ក្រុមប្រឹក្សាឃុំ សង្កាត់ ដែលជាតំណាងរបស់ប្រជាពលរដ្ឋតាមរយៈការបោះឆ្នោត មានសត្តានុពលដើម្បីបង្កើតបរិយាកាសមួយដែលនាំឱ្យមាននូវកិច្ចការពារ និងការលើកកម្ពស់សិទ្ធិនារី និងកុមារនៅតាមឃុំ សង្កាត់។ ហេតុនេះ កម្មវិធីសិទ្ធិកុមារ បានជួយពង្រឹងក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាអ្នកមានសិទ្ធិបំពេញការងារ និងភារកិច្ចដ៏សំខាន់ក្នុងការធ្វើឱ្យសិទ្ធិកុមារមានពិតប្រាកដនៅមូលដ្ឋាន។ កម្មវិធីនេះ ក៏បានជួយធ្វើឱ្យមានភាពប្រសើរឡើងនូវការសម្របសម្រួលរវាងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ តំណាងប្រជាពលរដ្ឋ និងអ្នកផ្តល់សេវាសង្គមនៅមូលដ្ឋាន (ដូចជា គណៈកម្មាធិការទ្រទ្រង់សាលា និងមណ្ឌលសុខភាពជាដើម)ដើម្បីពង្រឹងនូវការផ្តល់សេវាសង្គមនៅមូលដ្ឋានសម្រាប់ស្ត្រី និងកុមារ ព្រមទាំងកៀរគរសហគមន៍ឱ្យមានសកម្មភាពរួបរួមគ្នា និងមានការផ្លាស់ប្តូរសង្គម។

លទ្ធផលនៃការសិក្សាវាយតម្លៃនានា បានបង្ហាញថា (ក). គ.ក.ន.ក ដែលបានបង្កើតយូរហើយកំពុងទទួលបានលទ្ធផលជាវិជ្ជមាន និងបានផ្តល់អាទិភាពខ្ពស់ទៅលើបញ្ហាស្ត្រី និងកុមារ ពាក់ព័ន្ធនឹងបញ្ហាសុខភាព និងការអប់រំ ច្រើនជាង គ.ក.ន.ក ដែលទើបបានបង្កើតក្រោយឆ្នាំ២០០៧ (ខ).គំនិតផ្តួចផ្តើមក្នុងការគាំទ្រផ្សេងៗដូចជា ការបណ្តុះបណ្តាលនានា បានធ្វើឱ្យប្រសើរឡើងនូវសមត្ថភាព និងការយល់ដឹងពីមុខងាររបស់គណៈកម្មាធិការនេះ។ ទោះបីជាយ៉ាងណាក៏ដោយ សមត្ថភាពរបស់សមាជិក គ.ក.ន.ក នីមួយៗមិនអាចមានភាពស្មើគ្នាទេ ទីមួយគឺអាស្រ័យលើកត្តាផ្សេងៗ ដូចជាបទពិសោធន៍ ទំនុកចិត្ត ការប្តេជ្ញាចិត្តរបស់បុគ្គលជាសមាជិក គ.ក.ន.ក និងឋានៈរបស់ពួកគេនៅក្នុងឃុំ សង្កាត់ និងរបៀបដែលអ្នកពាក់ព័ន្ធឯទៀតត្រូវភ្ជាប់ទំនាក់ទំនងជាមួយ គ.ក.ន.ក/អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់។ ទីពីរ គណៈកម្មាធិការមួយចំនួនបានកើតឡើងជាច្រើនឆ្នាំមកហើយ ខណៈពេលដែលគណៈកម្មាធិការមួយចំនួនទៀតទើបតែបានបង្កើតឡើង។ ទីបី គណៈកម្មាធិការមួយចំនួនទទួលបានការគាំទ្រពីភ្នាក់ងារអន្តរជាតិ (កម្មវិធីសិទ្ធិកុមារនៃ

អង្គការយូនីសេហ្វ ឬ UNFPA) ហើយគណៈកម្មាធិការមួយចំនួនទៀតទទួលបានការគាំទ្រពីភ្នាក់ងាររបស់រដ្ឋាភិបាល (អង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត ការិយាល័យកិច្ចនារីស្រុក) មួយចំនួនទៀតទទួលបានការគាំទ្រពីអង្គការមិនមែនរដ្ឋាភិបាល (អង្គការចំរើនស្ត្រី) ។ នៅក្នុងស្ថានភាពខ្លះ ការគាំទ្រ គ.ក.ន.ក មិនបានធ្វើការសម្របសម្រួលគ្នាទេ ហេតុនេះ គ.ក.ន.ក មួយចំនួនទទួលបានការគាំទ្រច្រើន និងញឹកញាប់ និងមួយចំនួនទៀតទទួលបានការគាំទ្រតិចតួច ។

ការសិក្សាវាយតម្លៃនេះ ផ្តល់ឱកាសឱ្យយើងកំណត់បាន និងធ្វើការសាកល្បងទៅលើការសន្មត់ខុសៗគ្នាដែលនាំទៅដល់ការអភិវឌ្ឍសមត្ថភាព គ.ក.ន.ក/អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ។

ការសន្មត់ទាំងនេះមានដូចជា:

- អាចកំណត់ពីសមត្ថភាពដែលបង្កើតបានជាមូលដ្ឋានគ្រឹះសម្រាប់បំពេញការងាររបស់ គ.ក.ន.ក
- សមត្ថភាពមានការរីកចម្រើនជាធម្មតា ផ្អែកលើបទពិសោធន៍ និងការរៀនសូត្រ
- មានថាមពលរួម ដែលរំពឹងថាទទួលបានពីការអភិវឌ្ឍសមត្ថភាពតាមបែបបំពេញបន្ថែមរបស់រដ្ឋាភិបាលមូលដ្ឋាន ប្រកបដោយការទទួលខុសត្រូវ និងគណនេយ្យភាព
- មានការលើកឡើងនូវការអនុវត្តល្អៗ ដែលបានប្រតិបត្តិនៅកន្លែងផ្សេងៗ សម្រាប់ពន្លឿនដល់ការអភិវឌ្ឍសមត្ថភាព គ.ក.ន.ក នៅទូទាំងប្រទេស
- មានឱកាសបង្កើតទំនាក់ទំនងរវាង គ.ក.ន.ក ជាមួយគណៈកម្មាធិការនានានៅមូលដ្ឋាន អ្នកផ្តល់សេវានានារបស់រាជរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីឱ្យមានវិធីសាស្ត្រសម្របសម្រួលកាន់តែច្រើនឡើងក្នុងការផ្តល់សេវាសង្គមនានា។

## ១.២.គោលបំណងនៃការសិក្សាវាយតម្លៃ

តាមការប្រៀបធៀបរវាងលទ្ធផល និងបញ្ហាប្រឈមក្នុងការបំពេញកាងាររបស់ គ.ក.ន.ក ការសិក្សានេះសំដៅកំណត់កត្តាជោគជ័យសំខាន់ៗដែលជំរុញឱ្យ គ.ក.ន.ក មានការរីកចម្រើន និងកំណត់ពីឧបសគ្គដែលរារាំងដល់ការអភិវឌ្ឍរបស់ គ.ក.ន.ក ។

គោលបំណងនៃការសិក្សាមាន :

- ទី១: សិក្សាវាយតម្លៃសមត្ថភាពបច្ចុប្បន្នរបស់ គ.ក.ន.ក និងរចនាសម្ព័ន្ធគាំទ្រ ដើម្បីបំពេញភារកិច្ចរបស់ខ្លួន ឱ្យបានពេញលេញ។

  <u>លទ្ធផល:</u> កម្រងសមត្ថភាពរយៈពេលវែងមួយសម្រាប់ គ.ក.ន.ក. និងអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ដែលបង្ហាញពីរបៀបកើនឡើងនូវសមត្ថភាព និងទំនុកចិត្ត ចាប់តាំងពីការផ្តួចផ្តើមបង្កើតដំបូងរហូតដល់ដំណាក់កាល ដែល គ.ក.ន.ក អនុវត្តមុខងារបានពេញលេញ។
- ទី២: បង្កើតយុទ្ធសាស្ត្រអភិវឌ្ឍន៍សមត្ថភាពរយៈពេលវែង តាមរយៈរបកគំហើញនៃការសិក្សាដំបូង និងការសិក្សាបន្តបន្ទាប់ ដើម្បីគាំទ្រ គ.ក.ន.ក ឱ្យបំពេញភារកិច្ចរបស់ខ្លួនបានពេញលេញ។

  <u>លទ្ធផល:</u> យុទ្ធសាស្ត្រអភិវឌ្ឍន៍សមត្ថភាពរយៈពេលវែង។

## ១.៣.ទំហំ និងដែនកំណត់នៃការសិក្សាវាយតម្លៃ

ក្រសួងមហាផ្ទៃ (នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន) និងអង្គការយូនីសេហ្វ បានសហការគ្នាក្នុងការសិក្សាវាយតម្លៃសមត្ថភាព គ.ក.ន.ក ដោយបានបង្កើតក្រុមការងារមួយដឹកនាំកិច្ចសម្ភាសន៍ដោយវិទ្យាស្ថានបំរើអ្នកសំរបសំរួលការងារអភិវឌ្ឍន៍។ ក្រុមការងារ បានចុះធ្វើកិច្ចសម្ភាសន៍នៅក្នុងខេត្តចំនួន៥ ដែលក្នុងនោះខេត្តចំនួន៣ជាខេត្តគាំទ្រដោយកម្មវិធីសិទ្ធិកុមារ នៃអង្គការយូនីសេហ្វ គឺ ខេត្តកំពង់ស្ពឺ ខេត្តកំពង់ធំ និងខេត្តឧត្តរមានជ័យ និងខេត្តចំនួន២ទៀតដែលមិនមានការគាំទ្រពីកម្មវិធីសិទ្ធិកុមារ គឺខេត្តកំពង់ចាម និងខេត្តរតនគិរី។ ការចុះសម្ភាសន៍នេះផ្តោតទៅលើក្រុមពិភាក្សា និងកិច្ចសម្ភាសន៍ស៊ីជម្រៅជាមួយ គ.ក.ន.ក និងអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ តំណាងមកពីសហគមន៍ (អ្នកប្រើប្រាស់សេវា) មន្ត្រីតំណាងមកពីថ្នាក់ខេត្ត និងស្រុកពាក់ព័ន្ធ ភ្នាក់ងាររដ្ឋាភិបាលដែលបានចូលរួមចំណែកក្នុងការអភិវឌ្ឍន៍សមត្ថភាព គ.ក.ន.ក និងអង្គការមិនមែនរដ្ឋាភិបាលដែលកំពុងធ្វើការពាក់ព័ន្ធបញ្ហាស្ត្រី និងកុមារ។

លើសពីនេះទៀត ក្រុមការងារបានធ្វើកិច្ចសម្ភាសន៍ស៊ីជម្រៅជាមួយអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ដើម្បីរកឱ្យឃើញបញ្ហាជាក់លាក់ដែលពួកគាត់មានបទពិសោធន៍ក្នុងការបំពេញតួនាទី និងភារកិច្ច។ កិច្ចសម្ភាសន៍ស៊ីជម្រៅត្រូវបានរៀបចំជាមួយមនុស្សសំខាន់ៗឯទៀតតាមតម្រូវការចាំបាច់។ មានការពិគ្រោះយោបល់ផងដែរជាមួយដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ដែលបាន និងកំពុងធ្វើការគាំទ្រការអភិវឌ្ឍសមត្ថភាពរបស់ គ.ក.ន.ក (ឧ.ការធ្វើសម្ភាសន៍ជាមួយក្រុមការងារដៃគូរអភិវឌ្ឍន៍ក្នុងការងារវិមជ្ឈការ និងវិសហមជ្ឈការ អង្គការ ចំរើនស្ត្រី និងអង្គការផ្លែនអន្តរជាតិ) នៅរាជធានីភ្នំពេញ។

ការសិក្សានេះក៏បានពិនិត្យមើលផងដែរទៅលើកិច្ចអន្តរាគមន៍ នៃការកសាងសមត្ថភាព ដែលបានរៀបចំដឹកនាំដោយភ្នាក់ងាររាជរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិនានា។ កិច្ចអន្តរាគមន៍លើការកសាងសមត្ថភាពទាំងនោះរួមមាន វគ្គបណ្តុះបណ្តាលអំពីសិទ្ធិកុមារ សុខភាព អប់រំ កិច្ចការពារកុមារ ទឹកស្អាត និងអនាម័យ គាំទ្រដោយភ្នាក់ងាររាជរដ្ឋាភិបាល, អង្គការ **UNFPA**, និងអង្គការយូនីសេហ្វ, វេទិកាដែលសម្របសម្រួលដោយអង្គការចំរើនស្ត្រី, វគ្គបណ្តុះបណ្តាលវិជ្ជាជីវៈ និងវគ្គបណ្តុះបណ្តាលចំណេះដឹងកម្រិតមូលដ្ឋានសម្រាប់មន្ត្រីសង្គមកិច្ចនៅថ្នាក់ស្រុកដែលដឹកនាំដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា[1] និងកម្មវិធីបណ្តុះបណ្តាលដោយផ្ទាល់ដល់ស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ ដែលគាំទ្រដោយគណៈកម្មាធិការដើម្បីលើកកម្ពស់ស្ត្រីក្នុងវិស័យនយោបាយ។

ចំណុចចុងក្រោយ ការសិក្សានេះដកស្រង់យកលទ្ធផលមួយចំនួនពីការពិគ្រោះយោបល់ដែលនៅក្នុងនោះរួមមាន ការងារពង្រឹងការសម្របសម្រួលរវាង គ.ក.ន.ក និងរចនាសម្ព័ន្ធផ្នែកសេវាសុខភាព ដែលដឹកនាំដោយកាកបាទក្រហមស្វីសនៅខេត្តតាកែវ ការសិក្សាវាយតម្លៃសមត្ថភាពស្តីពីកិច្ចការពារសង្គមដែលដឹកនាំដោយវិទ្យាស្ថានអភិវឌ្ឍន៍អន្តរជាតិ (DFID) ការពិគ្រោះយោបល់ស្តីពីផែនទីសេវាសង្គម ដែលដឹកនាំដោយអង្គការយូនីសេហ្វ និងការពិគ្រោះយោបល់ដើម្បីបង្កើតក្របខ័ណ្ឌការងារកសាងសមត្ថភាពស្ត្រីនៅថ្នាក់ក្រោមជាតិ (McKay2009)។

*បញ្ជីឈ្មោះអ្នកផ្តល់ព័ត៌មានសំខាន់ៗលើការសិក្សានេះមាននៅក្នុងឧបសម្ព័ន្ធ២។*

[1] របាយការណ៍វាត់លៃវគ្គស្តីពីការងារសង្គមកិច្ចដោយលោក Steve Harknett ២០០៨, យូនីសេហ្វ-កម្ពុជា (មិថុនា២០០៥)

មន្ត្រីអង្គការយូនីសេហ្វ និងមន្ត្រីនាយករដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ បានរៀបចំការប្រជុំពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធឯទៀត ដើម្បីធ្វើការបង្ហាញ ពិភាក្សា និងផ្តល់យោបល់ត្រឡប់លើរកបកគំហើញដំបូង និងសេចក្តីព្រាងកម្រងសមត្ថភាព។ បន្ទាប់មក មានសិក្ខាសាលាមួយបានយកមតិត្រឡប់នេះមកពិចារណាលើសំណួរសំខាន់ៗដែលបានលើកឡើងនៅក្នុងអង្គប្រជុំមុន។ នៅខែធ្នូ ឆ្នាំ២០០៩ មានការបង្ហាញអំពីសេចក្តីព្រាងយុទ្ធសាស្ត្រ នៃការអភិវឌ្ឍស្ថាប័ន គ.ក.ន.ក រយៈពេលវែងដើម្បីពិភាក្សា និងផ្តល់យោបល់ត្រឡប់។

*កិច្ចព្រមព្រៀងសម្រាប់ការសិក្សាស្រាវជ្រាវនេះមាននៅក្នុងឧបសម្ព័ន្ធ១។*

ទំនាក់ទំនងរវាងសមាសភាពស្រាវជ្រាវផ្សេងៗមានបង្ហាញក្នុងគំនូសតាងទី១ (ខាងក្រោម)។

កម្រងសមត្ថភាពនេះត្រូវបានបង្កើតឡើងដោយផ្អែកលើការចុះសម្ភាសន៍នៅមូលដ្ឋាន និងការសិក្សាស្រាវជ្រាវឯកសារដែលមានស្រាប់ សម្រាប់ធ្វើជាព័ត៌មានក្នុងការបង្កើតយុទ្ធសាស្ត្រអភិវឌ្ឍសមត្ថភាពរយៈពេលវែង។

ដែនកំណត់នៃការសិក្សាការស្រាវជ្រាវនេះ គឺបានផ្តោតទៅលើខេត្តប្រាំ (ខេត្តកំពង់ស្ពឺ ខេត្តកំពង់ធំ ខេត្តឧត្តរមានជ័យ ខេត្តកំពង់ចាម និងខេត្តរតនគិរី) ឃុំចំនួន៩ សង្កាត់១ ស្រុក៥ និងក្រុង១ ដើម្បីសម្ភាសន៍។ ជាមួយគ្នានេះដែរ ក៏មានការវិភាគទិន្នន័យដែលបានពីការសិក្សាឯកសារស្រាវជ្រាវផ្សេងៗទៀតផងដែរ លើសពីនេះទៀត ការសិក្សាស្រាវជ្រាវនេះ កំណត់បានជាខ្នាតគំរូមួយសម្រាប់ឱ្យ គ.ក.ន.ក/អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់អាចប្រើប្រាស់បានរួមគ្នា។ ប៉ុន្តែនៅពេលបានឃើញរូបតាងខាងក្រោម គ.ក.ន.ក/អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់នីមួយៗ មានការអភិវឌ្ឍអាស្រ័យលើសមត្ថភាពរបស់ខ្លួន និងកត្តាខាងក្រៅជាច្រើនទៀត ។ ការសន្មត់ទុកជាមុនមួយនៅក្នុងការសិក្សាវាយតម្លៃនេះ គឺថា អ្នកផ្តល់ការបណ្តុះបណ្តាលត្រូវជៀសវាងការផ្តល់ការបណ្តុះបណ្តាល ឬវិធីសាស្ត្របណ្តុះបណ្តាលតែមួយបែបសម្រាប់ទៅគ្រប់ គ.ក.ន.ក/អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ តែត្រូវមានការបត់បែនឱ្យបានល្អទៅតាមកម្រិតយល់ដឹងរបស់ គ.ក.ន.ក។ វិធីសាស្ត្របណ្តុះបណ្តាលបែបនេះនឹងត្រូវលើកឡើងជាអនុសាសន៍សម្រាប់ដាក់បញ្ចូលទៅក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍សមត្ថភាព។ លើសពីនេះទៀត កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យរយៈពេលដប់ឆ្នាំ ត្រូវបានបង្កើតឡើងនៅខណៈដែលយើងកំពុងធ្វើការសិក្សាស្រាវជ្រាវនេះផងដែរ ហេតុដូចនេះ តម្រូវឱ្យមានការពិនិត្យមើលអនុសាសន៍ដែលមាននៅក្នុងរបាយការណ៍នេះឡើងវិញបន្ទាប់ពីកម្មវិធីជាតិរយៈពេលដប់ឆ្នាំនោះត្រូវបានបញ្ចប់។ តម្រូវការនៃការអភិវឌ្ឍសមត្ថភាព និងការកសាងយុទ្ធសាស្ត្រ គឺផ្អែកទៅលើវដ្តប្រាំឆ្នាំដែលស្របទៅនឹងអាណត្តិនៃការបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ ហើយសន្មត់ថា ឆ្នាំទីមួយ ជាដំណាក់កាលចាប់ផ្តើម ឆ្នាំទីពីរ និងឆ្នាំទីបីជាដំណាក់កាលកំពុងអភិវឌ្ឍ ហើយឆ្នាំទីបួន និងឆ្នាំប្រាំជាដំណាក់កាល ដែលមានភាពម្ចាស់ការ។

ជាចុងក្រោយនេះ ការអភិវឌ្ឍសមត្ថភាព គ.ក.ន.ក មានការចាប់អារម្មណ៍ខ្លាំងពីរាជរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធ ដែលបញ្ហានេះមិនទាន់អាចព្យាករបានថាតើអាចប៉ះពាល់ដល់ដំណើរការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការដែរ ឬក៏អត់នៅពេលដែលស្ថានភាពសេដ្ឋកិច្ចនាពេលបច្ចុប្បន្នធ្លាក់ចុះ។

# គំនូសតាងទី១: ទំនាក់ទំនងរវាងសមាសធាតុស្រាវជ្រាវនានា



## ១.៤.អត្ថន័យនៃការអភិវឌ្ឍសមត្ថភាព

### ១.៤.១.ការយល់ឃើញជាលក្ខណៈប្រព័ន្ធ

វាប្រាកដណាស់ថា មនុស្សមានទស្សនៈផ្សេងៗគ្នា នៅពេលដែលគេនិយាយពីការអភិវឌ្ឍសមត្ថភាព ( Land និង Morgan ២០០៨) ។ គំនិតខាងក្រោមនេះ បញ្ជាក់ពីរបៀបរៀនសូត្រ និងការអភិវឌ្ឍសមត្ថភាព ដែលត្រូវបានពន្យល់នៅក្នុងការសិក្សានេះ :

- ការអភិវឌ្ឍសមត្ថភាពមានន័យលើសពីអ្វីដែលគ្រាន់តែជាការផ្ទេរចំណេះដឹង តាមរយៈការផ្តល់ចំណេះដឹងពីខាងក្រៅ ។ ផ្ទុយមកវិញ ការអភិវឌ្ឍសមត្ថភាពត្រូវបានគេយល់ថា ជាដំណើរផ្លាស់ប្តូរមួយដែលចេញពីខាងក្នុង
- ការអភិវឌ្ឍសមត្ថភាពមិនកើតឡើងដាច់តែឯងទេ ប៉ុន្តែការរៀនសូត្រតាមលក្ខណៈធម្មជាតិកើតឡើង នៅពេលដែលគេយកចំណេះដឹងទាំងនោះទៅប្រើប្រាស់ក្នុងការអនុវត្តការងារជាក់ស្តែង
- ការអភិវឌ្ឍសមត្ថភាពកើតមានឡើងព្រមគ្នានៅគ្រប់លំដាប់ថ្នាក់ ដូចជាបុគ្គល អង្គការ មន្ទីរវិស័យ ថ្នាក់តំបន់ ថ្នាក់ជាតិ និងគ្រប់លំដាប់ថ្នាក់ពាក់ព័ន្ធ
- បុគ្គលម្នាក់អាចបង្កើតសមត្ថភាពខ្លួនឯង ហើយស្ថាប័នអាចជំរុញឱ្យសមត្ថភាពរួមប្រសើរឡើង ដែលធាតុទាំងពីរត្រូវចងក្រងជារបៀបរួមមួយដែលជាប់ទាក់ទងគ្នា ដើម្បីធ្វើឱ្យមានសមត្ថភាពជាលក្ខណៈប្រព័ន្ធ
- កត្តាគុណភាព ដូចជា ភាពមានទំនុកចិត្ត ភាពក្លាហាន(ភាពលុះ) គំនិតច្នៃប្រឌិត មោទនៈភាព និងការប្តេជ្ញាចិត្ត គឺជាកត្តាគន្លឹះសំខាន់ៗនៃលក្ខខណ្ឌសមត្ថភាព និងដំណើរការធ្វើឱ្យសម្រេចលទ្ធផល ។

ទស្សនៈសំខាន់ៗ នៃការអភិវឌ្ឍសមត្ថភាពជាច្រើនកើតឡើងពីការគិតឡើងវិញ(Morgan et al.២០០៥) ទី១,ការអភិវឌ្ឍសមត្ថភាព គឺការអភិវឌ្ឍនៃបុគ្គលម្នាក់ៗ ក៏ដូចគ្នាទៅនឹងការអភិវឌ្ឍសមត្ថភាពសង្គមស៊ីវិលផងដែរ ។ ទី២,នៅថ្នាក់មូលដ្ឋាន(បុគ្គល សហគមន៍ និងអង្គការ) សមត្ថភាព ជាសក្តានុពល និងភាពខ្លាំងដែលមនុស្សគ្រប់រូបត្រូវបង្កើតអនាគតរបស់ខ្លួនផ្ទាល់ ។ ទី៣. នៅពេលដែលសក្តានុពលនេះអំណោយផលក្នុងការរៀនសូត្រ និងរីកលូតលាស់ គេអាចបង្កើនសមត្ថភាពឱ្យប្រសើរជាងមុនដោយកត្តាផ្សេងៗ ដូចជា វគ្គបណ្តុះបណ្តាល ហើយក៏ចាំបាច់ត្រូវរកឱ្យឃើញដោះស្រាយនូវបញ្ហារារាំងទាក់ទងនឹងបរិយាកាសសង្គម និងរបៀបធ្វើការក្នុងស្ថាប័នដែលរារាំងមិនអាចសម្រេចបាននូវសក្តានុពលទាំងនោះ ។ ទី៤. គោលបំណង នៃការអភិវឌ្ឍសមត្ថភាព គួរធ្វើការវិភាគនៅបីកំរិត គឺ កំរិតបុគ្គល ស្ថាប័ន និងបរិយាកាស ។

ការគិតគូរឡើងវិញពីការអភិវឌ្ឍសមត្ថភាពតាមមធ្យោបាយនេះទាមទារឱ្យប្តូរវិធីសាស្ត្រដែលយើងប្រើក្នុងការបំពេញការងារ គឺ យើងត្រូវចៀសវាងយុទ្ធសាស្ត្រ"ទំហំមួយត្រូវគ្រប់គ្នា" យើងត្រូវផ្តោតលើទំនាក់ទំនងរវាងការរៀនសូត្រ និងសកម្មភាព (ការប្រតិបត្តិការរៀនសូត្រ) ហើយយើងត្រូវប្រើប្រាស់វិធីសាស្ត្ររៀនសូត្រតាមបែបគុណភាពឱ្យកាន់តែច្រើន ជាពិសេស ការសិក្សាស្រាវជ្រាវ ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃ ។

## ១.៤.២.ការអភិវឌ្ឍសមត្ថភាពក្នុងបរិបទវិមជ្ឈការ

នៅក្នុងអំឡុងទសវត្សរ៍ចុងក្រោយ កម្មវិធីនយោបាយសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាលកម្ពុជាបានណែនាំឱ្យប្រើយុទ្ធសាស្ត្រចតុកោណ ដែលចំណុចសំខាន់ នៃយុទ្ធសាស្ត្រនេះ គឺអភិបាលកិច្ចល្អ រួមទាំងវិមជ្ឈការ និងវិសហមជ្ឈការ ។ គោលដៅវិមជ្ឈការដែលរាជរដ្ឋាភិបាលបានលើកឡើងនេះ គឺការពង្រឹងមូលដ្ឋាន, ប្រជាធិបតេយ្យដោយមានការចូលរួម និងកាត់បន្ថយភាពក្រីក្រ ។ ម្ចាស់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាលក៏មើលឃើញថា វិមជ្ឈការជាឱកាសមួយដើម្បីកាត់បន្ថយភាពក្រីក្រ និងដើម្បីប្រើប្រាស់ថវិកាជំនួយផ្នែកអភិវឌ្ឍន៍សម្រាប់ជំរុញអភិបាលកិច្ចឱ្យប្រសើរឡើង ។ រាជរដ្ឋាភិបាល ក៏ដូចម្ចាស់ជំនួយអន្តរជាតិបានវិនិយោគទៅលើការលើកកម្ពស់គំរូនៃអភិបាលកិច្ចល្អ ។ ទោះបីជាយ៉ាងណាក៏ដោយ កម្មវិធីនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ គឺជាគោលដៅមួយដ៏ធំធេងដែលត្រូវធ្វើឱ្យសម្រេច ហើយមានបញ្ហាប្រឈមជាច្រើនដែលបង្ករឱ្យរាំងស្ទះដល់ដំណើរការវិមជ្ឈការដែលនឹងប៉ះពាល់ដល់លទ្ធផលសម្រេចបាន :

- ទីមួយ លំនាំប្រវត្តិសាស្ត្រ នយោបាយ វប្បធម៌ ដែលធ្វើឱ្យលេចចេញជារូបរាងជុំវិញការអភិវឌ្ឍ ជាពិសេសនៅរបបខ្មែរក្រហម(១៩៧៥-១៩៧៩) បានធ្វើឱ្យបែកបាក់ទាំងស្រុងនូវរចនាសម្ព័ន្ធគ្រួសារ និងសង្គម ។ ជាលទ្ធផល គឺការបំផ្លាញស្ទើរតែទាំងស្រុងនូវចំណងសង្គម និងធ្វើឱ្យគ្រួសារដែលមានលក្ខណៈជិតស្និតគ្នាបានបាត់បង់ការជឿទុកចិត្តគ្នារវាងបុគ្គល និងស្ថាប័នព្រមទាំងចំពោះប្រជាពលរដ្ឋទូទៅផងដែរ ។ មានការស្រាវជ្រាវជាច្រើន(ឧទាហរណ៍ Moira O'leary និង Meas Nee, 2000; Jenny knowles, 2009: Leng Chay និង Jenny Peason, 2006) បានលើកឡើងថា ពលរដ្ឋកម្ពុជាជាច្រើន មានអារម្មណ៍សង្ស័យពីការផ្លាស់ប្តូរ និងសម្តែងចេញនូវការប្រុងប្រយ័ត្ននៅក្នុងសកម្មភាពសាធារណៈ ។
- ទីពីរ ភាពពឹងផ្អែកទៅលើប្រពៃណីយ៍នៃការគោរពតាមឋានានុក្រម និងប្រព័ន្ធគ្រប់គ្រងដែលប្រើអំណាចផ្តាច់ការ តែងតែចម្លងទៅក្នុងការងារអភិវឌ្ឍ និងប៉ះពាល់ដល់របៀបដែលសហគមន៍ឆ្លើយតប និងចូលរួមក្នុងដំណើរការអភិវឌ្ឍ ហើយតែងតែមានគម្លាតរវាងចំណេះដឹង និងឥរិយាបថ ដែលបានបង្ហាញនៅក្នុងសន្ទរកថាពាក់ព័ន្ធការអភិវឌ្ឍ និងការសម្រេចដាក់ឱ្យអនុវត្ត ។ លទ្ធផលមិនភ្ជាប់ទំនាក់ទំនងគ្នាយ៉ាងនេះបានមកពីភាពតានតឹងរវាងជំនឿវប្បធម៌ ប្រពៃណីយ៍ និងការឱ្យតម្លៃបែបទំនើប ។ ជំនឿវប្បធម៌ និងការឱ្យតំលៃ កើតឡើងផ្ទុយគ្នាទៅនឹងគោលការណ៍ច្បាប់គ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឧទាហរណ៍ ការសំរេចចិត្តតាមឋានានុក្រមប្រឆាំងទៅនឹងការចូលរួមតាមបែបប្រជាធិបតេយ្យ (O'Leary 2007) ។ ការប្រៀបធៀបរវាងការឱ្យតំលៃទៅលើប្រពៃណីយ៍របស់ប្រជាជនកម្ពុជា និងការឱ្យតំលៃទៅលើប្រពៃណីយ៍ដែលមានចែងបង្កប់នៅក្នុងអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ(UNCRC) ជាឧទាហរណ៍ មានទស្សនៈពីរខុសពីគ្នានៅក្នុងការគោរព :

*-វប្បធម៌រឹងប៉ឹង សង្កត់ធ្ងន់ទៅលើកិត្តិយស ឬកេរ្តិ៍ឈ្មោះរបស់ឪពុកម្តាយ និងគ្រួសារ ព្រមទាំងការរីករាលដាលនៃឥទ្ធិពលឋានានុក្រម និងនៅក្នុងទំនាក់ទំនងរវាងឪពុកម្តាយ និងកូន ដែលរារាំងមិនឱ្យសិទ្ធិកុមារកើតមានឡើងពិតប្រាកដនៅក្នុងជីវិតរស់នៅរបស់គ្រួសារនៅក្នុងតំបន់ជាច្រើន ។*

*-នៅពេលជាមួយគ្នានេះដែរ ឪពុកម្តាយមានឆន្ទៈចង់គោរពសិទ្ធិកុមារនៅតំបន់ផ្សេងទៀតនៅពេលដែលកុមារបានទទួលស្គាល់ការទទួលខុសត្រូវរបស់ខ្លួនចំពោះឪពុកម្តាយ និងគ្រួសារ ដែលនេះគឺជាការឱ្យតម្លៃមួយនៅក្នុងវប្បធម៌កម្ពុជា និងវប្បធម៌របស់ UNCRC ប៉ុន្តែគេមិនសូវឃើញមានដោបញ្ជាក់ពីការឱ្យតម្លៃនេះនៅក្នុងគម្រោងសិទ្ធិកុមារ (Gourley, 2009:5) ។*

- ទីបី ប្រព័ន្ធអប់រំដែលមិនលើកទឹកចិត្តឱ្យមានការសួរនាំដោយចងភ្ជាប់ជាមួយឋានានុក្រមនោះ ផ្តល់លទ្ធផលនាំឱ្យមានភាពស្ទាក់ស្ទើរមិនហ៊ាននិយាយជំទាស់ ឬមិនយល់ស្របជាមួយ ឬសូម្បីតែសួរទៅកាន់អ្នកមានអំណាចក៏មិនហ៊ានដែរ ហើយថែមមានភាពទាំងរួញរាក្នុងការសាកល្បងរៀនសូត្រតាមបែបផ្សេង។

ទំនោរទាំងនេះ មានផលប៉ះពាល់ដល់របៀបដែលបុគ្គលម្នាក់ៗប្រព្រឹត្ត និងឆ្លើយតបចំពោះការផ្តួចផ្តើមគំនិតក្នុងការអភិវឌ្ឍសមត្ថភាព។ ហេតុនេះភាពខុសគ្នារវាងការឱ្យតម្លៃ និងវប្បធម៌ត្រូវមានការកំណត់ និងឆ្លើយតបបានច្បាស់លាស់នៅក្នុងកម្មវិធីអភិវឌ្ឍន៍សមត្ថភាព ហើយរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល និងវិស័យឯកជនត្រូវអនុវត្តវិធីសាស្ត្រនៃវប្បធម៌រៀនសូត្រសមស្របដែលផ្តោតទៅលើការអប់រំ(រៀនសូត្រ មិនមែននិយាយប្រាប់)។ អ្វីដែលត្រូវការគឺ *"ផ្លូវកណ្តាល"ដែលត្រូវធ្វើឱ្យមានសមាហរណកម្ម និងទទួលយកគោលគំនិតថ្មីៗនៃយុត្តិធម៌សង្គម និងសិទ្ធិបុគ្គលម្នាក់ៗ ដែលបកស្រាយឡើងវិញនូវទិដ្ឋភាពនៃវប្បធម៌ទាំងឡាយណាដែលមិនឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់មនុស្សជំនាន់ក្រោយនៅពេលដែលអ្នកទាំងនោះកំពុងមានមោទនៈភាពក្នុងការប្រព្រឹត្តិអំពើនោះ"* (Gourley ២០០៩ :៥) ។

យ៉ាងណាក៏ដោយ ការផ្លាស់ប្តូរនៅកម្ពុជាកំពុងតែកើតឡើង និងមានភស្តុតាងគ្រប់គ្រាន់ដែលបញ្ជាក់ថា ដំណើរការវិមជ្ឈការ និងវិសហមជ្ឈការកំពង់តែចាក់ឫសគល់នៅកម្ពុជា ហើយការបង្កើតក្រុមប្រឹក្សាឃុំ សង្កាត់តាមរយៈការបោះឆ្នោត បានបង្ហាញឱ្យឃើញនូវលទ្ធផលវិជ្ជមានមួយចំនួន។ ទីមួយ ក្រុមប្រឹក្សាឃុំ សង្កាត់ បានទទួលស្គាល់ដោយច្បាប់ថាជាអង្គការតំណាងឱ្យប្រជាពលរដ្ឋក្នុងការដឹកនាំដើម្បីកំណត់ឡើងវិញនូវជំនួយផ្នែកអភិវឌ្ឍន៍។ ទីពីរ ការកសាងផែនការ និងថវិកាដោយមានការចូលរួម បានអនុញ្ញាតឱ្យប្រជាពលរដ្ឋបង្ហាញចំណង់ចំណូលចិត្តរបស់ខ្លួនក្នុងនាមតម្រូវការសហគមន៍។ ទីបី វិមជ្ឈការបានរួមចំណែកក្នុងការកសាងសុវត្ថិភាព សុខសន្តិភាព និងការធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធដែលនាំឆ្ពោះទៅរកកំណើនសេដ្ឋកិច្ច។ ចុងបញ្ចប់ កំណែទម្រង់នៅថ្នាក់ឃុំ សង្កាត់ ត្រូវបានពង្រឹង ធ្វើឱ្យមានស្ថេរភាព និងធ្វើឱ្យគេទទួលស្គាល់ថាត្រឹមត្រូវតាមច្បាប់របស់រដ្ឋាភិបាលថ្នាក់កណ្តាលទៀតផង។

ការស្រាវជ្រាវដ៏មានអត្ថន័យ (Knowles, 2009) បង្ហាញថាការផ្លាស់ប្តូរនេះត្រូវបានដឹកនាំដោយភ្នាក់ងារផ្លាស់ប្តូរថ្នាក់ជាតិដែលបំពេញការងារ និងបណ្តុះបណ្តាលដោយកម្មវិធីសិលា ហើយភ្នាក់ងារទាំងនេះបានដើរតួនាទីជា "អន្តរការីវប្បធម៌"(ស្ពានចម្លង)រវាងការរំពឹងទុកនៅក្នុងដំណើរការវិមជ្ឈការ និងវិសហមជ្ឈការ និងម្ចាស់ជំនួយ ដែលជាអ្នកជួយគាំទ្រ ហើយម្ខាងទៀតជារដ្ឋាភិបាលថ្នាក់ក្រោមជាតិ ក្រុមប្រឹក្សាឃុំ សង្កាត់ និងសហគមន៍។ នៅពេលជាមួយគ្នានេះដែរ ភ្នាក់ងារផ្លាស់ប្តូរទាំងនេះត្រូវប្រឈមខ្លួនទៅនឹងការយល់ឃើញជាសកល និងរបៀបធ្វើការងារដូច្នេះការងារនេះតំរូវឱ្យមានការគាំទ្រយ៉ាងធំធេងមួយ ដូចជា"ការបង្ហាត់បង្ហាញ"ពីអ្នកឯកទេសអន្តរជាតិ ដែលដឹកនាំគម្រោង (MacKay, 2009)។ *យើងនឹងនិយាយអំពីចំណុចនេះម្តងទៀតនៅផ្នែកទីបួន។*

# ផ្នែកទី២.ការសិក្សាវាយតម្លៃសមត្ថភាព គ.ក.ន.ក

## ២ .១. របកគំហើញចម្បងៗពីការសិក្សាវាយតម្លៃបែបគុណភាព

ការសិក្សានេះប្រើប្រាស់ទិន្នន័យដែលបានមកពីការចុះសិក្សាផ្ទាល់ ព្រមទាំងឯកសារដែលបានមានពីការសិក្សាស្រាវជ្រាវកាលពីមុន។ តាមរយៈការពិនិត្យមើលទៅលើរបកគំហើញពីការសិក្សាស្រាវជ្រាវផ្សេងៗ យើងអាចទទួលស្គាល់ថា មានការរីកចំរើន ក៏ដូចជាកំណត់បានលំនាំគំរូមួយចំនួនដែលបានកើតឡើងជារឿយៗ។

### ២.១.១.ការសិក្សាវាយតម្លៃបែបគុណភាពលើ គ.ក.ន.ក និងអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ ដែលគាំទ្រដោយកម្មវិធីសិទ្ធិកុមារ

ក្នុងឆ្នាំ២០០៦ អង្គការយូនីសេហ្វបានផ្សព្វផ្សាយអំពីការសិក្សាស្រាវជ្រាវបែបគុណភាពទៅលើ គ.ក.ន.ក និងអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំនៅក្នុងខេត្តចំនួន៣ដែលគាំទ្រដោយអង្គការយូនីសេហ្វ។ ជាពិសេសការសិក្សានេះបានពិនិត្យមើលទៅលើតួនាទីរបស់អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំក្នុងដំណើរការកសាងផែនការ និងការផ្តល់សេវាទៅឱ្យស្ត្រី និងកុមារនៅក្នុងមូលដ្ឋាន និងមុខងារដទៃទៀតរបស់ គ.ក.ន.ក។

ការសិក្សានេះ បានរាយការណ៍ឱ្យដឹងថាមានគំនិតផ្តួចផ្តើមជាច្រើន រួមទាំងការបណ្តុះបណ្តាល ដែលជួយបង្កើនកំរិតសមត្ថភាព និងការយល់ដឹងអំពីមុខងារក្នុងគណៈកម្មាធិការឱ្យកាន់តែប្រសើរ។ សមាជិករបស់ គ.ក.ន.ក. ត្រូវបានសន្មត់ថាចាប់ផ្តើមអនុវត្តតួនាទីជាអ្នកស្វែងរកការគាំទ្រមតិសម្រាប់បញ្ហាស្ត្រី និងកុមារក្នុងសហគមន៍។ គ.ក.ន.ក ក៏បានជំរុញផងដែរនូវការផ្តល់សេវាមួយចំនួនតាមរយៈការបង្កើតសាលាមត្តេយ្យសិក្សាសហគមន៍ ការរៀបចំសកម្មភាពលើកកម្ពស់ការយល់ដឹងពីអំពើហឹង្សាក្នុងគ្រួសារ ជំរុញលើកទឹកចិត្តឱ្យកុមារទទួលបានថ្នាំបង្ការគ្រប់គ្រាន់ រៀបចំយុទ្ធនាការផ្សព្វផ្សាយពីសុខភាពដើម្បីលើកកម្ពស់អនាម័យ សហការណ៍ជាមួយមណ្ឌលសុខភាពដើម្បីជំរុញឱ្យមានការបំបៅកូនដោយទឹកដោះម្តាយ និងជំរុញឱ្យមានវគ្គអក្ខរកម្មសម្រាប់មនុស្សពេញវ័យ។

មិនមានអ្វីភ្ញាក់ផ្អើលទេ ដែលការសិក្សាស្រាវជ្រាវត្រូវបានធ្វើឡើងមួយឆ្នាំបន្ទាប់ពីបានបង្កើត គ.ក.ន.ក នៅក្នុងឆ្នាំ២០០៤ ហើយសមត្ថភាព និងចំណេះដឹងខាងបច្ចេកទេសរបស់សមាជិក គ.ក.ន.ក. នៅមានកំរិត និងផ្តល់អនុសាសន៍ថាមានតម្រូវការជួយគាំទ្របន្ថែមទៀត។ ខ្លឹមសារវគ្គបណ្តុះបណ្តាល[2] (សុខភាព អប់រំ កិច្ចការពារ កុមារ និងសិទ្ធិកុមារ) និងវេទិការៀនសូត្រជាច្រើន ត្រូវបានកំណត់ជាកាតាលិករក្នុងការពន្លឿនឱ្យមានការផ្លាស់ប្តូរបន្ថែមទៀត។ ការសិក្សានេះបានផ្តល់អនុសាសន៍ថា គួរធ្វើការផ្តល់ថវិកាប្រតិបត្តិការដើម្បីជួយបង្កើត និងគ្រប់គ្រង គ.ក.ន.ក។

ការសិក្សានេះបានរំលេចឡើងពីសារៈសំខាន់ក្នុងការកសាងទំនាក់ទំនង ដើម្បីបំពេញមុខងាររបស់ គ.ក.ន.ក ដោយបានកត់សំគាល់ថា ទំនាក់ទំនងការងារកើតឡើងក្នុងចំណោមសមាជិកគណៈកម្មាធិការដែលត្រូវបានធ្វើឡើងនៅក្រោយកិច្ចប្រជុំប្រចាំខែរបស់ គ.ក.ន.ក និងក្រៅម៉ោងធ្វើការងារ ហើយ គ.ក.ន.ក បានចាប់ផ្តើមមានការបត់បែនយ៉ាងច្រើន និងធ្វើកិច្ចសហការជាមួយគ្នាល្អជាងមុនទាំងក្នុង និងក្រៅកិច្ចប្រជុំ។

[2] មាតិកាបណ្តុះបណ្តាលគឺជាសិក្ខាសាលាអភិវឌ្ឍសមត្ថភាពដែលត្រូវបានបង្កើតឡើងដើម្បីលើកកំពស់ការយល់ដឹងពីបញ្ហាសុខភាព អប់រំ និងការគាំពារកុមារព្រមទាំងវិភាគទៅលើមូលហេតុដែលមានស្រាប់។ មាតិការបណ្តុះបណ្តាលបានកំនត់ពីសេវាមូលដ្ឋានដែលអាចអោយកំរិតភូមិ និងឃុំអាចប្រើប្រាស់បាន។ តាមរយៈមាតិកាបណ្តុះបណ្តាលធ្វើឱ្យក្រុមប្រឹក្សាឃុំសង្កាត់ដឹងថាតើពួកគាត់នឹងត្រូវលើកឡើងពីបញ្ហាស្ត្រី និង កុមារឱ្យគេទទួលស្គាល់តាមរបៀបណា។

គ.ក.ន.ក/អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ ដែលទទួលបានបទពិសោធន៍ពីសមាជិកសហគមន៍មួយចំនួនទទួលស្គាល់ថា ពួកគេត្រូវការចំណាយពេលវេលាក្នុងការធ្វើឱ្យសមាជិកសហគមន៍យល់ដឹង និងទទួលស្គាល់ការងាររបស់ គ.ក.ន.ក និងតួនាទីរបស់អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ មុននឹងសហគមន៍មើលឃើញការរីកចំរើនកើតឡើងពិតប្រាកដ។ ការងារនេះមានសារៈសំខាន់ណាស់ក្នុងគោលដៅអភិវឌ្ឍន៍សង្គម ដែលជាទូទៅមិនអាចមើលឃើញភ្លាមៗទេ។ ឧទាហរណ៍ ស្ពានដែលទើបនឹងសង់រួចថ្មីៗ គឺជាសមិទ្ធផលរូបីមួយ រីឯអត្រាកើនឡើងនៃការចូលរៀនរបស់សិស្សមិនអាចមើលឃើញ។ របកគំហើញនេះជាផ្នែកមួយក្នុងការពន្យល់ថា ហេតុអ្វីបានជាក្រុមប្រឹក្សាឃុំ សង្កាត់ ឱ្យតំលៃយ៉ាងខ្លាំងទៅលើគម្រោងហេដ្ឋារចនាសម្ព័ន្ធ។

ការសិក្សាក៏បានរំលេចពីបញ្ហាប្រឈមមុខមួយចំនួន ដែល គ.ក.ន.ក/អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ ជួបប្រទះក្នុងការបំពេញការងារ ក្នុងនោះរួមមាន ៖

ក. មធ្យោបាយធ្វើដំណើរទៅកាន់តំបន់ដាច់ស្រយាល និងក្នុងអំឡុងពេលរដូវភ្លៀង ព្រមទាំងការព្រួយបារម្ភពីសន្តិសុខ និងថវិកាប្រតិបត្តិការមិនគ្រប់គ្រាន់

ខ. គណៈកម្មាធិការមួយចំនួនបានទទួលវគ្គបណ្តុះបណ្តាលពីអង្គការជាច្រើន ហើយមានអារម្មណ៍ថាច្រើនលើសលប់

គ. ទំនុកចិត្តតិចតួចដោយការខ្វះចំណេះដឹងបច្ចេកទេសធ្វើឱ្យកាន់តែមានភាពស្រពិចស្រពិលថែមទៀត ជាពិសេសបទពិសោធន៍ទទួលបានពីបុគ្គលិករដ្ឋបាលក្រោមថ្នាក់ជាតិ ក្រុមការងារ និងក្រុមអ្នកសម្របសម្រួល

ឃ. សមាជិក គ.ក.ន.ក មួយចំនួនមានតួនាទីក្នុងគណៈកម្មាធិការជាច្រើន ប៉ុន្តែមិនអាចធ្វើការសម្របសម្រួល ឬធ្វើសមាហរណកម្មការទទួលខុសត្រូវផ្សេងៗគ្នារបស់ខ្លួននៅឡើយទេ ហើយការងារនេះធ្វើឱ្យកាន់តែធ្ងន់ឡើងដែលសមាជិក គ.ក.ន.ក ទាំងអស់មិនមែនការប្តេជ្ញាចិត្តស្មើគ្នានោះទេ

ង. ខ្វះខាតទិន្នន័យ និងស្ថិតិដែលគួរឱ្យជឿទុកចិត្តដើម្បីផ្តល់ពត៌មានដល់ការកសាងផែនការ និងការសម្រេចចិត្ត

ច. ការយល់ដឹងពីការប្រើប្រាស់ថវិកាប្រតិបត្តិការ និងពីរបៀបបែងចែកថវិកានៅមានកម្រិតដោយមានការលើកឡើងថា មានការខ្វះទំនុកចិត្ត និងមិនសូវមានតម្លាភាពរវាងក្រុមប្រឹក្សាឃុំ និង គ.ក.ន.ក/អ្នកទទួលន្ទុកកិច្ចការនារី និងកុមារឃុំ

ឆ. មានការលើកឡើងផងដែរថា អង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការក្នុងវិស័យសង្គមនៅមូលដ្ឋានតែងតែមានទំនាក់ទំនងល្អជាមួយនឹងប្រជាជនសាមញ្ញ រីឯទំនាក់ទំនងជាមួយអាជ្ញាធរថ្នាក់ស្រុក ឬថ្នាក់ឃុំ សង្កាត់ ជាទូទៅនៅមានភាពខ្សោយនៅឡើយ។ ជាលទ្ធផល ទំនាក់ទំនងការងាររវាង គ.ក.ន.ក/អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ជាមួយអង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាល នៅមិនទាន់បានស្មើគ្នាទេ។

សរុបមកករណីសិក្សាដែលបានពីការសិក្សានេះបង្ហាញថា អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ហាក់បីដូចជាមានភាពស្ទាក់ស្ទើរនៅខណៈពេលដែលការងារមានភាពរីកចំរើនតាមតួនាទីរបស់គាត់។ ករណីទាំងនេះនៅមានដូចៗគ្នាដែរចំពោះអ្នកមានបទពិសោធន៍ និងមានទំនុកចិត្ត ព្រមទាំងអ្នកដែលមិនមានបទពិសោធន៍។ ការប្រឈមទាំង

នេះ រួមបញ្ចូលផងដែរនូវការមានអារម្មណ៍មិនចង់ប្រាប់ ការមិនយល់ពីបញ្ហាបានលើកឡើងក្នុងពេលប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ ការរើសអើងពីបុរសរួមការងារ និងការខ្វះទំនុកចិត្តជាដើម ។

### ២.១.២. ការសិក្សាវាយតំម្លៃអំពីចំណេះដឹង អាកប្បកិរិយា និងការអនុវត្តការងាររបស់អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ (KAP STUDY)

តាមការសិក្សាវាយតំម្លៃអំពីចំណេះដឹង អាកប្បកិរិយា និងការអនុវត្តការងាររបស់អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ឆ្នាំ២០០៨នេះបានពិនិត្យមើលឡើងវិញនូវមុខងារ ចំណុចខ្លាំង និងសកម្មភាពនានារបស់គ.ក.ន.ក/អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ទាំងនៅខេត្តដែលគាំទ្រដោយកម្មវិធីសិទ្ធិកុមារ និងខេត្តដែលមិនមានការគាំទ្រពីកម្មវិធីសិទ្ធិកុមារ ។ គោលបំណងទី១ គឺ កត់ត្រាសកម្មភាពនានារបស់អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ ។ គោលបំណងទី២ គឺ លើកកម្ពស់ការយល់ដឹង និងការគិតគូស៊ីជម្រៅទៅលើតួនាទីរបស់ពួកគេក្នុងចំណោមភ្នាក់ងាររដ្ឋាភិបាលពាក់ព័ន្ធ ។ ការស្ទង់មតិត្រូវបានធ្វើទៅលើអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ មេឃុំ និងអ្នកពាក់ព័ន្ធនានា (អ្នកតំណាងមកពីសាលារៀន និងមណ្ឌលសុខភាព គ្រូមត្តេយ្យសហគមន៍ និងមេភូមិ)[3] ។ ការសិក្សានេះ បានរកឃើញថា អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំភាគច្រើនបានបង្ហាញពីតួនាទី និងការទទួលខុសត្រូវយ៉ាងច្បាស់លាស់ ព្រមទាំងបានលើកពីបញ្ហាស្ត្រី និងកុមារយ៉ាងសកម្ម ។ អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ជាទូទៅរកឃើញថាជាមនុស្សដែលមានការលើកទឹកចិត្តយ៉ាងខ្លាំង ធ្វើការងារច្រើន ចេះបត់បែន ហើយមានការយល់ដឹងពីតម្រូវការ ព្រមទាំងចេះប្រើប្រាស់វិធីសាស្ត្រផ្សេងៗឱ្យស្របទៅតាមស្ថានភាពរបស់គណៈកម្មាធិការ និងក្រុមសហគមន៍ផ្សេងៗ ។ ប៉ុន្តែការសម្របសម្រួល និងកិច្ចសហការ នៅតែជាឧបសគ្គចំពោះពួកគាត់ ដែលនេះជាហេតុផលមកពីការខ្វះជំនាញក្នុងការចរចារ និងការតស៊ូមតិ ហើយចំពោះអ្នកខ្លះទៀត នៅតែខ្វះទំនុកចិត្ត ចំណែកឯការធ្វើដំណើរទៅតំបន់ដាច់ស្រយាលនៅតែជាជាបញ្ហាលំបាកសម្រាប់ពួកគាត់ដែរ ។

នៅក្នុងការអនុវត្តជាក់ស្តែង អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំដែលមានការជួយគាំទ្រពីកម្មវិធីសិទ្ធិកុមារនៃអង្គការយូនីសេហ្វ និងមិនមានការគាំទ្រពីកម្មវិធីសិទ្ធិកុមារនៃអង្គការយូនីសេហ្វ បានធ្វើការដោះស្រាយបញ្ហាចំបងៗ ដូចជា វិស័យអប់រំ សុខាភិបាល អំពើហឹង្សាក្នុងគ្រួសារ និងយេនឌ័រទៅតាមកម្រិតខុសៗគ្នា និងតាមវិធីសាស្ត្រផ្សេងគ្នា ។ អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំដែលមានការជួយគាំទ្រពីកម្មវិធីសិទ្ធិកុមារនៃអង្គការយូនីសេហ្វ មានការផ្តោតខ្លាំងលើបញ្ហាសុខភាព និងការអប់រំ នៅខណៈពេលដែលអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំមិនមានការជួយគាំទ្រពីកម្មវិធីសិទ្ធិកុមារនៃយូនីសេហ្វមិនសូវផ្តោតការយកចិត្តទុកដាក់លើបញ្ហាកុមារ ។ លើសពីនេះទៅទៀត ពួកគេហាក់បីដូចជាមានការប្រតិបត្តិការងារ មានលក្ខណៈឯករាជ្យជាងឃុំដែលមានការគាំទ្រពីកម្មវិធីសិទ្ធិកុមារ នៃអង្គការយូនីសេហ្វ ។ ផ្ទុយទៅវិញ អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំដែលមានការជួយគាំទ្រកម្មវិធីសិទ្ធិកុមារ នៃអង្គការយូនីសេហ្វ បានផ្តោតសំខាន់លើការធ្វើការងារដោយមានកិច្ចសហការជាមួយដៃគូនានា ដូចជា សាលារៀន និងមណ្ឌលសុខភាព ហើយក្លាយជាចំណុចកណ្តាលក្នុងការទំនាក់ទំនងសម្រាប់សមាជិកសហគមន៍ជាលក្ខណៈបុគ្គល និងអាជ្ញាធរមូលដ្ឋានក្នុងការ

[3] កំនត់សំគាល់: ទិន្នន័យត្រូវបានប្រមូលកាលពីខែកុម្ភៈឆ្នាំ ២០០៧ របាយការណ៏ត្រូវបានសរសេររួចរាល់នៅឆ្នាំបន្ទាប់ ។ ការស្ទាបស្ទង់មតិនេះបានធ្វើទៅលើខេត្តចំនួន ៤ ឃុំចំនួន ៧០ ឃុំ ដែលក្នុងនោះ ៥០ឃុំនៅក្រោមការគាំទ្ររបស់កម្មវិធីសិទ្ធិកុមារ នៃអង្គការយូនីសេហ្វ ។

ជំរុញឱ្យមានសេវាជាមូលដ្ឋានសម្រាប់ស្ត្រី និងកុមារ ។ បើនិយាយឱ្យខ្លីទៅ អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ បានដើរតួជាស្ពានក្នុងការភ្ជាប់ទំនាក់ទំនងរវាងក្រុមប្រឹក្សាឃុំជាមួយសហគមន៍ និងដើរតួសំខាន់នៅក្នុងការពង្រឹងបណ្ដាញការងារទាំងមូលផងដែរ ។

អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំក៏បានជួយផ្ដល់ដោយផ្ទាល់ផងដែរនូវសូចនាករពាក់ព័ន្ធស្ត្រី[4] និងកុមារដែលសូចនាករទាំងនោះពាក់ព័ន្ធនឹងសុខភាព និងការរស់រានមានជីវិតរបស់កុមារ( ការចាក់ថ្នាំបង្ការ និងការបំបៅកូនដោយទឹកដោះម្ដាយ) ការអប់រំ( ការចុះឈ្មោះចូលរៀន ការកាត់បន្ថយអត្រាបោះបង់ការសិក្សា) កិច្ចការពារកុមារ ( ការចុះបញ្ជីកំណើត និងការប្រឆាំងសកម្មភាពជួញដូរ និងការកេងប្រវ័ញ្ចផ្លូវភេទ) ជំងឺអេដស៍( តាមរយៈការជំរុញឱ្យមានការយល់ដឹង និងការការពារ) បញ្ហាយេនឌ័រ ( អំពើហិង្សាក្នុងគ្រួសារ និងការលើកកម្ពស់ការចូលរួមរបស់ស្ត្រី) ។

គោរពទៅតាមគោលដៅអភិវឌ្ឍសមត្ថភាព វគ្គបណ្ដុះបណ្ដាលជំនាញសម្របសម្រួល និងជំនាញទំនាក់ទំនងត្រូវបានចាត់ជាជំនាញមូលដ្ឋានសំខាន់ដែលផ្ដល់ជាគ្រឹះក្នុងការបង្កើតទំនាក់ទំនងកិច្ចសហប្រតិបត្តិការ ការចរចារ និងឥទ្ធិពលក្នុងការពង្រឹងបណ្ដាញការងារ ។ វេទិកា[5] ដែលផ្ដោតលើការអភិវឌ្ឍជំនាញការប្រាស្រ័យទាក់ទង និងការសម្របសម្រួលត្រូវបានទទួលស្គាល់ថាពិតជាមានប្រយោជន៍យ៉ាងច្រើន ។ អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំដែលគាំទ្រដោយកម្មវិធីសិទ្ធិកុមារ នៃអង្គការយូនីសេហ្វ បានទទួលផលប្រយោជន៍ពីវគ្គបណ្ដុះបណ្ដាលតាមវិស័យជំនាញលើផ្នែកបួន( សុខភាពកុមារ សិទ្ធិកុមារ កិច្ចការពារកុមារ និងការអប់រំ) ។

ការប្រឈមជាច្រើនត្រូវបានកត់សំគាល់ក្នុងការសិក្សានេះ :

ក. អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំមួយចំនួនបាននិយាយថាអំណាចក្នុងការធ្វើសេចក្ដីសម្រេចនៅក្នុងក្រុមប្រឹក្សាឃុំនៅមានកំរិតដោយសារតែអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំភាគច្រើន ត្រូវបានតែងតាំង( គ្មានឋានៈ និងសិទ្ធបោះឆ្នោត) ម្យ៉ាងទៀតពួកគេខ្វះទំនុកចិត្តលើសមត្ថភាពក្នុងការនិយាយ និងអ្វីដែលមានតំលៃត្រូវនិយាយ ។ កត្តាចូលរួមមួយទៀតនោះគឺ ក្រុមប្រឹក្សាឃុំបន្តជួយទៅលើគម្រោងហេដ្ឋារចនាសម្ព័ន្ធច្រើនជាងគម្រោងសេវាសង្គម ។ ដូចនេះត្រូវពង្រឹងការអភិវឌ្ឍទំនាក់ទំនងការងាររវាងអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ មេឃុំ ជំទប់ ព្រមទាំងសមាជិក គ.ក.ន.ក ដទៃទៀត ។ ( ធ្វើទាំងអស់គ្នាជាជាងធ្វើតាមផ្នែក) ។

ខ. មានការទទួលស្គាល់ពីតម្រូវការ ក្នុងការកសាងភាពជាដៃគូឱ្យកាន់តែមានប្រសិទ្ធភាពជាមួយនឹងអ្នកផ្ដល់សេវា និងជាមួយមន្ទីរវិស័យពាក់ព័ន្ធ( រួមមាន សុខាភិបាល អប់រំ សង្គមកិច្ច និងអភិវឌ្ឍន៍ជនបទ) ដើម្បីបង្កើនការទទួលបាននូវសេវា និងគុណភាពនៃសេវាសំខាន់ៗទាំងនេះ ។ ក្នុងពេលជាមួយគ្នានោះដែរក៏មានតម្រូវការក្នុងការពង្រីកយុទ្ធសាស្ត្រទំនាក់ទំនង( បង្កើនការយល់ដឹង) ដើម្បីពង្រឹងការឥស្សមតិ ការធ្វើការ

[4] ផែនការសកម្មភាពកម្មវិធីប្រចាំប្រទេសរបស់អង្គកាតយូនីសេហ្វកម្ពុជា( CPAP ) ឆ្នាំ២០០៦-២០១០ ។ អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំរួមចំណែកនៅក្នុងការសម្រេចសមិទ្ធិផលដែលមានក្នុងគោលដៅរបស់កម្មវិធីសិទ្ធកុមារនៃអង្គការយូនីសេហ្វ និងផ្នែកផ្សេងទៀតរបស់អង្គការយូនីសេហ្វ ។

[5] វេទិកា គ.ក.ន.ក ត្រូវបានរៀបចំឡើងដោយអង្គការចំរើនស្ត្រីចាប់តាំងពីឆ្នាំ២០០៦មកម្លេះ ។ ក្រោយមកទៀតវេទិកានេះត្រូវបានរៀបចំឡើងដោយ PDWA/DoWA ។ វេទិកានឹងត្រូវពណ៌នាជាពិស្តារបន្ថែមនៅទំព័រក្រោយៗ ។

ផ្ទាល់ជាមួយយុវជន និងកុមារ និងសម្របសម្រួលឱ្យមានការទំនាក់ទំនងទៅវិញទៅមករវាងសហគមន៍ និងអាជ្ញាធរមូលដ្ឋាន។

គ. របៀបប្រមូល និងប្រើប្រាស់ទិន្នន័យ ត្រូវកែលម្អ។ ផ្នែកមួយដែលត្រូវកែលម្អនោះ គឺរបៀបប្រើប្រាស់ (បកស្រាយ) ទិន្នន័យសម្រាប់ការតាមដានត្រួតពិនិត្យ ការសរសេររបាយការណ៍ និងការធ្វើផែនការសកម្មភាពឱ្យមានប្រសិទ្ធភាព។ ផ្នែកមួយទៀត គឺបង្កើនការយល់ដឹងដល់អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំអំពីដំណើរការសាងផែនការ និងពីរបៀបទាញយកទិន្នន័យដើម្បីផ្តល់ពត៌មាន និងធ្វើឱ្យមានឥទ្ធិពលលើការរៀបចំកម្មវិធីវិនិយោគឃុំ។

ឃ. មានតម្រូវការក្នុងការផ្តល់ការយកចិត្តបន្ថែមទៀតលើកិច្ចការពារកុមារ ទឹកស្អាត និងអនាម័យ អាហារូបត្ថម្ភ និងសុខភាពមាតា។ ជាចុងក្រោយ ការសិក្សាបានផ្តល់អនុសាសន៍ថា សារៈសំខាន់ក្នុងការបង្កើតយុទ្ធសាស្ត្រអភិវឌ្ឍសមត្ថភាពរយៈពេលវែងរបស់ថ្នាក់ជាតិ គឺផ្តោតទៅលើបញ្ហាស្មើៗគ្នាដែលប្រឈមទៅលើស្ត្រី និងកុមារ និងផ្អែកទៅលើវិធីសាស្ត្ររៀនសូត្របែបសកម្មភាព ដែលអាចជួយឱ្យអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ អាចសម្របខ្លួនទៅនឹងបរិយាកាសនៃការផ្លាស់ប្តូរនេះ។

### ២.១.៣. ការពិនិត្យមើលរបស់ UNFPA ទៅលើផែនការខេត្ត និងកម្មវិធីវិនិយោគឃុំ

កម្មវិធីជំនួយប្រចាំប្រទេសរបស់ UNFPA សម្រាប់ឆ្នាំ២០០៦-២០១០ ស្វែងរកការជំរុញឱ្យមានការធ្វើសមាហរណកម្ម និងការអនុវត្តលើបញ្ហាប្រជាជនសំខាន់ៗមួយចំនួន រួមមាន យេនឌ័រ សុខភាពបន្តពូជ មេរោគអេដស៍ និងយុវជននៅក្នុងផែនការអភិវឌ្ឍនៅថ្នាក់ជាតិ និងថ្នាក់ឃុំ សង្កាត់។ ចាប់តាំងពីឆ្នាំ២០០៦មក UNFPA បានជួយគាំទ្រនាយកដ្ឋានរដ្ឋបាលមូលដ្ឋាននៃក្រសួងមហាផ្ទៃដើម្បីកសាងសមត្ថភាព និងធ្វើឱ្យមានការជ្រួតជ្រាបទៅដល់ក្រុមប្រឹក្សាឃុំទាំងអស់ និងអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំនៅក្នុងខេត្តដែលបានជ្រើសរើស[6]។ គោលដៅចុងក្រោយ គឺដើម្បីធានាថាផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគថ្នាក់ខេត្ត និងឃុំ សង្កាត់ ត្រូវបានដាក់បញ្ចូល និងឆ្លើយតបយ៉ាងសមស្របទៅនឹងបញ្ហាយេនឌ័រ សុខភាពបន្តពូជ ប្រជាជន និងយុវជន។

ការសិក្សានេះ ពិនិត្យមើលឡើងវិញលើផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ សង្កាត់សម្រាប់ឆ្នាំ២០០៧ និងឆ្នាំ២០០៨ នៅក្នុងតំបន់ដែល UNFPA ជួយគាំទ្រដើម្បីកំណត់រក (ក).កំរិតដែលក្រុមប្រឹក្សាឃុំ និងតួអង្គពាក់ព័ន្ធ (ដូចជាអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ) បានយល់ដឹងពីសារៈសំខាន់នៃបញ្ហាប្រជាជន សុខភាពបន្តពូជ និងយេនឌ័រ។ (ខ).របៀបឆ្លុះបញ្ចាំងពីសារៈសំខាន់នៃបញ្ហាប្រជាជន សុខភាពបន្តពូជ និងយេនឌ័រទៅក្នុងកម្មវិធីវិនិយោគឃុំ ហើយការសិក្សានេះក៏មានគោលដៅផងដែរក្នុងការចងក្រងពីរបៀបឆ្លុះបញ្ចាំងអំពីសារៈសំខាន់ទាំងនោះទៅក្នុងផែនការអភិវឌ្ឍន៍ខេត្ត និងរបៀបចាត់វិធានការណ៍ដើម្បីដោះស្រាយបញ្ហាទាំងនេះ។

ការសិក្សាបានរកឃើញថា ជាទូទៅកំរិតយល់ដឹងទៅលើបញ្ហាដែលពាក់ព័ន្ធនឹងប្រជាជន យេនឌ័រ និងសុខភាពបន្តពូជ និងយុវជនបានកើនឡើងរវាងឆ្នាំ២០០៧ និងឆ្នាំ២០០៨។ បញ្ហាយេនឌ័រជាង៩០ភាគរយ បានលើកឡើងនៅ

[6] ការងារនោះចាប់ផ្តើមពីឆ្នាំ២០០៦ នៅក្នុងស្រុកចំនួ១៥(១០១ឃុំ) ក្នុងខេត្តចំនួនបី(កោះកុង ក្រចេះ និងសៀមរាប)។ នៅឆ្នាំ២០០៧ ការងារនេះបានពង្រីកទៅខេត្តចំនួនពីរទៀត គឺខេត្តបាត់ដំបង និងខេត្តកំពង់ចាម ដែលមាន ២២ស្រុក និង២៤៥ឃុំ។ នៅឆ្នាំ២០០៩-២០១០ ការគាំទ្រនឹងពង្រីកឱ្យដល់ស្រុកចំនួន៦៧ នៅក្នុង១៤ខេត្ត (៤៤៦ ឃុំ)។

ក្នុងកម្មវិធីវិនិយោគឃុំ សង្កាត់ ហើយជាក់ស្តែងបញ្ហាសុខភាពបន្តពូជ និងយុវជនរួមមានជិត៨០ភាគរយ ត្រូវបានដាក់បញ្ចូលនៅក្នុងកម្មវិធីវិនិយោគឃុំ សង្កាត់។ លើសពីនេះទៀត សមត្ថភាពក្នុងការពន្យល់ និងពិភាក្សាលើបញ្ហា ក៏មានការកើនឡើងផងដែរ។ ឧទាហរណ៍ នៅក្នុងឆ្នាំ២០០៧ មេឃុំ និងអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំមួយចំនួនអាចគ្រាន់តែឆ្លើយតបដោយរៀបរាប់នូវចំណេះដឹងដែលបានចងចាំតែប៉ុណ្ណោះ ហើយការពិភាក្សានៅក្នុងឆ្នាំ២០០៩បានបង្ហាញឱ្យឃើញថា ពួកគាត់កាន់តែមានភាពប្រសើរឡើង។ របាយការណ៍បានផ្តល់យោបល់ដល់ **UNFPA** និង **DOLA / PLAU** ចំពោះការរួមចំណែករបស់ពួកគេក្នុងការសំរេចបានលទ្ធផលទាំងនេះ។

ការបញ្ជ្រាបយេនឌ័រ យេនឌ័រ និងការអប់រំ អំពើហិង្សាក្នុងគ្រួសារ ការជួញដូរ និងស្ត្រីនៅក្នុងការធ្វើសេចក្តីសម្រេច និងនយោបាយ គឺជាបញ្ហាដែលបានលើកឡើងញឹកញាប់ជាងគេ។ នៅពេលដែលបុគ្គលមួយចំនួនមានការនិយាយវែកញែកច្បាស់ជាងអ្នកផ្សេងទៀតនោះ ជារួមក្នុងរបាយការណ៍បានកត់សំគាល់ថា "កំរិតចំណេះដឹង និងការយល់ដឹងបានបង្ហាញឱ្យឃើញច្បាស់តាមរយៈសមត្ថភាពក្នុងការពន្យល់បញ្ហាតាមការយល់ឃើញបែបទ្រឹស្តី ដោយភ្ជាប់ជាមួយឧទាហរណ៍ពីជីវិតរស់នៅផ្ទាល់ខ្លួនជាក់ស្តែង និងពីសហគមន៍ដែលរស់នៅជិតខាង"។

របាយការណ៍បានកំណត់ថា យុទ្ធនាការផ្សព្វផ្សាយឱ្យមានការយល់ដឹងជាសាធារណៈ (តាមរយៈការឃោសនាតាមទូរទស្សន៍ និងវិទ្យុ វេទិកាសាធារណៈ និងសកម្មភាពសហគមន៍) ជាកត្តាជួយឱ្យមានសមត្ថភាពយ៉ាងសំខាន់មួយផងដែរ ប៉ុន្តែការយល់ដឹងនេះ គឺជាតម្រូវការចាំបាច់ដំបូងបំផុតមុននឹងរឿងរ៉ាវកើតឡើងពិត ឬមុនពេលទទួលបានផលប៉ះពាល់ពីរឿងជាក់ស្តែង ដូចយើងបានឃើញនៅក្នុងការពិភាក្សាថាតើហេតុអ្វីបានជាចំណាកស្រុកទៅកាន់ប្រទេសថៃមានការធ្លាក់ចុះ :

*"ជោគជ័យដែលទទួលបានពីការតស៊ូដោយកំលាំង ពិតជាមានការលំបាក។ កម្មករចំនាកស្រុកភាគច្រើន មិនបានទទួលប្រាក់សមរម្យដែលបានពីការប្តូរជាមួយនឹងកំលាំងពលកម្មរបស់ពួកគេទេ។ យើងបានឃើញថាកម្មករភាគច្រើនទូរស័ព្ទមកឱ្យឪពុកម្តាយដើម្បីផ្ញើលុយខ្លះមកពួកគេសម្រាប់ធ្វើដំណើរត្រលប់មកផ្ទះវិញ"។*

ការប្រើប្រាស់មណ្ឌលសុខភាព មានការកើនឡើងគួរឱ្យកត់សំគាល់នៅក្នុងរយៈពេលនៃការសិក្សា ជាពិសេសក្នុងចំណោមមនុស្សពេញវ័យបន្តពូជ(២៥-៣៥ឆ្នាំ)។ កត្តាដែលសំរេចបានដូចនេះគឺដោយសារមានការផ្លាស់ប្តូរអាកប្បកិរិយាជាវិជ្ជមានក្នុងការកែលំអការបំពេញការងាររបស់មណ្ឌលសុខភាព ជាពិសេសទាក់ទងនឹងការផ្លាស់ប្តូរអាកប្បកិរិយារបស់បុគ្គលិកពេទ្យទ្វេដង។ អ្នកភូមិជាច្រើន ចាប់ផ្តើមពន្យល់ណែនាំគ្នាពីម្នាក់ទៅម្នាក់ នៅពេលដែលគ្រួសារនីមួយៗចាប់ផ្តើមប្រើប្រាស់សេវាសុខភាព ហើយចាប់ផ្តើមមានសុខភាពល្អ និងទ្រព្យសម្បត្តិទៀតនោះ រីឯគ្រួសារដទៃទៀតចាប់ផ្តើមជឿ និងប្រើប្រាស់សេវានេះដែរ។

ការសិក្សាបានសរសើរអំពីគំរូនៃការគាំទ្រផ្នែកហិរញ្ញវត្ថុដែលបានផ្តល់ឱ្យស្ថិតក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន/អង្គភាពរដ្ឋបាលមូលដ្ឋានខេត្តដែលតាមរយៈគំរូនេះបានផ្តល់ភាពជាម្ចាស់ទៅឱ្យក្រុមប្រឹក្សាឃុំ ដូចជាពួកគេធ្វើផែនការ និងអនុវត្តសកម្មភាពដោយខ្លួនឯង។ តាមសំដីរបស់អ្នកទទួលបន្ទុកកិច្ចការនារីម្នាក់បាននិយាយថា:

*"លុយដែលផ្តល់ឱ្យមិនច្រើនទេ តែវាផ្តល់ជាមធ្យោបាយសម្រាប់យើងធ្វើការងារ ។ វាគឺសំខាន់ណាស់ក្នុងការបង់ថ្លៃប្រេងសាំង ។ ចំពោះខ្ញុំផ្ទាល់ ខ្ញុំចំណាយលុយខ្លួនឯងរាល់ពេលខ្ញុំទៅចូលរួមវគ្គបណ្តុះបណ្តាល ប៉ុន្តែខ្ញុំសប្បាយចិត្តនឹងចំណាយ ។ យើងចំណាយលុយមួយចំនួនសំរាប់ទិញទឹកសុទ្ធ និងនំ នៅក្នុងវគ្គបណ្តុះបណ្តាលលើកទីមួយ ។ វគ្គបណ្តុះបណ្តាលបន្ទាប់ យើងទិញជាសៀវភៅ និងប៊ិច.. ។ មានពេលមួយ អ្នកភូមិទទួលបានរបស់នៅពេលដែលពួកគាត់ចូលរួមវគ្គបណ្តុះបណ្តាល វាមិនមានការលំបាកទេក្នុងការហៅពួកគាត់មកម្តងទៀតសំរាប់វគ្គក្រោយៗ ។ តែជារឿយៗ យើងទទួលបានអ្នកចូលរួមច្រើនជាងផែនការកំណត់ ។ ក្មេងតូចៗ ក៏មានចំណីសម្រាប់ហូបដែរ ធ្វើដូចនេះទើបម្តាយរបស់ក្មេងអាចចូលរួមរហូតដល់កម្មវិធីចប់ ។"*

ការសរសើរសំខាន់ផ្សេងទៀតដែលបានកើតឡើងតាមរយៈមូលនិធិនេះ គឺក្រុមប្រឹក្សាឃុំអាចដឹកនាំវគ្គបណ្តុះបណ្តាលកិរិតភូមិបានទៀងទាត់ដោយមិនផ្អែកលើវគ្គបណ្តុះបណ្តាល ឬសកម្មភាពរបស់អង្គការមិនមែនរដ្ឋាភិបាលម្តងណាឡើយ ។ *"នេះគឺជាភាពខុសគ្នាក្នុងការធ្វើការជាមួយអង្គការមិនមែនរដ្ឋាភិបាល ពួកគេបែរជាធ្វើអ្វីៗដោយខ្លួនឯង"* ការប្រឈមមួយចំនួនត្រូវបានកំណត់ក្នុងការសិក្សានេះគឺៈ

ក. បញ្ហាទាក់ទងនឹងសុខភាព និងយេនឌ័រ និងការរំលោភផ្លូវភេទ ត្រូវបានដាក់បញ្ចូលតិចតួចទៅក្នុងកម្មវិធីវិនិយោគឃុំ ។ ហេតុផលមួយដែលអាចកើតមានឡើងនោះ គឺការចំលងមេរោគហ៊ីវពីប្តីទៅប្រពន្ធ និងការរំលោភផ្លូវភេទនៅតែជាប្រភពនៃការខ្មាស់អៀន( នាំឱ្យមានការអាប់អោនកិត្តិយស) នៅក្នុងគ្រួសារ ។

ខ. បញ្ហាប្រជាជននៅតែជាការប្រឈមមួយពីព្រោះជាទូទៅបញ្ហាប្រជាជនមានភាពស្មុគស្មាញ និងលំបាកនៅក្នុងការគ្រប់គ្រង ។

គ. ក្នុងករណីខ្លះ វាបានលេចឡើងនៅក្នុងការរៀបចំកម្មវិធីវិនិយោគឃុំ ដែលក្រុមប្រឹក្សាឃុំគ្រាន់តែចម្លងចេញពីតារាងមក ដោយមិនមានការវិភាគឱ្យបានច្បាស់លាស់ពីហេតុផលក្នុងការជ្រើសរើសយកជម្រើសនេះ ឬការជាប់ទាក់ទងទៅនឹងជម្រើសទាំងនេះ ។ កំណត់សំគាល់ជាវិជ្ជមានមួយ ដែលការសិក្សាបានរកឃើញថា ផែនការត្រូវបានអនុវត្តជាសកម្មភាព ហើយបញ្ហាដែលបានលើកឡើងក្នុងពេលប្រជុំភូមិ ក៏មានឥទ្ធិពលដល់ដំណើរការកសាងផែនការផងដែរ ។

ឃ. ធនធានមូលនិធិជាច្រើនពីដៃគូអភិវឌ្ឍផ្សេងៗ អង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ព្រមទាំងភ្នាក់ងាររដ្ឋាភិបាល ( ជាពិសេស គឺក្រសួងសុខាភិបាល ក្រសួងកិច្ចការនារី និងក្រសួងផែនការ) មិនបានជួយដល់បញ្ហាអាទិភាពដែលលើកឡើង មិនបានជួយសម្របសម្រួលក្នុងការធ្វើផែនការសកម្មភាព ឬការតាមដានត្រួតពិនិត្យ និងការធ្វើរបាយការណ៍ឡើយ ។

ង. មានលទ្ធផលរួមមួយអំពីស្ត្រីដែលត្រូវបានផ្តល់ឱកាសឱ្យចូលរួមក្នុងតួនាទីជាអ្នកធ្វើសេចក្តីសម្រេចចិត្ត ដែលនៅក្នុងពេលនោះដែរ អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំភាគច្រើន បានបង្ហាញពីការស្ងើចសរសើរយ៉ាងខ្លាំង ហើយស្ត្រីភាគច្រើនដែលបានចូលរួមសម្ភាសន៍បានបង្ហាញពីភាពស្ទាក់ស្ទើរក្នុងការចូលរួម ដោយសារតែជាប់រវល់ក្នុងការរកចំណូលដើម្បីជួយគ្រួសារ ឬខ្វះការគាំទ្រពីស្វាមីរបស់ពួកគេ ។

ការសិក្សានេះ បានសន្និដ្ឋានថា មានការជាប់ទាក់ទងគ្នាផ្ទាល់រវាងការគាំទ្ររបស់ UNFPA និងការយកចិត្តទុកដាក់លើបញ្ហាស្ត្រី និងកុមារ នៅក្នុងកម្មវិធីវិនិយោគឃុំ។ ការយកចិត្តទុកដាក់នេះបានធ្វើឱ្យកើនឡើងនូវបទពិសោធន៍ ហើយការផ្តល់មូលនិធិគឺជាសមាសភាពគ្រាប់ពូជសំខាន់មួយដែរ។ ការងារសំខាន់មួយទៀត គឺ ក៏រិត និងភាពញឹកញាប់នៃការអនុវត្តការងារហាក់បីដូចជាធ្វើតែនៅពេលដែលមានមូលនិធិផ្តល់ឱ្យ តែមិនធ្វើការងារឱ្យហួសពីលទ្ធភាពចំណាយ ឬធ្វើសកម្មភាពច្រើនពេក។ ក្រុមប្រឹក្សាឃុំណាដែលបានទទួលមូលនិធិពី UNFPA និងពីប្រភពដទៃទៀត (ឧទាហរណ៍ គម្រោងរបស់អង្គការមិនមែនរដ្ឋាភិបាល) ក៏អាចស្រូបមូលនិធិដើម្បីយកទៅធ្វើការតាមការប្តេជ្ញាចិត្តរបស់ខ្លួន។

## ២.១.៤. ការសិក្សាវាយតម្លៃសមត្ថភាព គ.ក.ន.ក/អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ដោយ MOI-DOLA/UNICEF

ដូចបានពិពណ៌នានៅក្នុងផ្នែកទី ១.៣ ខាងលើ ការសិក្សានេះបានប្រើវិធីសាស្ត្រក្រុមពិភាក្សា និងការសម្ភាសន៍ដោយស៊ីជម្រៅជាមួយ គ.ក.ន.ក និងអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ អ្នកតំណាងមកពីសហគមន៍ (អ្នកប្រើប្រាស់សេវា) និងអ្នកផ្តល់សេវាជាច្រើនទៀតនៅក្នុងខេត្តចំនួន៥។ បន្ថែមលើនេះទៅទៀតក៏មានការសម្ភាសន៍ដោយស៊ីជម្រៅជាមួយអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ដើម្បីពិនិត្យរកមើលបញ្ហាជាក់លាក់ដែលពួកគេមានបទពិសោធន៍ក្នុងការបំពេញតួនាទីរបស់ខ្លួន។ ក្នុងការសម្ភាសន៍ដោយស៊ីជម្រៅជាមួយក្រុមអ្នកផ្តល់ព័ត៌មានផ្សេងទៀតត្រូវបានរៀបចំឡើងទៅតាមតម្រូវការ។ ទិន្នន័យទាំងនេះ ត្រូវបានបំពេញបន្ថែម តាមរយៈការពិគ្រោះយោបល់ជាមួយដៃគូអភិវឌ្ឍន៍ អង្គការជាតិ និងអន្តរជាតិផ្សេងៗ ដែលធ្លាប់បានធ្វើការគាំទ្រការអភិវឌ្ឍសមត្ថភាពគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ព្រមទាំងបានពិនិត្យឡើងវិញនូវកិច្ចអន្តរាគមន៍ក្នុងការអភិវឌ្ឍសមត្ថភាពដែលបានធ្វើឡើងដោយរាជរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធដែលជាអង្គការមិនមែនរដ្ឋាភិបាល[7]។

ការសិក្សានេះ ជាការបញ្ជាក់អះអាងបន្ថែមទៅលើរបកគំហើញពីការសិក្សាមុនៗដែលបានរៀបរាប់ខាងលើ និងបង្ហាញពីទស្សនៈថ្មីៗបន្ថែមទៀតផងដែរ ហើយទស្សនៈទាំងនោះ បានសង្ខេបជាកត្តាជោគជ័យគន្លឹះៗ ដែលជួយឱ្យគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ មានការរីកលូតលាស់ និងអភិវឌ្ឍន៍។

### *អនុញ្ញាតឱ្យមានការរីកលូតលាស់តាមដំណាក់កាល ដែល គ.ក.ន.ក/អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ បំពេញការងារពីមួយឆ្នាំទៅមួយឆ្នាំ*

ទិន្នន័យបានបញ្ជាក់អះអាងយ៉ាងច្បាស់ថា របកគំហើញពីការសិក្សារបស់ UNFPA ដែលបានរៀបរាប់ខាងលើ គឺថា គ.ក.ន.ក និងអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ បានចូលរួមយ៉ាងសកម្មនៅក្នុងការរៀបចំផែនការការងារ និងថវិកាប្រចាំឆ្នាំដើម្បីដាក់ជូនក្រុមប្រឹក្សាឃុំ សង្កាត់ពិនិត្យនិងអនុម័ត។ វាបានកើតឡើងសូម្បីតែនៅពេលខ្លះផែនការការងារនៅឆ្នាំទី១មានទំនោរលើការប្រតិបត្តិច្រើន (ការរៀបចំកិច្ចប្រជុំរបស់ គ.ក.ន.ក និងព័ត៌មានអំពីការចំណាយលើកិច្ចប្រជុំ និងមធ្យោបាយធ្វើដំណើរ)។ កិច្ចការនេះក៏ជាផ្នែកមួយដែរពីព្រោះថា គ.ក.ន.ក ត្រូវការបញ្ជាក់ខ្លួនឯងថាតើមានការងារអ្វីខ្លះត្រូវធ្វើ ពីព្រោះនៅក្នុងកន្លែងខ្លះពួកគេត្រូវការបង្កើនការយល់ដឹងក្នុងចំណោមសហគមន៍ និង

---

[7] ការពិនិត្យនេះ រួមបញ្ចូលទាំងការពង្រឹងការសម្របសម្រួលរវាង គ.ក.ន.ក និងរចនាសម្ព័ន្ធដែលទាក់ទងការងារសុខភាព ដឹកនាំការសិក្សាដោយកាកបាទក្រហមស្វីស នៅខេត្តតាកែវ។ ការសិក្សាវាយតម្លៃសមត្ថភាពក្នុងកិច្ចការពារសង្គមដែលធ្វើដោយ DFIF ។ ការពិគ្រោះយោបល់ទៅលើផែនទីសេវាសង្គមដែលធ្វើដោយយូនីសេហ្វ និងការពិគ្រោះយោបល់សម្រាប់រៀបចំក្របខ័ណ្ឌការងារសម្រាប់ការអភិវឌ្ឍសមត្ថភាពស្ត្រីនៅថ្នាក់ក្រោមជាតិ។

អ្នកផ្តល់សេវាអំពីរបៀបដែលពួកគាត់ត្រូវបន្ថែមការឱ្យតម្លៃ។ នៅឆ្នាំទី២ទើបផែនការការងារនេះអាចផ្តោតជាក់លាក់ទៅលើសកម្មភាពដែលលើកកម្ពស់បញ្ហាស្ត្រី និងកុមារឃុំ។

កាន់តែសំខាន់ទៅទៀតនោះ ការសិក្សាបានបង្ហាញឱ្យឃើញច្បាស់ថា គ.ក.ន.ក បង្កើតឡើងដើម្បីភ្ជាប់ទំនាក់ទំនងរវាងក្រុមប្រឹក្សាឃុំ សង្កាត់ជាមួយសហគមន៍ និងរវាងក្រុមប្រឹក្សាឃុំ សង្កាត់ជាមួយគណៈកម្មាធិការផ្សេងទៀត (ដូចជា គណៈកម្មាធិការវត្ត ឬក្រុមទ្រទ្រង់សុខភាពភូមិ)។ នៅពេលបញ្ហាត្រូវបានកំណត់ច្បាស់លាស់ហើយនោះ អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ឬសមាជិក គ.ក.ន.ក បានយកទិន្នន័យនោះទៅលើកនៅក្នុងកិច្ចប្រជុំ គ.ក.ន.ក ហើយគណៈកម្មាធិការអាចលើកយកបញ្ហានេះមកពិភាក្សា និងស្នើសុំផ្តល់ចម្លើយដែលអាចធ្វើបាន។ របៀបនៃការពិភាក្សានេះផ្តល់ឱកាសឱ្យ គ.ក.ន.ក ដើម្បីរៀបចំជាសកម្មភាពការងារសម្រាប់អនុវត្ត និងដើម្បីជួយឱ្យគាត់ហ្វឹកហាត់ធ្វើបទបង្ហាញអំពីសកម្មភាពការងារដែលបានគ្រោងទុកមុននឹងបន្តបង្ហាញនៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ និងកិច្ចប្រជុំថ្នាក់ ស្រុក ឬថ្នាក់ខេត្ត។ នៅក្នុងការសិក្សានេះបានកត់សំគាល់ផងដែរថា មិនមានគ្រប់ គ.ក.ន.ក ទាំងអស់អាចមានសមត្ថភាពដើម្បីវិភាគទិន្នន័យ ឬបង្កើតហេតុផលដែលទាក់ទងគ្នាផ្អែកទៅលើការវិភាគនោះទេ។ ធាតុចូលបន្ថែមនោះ គឺត្រូវដឹងពីរបៀបប្រមូល និងវិភាគព័ត៌មានដែលពាក់ព័ន្ធបញ្ហាស្ត្រី និងកុមារ និងរបៀបធ្វើសមាហរណកម្មព័ត៌មានដែលអាចប្រើប្រាស់បានទៅក្នុងផែនការសកម្មភាព។ ការងារថ្មីដែលរៀបចំដោយអង្គការយូនីសេហ្វដើម្បីណែនាំឱ្យប្រើប្រាស់ឧបករណ៍រៀបចំផែនទីសេវាសង្គម (សូមមើលទៅផ្នែកទី៤) នឹងជួយសម្រាលដល់ការងារវិភាគទិន្នន័យដែលនៅខ្វះខាតទាំងនេះ។ នៅខណៈពេល គ.ក.ន.ក ឬអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ កំពុងតែពង្រឹងការប្រាស្រ័យទាក់ទង ការសម្របសម្រួល និងការសហប្រតិបត្តិការក្នុងចំណោមក្រុមប្រឹក្សាឃុំ សង្កាត់ អ្នកផ្តល់សេវា និងអ្នកភូមិ ការសិក្សាបានបង្ហាញឱ្យឃើញច្បាស់ថា នៅឆ្នាំទី១ គ.ក.ន.ក កំពុងតែរកមើលការណែនាំបន្ថែមអំពីរបៀបរៀបចំបង្កើតសៀវភៅរាយឈ្មោះអ្នកផ្តល់សេវា។ នៅឆ្នាំទី២បានបង្ហាញឱ្យឃើញច្បាស់ថា សមាជិក គ.ក.ន.ក បានធ្វើការភ្ជាប់ទំនាក់ទំនងជាមួយអ្នកផ្តល់សេវា។ នៅឆ្នាំទី៣ ទំហំនៃការទំនាក់ទំនងរីកធំឡើង និងមានរបាយការណ៍អន្តរាគមន៍មួយចំនួនធំដែលលើកទឹកចិត្តឱ្យមានស្នើសុំ និងប្រើប្រាស់សេវា (ដូចជា ការចុះឈ្មោះចូលរៀន យុទ្ធនាការបំបៅកូនដោយទឹកដោះម្តាយ និងការយល់ដឹងពីបញ្ហាអំពើហិង្សាក្នុងគ្រួសារ)។ ការចុះសិក្សាស្រាវជ្រាវដល់ទីកន្លែង បានបង្ហាញឱ្យឃើញថា គ.ក.ន.ក បំពេញការងារយ៉ាងសកម្ម និងមានការលើកទឹកចិត្តខ្ពស់។

*ខ្ញុំជឿថា គ.ក.ន.ក កំពុងធ្វើការងារច្រើនជាងអ្វីដែលគាត់បានរាយការណ៍ ( លើកឡើងដោយលោកស្រីអភិបាលខេត្តរងខេត្តឧត្តរមានជ័យ)។*

*ខ្ញុំសប្បាយចិត្តក្នុងការធ្វើការងារដែលពាក់ព័ន្ធបញ្ហាស្ត្រី និងកុមារ ពីព្រោះខ្ញុំចង់ឱ្យប្រជាពលរដ្ឋមើលឃើញថា ខ្ញុំជាស្ត្រី តែខ្ញុំអាចធ្វើការនេះបាន។ ជាមួយគ្នានេះដែរ ខ្ញុំបានទទួលការគាំទ្រជាច្រើនពីសហគមន៍ (លើកឡើងដោយអ្នកទទួលបន្ទុកកិច្ចការ នារី និងកុមារឃុំ នៅខេត្តខេត្តឧត្តរមានជ័យ)។*

នៅពេលមានការស្ងើចសរសើរ និងមានការលើកទឹកចិត្តដែលជាភស្តុតាងមាននៅក្នុងឆ្នាំទីមួយនោះ ក៏មានការរកឃើញផងដែរថា មិនមែនគ្រប់ សមាជិក គ.ក.ន.ក ទាំងអស់សុទ្ធតែយល់ពីសក្តានុពលនៃតួនាទី និងការទទួល

ខុសត្រូវរបស់គាត់នោះទេ ហើយ គ.ក.ន.ក ខ្លះអាចឆ្លើយតបទៅនឹងសេចក្តីណែនាំរបស់ គ.ជ.អ.ប តាមរបៀបជាយន្តការ។ ជាឧទាហរណ៍ ការរៀបចំផែនការ និងថវិកាប្រចាំឆ្នាំ នៅពេលខ្លះមិនបានធ្វើការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ ឬធ្វើការវិភាគលើទិន្នន័យដែលអាចប្រើប្រាស់នោះទេ។ ដូច្នេះហើយនៅពេលនេះ សេចក្តីណែនាំលេខ ០៨២ ស.ណ.ន/គ.ជ.វ.វ ចុះថ្ងៃទី ០៨ ខែសីហា ឆ្នាំ២០០៧ស្តីពីការរៀបចំ និងបង្កើតគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំនៅគ្រប់ឃុំ សង្កាត់ទូទាំងប្រទេស គឺជាក្របខ័ណ្ឌការងារមួយសម្រាប់ គ.ក.ន.ក អនុវត្តនៅក្នុងដំណាក់កាលចាប់ផ្តើមដំបូង។ គណៈកម្មាធិការនីមួយៗអាច(គួរតែត្រូវបានលើកទឹកចិត្ត) ធ្វើឱ្យមានការបត់បែនល្អជាងនេះ ជាពិសេសបើសិនពួកគាត់អាចបង្ហាញពីលទ្ធផលវិជ្ជមាន និងឆ្លើយតបចំពោះបញ្ហាស្ត្រី និងកុមារ ដែលបានកំណត់នៅតាមមូលដ្ឋាន។ ទោះជាយ៉ាងណាក៏ដោយ ជាទូទៅការយល់ដឹងពីតួនាទីរបស់សមាជិក គ.ក.ន.ក ពិតជាស៊ីជម្រៅពីមួយឆ្នាំទៅមួយឆ្នាំ ឯភាពជឿជាក់ក៏កើនឡើង ហើយការឆ្លើយតបទៅនឹងតម្រូវការប្រជាពលរដ្ឋនៅតាមមូលដ្ឋានក៏កើនឡើងផងដែរ។

តួនាទីក្នុងការតាមដានត្រួតពិនិត្យហាក់ដូចជាកើតឡើង ដោយមានតម្រូវការដើម្បីឱ្យ"របាយការណ៍"ច្រើនជាងមានការយល់ដឹងថាការពិភាក្សាអំពីអាទិភាពអ្វីដែលអាចធ្វើ ឬអ្វីដែលមិនអាចធ្វើ ដើម្បីកែតម្រូវទៅតាមការចាំបាច់ ហើយមានការផ្តល់ព័ត៌មានត្រលប់តិចតួចទៅលើរបាយការណ៍ដែលបានផ្ញើទៅ។ ការផ្តល់ព័ត៌មានត្រលប់តិចតួចបែបនេះធ្វើឱ្យធ្លាក់ចុះទំនុកចិត្តក្នុងការសរសេររបាយការណ៍ និងការលើកឡើងជាការព្រួយបារម្ភថា"យើងប្រហែលជាធ្វើរបាយការណ៍មិនបានល្អទេ"។ ពត៌មានត្រលប់ច្រើនពីថ្នាក់ស្រុក និងខេត្តអាចត្រូវបានគេឱ្យតម្លៃខ្ពស់។ បន្ថែមលើនេះទៅទៀត គឺការសរសេររបាយការណ៍ខ្លី និងមានការចោទសួរត្រឹមត្រូវអំពី"អ្វីខ្លះ និងហេតុអ្វី" ដែលជាបញ្ហាស្ត្រី និងកុមារ ក៏អាចជាជំនួយក្នុងការសរសេររបាយការណ៍ផងដែរ។

## បង្កើតទំនាក់ទំនងការងារដែលមានកិច្ចសហការ

ដូចបានរៀបរាប់នៅក្នុងការសិក្សាពីខាងដើម កត្តាជោគជ័យសំខាន់នៅក្នុងការបង្កើត គ.ក.ន.ក គឺសមត្ថភាពដើម្បីបង្កើតទំនាក់ទំនងកិច្ចសហការជាមួយសមាជិកនៅក្នុងគណៈកម្មាធិការ និងជាមួយស្ត្រី និងកុមារនៅក្នុងសហគមន៍ ព្រមទាំងជាមួយគណៈកម្មាធិការពាក់ព័ន្ធ អង្គមិនមែនរដ្ឋាភិបាលនានា ភ្នាក់ងារខ្សែបណ្តោយរបស់រដ្ឋាភិបាល និងនៅពេលខ្លះជាមួយផ្នែកឯកជនផងដែរ។ ភាគច្រើននៃឆ្នាំទី១ គឺផ្តោតសំខាន់ទៅលើការបង្កើតទំនាក់ទំនងនេះ។ នៅឆ្នាំទី៣ និងទី៤ គ.ក.ន.ក គឺជាស្ពានឆ្លងរវាងភ្នាក់ងារជាមួយសហគមន៍ ព្រមទាំងក្រុមសង្គមស៊ីវិលនៅមូលដ្ឋាន។

មានរបាយការណ៍ជាច្រើនពី គ.ក.ន.ក និងអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ និយាយថា ការកសាងទំនាក់ទំនងជាមួយអង្គការមិនមែនរដ្ឋាភិបាលដែលអនុវត្តកម្មវិធីផ្នែកសង្គមនៅតែជាការប្រឈម ហើយមិនមែនជាការងាយស្រួលទេក្នុងការ"លួចចូលទៅក្នុង"បណ្តាញការងារនៅមូលដ្ឋានដែលបានបង្កើតឡើងដោយអង្គការមិនមែនរដ្ឋាភិបាល។ អង្គការមិនមែនរដ្ឋាភិបាលមួយចំនួនដែលធ្វើការដើម្បីលើកកម្ពស់សិទ្ធិស្ត្រី និងកុមារ ក៏កំពុងតែស្វែងរកការលើកទឹកចិត្តឱ្យមានតម្រូវការ និងប្រើប្រាស់សេវានៅក្នុងវិស័យសេដ្ឋកិច្ច និងសង្គម ហើយកាលានុវត្តភាពសម្រាប់កិច្ចសហការត្រូវបានបាត់បង់។ កាផ្សារភ្ជាប់កិច្ចសន្ទនាជាមួយអង្គការមិនមែនរដ្ឋាភិបាលទាំងនោះអាចជួយឱ្យ គ.ក.ន.ក

/អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ទទួលស្គាល់គ្រួសារដែលងាយរងគ្រោះ។ នេះក៏អាចជួយឱ្យអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់សម្របសម្រួលតួនាទីក្នុងការតាមដានត្រួតពិនិត្យ ព្រមទាំងអាចជួយសម្របសម្រួលឱ្យពួកគាត់ខិតខំចូលទៅដល់សហគមន៍(ឧ.តាមរយៈការជួយសំរួលមធ្យោបាយធ្វើដំណើរ)។ នៅក្នុងតំបន់ដាច់ស្រយាល ដូចជា នៅខេត្តរតនៈគីរី និងខេត្តកោះកុងដែលប្រជាជនរស់នៅដាច់ឆ្ងាយៗពីគ្នា ការកសាងទំនាក់ទំនងការងាររវាងរាជរដ្ឋាភិបាល និងបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល គឺជាគន្លឹះក្នុងការអភិវឌ្ឍកំណើនសេដកិច្ច។

នៅពេលអនាគត វាមានសារៈសំខាន់ណាស់ដើម្បីផ្តល់ការយកចិត្តទុកដាក់បន្ថែមក្នុងការសម្របសម្រួលភ្ជាប់ទំនាក់ទំនងរវាង គ.ក.ន.ក និងគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារថ្នាក់ខេត្ត និងស្រុក ដែលនឹងបង្កើតថ្មី។ ការងារនេះអាចធ្វើទៅបាន តាមរយៈវេទិកាពិគ្រោះយោបល់ប្រចាំត្រីមាស ដែលធ្លាប់បានធ្វើរួចហើយនៅថ្នាក់ក្រុង ស្រុក ខណ្ឌ។

## ការកសាងក្រុម

តាមការសិក្សាបានបង្ហាញឱ្យឃើញថា នៅពេលដែលមេឃុំ ជំទប់ទី២ និងអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ អាចមកធ្វើការរួមគ្នាយ៉ាងសកម្ម ដូចជា "ក្រុមស្នូល"មួយ នៅក្នុងឆ្នាំទី១ ដែលគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់អាចបង្កើតឡើងដោយខ្លួនឯងយ៉ាងឆាប់រហ័សក្នុងការធ្វើឱ្យប្រសើរឡើងលើបញ្ហាដែលកើតឡើង។ នៅត្រង់ចំណុចនេះ ស្នើឱ្យពិនិត្យលទ្ធភាពក្នុងការផ្តល់វគ្គបណ្តុះបណ្តាលជាក់លាក់សម្រាប់ក្រុមការងារនេះ (ជាជាងផ្តល់វគ្គបណ្តុះបណ្តាលសម្រាប់គណៈកម្មាធិការទាំងអស់រួមគ្នា) តាមមើលប្រហែលជាតាមរយៈវេទិកាពិគ្រោះយោបល់ប្រចាំត្រីមាសនៅថ្នាក់ក្រុង ស្រុក ខណ្ឌ ដែលជាវិធីមួយផ្តល់ឱ្យមានការរៀនសូត្រសម្រាប់អ្នកមានវ័យប្រហាក់ប្រហែលគ្នា ព្រមទាំងអាចពង្រីកកំណើនសេដ្ឋកិច្ចគ្រួសារផងដែរ។

តួនាទីសំខាន់មួយទៀតសម្រាប់មេឃុំ ចៅសង្កាត់នៅក្នុងឆ្នាំទី១ដោយមានជំនួយពីជំទប់ទី២ ចៅសង្កាត់រងទី២ និងអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់គឺបង្កើតក្រុមដែលមានឋានៈស្មើ និងព្យាយាមជម្នះនូវឋានានុក្រមមានតាំងពីកំណើតដែលរារាំងដល់ការចូលរួមដោយពេញលេញ។ ក្នុងឆ្នាំទី៤ និងឆ្នាំទី៥ នៅពេលការបោះឆ្នោត ជិតមកដល់ ការយកចិត្តទុកដាក់ជាសំខាន់នោះ គឺការតម្រង់ទិសសមាជិកថ្មីនៅក្នុងក្រុមបច្ចុប្បន្ន (ធ្វើដូច្នេះគឺមិនអាចបាត់បង់កម្លាំងណាមួយ)។

លើកលែងតែអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់មានបទពិសោធន៍នៅក្នុងកិច្ចការរបស់ឃុំ សង្កាត់ និងមានទំនុកចិត្តទៅលើចំណេះដឹង និងជំនាញដែលគាត់មានស្រាប់ អ្នកទទួលបន្ទុកតែងតែមិនសូវបញ្ចេញមតិ និងមិនសូវធ្វើការទាក់ទាញគាំទ្រ ក្នុងរង្វង់ការងារក្រុមប្រឹក្សាឃុំ សង្កាត់និង គ.ក.ន.ក នៅឆ្នាំទី១ (ឬសូម្បីតែនៅឆ្នាំទី២)។

*ចាប់តាំងពីគេបាននិយាយប្រាប់ថា ខ្ញុំជាអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ ខ្ញុំមិនមានអ្វីត្រូវធ្វើក្រៅពីការចូលរួមការប្រជុំប្រចាំខែតែប៉ុណ្ណោះ។ ខ្ញុំគ្រាន់តែឡើងមកក្រុងនៅពេលមានគេហៅតែប៉ុណ្ណោះ... ។ ខ្ញុំមិនមានអ្វីត្រូវ*

*រាយការណ៍ក្នុងពេលប្រជុំប្រចាំខែទេ ពីព្រោះខ្ញុំមិនបានធ្វើសកម្មភាពណាមួយទេ។ រហូតមកដល់ពេលនេះខ្ញុំមិនដឹងថាតើខ្ញុំមានតួនាទី និងការទទួលខុសត្រូវអ្វីខ្លះទេ (សំដីរបស់អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ ខេត្តរតនះគីរី)។*

ជាការពិតមានរបាយការណ៍ខ្លះបាននិយាយថា អ្នកទទួលបន្ទុកកិច្ចការនារី និង កុមារឃុំអាចមានការពិបាកនៅក្នុងការគេទទួលស្គាល់នៅក្នុង គ.ក.ន.ក ជាពិសេសនៅពេលដែលគាត់ត្រូវគេជ្រើសរើសជាជាងគាត់ត្រូវបានជ្រើសចេញពីសមាជិកក្រុមប្រឹក្សាឃុំ ឬនៅពេលដែលក្រុមប្រឹក្សាឃុំ ឬ គ.ក.ន.ក ត្រូវបានគ្របដណ្តប់ដោយទស្សនះរបស់បុរស។

*នៅពេលដំបូងដែលខ្ញុំត្រូវតែងតាំងជាអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ ខ្ញុំត្រូវគេតម្រង់ទិសអំពីតួនាទី និងអ្វីដែលខ្ញុំអាចធ្វើដើម្បីស្ត្រី និងកុមារនៅក្នុងឃុំរបស់ខ្ញុំ។ ខ្ញុំជឿថាតួនាទីដែលខ្ញុំធ្វើ មានសារៈសំខាន់ណាស់។ ប៉ុន្តែនៅពេលដែលខ្ញុំចែករំលែក ឬផ្តួចផ្តើមគំនិតអ្វីមួយជាមួយសមាជិកគណៈកម្មាធិការផ្សេងទៀត ពួកគាត់ហាក់ដូចជាមិនអើពើសំដីរបស់ខ្ញុំ។ ខ្ញុំមានអារម្មណ៍ថាពួកគាត់មើលមិនឃើញពីសារៈសំខាន់របស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំដូចដែលខ្ញុំជឿជាក់នោះទេ។ ខ្ញុំសួរទៅខ្លួនឯងថា នេះដោយសារតែខ្ញុំជាស្ត្រី ឬដោយសារតែសមត្ថភាពរបស់ខ្ញុំក្នុងការនិយាយឱ្យពួកគេយល់នៅមានកំរិត (សំដីរបស់អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ ខេត្តកំពង់ធំ)។*

ប្រសិនបើគ្មានអ្វីបន្ថែមទៀតទេ នេះគឺជាការរំលេចឡើងពីតម្រូវការដើម្បីផ្សព្វផ្សាយអំពីជំនាញភាពជាអ្នកដឹកនាំ និងជំនឿចិត្តក្នុងចំណោមអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ និងបន្តការយល់ដឹងពីយេនឌ័រ ដែលត្រូវធ្វើជាមួយសមាជិក គ.ក.ន.ក ដើម្បីបំបាត់ចោលគំនិតដែលថាស្ត្រីអាចធ្វើ ឬមិនអាចធ្វើអ្វីបាន។

របកគំហើញនៃការសិក្សាស្រាវជ្រាវបានស្នើថា យ៉ាងហោចណាស់នៅឆ្នាំទី១ សមាជិក គ.ក.ន.ក មិនទាន់យល់បានពេញលេញពីសក្តានុពលនៃតួនាទី និងការទទួលខុសត្រូវរបស់ខ្លួននៅឡើយទេ។ នៅក្នុងករណីខ្លះ សមាជិក គ.ក.ន.ក មានអារម្មណ៍ថាមានបន្ទុកខ្លាំងដោយសារតែពួកគាត់ត្រូវគេស្នើសុំឱ្យធ្វើនេះធ្វើនោះ ឬដោយសារតែចំណេះដឹងមូលដ្ឋានដែលពួកគាត់ត្រូវចាប់យក។ វាជារឿងស្វ័យប្រវត្តិដែលថា ពួកគាត់មិនប្តេជ្ញាចិត្តពេញលេញក្នុងការបំពេញការងារអ្វីមួយដែលពួកគាត់មិនយល់ច្បាស់។ ដូច្នេះលទ្ធផលនៃវគ្គបណ្តុះបណ្តាលចាំបាច់ត្រូវរៀបចំបង្កើតដោយប្រុងប្រយ័ត្ន និងតម្រង់ទិសសកម្មភាពដែលត្រូវអនុវត្ត។

វាជារឿងសំខាន់ណាស់ដែល គ.ក.ន.ក មើលឃើញថា ជំនួយដែលផ្តល់ដោយភ្នាក់ងារអន្តរជាតិ ដូចជា អង្គការយូនីសេហ្វ និង UNFPA ឬអង្គការមិនមែនរដ្ឋាភិបាលជាច្រើនទៀតដែលផ្តល់ការគាំទ្រដល់ក្រុមប្រឹក្សាឃុំ សង្កាត់ និង/ឬ គ.ក.ន.ក មិនមែនជា "ការងារបន្ថែម" ប៉ុន្តែជាការងារដែលជួយឱ្យសម្រេចគោលបំណងផ្ទាល់របស់ពួកគាត់។ ដូចនេះគ្រប់ភ្នាក់ងារទាំងអស់ដែលធ្វើការជាមួយ គ.ក.ន.ក ត្រូវការពេលវេលាដើម្បីបង្ហាញឱ្យពីសកម្មភាពស្នើឡើងដែលទាក់ទងនឹងអាណត្តិរបស់គ.ក.ន.ក។ និយាយឱ្យខ្លី ភ្នាក់ងារទាំងនេះត្រូវកសាងការយល់ដឹង និងភាពជាម្ចាស់របស់ គ.ក.ន.ក។ ការយល់ដឹង និងភាពជាម្ចាស់គឺជាការនាំមុខដ៏សំខាន់ចំពោះការស្ទើចសរសើរ ថាមពល និងការប្តេជ្ញាចិត្ត ដែលចាំបាច់សម្រាប់ធ្វើការតទៅមុខទៀត។

## បង្កើតភាពជឿជាក់

សមាជិកសហគមន៍ និងអ្នកធ្វើការផ្នែកសង្គមស៊ីវិលផ្សេងៗទៀត ហាក់ដូចជាមានការប្រយ័ត្នប្រយ៉ែងចំពោះរចនាសម្ព័ន្ធថ្មី និងប្រកាន់តំរិយាបថ "រង់ចាំ និងមើល" នៅពេលគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និង កុមារឃុំ សង្កាត់ ចាប់ផ្តើមបង្កើតឡើងដំបូង។

*ពីដំបូងស្ត្រីទាំងអស់ជឿជាក់ទៅលើឆ្មបបុរាណ និងមិនព្រមទៅសំរាលកូននៅមណ្ឌលសុខភាពទេ។ នៅពេលឃើញមានការស្លាបក្នុងអំឡុងពេលសំរាលកូនដោយឆ្មបបុរាណ ហើយនៅពេលនេះពួកគាត់ទៅមណ្ឌលសុខភាព ដើម្បីពិនិត្យផ្ទៃពោះ (អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ ខេត្តកំពង់ចាមបានលើកឡើង)។*

*ឥឡូវនេះប្រជាពលរដ្ឋចាប់ផ្តើមយល់ពីការចុះបញ្ជីកំណើតកុមារ ពីព្រោះបើគ្មានសំបុត្រកំណើតទេ កូនរបស់ពួកគាត់ មិនអាចចូលរៀននៅសាលាបឋមសិក្សា ឬ មិនអាចធ្វើការងារនៅក្នុងរោងចក្របានទេ (សំដីរបស់ជំទប់ទី២ នៅខេត្តកំពង់ធំ)។*

ការព្រួយបារម្ភចំបងរបស់សហគមន៍ គឺសន្តិសុខស្បៀង និងការមានការងារធ្វើដែលទាមទារឱ្យគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ត្រូវតែយកចំណុចនេះមកពិចារណា។

*យើងអាចយល់ដឹងបានថា អ្នកភូមិគ្រាន់តែធ្វើតាមយើង ប្រសិនបើពួកគេមានអ្វីញ៉ាំប៉ុណ្ណោះ ដូចនេះហើយបានជាគណៈកម្មាធិការស្នើរឱ្យផ្តោតអារម្មណ៍ទៅលើគោលបំណងបីៈ ការអភិវឌ្ឍសេដ្ឋកិច្ចគ្រួសារ ការពារក្រុមគ្រួសារ ហើយប្រជាពលរដ្ឋមានករណីកិច្ចចូលរួមក្នុងសកម្មភាពការងារសង្គមកិច្ច( សំដីរបស់មេឃុំ ខេត្តឧត្តរមានជ័យ)។*

គ.ក.ន.ក ចាំបាច់ត្រូវបង្កើតភាពជឿជាក់នៅក្នុងឃុំ សង្កាត់តាមរយៈការអនុវត្តដោយតម្លាភាព និងរាយការណ៍អំពីមូលនិធិអ្វីខ្លះដែលអាចប្រើប្រាស់បាន ហើយត្រូវបានបែងចែកមូលនិធិនេះយ៉ាងដូចម្តេច និងហេតុអ្វី។ គ.ក.ន.ក អាចបង្កើតភាពជឿជាក់តាមរយៈការធ្វើឱ្យសម្រេចបានជោគជ័យបន្តិចបន្តួច ដែលជួយឱ្យស្ត្រីម្នាក់អាចប្រើប្រាស់សេវាសុខភាព និងផ្តល់កង់សម្រាប់ឱ្យសិស្សធ្វើដំណើរទៅសាលារៀន។ ដោយសារតែការយល់ដឹងរបស់សហគមន៍កើនឡើង ដូចនេះការធ្វើការងារជាមួយអ្នកទទួលបន្ទុក កិច្ចការនារី និងកុមារឃុំ សង្កាត់ និង គ.ក.ន.ក នាំទៅរកការទទួលបានសេវាសង្គម និងការចូលរួមក្នុងសង្គម ដែលនេះជាការទទួលស្គាល់តម្លៃផ្តល់ដោយ គ.ក.ន.ក ។ ការទទួលស្គាល់តម្លៃនេះ លើកទឹកចិត្តឱ្យមានភាពជឿជាក់ និងជំរុញឱ្យចង់ធ្វើអ្វីមួយក្នុងចំណោម គ.ក.ន.ក និងអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ។

ការពន្យល់នេះគឺជាមូលហេតុដែលធ្វើឱ្យ គ.ក.ន.ក និងអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ត្រូវចំណាយពេលវេលានៅក្នុងការបង្កើនការយល់ដឹងអំពីបញ្ហាស្ត្រី និងកុមារ និងបញ្ជ្រាបទៅក្នុងការងាររបស់ គ.ក.ន.ក នៅមុនពេលសកម្មភាពជាក់ស្តែងត្រូវបានដំណើរការអនុវត្ត។ នៅពេលបង្កើត គ.ក.ន.ក មួយឡើង វាមានប្រយោជន៍ដើម្បីបង្កើតយុត្តិសាស្ត្រមួយស្របគ្នាក្នុងការធ្វើឱ្យគេប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយទូលំទូលាយ (វិទ្យុ និងទូរទស្សន៍) សម្រាប់ផ្សព្វផ្សាយពីការងាររបស់ គ.ក.ន.ក។ ការធ្វើបែបនេះអាចត្រួសត្រាយផ្លូវ និងជួយឱ្យ គ.ក.ន.ក ចាកចេញយ៉ាងឆាប់រហ័សពីដំណាក់ការផ្សព្វផ្សាយការយល់ដឹងដែលផ្តោតទៅលើបញ្ហាស្ត្រី និងកុមារ ហើយពង្រឹងការផ្តល់សេវាវិញម្តង។

## ២.២. តើ គ.ក.ន.ក/អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់មានការអភិវឌ្ឍយ៉ាងដូចម្តេច? ហើយថាតើយើងសង្ឃឹមចង់ឃើញអ្វីខ្លះ?

តារាងទី១ ជាការសង្ខេបរបកគំហើញពីប្រភពទិន្នន័យផ្សេងៗពីខាងលើដើម្បីបង្ហាញថា គ.ក.ន.ក និងអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់មានការរីកចំរើន និងអភិវឌ្ឍន៍(តាំងពីចាប់កំណើតរហូតដល់ពេញវ័យ) ហើយថាតើយើងសង្ឃឹមចង់ឃើញអ្វីខ្លះពី គ.ក.ន.ក និងអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំក្នុងការងារអភិវឌ្ឍន៍។

**តារាងទី១: របៀបដែល គ.ក.ន.ក/អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់មានការអភិវឌ្ឍតាមដំណាក់កាល**

| ដំណាក់កាលទី១<br>ការចាប់ផ្តើម (ឆ្នាំទី១) | ដំណាក់កាលទី២<br>ការអភិវឌ្ឍ (ឆ្នាំទី២-៣) | ដំណាក់កាលទី៣<br>ស្វ័យភាព (ឆ្នាំទី៤-៥) |
|---|---|---|
| **ការកសាងក្រុម** | | |
| មនុស្សសំខាន់ៗនៅក្នុងដំណាក់កាលចាប់ផ្តើម គឺ មេឃុំ/ចៅសង្កាត់ ជំទប់ទី២/ចៅសង្កាត់រងទី២ និងអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ (និងពេលខ្លះស្មៀន) នៅពេល "ក្រុមស្នូល"នេះ ត្រូវបានគេលើកទឹកចិត្តឱ្យសកម្មការងារ ដូច្នេះ គ.ក.ន.ក មានដំណើរការយ៉ាងឆាប់រហ័ស។ មេឃុំចៅសង្កាត់ ត្រូវប្រឹងប្រែងយកចិត្តទុកដាក់លើការកសាងក្រុមដើម្បីយល់ពីគ្នា និងបញ្ច្រាបដល់សមាជិកគ.ក.ន.ក ទាំងអស់។ | នៅដំណាក់កាលនេះ យើងឃើញថា អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ កាន់តែមានភាពជឿជាក់ ហើយសមាជិកនីមួយៗកាន់តែមានការយល់ដឹងពីតួនាទី និងការទទួលខុសត្រូវ។ ការយល់ដឹងនេះនាំឱ្យមានការចូលរួមកាន់តែប្រសើរឡើង និងមានការរួមដៃគ្នាពីសមាជិកគ.ក.ន.ក ផ្សេងៗទៀត ក្នុងការគាំទ្រដល់អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់។ | យើងអាចឃើញប្រសិទ្ធភាពនៃក្រុមការងារកាន់តែសំខាន់ និងមានភាពជឿជាក់ក្នុងការអនុវត្ត តាមដានត្រួតពិនិត្យសកម្មភាព និងមានគំនិតយកចិត្តទុកដាក់លើតំបន់ថ្មីទៀត។ រឿងសំខាន់សម្រាប់ គ.ក.ន.ក គឺរបៀបចាត់ចែង"ប្រគល់ការងារឱ្យ" និងរបៀបតម្រង់ទិសសមាជិកថ្មី។ ធ្វើដូច្នេះមិនបាត់បង់ប្រសិទ្ធភាពការងារទេ។ |
| **ការរៀបចំផែនការការងារ និងថវិកាប្រចាំឆ្នាំ** | | |
| ជាទូទៅចំណុចផ្តោត គឺមានផែនការការងារ និងថវិកា ដែលជាចំណុចចាប់ផ្តើមធ្វើការងារ។ នៅពេលខ្លះផែនការត្រូវបានរៀបចំឡើងដោយ | ឧទាហរណ៍នៅក្នុងកម្មវិធីវិនិយោគឃុំ សង្កាត់មានរំលេចឱ្យឃើញច្បាស់អំពីសកម្មភាពសេវាសង្គម ការសម្រុះសម្រួល និងកិច្ចសហការជាមួយអ្នក | មានឧទាហរណ៍ជាច្រើនពីបញ្ហាស្ត្រី និងកុមារត្រូវបានគេមើលឃើញនៅក្នុងកម្មវិធីវិនិយោគឃុំ សង្កាត់។ |

| | | |
|---|---|---|
| មិនបានធ្វើការពិភាក្សា ឬធ្វើការវិភាគទិន្នន័យដែលមានស្រាប់ ឱ្យបានច្បាស់លាស់នោះទេ។<br>ការងារនេះអាចឆ្លើយតបតាមរយៈផែនការបានណែនាំ និងតាមការបែងចែកមូលនិធិមានកំណត់លក្ខខណ្ឌ ជាពិសេសសកម្មភាពអាទិភាពខ្ពស់ដែលឆ្លើយតបយឺតជាងគេនៅក្នុង MDG (ឧ. អនាម័យ ឬសុខភាពមាតា និងទារក)។<br>របាយការណ៍ប្រចាំខែហាក់ដូចជាយកចិត្តទុកដាក់តែលើសកម្មភាពរបស់ គ.ក.ន.ក ហើយមិនបានផ្តោតទៅលើលទ្ធផលដែលទាក់ទងនឹងសហគមន៍នោះទេ។ | ពាក់ព័ន្ធផ្សេងៗទៀត។<br>សមាជិក គ.ក.ន.ក ផ្សេងៗទៀតចាប់ផ្តើមមើលឃើញ និងកាន់តែឱ្យតម្លៃទៅលើ គ.ក.ន.ក ដែលជាចំណុចចាប់ផ្តើមមានឥទ្ធិពលក្នុងការនិយាយ និងលើកឡើងពីរបៀបវារៈផ្សេងៗនៅក្នុងក្រុមប្រឹក្សាឃុំ សង្កាត់។<br>ដោយ គ.ក.ន.ក ទើបនឹងចាប់ផ្តើមបំប៉នសមត្ថភាពរបស់ខ្លួនក្នុងការយល់ដឹង និងកំណត់បញ្ហាស្ត្រី និងកុមារនៅមូលដ្ឋាន ពេលនោះការបែងចែកមូលនិធិអាចច្របាច់បញ្ចូលគ្នារវាងមូលនិធិមានកំណត់លក្ខខណ្ឌ និងមូលនិធិមិនកំណត់លក្ខខណ្ឌ។ | យើងក៏ឃើញមានជាប់ទាក់ទងគ្នារវាងការតាមដានត្រួតពិនិត្យ និងការរាយការណ៍ពីការអនុវត្តផែនការផងដែរ។<br>នៅក្នុងដំណាក់កាលទី៣នេះ យើងសង្ឃឹមថានឹងឃើញ គ.ក.ន.ក ចេះចាត់ចែង និងគ្រប់គ្រងមូលនិធិមិនកំណត់លក្ខខណ្ឌ។ |
| **ផ្តល់យោបល់ និងជួយក្រុមប្រឹក្សាឃុំ សង្កាត់ និងជួយមេឃុំ សង្កាត់ លើការងារដែលពាក់ព័ន្ធបញ្ហាស្ត្រី និងកុមារ** | | |
| ជាដំបូង គ.ក.ន.ក ត្រូវពង្រឹងការយល់ដឹងផ្ទាល់ខ្លួនឯងទាក់ទងទៅនឹងបញ្ហាស្ត្រី និងកុមារ។ សមត្ថភាព គ.ក.ន.ក (ជាពិសេសក្រុមស្នូល) ត្រូវមានចំណេះដឹង នឹងចេះសម្របសម្រួលបញ្ហាដែលពាក់ព័ន្ធការងាររបស់អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់។ ក្រៅពីនេះមានការយកចិត្តទុកដាក់លើការកសាងការយល់ដឹង និងបញ្ជ្រាបចំណេះដឹងរបស់គេទៅក្នុងការងាររបស់ គ.ក.ន.ក។ វាជាការសំខាន់ណាស់ដែល គ.ក.ន.ក | ទំនុកចិត្តរបស់អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់មានការកើនឡើងដោយហ៊ាននិយាយ និងបង្ហាញពីបញ្ហារបស់ស្ត្រី និងកុមារ ទោះបីជានៅមានការខ្វះខាតក្នុងការបញ្ជាក់នូវភាពស្មុគស្មាញយ៉ាងណាក៏ដោយ។<br>អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ និងសមាជិក គ.ក.ន.ក មួយចំនួនផ្សេងទៀតបានទទួលតួនាទីក្នុងការសម្របសម្រួលកាន់តែពិបាក (ឧទាហរណ៍ ការជាប់ពាក់ព័ន្ធអំពើហឹង្សាក្នុងគ្រួសារ ការលើកឡើងនូវ | យើងអាចមើលឃើញពីការលើកទឹកចិត្តឱ្យមានការដោះស្រាយតាមលំដាប់ នៃបញ្ហាអភិវឌ្ឍន៍សង្គម ហើយភ្ជាប់លំដាប់នៃបញ្ហាទាំងនេះទៅនឹងកន្លែងដែលមានចំណេះដឹងបច្ចេកទេស។<br>បង្កើនទំនុកចិត្តដើម្បីតស៊ូមតិលើបញ្ហាលំបាកដែលទាក់ទងនឹងទំនាស់ផលប្រយោជន៍ ឬអំណាច និងតួនាទី។ |

| | | |
|---|---|---|
| កំណត់កាលានុវត្តភាព ដើម្បីធ្វើឱ្យសហគមន៍មានជំនឿតាមរយៈការទទួលបាន"ជោគជ័យបន្តិចបន្តួច" ។ | សំណួរអំពីគ្រួសារងាយរងគ្រោះ) ។ ដោយសារការទំនាក់ទំនង និងទំនុកចិត្តមានការកើនឡើងក្នុងក្រុមស្នូល ដូច្នេះការងាររបស់ គ.ក.ន.ក ត្រូវបញ្ចូលទៅជាការងារក្រុមប្រឹក្សាឃុំ សង្កាត់ ។ | |
| **លើកឡើងនូវការយល់ដឹងអំពីច្បាប់ សិទ្ធិ និងគៀរគរសហគមន៍ និងអ្នកផ្តល់សេវានានា** | | |
| នៅពេលខ្លះ ការលើកឡើងអំពីច្បាប់ និងសិទ្ធិ មានកើតឡើងជាក់លាក់ នៅក្នុងវេទិកាសាធារណៈ ឬកិច្ចប្រជុំនានា។ ប៉ុន្តែវាកើតឡើងតាមធម្មតាផងដែរ ឧ. ការនិយាយជាមួយស្ត្រីអំពីសារៈសំខាន់នៃការចុះបញ្ជីកំណើតកុមារ ការចាក់ថ្នាំបង្ការ និងការចូលរៀននៅសាលា។ តួនាទីសំខាន់ៗរបស់ក្រុមស្នូលដាក់បញ្ចូលទៅក្នុងបណ្តាញការងារដែលមានស្រាប់ ហើយពង្រីក នឹងពង្រឹងការភ្ជាប់ទំនាក់ទំនងរវាងសហគមន៍ និងបណ្តាញការងារទាំងនោះ។ | មានការយល់ដឹងពីការអនុវត្តតួនាទី និងការទទួលខុសត្រូវ (ភស្តុតាងនៅក្នុងរបាយការណ៍ដែលបានដាក់ជូនក្រុមប្រឹក្សាឃុំ សង្កាត់) ឧ. ទីកន្លែងដែល គ.ក.ន.ក/ អ្នកទទួលបន្ទុកកិច្ចការនារី និង កុមារឃុំ សង្កាត់ កំពុងសម្របសម្រួលការងារសេវាសង្គមជាពិសេស(សុខភាព និងការអប់រំ) ។ មានឧទាហរណ៍មួយចំនួនទៀត ដែល គ.ក.ន.ក និងអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ បានសម្របសម្រួលក្នុងការភ្ជាប់ទំនាក់ទំនងជាមួយអ្នកផ្តល់សេវាកម្មជាច្រើន ។ | ការសហការណ៍នៅឆ្នាំទី៤-៥ កាន់តែមានប្រសិទ្ធិភាព។ គ.ក.ន.ក និង អ្នកទទួលបន្ទុកកិច្ចការនារី និង កុមារដើរតួនាទីជាស្ពានរវាងភ្នាក់ងារអភិវឌ្ឍន៍សហគមន៍ និងក្រុមប្រជា ពលរដ្ឋ។ ឧទាហរណ៍ នៅឆ្នាំទី៤មានការគិតដោយប្រុងប្រយ័ត្នពីបញ្ហាលំបាកនានា ឧទាហរណ៍:សំរុះសំរួលអំពើហឹង្សាផ្សេងៗទៀត ។ |
| **តស៊ូមតិឱ្យស្ត្រីចូលរួមក្នុងការធ្វើសេចក្តីសម្រេច** | | |
| យកចិត្តទុកដាក់ជាសំខាន់លើការលើកយកបញ្ហាមកពិភាក្សា ហើយត្រូវតែនិយាយពីបញ្ហានេះ។ ជាធម្មតា វាមានការខ្វះខាតសម្លេងគួរឱ្យជឿបាន ដូច្នេះ អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់អាចតស៊ូ ដើម្បីយកបញ្ហា | មានទំនុកចិត្តកើនឡើងក្នុងការនិយាយនិងបញ្ជាក់ពីបញ្ហាផ្សេងៗ ហើយបង្ហាញពីការជាប់ទាក់ទងពីបញ្ហាមួយទៅបញ្ហាមួយទៀតក្នុងរបៀបមួយដែលសមរម្យ ។ | មានការកើនឡើងនូវការទទួលស្គាល់ថាការតស៊ូមតិមិនត្រឹមតែការនិយាយ ជំនួសអ្នកដទៃទេ តែវាជាតម្រូវការមួយដែលត្រូវ បង្កើតជំនាញតស៊ូមតិ ។ |

| | | |
|---|---|---|
| ដែលលើកឡើងដើម្បីពិភាក្សា។ | | |
| **ពង្រឹងការប្រាស្រ័យទាក់ទង កិច្ចសហការ និងសម្របសម្រួលរវាងក្រុមប្រឹក្សាឃុំ សង្កាត់ អ្នកផ្តល់សេវានានា និងអ្នកភូមិ** | | |
| សមាជិក គ.ក.ន.ក ត្រូវការការណែនាំពីរបៀបរៀបចំប្រព័ន្ធនៃអ្នកផ្តល់សេវា និងការភ្ជាប់ទំនាក់ទំនងរបស់ពួកគេ ដើម្បីរៀបចំបញ្ជីឈ្មោះអ្នកផ្តល់សេវា។ គិតគូរពីពេលវេលាចាំបាច់ក្នុងការបង្កើតទំនាក់ទំនងជាមួយអ្នកផ្តល់សេវានានា (ភាគច្រើនជារដ្ឋាភិបាល) ហើយខិតខំប្រឹងប្រែងបន្ថែមទៀត ដើម្បីទាញយកអង្គការមិនមែនរដ្ឋាភិបាលដែលសកម្មនៅក្នុងឃុំ សង្កាត់។ | យើងឃើញថាមានការកើនឡើងនូវចំនួននៃការសន្យាជាមួយឧទាហរណ៍នៃ"ការអនុវត្តល្អ" ជាពិសេសការងារពាក់ព័ន្ធសុខភាព ការអប់រំ ទឹកស្អាត និងអនាម័យ។ យើងក៏ឃើញមានការកើនឡើងផងដែរនូវផលប្រយោជន៍ពីអ្នកពាក់ព័ន្ធ ហើយអ្នកផ្តល់សេវាចាប់ផ្តើមលើកសរសើរថា ពួកគេអាចមានភាពជឿនលឿនលើកិច្ចការដែលត្រូវធ្វើផ្ទាល់ខ្លួន ( និងមានផលប៉ះពាល់ច្រើន ) ដោយធ្វើការជាមួយ គ.ក.ន.ក ។ ក្រុមប្រឹក្សាឃុំ សង្កាត់ ចាប់ផ្តើមឱ្យតម្លៃថា វត្តមាន និងមុខងាររបស់ គ.ក.ន.ក គឺជួយដល់ក្រុមប្រឹក្សាឃុំ សង្កាត់ដើម្បីបំពេញបេសកម្មរបស់ខ្លួន។ | គ.ក.ន.ក ក្លាយទៅជាបណ្តាញការងារដោះស្រាយបញ្ហា ដែលអាចជួយឱ្យឃុំ សង្កាត់ ស្វែងរកវិធីសាស្ត្រសម្រប សម្រួលក្នុងការដោះស្រាយបញ្ហាសង្គមនៅក្នុងឃុំសង្កាត់។ ការធ្វើដូចនេះគឺដើម្បីទទួលបានព័ត៌មានរួមពីផ្នែកផ្សេងៗ ដែលដើរតួនាទីធ្វើជាចំណុចកណ្តាលសម្រាប់ភ្ជាប់ទំនាក់ទំនងពីផ្នែកមួយទៅផ្នែកមួយ រវាងអាជ្ញាធរដែនដី និងអ្នកផ្សេងៗទៀត។ |
| **ជួយក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការប្រមូល និងវិភាគទិន្នន័យដែលពាក់ព័ន្ធស្ត្រី និងកុមារ និងបញ្ចូលបញ្ហាទាំងនោះទៅក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ សង្កាត់** | | |
| ភាគច្រើនបំផុតប្រហែលជាការប្រមូលទិន្នន័យ និងការបំពេញទម្រង់មានការវិភាគទិន្នន័យមិនបានស៊ីជម្រៅ ឬមិនបានប្រើប្រាស់ទិន្នន័យនេះដើម្បីបង្កើតជាសកម្មភាព ឬការសម្រេចចិត្ត។ | យើងឃើញថា សមត្ថភាពមានការកើនឡើង ដើម្បីទទួលស្គាល់ពីភាពខុសគ្នាក្នុងការធ្វើការជាមួយគ្រួសារងាយរងគ្រោះ។ ក្នុងពេលជាមួយគ្នានេះដែរ សមត្ថភាពជាតម្រូវការមួយដែលត្រូវយកចិត្តទុកដាក់លើជំនាញ | ការខ្វះចន្លោះដែលបានកំណត់នៅក្នុងការសិក្សាស្រាវជ្រាវ គឺតម្រូវការឱ្យមានលទ្ធផលជាក់លាក់នៅក្នុងការតស៊ូមតិ ដោយផ្អែកលើភស្តុតាង និង |

| | | |
|---|---|---|
| | វិភាគ ។<br>ហើយវាជាតម្រូវការមួយ សម្រាប់ការដាក់បញ្ចូលរបៀបវិភាគទិន្នន័យ និងរបៀបសួរសំណួរព្រមទាំងរបៀបប្រើប្រាស់ឧបករណ៍វិភាគតម្រូវការដោយមានការចូលរួម និងវិធីសាស្រ្តវិភាគបែបគុណភាពផ្សេងៗទៀត ។ | ការវិភាគកាន់តែស៊ីជម្រៅ ។ |
| **ចូលរួមការអនុវត្ត តាមដានត្រួតពិនិត្យ និងវាយតម្លៃផែនការសកម្មភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ដែលពាក់ព័ន្ធស្រ្តី និងកុមារ** | | |
| មានភស្តុតាងយ៉ាងច្រើនបានបញ្ជាក់ថា គ.ក.ន.ក ឬអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ កំពុងរួមចំណែកក្នុងដំណើរការកសាងធ្វើផែនការឃុំ សង្កាត់ ហើយយកបញ្ហារបស់ស្រ្តី និងកុមារមកពិចារណា និងត្រូវតែខិតខំធ្វើការបន្ថែមទៀតលើការតាមដានត្រួតពិនិត្យ និងរបៀបប្រើប្រាស់ព័ត៌មាន ។ | កំពុងកើតមានឡើង<br>(ongoing) | កំពុងកើតមានឡើង<br>(ongoing) |
| **តាមដានត្រួតពិនិត្យស្ថានភាពរបស់ស្រ្តី និងកុមារនៅក្នុងឃុំ សង្កាត់ ហើយរាយការណ៍ជូនក្រុមប្រឹក្សាឃុំ សង្កាត់** | | |
| ភាគច្រើនធ្វើតាមទម្រង់ដែលស្នើដោយអង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត និងភ្នាក់ងារខ្សែបណ្តាយផ្សេងទៀត ។ ការសរសេររបាយការណ៍សង្ខេប ហើយមានភាពទាក់ទងពីផ្នែកមួយទៅផ្នែកមួយ គឺជាការលំបាកសម្រាប់មនុស្សភាគច្រើន ។ មិនសូវមាន ឬមិនមានចម្លើយតបលើរបាយការណ៍ទេ ។ | របាយការណ៍ចាប់ផ្តើមបញ្ចូលមតិយោបល់ ឬការវិភាគ (មិនត្រឹមតែទិន្នន័យដែលបានរាយការណ៍នោះទេ) ។ យើងចាប់ផ្តើមឃើញភាពខុសគ្នារវាងការតាមដានត្រួតពិនិត្យដើម្បីរាយការណ៍ជាមួយនឹងការតាមដានត្រួតពិនិត្យដែលជាឧបករណ៍មួយសម្រាប់ការផ្តល់សេវាកាន់តែមាន | យើងចាប់ផ្តើមឃើញមានការកើនឡើងនូវសមត្ថភាពក្នុងការតាមដានត្រួតពិនិត្យ និងការវិភាគទិន្នន័យ និងដើម្បីពិនិត្យឡើងវិញពីផែនការសកម្មភាព និងអាទិភាពផ្អែកលើការវិភាគទិន្នន័យនោះ ។ |

| | | |
|---|---|---|
| អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ អាចប្រើប្រាស់ទិន្នន័យដែលបានបង្កើតដើម្បីចាប់ផ្តើមចុះបញ្ជីសេវាដែលអាចប្រើប្រាស់បាន។ | ប្រសិទ្ធភាព។ | |

## ២.៣.បញ្ហាជាក់លាក់ពាក់ព័ន្ធនឹងការអភិវឌ្ឍសមត្ថភាព

នៅផ្នែកនេះផ្តោតលើបញ្ហាជាក់លាក់ដែលកើតឡើងទាក់ទងទៅនឹងការអភិវឌ្ឍសមត្ថភាព

### ២.៣.១.ផ្តល់ការរៀនសូត្រ និងការអភិវឌ្ឍសមត្ថភាពរួមគ្នា

*មានលុយតែមួយមុខមិនអាចអះអាងថា គ.ក.ន.ក នឹងធ្វើការងារបានល្អនោះទេ ប្រសិនបើពួកគាត់ មិនមានមានកម្លាំងគ្រប់គ្រាន់ ឬខ្វះចំណេះដឹងដើម្បីធ្វើការងាររបស់ខ្លួន។ ខ្ញុំគិតថាពួកគាត់ត្រូវការការកសាងសមត្ថភាពបន្ថែមទៀតដើម្បីឱ្យគណៈកម្មាធិការនេះមានភាពរឹងមាំ (អនុប្រធានភូមិ នៅឃុំកកោះ ខេត្តកំពង់ធំបានលើកឡើង)។*

វគ្គបណ្តុះបណ្តាល និងការផ្តួចផ្តើមគំនិតកសាងសមត្ថភាពពាក់ព័ន្ធ សុទ្ធតែនាំឱ្យកំរិតសមត្ថភាពប្រសើរឡើង ហើយគ្រប់សមាជិក គ.ក.ន.ក និងអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ទាំងអស់ បាននិយាយថា វគ្គបណ្តុះបណ្តាលដែលគាត់បានចូលរៀនសូត្រសុទ្ធតែមានប្រយោជន៍ ប៉ុន្តែនៅពេលគេសួគាត់អំពីវគ្គបណ្តុះបណ្តាលផ្សេងៗដែលគាត់បានរៀននោះ គ.ក.ន.ក និងអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ មិនទាន់អាចនឹកឃើញលំអិតថា វគ្គសិក្សានេះធ្វើនៅកន្លែងណា ឬការរៀនសូត្រនោះទាក់ទងទៅនឹងការងារគាត់របៀបណាទេ ។ ម្នាក់ៗសុទ្ធតែបង្ហាញពីភាពស្រពេចស្រពិលនៃវគ្គបណ្តុះបណ្តាលទាំងនោះ ។

អ្នកខ្លះរអ៊ូរថាគាត់ទទួលបានវគ្គបណ្តុះបណ្តាលបច្ចេកទេសច្រើនពេក តាមការសួរលំអិតវគ្គខ្លះមានកំរិតបច្ចេកទេសខ្លាំងពេក("ខ្ពស់ពេក") អញ្ចឹងហើយគាត់មិនអាចចាប់បាន ឬភ្ជាប់ទៅនឹងឧទាហរណ៍សម្រាប់អនុវត្តនោះបានទេ។ ហេតុនេះហើយវគ្គបណ្តុះបណ្តាលបច្ចេកទេសតាមវិស័យត្រូវបានស្គាល់ថាមានសារៈសំខាន់ណាស់(ដូចជា សុខភាពមាតា និងទារក សិទ្ធិនារី និងកុមារ កិច្ចការពារកុមារ និងការអប់រំជាដើម។ កម្មវិធីបណ្តុះបណ្តាលទាំងនោះត្រូវប្រុងប្រយ័ត្នកុំបញ្ចូលលក្ខណៈបច្ចេកទេសខ្លាំងពេក។ អ្វីដែលតម្រូវនោះ គឺអ្នកបណ្តុះបណ្តាល និងអ្នកសម្របសម្រួល ត្រូវមានសមត្ថភាព និងឆន្ទៈដើម្បីពន្យល់ប្រធានបទផ្នែកបច្ចេកទេសដោយប្រើភាសាដែលងាយស្រួលយល់ (ដោយមិននិយាយមើលងាយទៅកាន់សិក្ខាកាម)។

*សមត្ថភាពក្នុងការចាប់យកគំនិតយោបល់របស់ជនជាតិដើមភាគតិចក្នុងអំឡុងពេលបណ្តុះបណ្តាល នៅមានកំរិត។ អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំខ្លះ មិនអាចអាន និងសរសេរភាសាខ្មែរបានទេ ប៉ុន្តែគាត់អាចនិយាយជាភាសាជនជាតិគាត់បាន។ ពេលខ្លះនៅពេលចប់វគ្គ គាត់មិនដឹងថាវគ្គនោះនិយាយពីអ្វីផង (មន្ទីរកិច្ចការនារីក្រុងខេត្តរតនៈគីរី បានលើកឡើង)។*

វាបានរំលេចឱ្យឃើញច្បាស់ថា ការរៀបចំថ្នាក់រៀនជាការចាំបាច់ពីព្រោះ គ.ក.ន.ក រៀនបានល្អបំផុតនៅពេលពួកគេអាចទាញយកមេរៀនពីបទពិសោធន៍ជីវិតដែលភ្ជាប់ជាមួយស្ថានភាពផ្ទាល់ខ្លួន។ ពួកគេរៀនសូត្រតាមរយៈការធ្វើការងារ ហើយនៅឆ្នាំទី១នៃការបង្កើតគណៈកម្មាធិការនេះ គឺជាឆ្នាំនៃការហាត់រៀនធ្វើការងារតែប៉ុណ្ណោះ។ ដូច្នេះវាជាការសំខាន់ណាស់ថា រាល់កម្មវិធីបណ្តុះបណ្តាលត្រូវសង្កត់ធ្ងន់ទៅលើចំណេះដឹងនៃការអនុវត្ត ដោយផ្អែកលើបទពិសោធន៍ជាក់ស្តែងនៅក្នុងទម្រង់ជារឿងរ៉ាវ (ករណីសិក្សា) ដែលលើកទឹកចិត្ត និងជំរុញឱ្យមានការរៀនសូត្រពីអ្នកមានឋានៈ ឬវ័យប្រហាក់ប្រហែលគ្នា។

ខាងក្រោមនេះ គឺជារឿងរ៉ាវមួយដែលអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំហ៊ានក្រោកឈរ និងមានឥទ្ធិពលលើ គ.ក.ន.ក :

*គ្មានសមាជិកណាម្នាក់ហ៊ានទទួលយកប្រាក់ ៥០០ ដុល្លា សម្រាប់ការវិនិយោគលើសាលាមត្តេយ្យសហគមន៍នោះទេ ពីព្រោះពួកគេគិតថា ប្រាក់នេះមិនគ្រប់គ្រាន់ដើម្បីការកសាងសាលាមត្តេយ្យសហគមន៍នោះទេ។ នៅក្នុងពេលនោះខ្ញុំគិតថាប្រាក់នេះនឹងត្រឡប់ទៅយូនីសេហ្វវិញប្រសិនបើគ្មានអ្នកណាម្នាក់ហ៊ានប្រើវា។ ខ្ញុំបាននិយាយបញ្ចុះបញ្ចូលថា គេឱ្យប្រើប្រាក់នេះដើម្បីជាប្រយោជន៍ទៅដល់សហគមន៍។ ហេតុនេះខ្ញុំនិយាយជាមួយមេឃុំអំពីការទទួលយកប្រាក់នេះ...ហើយគាត់ក៏យល់ព្រម។ ឥឡូវនេះមត្តេយ្យសិក្សាសហគមន៍នេះដំណើការបានយ៉ាងល្អ ហើយ ខ្ញុំទទួលបានការសរសើរ និងអគុណយ៉ាងខ្លាំងពីសមាជិកគណៈកម្មាធិការ និងសហគមន៍ (អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ នៅឃុំកកោះ ខេត្តកំពង់ធំនិយាយ)។*

វគ្គបណ្តុះបណ្តាលគួរតែមានអមដោយការប្រជុំតាមដាន(ការបង្ហាត់បង្ហាញ)ដែលជួយឱ្យអ្នករៀនបាននិយាយអំពីការរីកចំរើនរបស់ពួកគេ និងបញ្ហាប្រឈម និងដំណោះស្រាយលើបញ្ហាប្រឈមទាំងនោះ ។ ដូចដែលយើងនឹងបានឃើញនៅក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍សមត្ថភាពដែលបានស្នើឡើង។ របកគំហើញទាំងនេះ អាចតម្រូវឱ្យមាន"វគ្គបណ្តុះបណ្តាល"ដល់អង្គភាពរដ្ឋបាលមូលដ្ឋានរាជធានី ខេត្ត ក្រុមអ្នកសម្របសម្រួលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

អ្នកចូលរួមសម្ភាសន៍បានកំណត់ថាជំនាញប្រាស្រ័យទាក់ទង និងជំនាញសម្របសម្រួល គឺជាជំនាញមូលដ្ឋានគ្រឹះដ៏សំខាន់ ដូចជាការបង្កើតទំនាក់ទំនង និងការធ្វើឱ្យមានឥទ្ធិពលទៅលើអ្នកដទៃ។ មានតម្រូវការជាច្រើន ដើម្បីឱ្យមានការយល់ដឹងអំពីការតស៊ូមតិបានល្អជាងមុន និងតម្រូវការសម្រាប់ការតស៊ូមតិដោយ"ផ្អែកលើភស្តុតាង" ជាជាង "ផ្អែកលើអារម្មណ៍ថាត្រឹមត្រូវ"។ គម្លាតសំខាន់ៗដែលពាក់ព័ន្ធ បានកត់សំគាល់នៅខាងលើ គឺជាសមត្ថភាពក្នុងការប្រមូល និងវិភាគទិន្នន័យ ហើយប្រើប្រាស់ទិន្នន័យនោះដើម្បីបង្កើតករណីសិក្សាសម្រាប់ការផ្លាស់ប្តូរ (ឧទាហរណ៍ ការផ្លាស់ប្តូរក្នុងការចាត់អាទិភាព ការបែងចែកថវិកា ឬការផ្លាស់ប្តូរកម្មវិធីដែលបានកំណត់) ។ ជំនាញភាពជាអ្នកដឹកនាំក៏ត្រូវបានលើកឡើងជាតម្រូវការផងដែរ។

ដូចដែលបានកត់សំគាល់នៅផ្នែក១.៤.២ មនុស្សមានទស្សនៈផ្សេងៗទៅលើការបណ្តុះបណ្តាល/ការរៀនសូត្រការងារយេនឌ័រ ការចូលរួមជាដើម ត្រូវបានរៀបចំឱ្យបានស៊ីជម្រៅ និងដំណើរទៅមុខដោយមិនមានបញ្ហា។ វាជាការសំខាន់ដែលការខំប្រឹងប្រែងកសាងសមត្ថភាពឱ្យឆ្លើយតបទៅនឹងការឱ្យតម្លៃ ដែលជាភស្តុតាងបញ្ជាក់នៅក្នុងដំណើរការ

វិមជ្ឈការ (ដូចជា ការចូលរួម និងការបញ្ចេញសំលេងដែលមានចំនួនស្មើគ្នាសម្រាប់ស្ត្រី) ព្រមទាំងរបៀបដែលស្ត្រី និងបុរសធ្វើការជាមួយគ្នា ដើម្បីដោះស្រាយបញ្ហាដែលជារឿងសំខាន់នៅក្នុងសហគមន៍។

## ២.៣.២.ការប្រើប្រាស់វិធីសាស្ត្ររៀនសូត្រដែលលើកទឹកចិត្តឱ្យមានកិច្ចសន្ទនាខាយៗ

ឱកាសនៃការរៀនមួយដែល គ.ក.ន.ក. និងអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ទទួលបានល្អនោះគឺការរៀនសូត្រតាមរយៈវេទិកាដែលផ្តល់ដោយអង្គការចំរើនស្ត្រី។ វេទិកាទាំងនេះ បានបញ្ចូលជំនាញទាក់ទងនឹងការកសាងផែនការ ការរៀបចំចាត់ចែង និងការសម្របសម្រួល (ទំនុកចិត្តខ្លួនឯង និងភាពច្នៃប្រឌិត ការលើកកម្ពស់ឱ្យមានការចូលរួមស្មើភាពគ្នា ការស្តាប់ដោយបើកចិត្តទូលាយ និងការឆ្លុះបញ្ចាំង)និងការកំណត់បញ្ហា និងដំណោះស្រាយ។ អ្នកភូមិម្នាក់នៅខេត្តរតនៈគីរីបានចាប់អារម្មណ៍ថា កិច្ចសន្ទនានៅសហគមន៍ដែលបានរៀបចំឡើងមានសារៈសំខាន់ខ្លាំងណាស់ពីព្រោះ :

*កិច្ចសន្ទនាសហគមន៍ដែលគាំទ្រដោយ UNDP បានជួយឱ្យអ្នកភូមិបើកចិត្ត និងចែករំលែករឿងរ៉ាវទាក់ទងនឹងអំពើហិង្សាក្នុងគ្រួសារ និងយល់ដឹងពីបញ្ហាដែលពាក់ព័ន្ធនានា។*

វិធីសាស្ត្រទាំងពីរនេះបន្ថែមទៅលើដំណើរការសម្របសម្រួលដែលលើកទឹកចិត្តឱ្យមានទំនាក់ទំនងផ្អែកលើការជឿទុកចិត្ត និងការគោរព ព្រមទាំងការលើកកម្ពស់ការឱ្យតំលៃខ្លួនឯង និងបើកចំហរការប្រាស្រ័យទាក់ទង។ អ្នកចូលរួមកិច្ចសន្ទនានិយាយថា គាត់មានអារម្មណ៍ថា គេឮអ្វីដែលគាត់បាននិយាយ ហើយគាត់មានទំនុកចិត្ត (ក្លាហាន) ក្នុង "សាកល្បង" គំនិត និងរបៀបធ្វើការងារថ្មីៗ ។ វិធីសាស្ត្រទាំងពីរនេះ នឹងមានរៀបរាប់បន្ថែមទៀតនៅក្នុងផ្នែកទី៤ ។

វាមានភាពស្មុកស្មាញសម្រាប់ គ.ក.ន.ក និងអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ នៅពេលសម្របសម្រួបសំរួលកិច្ចប្រជុំ និងកិច្ចពិភាក្សាជាមួយសហគមន៍ គឺពួកគេត្រូវការចងចាំថា មនុស្សអាចរៀនបាននៅពេលពួកគេចែករំលែកបទពិសោធន៍ និងគំនិតក្នុងក្រុមតូចៗ :

*នៅពេលអ្នកឱ្យប្រជាពលរដ្ឋនិយាយពីខ្លួនគាត់ នោះបញ្ហាសំខាន់ៗជាច្រើននឹងលេចចេញមក។ (មតិពីអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការជាមួយគណៈកម្មាធិការគ្រប់គ្រងមណ្ឌលសុខភាព) ។*

នេះមានន័យថា តួនាទីរបស់អ្នកទទួលបន្ទុកកិច្ចាការនារី និងកុមារឃុំ សង្កាត់ ឬ សមាជិក គ.ក.ន.ក នៅពេលពិគ្រោះយោបល់ជាមួយសមាជិកសហគមន៍ត្រូវតែអង្គុយស្ងាត់ស្ងៀម និងរង់ចាំអ្នកផ្សេងៗទៀតបើកចិត្ត និងនិយាយ។ តួនាទីនេះមិនងាយស្រួលសម្រាប់អ្នកអនុវត្តដើម្បីប្រតិបត្តិនោះទេ គឺវាទាមទារឱ្យមានការអនុវត្តប្រកបដោយមនះសិកា និងមានការអត់ធ្មត់ដើម្បីរៀនសូត្រពីរបៀបបញ្ជូនព័តិមាននៅពេលពិគ្រោះយោបល់ជាមួយសហគមន៍។

## ២.៣.៣.កុំធ្វើឱ្យមានភាពស្មុគស្មាញ

អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ មិនចាំបាច់ត្រូវការជំនាញឯកទេសទេ។ គ្រាន់តែគាត់ត្រូវការដើម្បីអាចពន្យល់បានថាហេតុអ្វីគាត់ប្រមូលទិន្នន័យទាក់ទងនឹងចំនួនគ្រួសារបានចូលរួមយុទ្ធនាការចាក់ថ្នាំបង្ការ ឬចំនួនស្ត្រីមានផ្ទៃពោះឆ្លងទន្លេតាមផ្ទះ។ គាត់មិនត្រូវការព័តិមានបច្ចេកទេសស៊ីជម្រៅនោះទេ នៅក្នុងករណីនេះគឺជាការ

ទទួលខុសត្រូវរបស់មណ្ឌលសុខភាពនៅឃុំ សង្កាត់ ឬ មន្ទីរពេទ្យបង្អែកស្រុកប្រតិបត្ត និងខេត្ត។ ការងាររបស់គាត់ គឺគាត់ត្រូវការឱ្យមានទំនុកចិត្តគ្រប់គ្រាន់ដោយនិយាយថា "ខ្ញុំមិនដឹងទេ ប៉ុន្តែខ្ញុំដឹងពីទីកន្លែងដែលអ្នកអាចទទួលព័ត៌មាននោះបាន" ដែលជាពាក្យខ្លីដើម្បីធ្វើការបញ្ជាក់អះអាង។

ការសិក្សាស្រាវជ្រាវបង្ហាញយ៉ាងច្បាស់ថា គ.ក.ន.ក/អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ រៀនសូត្រតាមរយៈការធ្វើការងារ ហើយឆ្នាំទី១ គឺជាឆ្នាំដែលហាត់រៀនធ្វើការ។ ហេតុនេះកម្មវិធីបណ្តុះបណ្តាលនីមួយៗ ដែលត្រូវបានរៀបចំដើម្បីកសាងសមត្ថភាពអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ និងសមាជិក គ.ក.ន.ក ដ៏ទៀតគួរតែឆ្លុះបញ្ចាំងទៅនឹងវិធីសាស្ត្ររៀនសូត្រតាមរយៈការធ្វើការងារ។

ការបណ្តុះបណ្តាលបន្ត ផ្តល់ឱ្យនូវយន្តការមួយសម្រាប់ឱ្យដំណើរការងារមានលំនឹងនៅទូទាំងប្រទេស។ ប៉ុន្តែបទពិសោធន៍បង្ហាញថា កម្មវិធីបណ្តុះបណ្តាលបន្តពីក្រុមថ្នាក់ជាតិទៅដល់ថ្នាក់ខេត្ត ថ្នាក់ស្រុក និងថ្នាក់ឃុំ សង្កាត់ អាចបាត់បង់មួយចំណែកតូច (ឬមិនច្បាស់) តាមរយៈការបណ្តុះបណ្តាលបន្តរបៀបនេះ។ ជាទូទៅចំណេះដឹងបច្ចេកទេសត្រូវបានគេឱ្យតម្លៃទៅលើដំណើរការរៀនសូត្រ។ គ្រោះថ្នាក់មួយដែលយើងរកឃើញ ឧទាហរណ៍អ្នកបណ្តុះបណ្តាល/អ្នកសម្របសម្រួលបង្រៀនស្ត្រីអំពីអំពើហិង្សាក្នុងគ្រួសារជាជាងសួរពីបទពិសោធន៍របស់ស្ត្រីទាំងនោះ និងសួរពីរបៀបដែលគាត់យល់ដឹងអំពីអំពើហិង្សាក្នុងគ្រួសារ។ បំណងប្រាថ្នាគឺចង់ឱ្យកើនឡើងនូវចំណេះដឹង និងយកចំណេះដឹងទាំងនោះដើម្បីបង្រៀនតាមបែបបញ្ចុះបញ្ចូល។ ក្រុមគ្រូបណ្តុះបណ្តាល/អ្នកសម្របសម្រួលត្រូវមានអារម្មណ៍សប្បាយរីករាយជាមួយវិធីសាស្ត្រសម្របសម្រួល និងមានការអត់ធ្មត់ជាមួយសេចក្តីត្រូវការ "បង្រៀន" របស់ខ្លួនឯង។

## ២.៣.៤.ការអភិវឌ្ឍសមត្ថភាពជាជំហានៗ

ការផ្តោតអារម្មណ៍របស់មេឃុំក្នុងការបង្កើត គ.ក.ន.ក គួរតែធ្វើការតម្រង់ទិសសមាជិកឱ្យបានច្បាស់លាស់អំពីតួនាទី និងការទទួលខុសត្រូវ អ្នកណាធ្វើអ្វី ហើយការគាំទ្រការងាររបស់ គ.ក.ន.ក តាមរយៈរបៀបណា និងទាយយកការងារពីគណៈកម្មាធិការដែលពាក់ព័ន្ធ (ដូចជាគណៈកម្មាធិការគ្រប់គ្រងមណ្ឌលសុខភាព គណៈកម្មាធិការវត្ត និងគណៈកម្មាធិការដែលពាក់ព័ន្ធនៅថ្នាក់ស្រុក ជាដើម)។ ពួកគេគួរតែផ្តល់ការយល់ដឹងឱ្យបានច្បាស់ក្នុងការកសាងក្រុម និងធ្វើការតម្រង់ទិសសមាជិកថ្មីសម្រាប់បន្តនិរន្តរភាពនៅពេលសមាជិកណាម្នាក់ផ្ទេរការងារទៅកាន់តួនាទីថ្មីនៅកន្លែងផ្សេង ឬមានសំណាងបានជាប់ឆ្នោតជាសមាជិកគណៈកម្មាធិការនេះ។

ជំនាញសម្របសម្រួលជាតម្រូវការចាំបាច់ដំបូងគេ។ ប៉ុន្តែដើម្បីក្លាយជាអ្នកមានសមត្ថភាពម្នាក់ ទាល់តែអ្នកសម្របសម្រួលអនុវត្តដោយមានភាពអំណត់ និងមានការតាំងចិត្តរយៈពេលយូរ។ តាមពេលវេលា អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ និង គ.ក.ន.ក ត្រូវការប្តូរពីជំនាញសម្របសម្រួលទូទៅទៅជាជំនាញសម្របសម្រួលស្មុគស្មាញ : ដូចជា របៀបគ្រប់គ្រងឧប្បត្តិហេតុនៃអំពើហិង្សាក្នុងគ្រួសារ ឬ ពីរបៀបសម្រុះសម្រួលជម្លោះនៅពេលមានទំនាស់ផលប្រយោជន៍កើតឡើង ដោយមិនឱ្យស្ថានភាពនោះកាន់តែតានតឹងឡើងៗ។

ជាទូទៅ ការប្រមូលទិន្នន័យ និងសរសេររបាយការណ៍ត្រូវបានធ្វើជាទៀងទាត់។ ទិន្នន័យត្រូវបានទាញចេញពីប្រភពដែលមានស្រាប់ (ដូចជា តួលេខទទួលបានពីមណ្ឌលសុខភាពដែលរៀបរាប់ថាអ្នកណាបានប្រើប្រាស់សេវានេះ)។ ទោះបីជាយ៉ាងណាក៏ដោយ តួលេខទាំងនេះគឺជាស្ថិតិ ហើយតែងតែមិនទទួលស្គាល់នូវភាពខុសគ្នានៃគ្រួសារដែលមិនបានទទួលសេវាសុខភាព។ ការយល់ដឹងលើសពីនេះទៀត គឺទាមទារឱ្យ គ.ក.ន.ក ទទួលស្គាល់ភាពប្រែប្រួលតាមពេលវេលា និងហេតុអ្វីមានការកើតឡើងបែបនេះ (ឧទាហរណ៍ ភាពខុសគ្នារវាងចំនួនកុមារចុះឈ្មោះចូលរៀនក្នុងសាលារៀននៅដើមឆ្នាំ នៅពាក់កណ្តាលឆ្នាំ និងចុងឆ្នាំ។) រកបកគំហើញនេះស្នើឱ្យមានការយកចិត្តទុកដាក់ថែមទៀតក្នុងការផ្តល់របៀបប្រមូលព័តិមានដែលកំណត់ច្បាស់ពីភាពខុសគ្នា (ដូចជា ឧបករណ៍សិក្សាវាយតម្លៃដោយមានការចូលរួម) និងបង្កើនសមត្ថភាពក្នុងការប្រើប្រាស់ទិន្នន័យដោយសួរថា ហេតុអ្វីមានភាពខុសគ្នាបែបនេះកើតឡើង? តើយើងឆ្លើយតបយ៉ាងដូចម្តេចទៅហេតុការណ៍នេះ ? តើយើងត្រូវការដើម្បីសិក្សាវាយតម្លៃអាទិភាពរបស់យើងឡើងវិញដែរឬទេ ?

សេចក្តីត្រូវការចាំបាច់ គឺបញ្ជាក់ឱ្យច្បាស់ពីតួនាទីក្នុងការតាមដានត្រួតពិនិត្យ និងរាយការណ៍ និងបញ្ជាក់ពីដំណើរការក្នុងការតាមដានត្រួតពិនិត្យ ការិភាគ និងការរៀបចំផែនការសកម្មភាពឡើងវិញដោយផ្អែកលើការវិភាគ។

ដូចគ្នានេះដែរ តួនាទីក្នុងការតស៊ូមតិមិនទាន់ត្រូវបានគេយល់បានល្អនៅឡើយទេ។ ហេតុផលមួយសម្រាប់ការតស៊ូមតិនេះ គឺធ្វើការតស៊ូមតិក្នុងនាមគ្រួសារ ឬសហគមន៍ដែលមិនទាន់ទទួលបានសេវាគ្រប់គ្រាន់ ហើយការតស៊ូមតិនេះអាចពឹងទៅលើសមត្ថភាពក្នុងការវិភាគទៅលើឋានៈក្នុងការចរចារ ក្នុងការមានឥទ្ធិពល និងករណីខ្លះទៀតក្នុងការប្រឈមមុខទៅនឹងឋានៈ និងអំណាច។

ការពន្យល់ចុងក្រោយបង្ហាញឱ្យឃើញថា ការវាយតម្លៃបញ្ចប់វគ្គ ឬសិក្ខាសាលា កម្មវិធីបណ្តុះបណ្តាលមិនត្រូវបានធ្វើការវាយតម្លៃដោយអ្នកឧបត្ថម្ភ ឬអ្នកផ្តល់សេវាណាមួយនោះទេ។ ការធ្វើរបៀបនេះបញ្ជាក់ឱ្យឃើញពីកង្វះចន្លោះ និងឱកាសសម្រាប់ជំរុញឱ្យមានកម្មវិធីអភិវឌ្ឍសមត្ថភាពដែលត្រូវផ្តល់ឱ្យនាពេលបច្ចុប្បន្ន ហើយក៏ជាផលប៉ះពាល់ដ៏ធំធេងនៅក្នុងដំណើរការកំពុងរៀនសូត្រ (**Mackay, 2010**)។

## ២.៤.តម្រូវការអភិវឌ្ឍសមត្ថភាពរបស់ គ.ក.ន.ក/អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំសង្កាត់ វិវត្តតាមពេលវេលាដោយរបៀបណា

តម្រូវការអភិវឌ្ឍសមត្ថភាពក៏មានការផ្លាស់ប្តូរទៅតាមពេលវេលាផងដែរ។ ឧទាហរណ៍ នៅឆ្នាំទី១ គ.ក.ន.ក (ជាពិសេស មេឃុំ ចៅសង្កាត់ ជំទប់ទី២ ចៅសង្កាត់រងទី២ និងអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់) ត្រូវការបង្កើតឱ្យមាន គ.ក.ន.ក និងធ្វើឱ្យមានការយល់គ្នានៅក្នុងគណៈកម្មាធិការនេះ។ នេះមានន័យថាពួកគេត្រូវមានសមត្ថភាពក្នុងការធ្វើផែនការ ចាត់ចែង និងកសាងថាមពលក្រុមដោយបញ្ជាក់ពីសេចក្តីរំពឹងទុកដែលនឹងទទួលបាន។ ពួកគេចាំបាច់ត្រូវប្រើប្រាស់ និងពង្រីកបណ្តាញការងារដែលមានស្រាប់។ អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំសង្កាត់ ត្រូវតែកសាងទំនុកចិត្ត និងសមត្ថកិច្ចដើម្បីអាចមានលទ្ធភាពនិយាយបានច្បាស់លាស់ និងត្រឹមត្រូវអំពីបញ្ហាស្ត្រី និងកុមារ។ ពួកគេចាំបាច់ត្រូវតែមានសមត្ថភាពផងដែរ ក្នុងការបង្ហាញសេចក្តីសំអាងឱ្យបានល្អថាហេតុអ្វីបានបញ្ហាស្ត្រី

និងកុមារមានសារៈសំខាន់។ នៅឆ្នាំទី២ និងទី៣ គ.ក.ន.ក ចាប់ផ្ដើមមានទំនាក់ទំនងកាន់តែខ្លាំងឡើងជាមួយនឹងបញ្ហាលំបាក និងស្មុគស្មាញ ហើយជំនាញចរចារនៅពេលនេះមានសារៈសំខាន់ខ្លាំងណាស់។ អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ អាចធ្វើការសម្របសម្រួលផងដែរ និងអាចទប់ទល់ស្ថានភាពដែលជាប់ទាក់ទងនឹងទំនាស់។ នៅឆ្នាំទី៤ និងទី៥ សមាជិកគណៈកម្មាធិការទាំងអស់គួរតែចាប់ផ្ដើមធ្វើការតស៊ូមតិដោយផ្អែកលើភស្តុតាង។

ការផ្លាស់ប្ដូរសមត្ថភាពទាំងនេះមានបង្ហាញនៅក្នុងតារាងទី២។

## តារាងទី២: តម្រូវការអភិវឌ្ឍសមត្ថភាពទៅតាមពេលវេលា

| ការចាប់ផ្ដើម (ឆ្នាំទី១) | ការអភិវឌ្ឍ (ឆ្នាំទី២ និងឆ្នាំទី៣) | ស្វ័យភាព (ឆ្នាំទី៤ និងឆ្នាំទី៥) |
|---|---|---|
| កសាងសមត្ថភាពក្រុម ដើម្បីឱ្យមានការយល់ដឹង ការប្ដេជ្ញាចិត្ត និងភាពជាម្ចាស់របស់ គ.ក.ន.ក ជាឧទាហរណ៍តាមរយៈករណីសិក្សា, ការនិយាយរឿងរ៉ាវប្រាប់, បច្ចេកទេសបញ្ជាក់ពីសារៈសំខាន់នៃតួនាទី និងការទទួលខុសត្រូវ និងអ្វីដែល គ.ក.ន.ក អាចក្លាយទៅជា(ចក្ខុវិស័យ), ការរៀបចំលំដាប់នៃការឱ្យតម្លៃ, ការតម្រង់ទិសអំពីវិមជ្ឈការ និងវិសហមជ្ឈការ/ច្បាប់រៀបចំអង្គការ និងសិទ្ធិនារី និងកុមារ ព្រមទាំងការណែនាំពីបញ្ហាដែលប្រកបដោយគ្រោះថ្នាក់ ចំនួន ២-៣ (អ្វីខ្លះ និងហេតុអ្វី) ដែល គ.ក.ន.ក នឹងត្រូវធ្វើនៅឆ្នាំទី១។ | ពង្រីកក្រុមដើម្បីផ្ដល់សមត្ថភាពថ្មីៗ និងរបៀបតម្រង់ទិសដល់សមាជិកថ្មី, ផ្ដល់ធនធានបច្ចេកទេសបន្ថែមដែលទាក់ទងទៅនឹងកិច្ចការពារសង្គម, ប្រជាជន និងការចំណាកស្រុក។ល។ | តម្រង់ទិសសម្រាប់សមាជិកថ្មី ការគ្រប់គ្រងកិច្ចការ ដែលប្រគល់ឱ្យ។ |
| ការដោះស្រាយបញ្ហា : ដោះស្រាយបញ្ហាដែលទាក់ទងជាមួយការងារដែលគិតស្មានមិនដល់(គ្រោះធម្មជាតិ មរណភាពឪពុកម្ដាយដោយទុកឱ្យកូននៅកំព្រា)។ | ការគិតដោយវិភាគ និងការធ្វើសេចក្ដីសំរេចៈ កំណត់ និងបង្ហាញពីភាពខុសគ្នាតាមរយៈផែនទីសេវាសង្គម និងឧបករណ៍ទាក់ទងផ្សេងៗ។ | ការវិភាគពីទំនាក់ទំនងអំណាចៈ <u>ឆ្នាំទី៥</u>: ពិនិត្យមើលឡើងវិញអំពីការរីកចំរើន និងបញ្ហាប្រឈម, វិភាគនិន្នាការពីខាងក្រៅ,សិក្សាវាយតម្លៃតម្រូវការ |

| | | |
|---|---|---|
| អភិវឌ្ឍសមត្ថភាពក្នុងការធ្វើរបាយការណ៍ដោយផ្ទាល់មាត់ និងជាលាយលក្ខណ៍អក្សរ ។ | អភិវឌ្ឍជំនាញក្នុងការវិភាគទិន្នន័យដើម្បីបង្កើតជាករណីសិក្សាសម្រាប់ផ្លាស់ប្តូរ ។ | វិភាគកង្វះចន្លោះសមត្ថភាពផ្ទាល់ខ្លួន និងវាយតម្លៃលើការបណ្តុះបណ្តាល, រៀបចំព្រៀងផែនការរយៈពេលវែង (សម្រាប់ គ.ក.ន.ក អាណត្តិក្រោយទៀត) ។ |
| ធ្វើផែនការ និងរៀបចំកិច្ចប្រជុំឱ្យមានប្រសិទ្ធិភាព ។<br>រៀបចំផែនការការងារ និងផែនការថវិកា ។ | របៀបបង្ហាញសេចក្តីសំអាងដោយមានការបញ្ចុះបញ្ចូលនៅក្នុងរបាយការណ៍ផ្ទាល់មាត់ និងជាលាយលក្ខណ៍អក្សរ ។ | |
| របៀបបំពេញទម្រង់របាយការណ៍, ទិន្នន័យអ្វីខ្លះដែលត្រូវប្រមូល, តាមដានត្រួតពិនិត្យការអនុវត្តផែនការរបស់ឃុំ សង្កាត់, ណែនាំឱ្យចងក្រងបញ្ជីឈ្មោះសេវា ។ | តាមដានត្រួតពិនិត្យ និងរាយការណ៍អំពីការធ្វើផែនការសកម្មភាព (ឧ. រៀបលំដាប់ និងស្រង់ទិន្នន័យ, រៀបចំផែនការសកម្មភាពសង្ខេប) ។<br>ការធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះសេវា ។ | តស៊ូមតិដោយផ្អែកលើភស្តុតាង (សម្រាប់សកម្មភាព និងការផ្លាស់ប្តូរ) ។<br>ជំនាញភាពជាអ្នកដឹកនាំ, ធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះសេវា,បញ្ចូលតម្រូវការផ្អែកជំនាញសម្រាប់ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ ។ |
| ជំនាញសម្របសម្រួល និងជំនាញប្រាស្រ័យទាក់ទង ដើម្បីកសាងទំនុកចិត្ត ឧ.លើកកម្ពស់ការចូលរួមដោយស្មើភាព, ការស្តាប់ដោយបើកចិត្តឱ្យទូលាយ, ការឆ្លុះបញ្ចាំង និងការសម្របសម្រួលដើម្បីឱ្យកិច្ចប្រជុំទទួលបានជោគជ័យ ។<br>និយាយឱ្យច្បាស់ និងមានទំនុកចិត្តលើការនិយាយអំពីបញ្ហាស្ត្រី និងកុមារចំនួន ២-៣ បញ្ហា ។<br>បង្ហាញរបាយការណ៍ដោយផ្ទាល់មាត់ | ចរចារ និងធ្វើឱ្យមានឥទ្ធិពល (ឧ. សម្រាប់បង្ហាញពីបញ្ហាអំពើហឹង្សានៅក្នុងគ្រួសារ) ។<br>ពន្យល់អំពីបញ្ហាដែលទាក់ទងទៅនឹងប្រជាជន និងចំណាកស្រុក ព្រមទាំងកិច្ចការពារសង្គម ។ | ការសម្របសម្រួលៈ ការធ្វើការជាមួយបញ្ហាទំនាស់ និងអំណាច ។ |

| | | |
|---|---|---|
| និងមានសរសេរជាលាយលក្ខណ៍អក្សរយ៉ាងសាមញ្ញ។ | | |
| អភិវឌ្ឍ និងគ្រប់គ្រងការទំនាក់ទំនងភាពដៃគូដែលផ្ដល់ផលប្រយោជន៍។ ភ្ជាប់បណ្ដាញការងារបច្ចុប្បន្ន និងបណ្ដាញការងារថ្មី។ | ពង្រឹង និងពង្រីកបណ្ដាញការងារ។ | រក្សាបណ្ដាញការងារផ្អែកលើពេលវេលា។ |

## ២.៥.កំណត់សំគាល់លើសេចក្ដីសន្និដ្ឋានដែលជាការឱ្យតម្លៃបន្ថែមដល់ គ.ក.ន.ក/អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់



បណ្ដាញការងារសង្គមមួយ ជារចនាសម្ព័ន្ធសង្គមមួយដែលបុគ្គល ឬអង្គការជាអ្នកបង្កើតឡើង សម្រាប់ភ្ជាប់អន្តរទំនាក់ទំនងរវាងគ្រួសារ មិត្តភក្ដិ ថៅកែ និងអតិថិជន ការផ្លាស់ប្ដូរហិរញ្ញវត្ថុ ទំនាក់ទំនងផ្អែកជំនឿសាសនា ចំណេះដឹង និងកិត្យានុភាព។ បណ្ដាញការងារសង្គម មានដំណើរការគ្រប់លំដាប់ថ្នាក់ចាប់តាំងពីគ្រួសារដល់ឃុំ សង្កាត់រហូតដល់ស្រុក ខេត្ត និងថ្នាក់ជាតិ។ បណ្ដាញសង្គមដើរតួយ៉ាងសំខាន់ក្នុងការកំណត់ពីមធ្យោបាយ ដែលត្រូវដោះស្រាយបញ្ហា របៀបប្រតិបត្តិរបស់ស្ថាប័ននីមួយៗ (ដូចជាក្រុមប្រឹក្សាឃុំ សង្កាត់ ក្រុមទ្រទ្រង់សុខភាពភូមិមណ្ឌលសុខភាព) ដែលបានបង្កើតឡើង និងកម្រិតដែលបុគ្គលជាសមាជិកសហគមន៍ចូលរួមក្នុងសកម្មភាពដែលពាក់ព័ន្ធ នឹងឃុំ សង្កាត់។

ការធ្វើផែនទីបណ្ដាញការងារសង្គមមួយជួយឱ្យយល់ពីទំនាក់ទំនងសង្គមនៅក្នុងបណ្ដាញការងារដទៃ ហើយថាតើទំនាក់ទំនងទាំងនេះត្រូវផ្អែកទៅលើកាលៈទេសៈ និងភាពងាយស្រួល ឬការជួយគាំទ្រតាមពេលវេលាកំណត់ដែរឬទេ។ ការវិភាគអំពីបណ្ដាញការងារសង្គម គឺផ្ដោតទៅលើរបៀបភ្ជាប់ទំនាក់ទំនងដែលមានឥទ្ធិពលលើបុគ្គល និងការទំនាក់ទំនងរបស់ពួកគេ ព្រមទាំងរបៀបភ្ជាប់ទំនាក់ទំនងទាំងនេះដឹកនាំទៅរកសកម្មភាពរួមមួយ។

មុខងារសំខាន់របស់ គ.ក.ន.ក គឺលើកកម្ពស់កិច្ចសហការ និងការភ្ជាប់ទំនាក់ទំនងរវាងសមាជិកសហគមន៍ ឃុំ សង្កាត់ និងអ្នកផ្ដល់សេវាតាមវិស័យ (ទាំងរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល) ដូចជា លើកទឹកចិត្តឱ្យមានតម្រូវការ ជំរុញឱ្យមានការផ្ដល់សេវា និងដើម្បីបង្ហាញឱ្យឃើញពីភាពខុសគ្នាក្នុងការភ្ជាប់ទំនាក់ទំនង។ ការធ្វើបែបនេះអាចឱ្យ គ.ក.ន.ក ចូលរួមចំណែកក្នុងការពង្រឹងបណ្ដាញការងារសង្គម។ នៅក្នុងដំណាក់កាលដំបូង គ.ក.ន.ក ចាប់ផ្ដើមបំពេញការងារជាមួយការបង្កើតទំនាក់ទំនងដោយផ្អែកលើការគោរព និងជឿទុកចិត្តគ្នាទៅវិញទៅមក។ ដំណាក់កាលនេះគឺជាមូលដ្ឋានគ្រឹះសម្រាប់កិច្ចសហការ និងការសម្របសម្រួលល្អបំផុតផ្អែកសេវាសង្គម។

*ការសម្របសម្រួលក្នុងការឆ្លើយតបទៅនឹងឧប្បត្តិហេតុនៃអំពើហិង្សាក្នុងគ្រួសារគឺជាមុខងារយ៉ាងសំខាន់ដែល គ.ក.ន.ក ធ្វើនៅក្នុងឃុំ សង្កាត់..បើសិនជាមានគ្រួសារណាជួបនឹងអំពើហិង្សាក្នុងគ្រួសារ គ.ក.ន.ក អាចសម្របសម្រួលដើម្បីជួយគ្រួសារនោះ ព្រមទាំងធ្វើឱ្យមានភាពប្រាកដថាតម្រូវការផ្នែកសុខភាព ការអប់រំកុមារ និងកិច្ចការពារ ត្រូវបានទទួល..ប៉ុន្តែនគរបាលរដ្ឋបាលក៏បានសារភាពថាគាត់គ្រាន់តែអាចធ្វើការលើបញ្ហាពាក់ព័ន្ធទៅនឹងច្បាប់ និងបញ្ហាកិច្ចការពារតែប៉ុណ្ណោះ ពួកគាត់ម្នាក់ឯងមិនអាចជួយដោះស្រាយបញ្ហាសង្គមបានទេ (អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារ ឃុំ ខេត្តឧត្តរមានជ័យ បានលើកឡើង)។*

សមាជិក គ.ក.ន.ក ធ្វើការងារដោយមានកិច្ចសហការជាមួយនឹងអ្នកផ្តល់សេវាជាច្រើនទៀតក្នុងការរៀបចំលំដាប់មុខងារផ្សេងៗ។ ឧទាហរណ៍នៅក្នុងវិស័យអប់រំពួកគេរៀបចំយុទ្ធនាការផ្សព្វផ្សាយពីការចុះឈ្មោះចូលរៀន និងផ្តល់កង់សម្រាប់កុមាររស់នៅភូមិដាច់ស្រយាលជិះទៅសាលារៀន។ ពួកគេរៀបចំអ្នកតំណាងសហគមន៍ដើម្បីជូនកុមារទៅសាសាមត្តេយ្យសហគមន៍បើឪពុកម្តាយកុមារកំពុងធ្វើការ ដូច្នេះកុមារអាចចូលរៀននៅសាសាមត្តេយ្យសហគមន៍។ ពួកគេតាមដានត្រួតពិនិត្យលើវត្តមានសិស្ស និងតាមដាននៅពេលដែលកុមារអវត្តមានពីសាលា។ ពួកគេក៏ត្រួតពិនិត្យមើលលើគ្រូមត្តេយ្យសហគមន៍ផងដែរដើម្បីធានាថាថ្នាក់មត្តេយ្យសហគមន៍ដំណើរការតាមកាលវិភាគកំណត់។ ការធ្វើរបៀបនេះផ្តល់ឱ្យអាជ្ញាធរមានសមត្ថកិច្ចតាមរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ផ្តោតលើជំនាញក្នុងការរៀបចំកម្មវិធីសិក្សា និងការបង្រៀន ការបណ្តុះបណ្តាលគ្រូ និងការធានាលើគុណភាពនៃការសិក្សា។ ស្ថិតិបង្ហាញថាកុមារដែលបានចូលរៀនសាលាមត្តេយ្យបានចុះឈ្មោះចូលរៀននៅសាលាបឋមតាមអាយុកំណត់ឱ្យចូលរៀន និងទទួលបានជោគជ័យ។

ស្រដៀងគ្នានេះដែរ គ.ក.ន.ក ក៏បានមើលឃើញភាពខុសគ្នានៅក្នុងផ្នែកសុខាភាពផងដែរ ឧទាហរណ៍ តាមរយៈការចំណាយលើមធ្យោបាយធ្វើដំណើរសម្រាប់ស្ត្រីមានផ្ទៃពោះរបស់គ្រួសារក្រីក្រទៅពិនិត្យផ្ទៃពោះនៅក្នុងមណ្ឌលសុខភាព ការផ្តល់ជាអាហារបន្ថែមសម្រាប់ស្ត្រីមានផ្ទៃពោះដែលជាគ្រួសារក្រីក្រ ការលើកទឹកចិត្តឱ្យស្ត្រីមានផ្ទៃពោះទៅសម្រាលកូននៅមណ្ឌលសុខភាព និងការលើកទឹកចិត្តឱ្យមានការបំបៅកូនដោយទឹកដោះម្តាយ។ នៅក្នុងការបំពេញមុខងារទាំងនេះ គ.ក.ន.ក កំពុងជំរុញឱ្យមានតម្រូវការ និងសម្របសម្រួលឱ្យប្រើប្រាស់សេវាទាំងនេះ ដើម្បីបង្កើនការថែទាំគ្រួសារ ហើយជាចុងក្រោយ ពួកគេកំពង់ចូលរួមចំណែកក្នុងការធ្វើសមេចនូវគោលដៅអភិវឌ្ឍន៍សហសវត្ស[8] ។

នៅក្នុងលក្ខណៈចាស់ទុំ គ.ក.ន.ក គឺជាបណ្តាញការងារដោះស្រាយបញ្ហាដែលអាចឱ្យឃុំ សង្កាត់ ស្វែងរកវិធីសាស្ត្រសម្របសម្រួលក្នុងការដោះស្រាយបញ្ហាសង្គមនៅក្នុងឃុំ សង្កាត់។ ការធ្វើរបៀបនេះ គឺដើម្បីប្រមូលព័ត៌មានរួមពីផ្នែកផ្សេងៗដោយដើរតួជាចំណុចកណ្តាលក្នុងការផ្សាភ្ជាប់ទំនាក់ទំនងរវាងអាជ្ញាធរមូលដ្ឋានជាមួយផ្នែកផ្សេងៗទៀត។ ធ្វើដូច្នេះជំរុញឱ្យមានចំណងដ៏រឹងមាំរវាងឃុំ/សង្កាត់ សហគមន៍ និងអ្នកផ្តល់សេវាតាមវិស័យជាច្រើនទៀត។ ពីព្រោះ គ.ក.ន.ក ជាភ្នាក់ងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ហើយ គ.ក.ន.ក អាចធ្វើឱ្យផ្នែកផ្សេងៗមានផលប៉ះពាល់យ៉ាងខ្លាំងលើការផ្តល់សេវា ប្រសិនបើពួកគេធ្វើការងារដោយឯករាជ្យ។ ក្នុងពេលនោះដែរ វត្តមាន និងមុខងាររបស់ គ.ក.ន.ក មានឥទ្ធិពលលើការលើកទឹកចិត្តឱ្យមានការប្រើប្រាស់សេវាដែល គ.ក.ន.ក គាំទ្រ។ ផ្ទុយមកវិញមុខងារនេះ អនុញ្ញាត

[8] កម្ពុជា MDG2 (សមិទ្ធិផលជាសកល ការអប់រំជាមូលដ្ឋានរយៈពេល៩ ឆ្នាំ) និងកម្ពុជា MDG4 ការកាត់បន្ថយការស្លាប់របស់កុមារ។

ឱ្យក្រុមក្រុមប្រឹក្សាឃុំ សង្កាត់បំពេញកាតព្វកិច្ចរបស់ខ្លួនចំពោះសហគមន៍តាមរយៈការជំរុញឱ្យមានការប្រើប្រាស់សេវា និងគុណភាពនៃការទទួលសេវា។

ក្នុងនាមជាបណ្តាញការងារដោះស្រាយបញ្ហា គ.ក.ន.ក ជួយពង្រឹងការយល់ដឹងពីបញ្ហាស្ត្រី និងកុមារ ក៏ដូចជាសេវាសង្គមដទៃទៀតនៅក្នុងចំណោមមេឃុំ/ចៅសង្កាត់ និងសមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់ ព្រមទាំងជួយសម្របសម្រួលការងាររបស់អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ទៀតផង។ ផ្អែកតាមពេលវេលា នៅពេលដែលទំនាក់ទំនងរវាងមេឃុំ/ចៅសង្កាត់ ចៅសង្កាត់រងទី២/ជំទប់ទី២ ស្មៀនឃុំ/សង្កាត់ និងអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់មានការរីកចំរើនហើយនោះ ការងាររបស់ គ.ក.ន.ក ក៏អាចបញ្ជ្រាបចូលទៅក្នុងមុខងារក្រុមប្រឹក្សាឃុំ សង្កាត់ដោយផ្ទាល់ផងដែរ។

*<u>ពាក្យដាស់តឿន</u>: នៅក្នុងការលើកទឹកចិត្តឱ្យមានការស្នើសុំសេវា គ.ក.ន.ក បានបង្ហាញនូវការរំពឹងទុកថា ការស្នើសុំសេវាទាំងនេះនឹងត្រូវបានផ្តល់ ទោះបីជានៅក្នុងសំណើខ្លះមិនមានការស្នើសុំក៏ដោយ។ ការងារកិច្ចការពារសង្គមមានការលំបាកដូចបានរៀបរាប់នៅផ្នែកទី៤.២ ពីព្រោះមិនមានបុគ្គលិកធ្វើការងារសង្គមដែលមានការបណ្តុះបណ្តាលគ្រប់គ្រាន់ ឬអ្នកពិគ្រោះយោបល់ដែលអាចបង្ហាញពីបញ្ហាពាក់ព័ន្ធនឹងកិច្ចការពារសង្គមនេះបានឡើយ។*

ផ្នែកបន្ទាប់ទៀត យើងនឹងលើកយករបកគំហើញ និងការវិភាគក្នុងផ្នែកទី២ដើម្បីកំណត់អំពីកម្រងសមត្ថភាពរបស់ គ.ក.ន.ក និងអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់។

## ផ្នែកទី៣៖ ការធ្វើការងារដោយសមត្ថភាព

### ៣.១.តើអ្វីជាសមត្ថភាព និងហេតុអ្វីត្រូវមានសមត្ថភាព?

ចំពោះគោលបំណងនៃការសិក្សានេះ សមត្ថភាពកំណត់អត្ថន័យបានតាមការសង្កេត (ហើយក្នុងករណីខ្លះអាចវាស់វែងបាន) ទៅលើ***ចំណេះដឹង ជំនាញ អាកប្បកិរិយា និងឥរិយាបថ*** ដែលជាតម្រូវការរបស់ គ.ក.ន.ក និងអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ដូច្នេះពួកគាត់អាចបំពេញកិច្ចការតាមតួនាទី និងការទទួលខុសត្រូវរបស់ខ្លួនដោយមានទំនុកចិត្ត។

សមត្ថភាពឱ្យអត្ថន័យបានថា **"មានអ្វីខ្លះ"** (ចំណេះដឹង និងជំនាញអ្វីខ្លះដែលត្រូវការ) និង **"ធ្វើរបៀបណា"** (អាកប្បកិរិយា និងឥរិយាបថ)។

ឧទាហរណ៍ ការសម្របសម្រួល គឺជាសមត្ថភាពដែលកំណត់នូវចំណេះដឹង និងជំនាញជាក់លាក់ ដោយគិតរួមទាំងសមត្ថភាពក្នុងការបង្ហាញព័ត៌មានបានយ៉ាងច្បាស់លាស់ និងយ៉ាងសង្ខេប សមត្ថភាពក្នុងការចាត់ចែងការងារក្រុម និងសមត្ថភាពក្នុងការដោះស្រាយកិច្ចសន្ទនាលំបាកៗជាដើម។ សមត្ថភាពនេះក៏រួមបញ្ចូលផងដែរនូវអាកប្បកិរិយា និងឥរិយាបថជាក់លាក់ដែលកំណត់ពីរបៀបអ្នកសម្របសម្រួលធ្វើការងារ ឧទាហរណ៍ ដូចជា ការស្តាប់ដោយយកចិត្តទុកដាក់ ឬមិនប្រាប់សហគមន៍ថាត្រូវធ្វើអ្វីនោះទេ ប៉ុន្តែដឹកនាំសមាជិកសហគមន៍ ឱ្យចេះរកដំណោះស្រាយដោយខ្លួនឯង។

ដូច្នេះសមត្ថភាពអនុញ្ញាតឱ្យយើងសម្រេចបាននូវលទ្ធផលដូចតទៅ ៖

១. ទីមួយ បុគ្គល ឬក្រុម ដឹងច្បាស់ពីការងារអ្វីដែលខ្លួនរំពឹងថាចង់ធ្វើ (ខ្នាតគំរូអប្បបរមា) និងត្រូវវាយតម្លៃការបំពេញការងាររបស់ពួកគាត់ដោយរបៀបណា

២. ទីពីរ ពួកគាត់អាចប្រើប្រាស់កម្រងសមត្ថភាពដើម្បីកំណត់ភាពខ្លាំង និងកង្វះចន្លោះសមត្ថភាពរបស់ខ្លួន

៣. ទីបី ការរៀនសូត្រ អាចធ្វើទៅតាមក៏រិតនៃការបំពេញការងារបច្ចុប្បន្នរបស់អ្នករៀនសូត្រ

៤. ទីបួន អ្នកផ្តល់វគ្គបណ្តុះបណ្តាល អាចធ្វើជាដំណាក់ៗក្នុងកម្មវិធីបណ្តុះបណ្តាលរបស់ខ្លួន៖ មុនដំបូងផ្តោតទៅលើតម្រូវការបន្ទាន់ និងបន្ទាប់មកបន្តទៅការរៀនសូត្រមួយដែលមានលក្ខណៈឈានមុខ[៩]

៥. ទីប្រាំ សមត្ថភាព ផ្តល់ឱ្យនូវការណែនាំមួយសម្រាប់ជ្រើសរើសសមាជិកក្រុមថ្មី (ផ្អែកលើសមត្ថភាពបច្ចុប្បន្ននៅក្នុងក្រុម ហើយសមត្ថភាពទាំងនោះ ជាតម្រូវការសម្រាប់អនាគត)។

### ៣.២.កម្រងសមត្ថភាពសម្រាប់ គ.ក.ន.ក/អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់

កម្រងសមត្ថភាព ញែកចំណេះដឹង និងជំនាញបច្ចេកទេសចេញពីសមត្ថភាពផ្នែកឥរិយាបថ (តារាងទី៣)។ ចំណេះដឹង និងជំនាញបច្ចេកទេស គឺ សំដៅទៅលើភាពជាក់ស្តែង ដែល គ.ក.ន.ក និងអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ត្រូវការមានចំណេះដឹងដើម្បីបំពេញការងាររបស់ខ្លួន។ ឧទាហរណ៍ ចំណេះដឹងអំពីច្បាប់ស្តីពីការគ្រប់

[៩] ការសិក្សាពីការអនុវត្តល្អបង្ហាញច្បាស់ថា នៅពេលដែលកម្មវិធីបណ្តុះបណ្តាលធ្វើឡើងដោយវិធីនេះ ហើយបានអនុវត្តនៅកន្លែងការងារ និងតាមដានការងារជាប្រចាំ នាំការរៀនសូត្រកាន់តែស៊ីជម្រៅ។

គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អត្ថន័យវិមជ្ឈការ សិទ្ធិកុមារ អាហាររូបត្ថម្ភ សុខភាពមាតា និងជំងឺអេដស៍។ វាជាការចាំបាច់ណាស់ដែលសមាជិក គ.ក.ន.ក និងអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ត្រូវដឹងខ្លះៗអំពីផ្នែកបច្ចេកទេសទាំងនោះ ពួកគេមិនចាំបាច់ត្រូវការចំណេះដឹងបច្ចេកទេសស៊ីជម្រៅនោះទេ។ លើសពីនេះទៅទៀត យើងសង្ឃឹមថា ឧទាហរណ៍ អ្នកតំណាងមណ្ឌលសុខភាព ឬក្រុមអ្នកទ្រទ្រង់សុខភាពភូមិ មានចំណេះដឹងជាក់លាក់ និងច្បាស់លាស់ជាងសមាជិក គ.ក.ន.ក។

### តារាងទី៣: សមត្ថភាពផ្នែកឥរិយាបថ ចំណេះដឹងផ្នែកបច្ចេកទេស និងផ្នែកជំនាញ របស់ គ.ក.ន.ក/អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់

| សមត្ថភាពផ្នែកឥរិយាបថ | ចំណេះដឹងផ្នែកបច្ចេកទេស និងជំនាញ |
|---|---|
| **ការគ្រប់គ្រងខ្លួនឯង**<br>១. បង្ហាញការគោរព<br>២. ការប្ដេជ្ញាចិត្ត<br>៣. ការទំនាក់ទំនងដោយមានប្រសិទ្ធភាព<br>• ការនិយាយ<br>• ការស្ដាប់<br>• ការសរសេររបាយការណ៍<br>៤. ការសម្របសម្រួល<br>**ការគ្រប់គ្រងទំនាក់ទំនង**<br>៥. ការងារជាក្រុម<br>៦. ការចរចា និងការមានឥទ្ធិពល<br>៧. ការលើកកម្ពស់ការសម្របសម្រួល និងកិច្ចសហការ<br>៨. ការតស៊ូមតិ<br>**ការគ្រប់គ្រងលទ្ធផលការងារ**<br>៩. ការធ្វើផែនការ និងការចាត់ចែង<br>១០. ការដោះស្រាយបញ្ហា<br>១១. ការគិតដោយវិភាគ និងការសម្រេច<br>១២. ការតាមដានត្រួតពិនិត្យ និងផែនការសកម្មភាព | ១. ការយល់ដឹងពីកំណែទម្រង់រដ្ឋបាល (ច្បាប់រៀបចំអង្គការ គោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ អភិបាលកិច្ចល្អ...) និងក្របខណ្ឌការងារ។<br>២. បញ្ហាតាមវិស័យរបស់ស្ត្រី និងកុមារ :<br>• ធ្វើឱ្យសិទ្ធិកុមារមានពិតប្រាកដ<br>• អាហាររូបត្ថម្ភ និងសុខភាពមាតា<br>• បញ្ហាសុខភាព និងកុមារ<br>• សិទ្ធិកុមារ និងការអប់រំ<br>• ទឹកស្អាត និងអនាម័យ<br>• កុមារងាយរងគ្រោះ និងកុមារត្រូវការកិច្ចការពារពិសេស<br>• ការកេងប្រវ័ញ្ច និងការរំលោភផ្លូវភេទ<br>៣. ជំងឺអេដស៍/ហ៊ីវ (ការយល់ដឹង និងការរើសអើង)<br>៤. អំពើហិង្សាក្នុងគ្រួសារ<br>៥. ទស្សនៈយេនឌ័រ :<br>• ការវិភាគយេនឌ័រ<br>• ការបញ្ជ្រាបយេនឌ័រ<br>• ច្បាប់ទប់ស្កាត់ការរើសអើងទៅលើស្ត្រី<br>• ការពង្រឹងអំណាច, ការចូលរួម និងការធ្វើសេចក្ដីសម្រេច<br>៦. ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃ |

សមត្ថភាពផ្នែកឥរិយាបថផ្ដោតទៅលើជំនាញជាក់លាក់ អាកប្បកិរិយា និងឥរិយាបថ គឺជាតម្រូវការ សម្រាប់ធ្វើការងារ។ សមត្ថភាពនេះរៀបរាប់អំពីរបៀបធ្វើការងារ និងអនុវត្តឱ្យបានសម្រេចទោះបីជាតិច ឬច្រើនដើម្បីឱ្យមានលក្ខណៈស្មើភាពគ្នាទៅគ្រប់សមាជិកគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់។

សមត្ថភាពផ្នែកឥរិយាបថ ត្រូវបានប្រមូលផ្ដុំជាបីក្រុមស្រដៀងគ្នា ដូចជា ការគ្រប់គ្រងខ្លួនឯង ការគ្រប់គ្រងទំនាក់ទំនង និងការគ្រប់គ្រងលទ្ធផលការងារ (គំនូសតាងទី២) ៖

- ការឱ្យតម្លៃផ្អែកលើសមត្ថភាពពីរគឺ ការគោរព និងការប្ដេជ្ញាចិត្តដែលជាចំណុចសំខាន់ក្នុងការ ***គ្រប់គ្រងខ្លួនឯង*** ព្រោះថាការឱ្យតម្លៃផ្អែកលើសមត្ថភាពទាំងពីរនេះជាប់ពាក់ព័ន្ធជាមួយសមត្ថភាពផ្សេងៗទៀត។ ***ការគោរព*** (ដូចជាបង្ហាញឱ្យឃើញតាមរយៈការយល់ចិត្តអ្នកដទៃ ស្ដាប់ដោយមិនមានការវិនិច្ឆ័យ ឬការរិះគន់ ការជ្រើសរើសសំណួរដើម្បីចំរាញ់យកព័ត៌មានដោយមិនមានការប្រមាថមើលងាយ ឬជាលក្ខណៈសួរចម្លើយ) គឺជាមូលដ្ឋានគ្រឹះក្នុងការសម្របសម្រួលប្រកបដោយប្រសិទ្ធភាព និងដើម្បីបង្កើតទំនាក់ទំនងដោយទុកចិត្តគ្នា។ ***ការប្ដេជ្ញាចិត្ត*** (ការឧទ្ទិស សេចក្ដីសប្បាយរីករាយ និងថាមពល) និងសមត្ថភាពក្នុងការលើកកម្ពស់ការយល់ដឹង និងភាពជាម្ចាស់ ត្រូវបានកំណត់ថាជាមូលដ្ឋានគ្រឹះដើម្បីបង្កើតភាពជឿជាក់ និងភាពជោគជ័យរបស់ គ.ក.ន.ក។ សមត្ថភាពពីរផ្សេងទៀតនៅក្នុងក្រុមនៃការគ្រប់គ្រងខ្លួនឯងគឺ ***ការប្រាស្រ័យទាក់ទង***ប្រកបដោយប្រសិទ្ធភាព (រួមទាំងការនិយាយ ការស្ដាប់ និងការសរសេររបាយការណ៍) និង***ការសម្របសម្រួល***។
- **ការគ្រប់គ្រងទំនាក់ទំនង** រួមមាន កសាងក្រុម ការចរចា និងការមានឥទ្ធិពល ការសម្របសម្រួល និងកិច្ចសហការ និងការតស៊ូមតិ។
- **ការគ្រប់គ្រងលទ្ធផលការងារ** រួមមាន ការធ្វើផែនការ និងការចាត់ចែង ការដោះស្រាយបញ្ហា ការគិតដោយវិភាគ និងការធ្វើសេចក្ដីសម្រេច ការតាមដានត្រួតពិនិត្យ និងសរសេររបាយការណ៍សម្រាប់ផែនការសកម្មភាព។

## គំនូសតាងទី២: កម្រងសមត្ថភាព



សមត្ថភាពនីមួយៗត្រូវបានកំណត់តាមរយៈចង្កោមឥរិយាបថដែលទាក់ទងនឹងការងាររបស់ គ.ក.ន.ក និងអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ (មើលនៅក្នុងឧបសម្ព័ន្ធ៣) ។

វាជាការសំខាន់ណាស់ក្នុងការបញ្ជាក់ថាសមត្ថភាពមានលក្ខណៈត្រួតគ្នា និងមានឥទ្ធិពលទៅវិញទៅមកជាមួយសមត្ថភាពផ្សេងៗទៀត ។ ឧទាហរណ៍ ការទាក់ទងប្រកបដោយប្រសិទ្ធភាព និងការគោរព គឺជាមូលដ្ឋានគ្រឹះនៃជំនាញសម្របសម្រួលដែលជួយគាំទ្រដល់ការចរចារ និងការមានឥទ្ធិពល ។ ការដោះស្រាយបញ្ហា និងការគិតបែបវិភាគ អាចឱ្យយើងចេះធ្វើការតាមដានត្រួតពិនិត្យ ចេះធ្វើរបាយការណ៍ និងចេះធ្វើផែនការសកម្មភាព និងលើកជាភស្តុតាងក្នុងការតស៊ូមតិ ។ ដូច្នេះ កម្មវិធីបណ្តុះបណ្តាលនឹងមិនបង្រៀនបុគ្គលឱ្យមានសមត្ថភាពដោយខ្លួនឯងនោះទេ ប៉ុន្តែជំនួសមកវិញដោយការប្រើប្រាស់កម្រងសមត្ថភាពដើម្បីពន្យល់ថា តើជំនាញ និងចំណេះដឹងអ្វីខ្លះដែលត្រូវការ ដើម្បីបំពេញមុខងារសំខាន់ៗទាំងនេះ ។

តារាងទី៤បង្ហាញពីរបៀបទំនាក់ទំនងរវាងសមត្ថភាពជាមួយនឹងតួនាទី និងការទទួលខុសត្រូវរបស់សមាជិក គ.ក.ន.ក និងអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ដែលបានកំណត់ក្នុងសេចក្តីណែនាំលេខ០៨២សណន/គ.ជ.វ.វ ចុះថ្ងៃទី ៨ ខែសីហា ឆ្នាំ២០០៧ របស់គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ។

### តារាងទី៤: សមត្ថភាពដែលទាក់ទងទៅនឹងតួនាទី និងការទទួលខុសត្រូវរបស់ គ.ក.ន.ក

| តួនាទី និងការទទួលខុសត្រូវសំខាន់ៗ | | លទ្ធផល | សមត្ថភាព |
|---|---|---|---|
| ១ | រៀបចំផែនការ និងថវិកាប្រចាំឆ្នាំសម្រាប់ គ.ក.ន.ក | ផែនការប្រចាំឆ្នាំរំលេចឱ្យឃើញពីតម្រូវការរបស់ស្ត្រី និងកុមារដែលបានកំណត់តាមរយៈការពិគ្រោះយោបល់ ។<br>សូចនាករ SMART (ជាក់លាក់ អាចវាស់វែង អាចធ្វើបាន ពិតប្រាកដ និងក្នុងរយៈពេលមួយកំណត់) កំណត់ឱ្យច្បាស់លាស់ពីថវិកាសម្រាប់អភិវឌ្ឍន៍ ។ | • ការធ្វើផែនការ និងការចាត់ចែង<br>• ការធ្វើការងារជាក្រុម<br>• ការទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព |
| ២ | ផ្តល់យោបល់ និងជួយក្រុមប្រឹក្សាឃុំ សង្កាត់ និងមេឃុំ ចៅសង្កាត់លើការងារពាក់ព័ន្ធបញ្ហានារី និងកុមារ | មេឃុំ ចៅសង្កាត់ អាចមានសមត្ថភាពបង្ហាញបញ្ហាពាក់ព័ន្ធនារី និងកុមារក្នុងវេទិកាសាធារណៈនៅថ្នាក់ខេត្ត និងស្រុក<br>ផ្លាស់ប្តូរការប្រើប្រាស់ថវិកាឃុំ សង្កាត់ដោយបង្កើនការចំណាយថវិកាទៅលើគម្រោងអភិវឌ្ឍន៍ផ្នែកសេវាសង្គម | • ទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព<br>• ការចរចារ និងការមានឥទ្ធិពល<br>• ការយល់ដឹងអំពីផ្នែកបច្ចេកទេស |

| | | | |
|---|---|---|---|
| ៣ | លើកឡើងពីការយល់ដឹងអំពីច្បាប់ និងសិទ្ធិផ្សេងៗពាក់ព័ន្ធសិទ្ធិនារី និងកុមារ នៅឃុំ សង្កាត់ ចលនាសហគមន៍ ឬអ្នកផ្តល់សេវា នានាលើវិស័យសុខភាព អប់រំ កិច្ចការពារកុមារ ការអភិវឌ្ឍន៍កុមារ និងការចុះបញ្ជីកំណើតកុមារ | ការចាក់ថ្នាំបង្ការប្រាំពីរមុខដល់កុមារ ស្ត្រីសម្រេចចិត្តក្នុងការផ្តល់ព័ត៌មាន និង រាយការណ៍ពីករណីអំពើហឹង្សាក្នុងគ្រួសារ | • ទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព<br>• បណ្តាញការងារ<br>• ការតាមដានត្រួតពិនិត្យ និងរាយការណ៍សម្រាប់ផែនការសកម្មភាព<br>• ការងារជាក្រុម |
| ៤ | តស៊ូមតិដើម្បីឱ្យស្ត្រីបានចូលរួម ក្នុងការធ្វើសេចក្តីសម្រេច | បង្កើនចំនួននៃការចូលរួមរបស់ស្ត្រីទៅក្នុង វេទិកាសាធារណៈ<br>បញ្ហាស្ត្រីត្រូវបានបញ្ចូលគ្រប់គ្រាន់ទៅក្នុង កម្មវិធីវិនិយោគឃុំ សង្កាត់ | • ការតស៊ូមតិ<br>• ការសម្របសម្រួល<br>• ការប្តេជ្ញាចិត្ត |
| ៥ | បង្កើន និងពង្រឹងការទំនាក់ទំនង កិច្ចសហការ និងការសម្រប សម្រួលក្នុងចំណោមក្រុមប្រឹក្សា ឃុំ សង្កាត់ អ្នកផ្តល់សេវា និង អ្នកភូមិ | សកម្មភាពផ្នែកសេវាសង្គមមានគោលដៅ ទៅលើភូមិដោយផ្អែកទៅលើការវិភាគ ទិន្នន័យ និងកំណត់ពីក្រុមងាយរងគ្រោះ និងក្រុមដែលមិនសូវបានគេយកចិត្តដាក់ | • លើកកម្ពស់ការសម្រប សម្រួល និងកិច្ចសហការ<br>• ការដោះស្រាយបញ្ហា |
| ៦ | ជួយក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការ ប្រមូល និងវិភាគព័ត៌មាន/ទិន្នន័យ ដែលទាក់ទងនឹងតម្រូវការរបស់ នារី និងកុមារ ហើយដាក់បញ្ចូល ព័ត៌មានទាំងនោះទៅក្នុងផែនការ អភិវឌ្ឍន៍ និងកម្មវិធីវិនិយោគ របស់ឃុំ សង្កាត់ | បញ្ហាអាទិភាពបានកំណត់ក្នុងផែនការ អភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ សង្កាត់ ដោយរំលេចបញ្ហាទាក់ទងជាមួយនារី និង កុមារ ដូចដែលបានកំណត់តាមរយៈដំណើរ ការពិគ្រោះយោបល់<br>បង្កើនការទទួលបានសេវាសម្រាប់ជនងាយ រងគ្រោះបំផុត | • ការធ្វើផែនការ និង ការចាត់ចែង<br>• ការគិតបែបវិភាគ និង ការធ្វើសេចក្តីសម្រេច<br>• ការតាមដានត្រួតពិនិត្យ កម្មវិធីវិនិយោគឃុំ សង្កាត់ និងផែនការស្រុក |
| ៧. | ចូលរួមក្នុងការអនុវត្តគម្រោង, ការតាមដានត្រួតពិនិត្យ និងការ វាយតម្លៃផែនការសកម្មភាពឃុំ សង្កាត់ពាក់ព័ន្ធនារី និងកុមារ | លើកទឹកចិត្តឱ្យមានតម្រូវការប្រើប្រាស់ សេវា ឧ. សេវាទឹកស្អាត និងអនាម័យ នៅ តាមសាលារៀន និងមណ្ឌលសុខភាព មាន ដំណើរការល្អ | • ការទំនាក់ទំនងប្រកប ដោយប្រសិទ្ធភាព<br>• ការដោះស្រាយបញ្ហា<br>• ការគិតបែបវិភាគ |

| | | | |
|---|---|---|---|
| ៨ | តាមដានត្រួតពិនិត្យស្ថានភាពរបស់នារី និងកុមារនៅក្នុងឃុំ សង្កាត់ និងរាយការណ៍ (តាមរយៈរបាយការណ៍ផ្ទាល់មាត់ និងរបាយការណ៍ជាលាយលក្ខណ៍អក្សរ) ឱ្យបានទៀងទាត់ទៅក្រុមប្រឹក្សាឃុំ សង្កាត់ | មានសមភាពយេនឌ័រនៅក្នុងដំណើរការកសាងផែនការឃុំ សង្កាត់<br>ថ្នាក់ស្រុកត្រូវមានកាលបរិច្ឆេទជាក់លាក់ដើម្បីជូនដំណឹងពីការរីកចម្រើន នៃការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ | • ការតាមដានត្រួតពិនិត្យ និងការសរសេររបាយការណ៍សម្រាប់ផែនការសកម្មភាព<br>• ការសម្របសម្រួល<br>• ការទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព |

## ៣.៣. ឧបករណ៍សិក្សាវាយតម្លៃខ្លួនឯង

ការប្រើប្រាស់សមត្ថភាពឱ្យមានប្រយោជន៍ គឺត្រូវបង្កើតឧបករណ៍សិក្សាវាយតម្លៃសមត្ថភាពខ្លួនឯងយ៉ាងសាមញ្ញមួយ ដែល គ.ក.ន.ក/អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ អាចប្រើប្រាស់ដើម្បីសិក្សាវាយតម្លៃចំណុចខ្លាំងរបស់ខ្លួន និងកំណត់ពីចំណុចកង្វះចន្លោះផ្នែកសមត្ថភាព។

**ឧទាហរណ៍** សមត្ថភាពក្នុង***ការកសាងផែនការ និងការចាត់ចែង*** គ.ក.ន.ក ត្រូវឆ្លុះបញ្ចាំងទៅនឹងផែនការប្រចាំឆ្នាំកាលពីឆ្នាំមុន មុននឹងកសាងផែនការឆ្នាំថ្មី ដូចខាងក្រោម :

| ការកសាងផែនការ និងការចាត់ចែង | ចាស/ទេ |
|---|---|
| ***ការប្រមូលទិន្នន័យ:***<br>តើយើងបានធ្វើការពិគ្រោះយោបល់ជាមួយសមាជិកសហគមន៍ និងគណៈកម្មាធិការនានាបានឬទេ? | |
| តើយើងបានទទួលព័តិមានអំពីការកសាងផែនការឃុំ សង្កាត់ ថវិកា និងការចំណាយដែរឬទេ? | |
| តើយើងបានប្រើប្រាស់ព័តិមានទាំងនោះដើម្បីកំណត់បញ្ហាសំខាន់ៗសម្រាប់ការផ្តល់សេវាឱ្យមានប្រសិទ្ធភាពដែរឬទេ? | |
| ***ការបង្កើតផែនការ និងថវិកាប្រចាំឆ្នាំ:***<br>តើយើងបានប្រើប្រាស់ព័តិមានទាំងនោះដើម្បីរៀបចំផែនការសកម្មភាពប្រចាំឆ្នាំដែរឬទេ? | |
| តើផែនការនេះមានបញ្ចូលខ្ទាតសម្រាប់វាស់សមិទ្ធផលដែរឬទេ? | |
| តើយើងបានរៀបចំថវិកាដែលអាចប្រើប្រាស់បាននៅពេលអនុវត្តផែនការដែរឬទេ? | |
| តើយើងបានដាក់ផែនការ និងថវិកាប្រចាំឆ្នាំជូនទៅក្រុមប្រឹក្សាឃុំ សង្កាត់ទាន់ពេលដែរឬទេ? | |

| | |
|---|---|
| ***ការអនុវត្ត និងការតាមដានត្រួតពិនិត្យផែនការ:*** <br> តើយើងបានចាត់អាទិភាពកិច្ចការដែរឬទេ? (អ្វីត្រូវធ្វើមុនគេ? អ្វីត្រូវធ្វើបន្ទាប់?) | |
| តើយើងបានបំពេញការងារនោះទាន់ពេល និងត្រូវតាមខ្ទង់ថវិកាដែលមានដែរឬទេ? | |
| តើយើងបានកត់ត្រាទុកនូវសកម្មភាពសំខាន់ៗ លទ្ធផល និងថវិកាចំណាយផ្សេងៗកន្លងទៅ បានទៀងទាត់ដែរឬទេ? | |

ស្រដៀងគ្នាដែរ នៅក្នុងសមត្ថភាពក្នុងការ***សម្របសម្រួល*** សមាជិកម្នាក់ៗ អាចវាយតម្លៃថា តើពួកគាត់បាន និងកំពុងចាត់ចែង និងសម្របសម្រួលកិច្ចប្រជុំបានល្អយ៉ាងដូចម្តេច ៖

| **ដំណើរការកិច្ចប្រជុំប្រកបដោយជោគជ័យ** | **ចាស/ទេ** |
|---|---|
| តើខ្ញុំអាចបង្កើតរបៀបវារៈ កំណត់គោលបំណង និង លទ្ធផលរំពឹងទុកសម្រាប់ការប្រជុំមួយដែរឬទេ? | |
| តើខ្ញុំប្រើពេលវេលាយ៉ាងដូចម្តេចនៅក្នុងអំឡុងពេលប្រជុំ ដើម្បីធ្វើឱ្យប្រាកដថាប្រធានបទសំខាន់ជាងគេត្រូវបានផ្តល់អាទិភាពខ្ពស់? | |
| តើខ្ញុំអាចសង្ខេបការពិភាក្សា និងការសម្រេចដែលបានឯកភាពបន្ទាប់ពីចប់របៀបវារៈនីមួយៗបានដែរឬទេ? | |
| តើខ្ញុំដឹងពីរបៀបបង្កើតវិន័យងាយៗ និងច្បាស់លាស់ចំនួន ៣-៤ ចំណុចបានដែរឬទេ? | |
| តើខ្ញុំអាចត្រួតពិនិត្យលំហូព័ត៌មាន (ការធ្វើឱ្យអង្គប្រជុំប្រព្រឹត្តទៅតាមការគ្រោង និងទាន់ពេល) បានដែរឬទេ? | |
| តើខ្ញុំអាចធ្វើឱ្យប្រាកដថា អ្នកចូលរួមម្នាក់ៗអាចចែករំលែកមតិយោបល់ (ដែលគ្មានអ្នកណាម្នាក់គ្របលើអ្នកណាម្នាក់) ដែរឬទេ? | |
| តើខ្ញុំបង្ហាញពីការអំណត់ និងទឹកចិត្តចង់ស្តាប់ទស្សនៈសិក្ខាកាមគ្រប់ៗគ្នាដែរឬទេ? | |

## ផ្នែកទី៤: យុទ្ធសាស្ត្រអភិវឌ្ឍសមត្ថភាពដែលបានស្នើឡើង

ប្រភេទនៃការរៀនសូត្រតែមួយគត់ដែលមានឥទ្ធិពលយ៉ាងខ្លាំងទៅលើឥរិយាបថនោះ គឺការស្វែងយល់ដោយខ្លួនឯង ឬការរៀនសូត្រដ៏សមស្របសម្រាប់ខ្លួនឯង ហើយជាការពិត ប្រភេទនៃការរៀនសូត្របែបនេះ ត្រូវបានចាត់ទុកដូចជាបទពិសោធន៍ផ្ទាល់ខ្លួន។

### ៤.១.វិធីសាស្ត្ររៀនសូត្រតាមបែបសិស្សមជ្ឈមណ្ឌល

ការរៀនសូត្រ គឺជាដំណើរការមួយដែលចេញមកពីតម្រូវការដើម្បីឱ្យមានបទពិសោធន៍ ដើម្បីកាត់បន្ថយភាពស្រពេចស្រពិល ដើម្បីបង្កើតសមត្ថភាព និងដើម្បីតម្រូវទៅនឹងការផ្លាស់ប្តូរការងារថ្មី។ ការរៀនសូត្រ គឺជាការទទួលបានព័ត៌មានថ្មីៗ និងស្វែងរកវិធីសាស្ត្រថ្មីដើម្បីប្រើប្រាស់ព័ត៌មានទាំងនោះ។ បទពិសោធន៍ ចំណេះដឹង និងជំនាញរបស់យើងដែលមានស្រាប់ អាចប៉ះពាល់ដល់របៀបដែលយើងរៀន។ មនុស្សពេញវ័យនៅកម្ពុជាដែលមានការយល់ដឹងអំពីទស្សនៈវិមជ្ឈការ និងអភិបាលកិច្ច គឺជាមនុស្សមានឥទ្ធិពលដោយសារមានបទពិសោធន៍ពីសម័យមុន ពីគោលនយោបាយរបស់រដ្ឋាភិបាល និងអ្នកដឹកនាំសម័យមុនជាដើម។ បុគ្គលនីមួយៗមានបទពិសោធន៍ខុសៗគ្នា។ បទពិសោធន៍មិនល្អមួយរបស់មេឃុំ ចៅសង្កាត់នៅអតីតកាល អាចធ្វើឱ្យមនុស្សម្នាក់មើលឃើញពីភាពអវិជ្ជមាននៃអភិបាលកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ រួមទាំងតួនាទី និងការទទួលខុសត្រូវរបស់ គ.ក.ន.ក ផងដែរ ហើយបទពិសោធន៍ល្អអាចមើលឃើញពីភាពវិជ្ជមាននៃអភិបាលកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់។

ការប្រឈមរបស់អ្នកសម្របសម្រួលដែលបានទទួលស្គាល់នោះគឺ:

-កិច្ចខិតខំប្រឹងប្រែងបង្កើនសមត្ថភាព ត្រូវចេះសម្របសម្រួលពីការរៀនសូត្ររបស់មនុស្សពេញវ័យ និងចេះប្រើប្រាស់វិធីសាស្ត្រតាមលំដាប់ដើម្បីបង្កើតបរិយាកាសដែលមានការលើកទឹកចិត្ត និងការរៀនសូត្រឱ្យបានស៊ីជម្រៅ។

-កិច្ចខិតខំប្រឹងប្រែងបង្កើនសមត្ថភាព ត្រូវផ្តោតលើការរុករកព័ត៌មានថ្មីៗ (ដូចជា ទស្សនៈស្តីពីវិមជ្ឈការ) ព្រមទាំងចេះនិយាយពីរបៀបប្រើប្រាស់ព័ត៌មានទាំងនោះនៅកន្លែងធ្វើការរបស់ពួកគេ។

នៅក្នុងផ្នែកទី ១.៤.២ បានពិភាក្សាពីប្រវត្តិសាស្ត្រ នយោបាយ វប្បធម៌សង្គម និងកត្តាទាំងឡាយ ដែលជះឥទ្ធិពលដល់ការគិតរបស់បុគ្គល និងឆ្លើយតបទៅនឹងគំនិតផ្តួចផ្តើមក្នុងការអភិវឌ្ឍសមត្ថភាព ដោយសន្និដ្ឋានទុកថា (ក) គំនិតផ្ទុយគ្នារវាងវប្បធម៌ និងការឱ្យតម្លៃនេះ ត្រូវបានកំណត់ និងនិយាយឱ្យបានច្បាស់លាស់នៅក្នុងកម្មវិធីអភិវឌ្ឍសមត្ថភាព និង(ខ) កម្មវិធីអភិវឌ្ឍសមត្ថភាព ត្រូវផ្តោតជាសំខាន់លើការរៀនសូត្រដែលមានន័យថា ជាការអនុវត្តជំនាញ អាកប្បកិរិយា និងឥរិយាបថនៅក្នុងការបំពេញការងារ។

នៅក្នុងផ្នែកទី ២-៣ បានបង្ហាញពីការប្រឈមក្នុងការអភិវឌ្ឍសមត្ថភាពជាក់លាក់ដែលលេចចេញពីការស្រាវជ្រាវនេះ ជាពិសេស ការប្រើប្រាស់វិធីសាស្ត្រពិគ្រោះយោបល់ដើម្បីរៀនសូត្រដែលលើកទឹកចិត្តឱ្យមានការចូលរួម និងបច្ចេកទេសងាយៗ (ដោយមិនបាត់បង់ខ្លឹមសារ) និងការរៀនសូត្រដោយមានការពិភាក្សា។ តារាងទី១ និងទី២ ផ្តល់

ឧទាហរណ៍ពីរបៀបនៃដំណាក់កាលរៀនសូត្រ និងការកើតមានឡើងនៃភាពរីកចម្រើនផ្នែកសមត្ថភាព។ ផ្នែកបន្ទាប់ពិពណ៌នាពីវិធីសាស្ត្រជាច្រើនសម្រាប់អភិវឌ្ឍសមត្ថភាពដែលបានលើកឡើងពីការប្រឈមនៅផ្នែកទី ១.៤ និង ២.៣។

## ៤.២.ការអនុវត្តល្អនាពេលបច្ចុប្បន្ន

### ៤.២.១.វេទិការៀនសូត្រ

អង្គការមិនមែនរដ្ឋាភិបាល ដូចជា អង្គការចំរើនស្ត្រី បានរួមចំណែកក្នុងការអភិវឌ្ឍសមត្ថភាពរបស់ គ.ក.ន.ក និងដៃគូអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាលនៅក្នុងខេត្តគោលដៅទាំងប្រាំមួយដែលគាំទ្រដោយកម្មវិធីសិទ្ធិកុមារ នៃអង្គការយូនីសេហ្វ។ គោលបំណងរួម គឺដើម្បីពង្រឹងទំនាក់ទំនងរវាងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ និងអ្នកផ្តល់សេវានៅក្នុងមូលដ្ឋានក្នុងគោលដៅដើម្បីលើកកម្ពស់គុណភាពសេវានៅមូលដ្ឋាន និងសមត្ថភាពរបស់សមាជិក គ.ក.ន.ក ផងដែរ។

ការធ្វើអន្តរាគមន៍បែបនេះ បានប្រតិបត្តិនៅពីរកម្រិត :

ទី១.អង្គការចំរើនស្ត្រី បានផ្តល់ការបណ្តុះបណ្តាលគ្រូបង្គោល ដល់មន្ត្រីរដ្ឋាភិបាល ដូចជា មន្ត្រីអង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត អ្នកសម្របសម្រួលខេត្ត ស្រុក មន្ត្រីបង្គោលកម្មវិធីសិទ្ធិកុមារខេត្ត ស្រុក និងមន្ត្រីមន្ទីរកិច្ចការនារី ក្នុងខេត្តគោលដៅរបស់កម្មវិធីសិទ្ធិកុមារនៃអង្គការយូនីសេហ្វ។ តាមរយៈការបណ្តុះបណ្តាលនេះ អ្នកសម្របសម្រួលផ្តល់ការបណ្តុះបណ្តាលបន្តដល់ គ.ក.ន.ក និងអ្នកទទួលបន្ទុកកិច្ចការនារី និង កុមារឃុំ សង្កាត់នៅថ្នាក់ឃុំ សង្កាត់។ ហើយវគ្គបណ្តុះបណ្តាលទាំងនេះ ជាប់ទាក់ទងទៅនឹងសមត្ថភាពបីគឺ:

- ***ការធ្វើផែនការ និងការចាត់ចែង*** ជាពិសេសគឺមានទំនាក់ទំនងជាមួយការធ្វើផែនការ និងការសម្របសម្រួលវេទិការៀនសូត្រ
- ***ជំនាញសម្របសម្រួល***ដោយផ្តោតលើទំនុកចិត្តខ្លួនឯង ការលើកទឹកចិត្តឱ្យក្នុងការអនុវត្តគំនិតច្នៃប្រឌិត ការលើកកម្ពស់ឱ្យមានការចូលរួម និងការបញ្ចេញមតិ ការស្តាប់ដោយយកចិត្តទុកដាក់ និងដោយគ្មានការរើសអើង និងដឹកនាំឱ្យមានការផ្តល់ព័ត៌មានត្រលប់ និងការប្រជុំវាយតម្លៃ
- ***ការកំណត់បញ្ហា និងដំណោះស្រាយ*** ។

ទី២. អង្គការចំរើនស្ត្រីបានដឹកនាំវេទិកាផ្ទាល់ជាមួយ គ.ក.ន.ក ផ្សេងៗពីគ្នា។ វេទិកានេះ បានផ្តល់ឱកាសដល់សមាជិក គ.ក.ន.ក ដើម្បីបញ្ជាក់នូវសំណួរមួយចំនួនដែលទាក់ទងនឹងតួនាទី និងភារកិច្ចរបស់ខ្លួន ការរើសអើងចំពោះស្ត្រី និងការងារទាក់ទងនឹងអំពើហិង្សាក្នុងគ្រួសារ។ ទន្ទឹមនឹងនេះ ក៏មានការបញ្ចូលផងដែរនូវជំនាញ ដូចជា ការធ្វើការងារជាក្រុមឱ្យមានប្រសិទ្ធភាព និងភាពជាអ្នកដឹកនាំ ការកំណត់បញ្ហា ការដោះស្រាយបញ្ហា ការធ្វើផែនការសកម្មភាព ការដឹកនាំកិច្ចប្រជុំប្រកបដោយប្រសិទ្ធភាព ការសរសេររបាយការណ៍ និងរបៀបកសាងភាពជាដៃគូជាមួយអ្នកដ៏ទៃ។

វេទិកាដែលផ្តល់ដោយអង្គការចំរើនស្ត្រី គឺមានលក្ខណៈល្អដោយសារបញ្ចូលនូវជំនាញអនុវត្ត (ការធ្វើផែនការ និងរៀបចំដោះស្រាយបញ្ហា) និងការយល់ដឹងអំពីបច្ចេកទេស(ឧទាហរណ៍ វិមជ្ឈការ និងអំពើហឹង្សាផ្អែកលើយេនឌ័រ) ជាមួយជំនាញសម្របសម្រួលដែលបង្កើនឱ្យមានទំនុកចិត្ត និងអនុវត្តដោយការឆ្លុះបញ្ចាំង។ វេទិកានេះ ផ្តោតទៅលើ

ការរៀនសូត្រ (ជាជាងការនិយាយប្រាប់)និងតាមគោលការណ៍សំខាន់ៗ (ការឱ្យតម្លៃខ្លួនឯង ការបញ្ចេញមតិយោបល់ ការចូលរួម និងការស្តាប់ដោយយកចិត្តទុកដាក់ ។ល ។) គឺជាតម្រូវចាំបាច់សម្រាប់ការពិគ្រោះយោបល់នៅសហគមន៍ ។

អង្គការចំរើនស្ត្រី ក៏បានអនុវត្តវិធីសាស្ត្រស្រដៀងគ្នានេះផងដែរក្នុងការធ្វើការងារជាមួយក្រុមប្រឹក្សាឃុំជាស្ត្រី និងបង្ហាត់បង្ហាញសិក្ខាកាមនូវជំនាញនីមួយៗ ហើយទាញយកនូវការគាំទ្រជាបន្តបន្ទាប់(**Ferber and Puthy,2008**) ។ នេះគឺជាការកត់សម្គាល់ជាទូទៅថា កម្មវិធីបណ្តុះបណ្តាល មិនមានការតាមដានត្រួតពិនិត្យ ឬ ការបង្ហាត់បង្ហាញបន្តនោះទេ (**MacKay,2009**) ។ ទោះបីជាយ៉ាងណាក៏ដោយ ការសិក្សាពី"**ការអនុវត្តល្អ**" បានបង្ហាញថា វិធីសាស្ត្រ នៃការបណ្តុះបណ្តាលទ្វេគុណ និងការរៀនបណ្តើរធ្វើបណ្តើរ បង្កើនឱ្យមានទំនុកចិត្ត និងមានការរៀនសូត្រប្រកបដោយការគិតពិចារណាយ៉ាងស៊ីជម្រៅ (សូមមើលឧទាហរណ៍របស់ **VBNK, 2008**) ។

## ៤.២.២.ការអភិវឌ្ឍជំនាញសម្របសម្រួលសម្រាប់ស្ត្រីជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់

គណៈកម្មាធិការលើកកម្ពស់សមត្ថភាពស្ត្រីក្នុងវិស័យនយោបាយ (**CPWP**) គឺជាគណៈកម្មាធិការមួយដែលបង្កើតឡើងដោយអង្គការក្នុងស្រុកចំនួន៧ ក្នុងនោះរួមមាន អង្គការចំរើនស្ត្រី(**WfP**), អង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា(**GAD/C**), សមាគមនារីដើម្បីសន្តិភាពនិងអភិវឌ្ឍន៍(**CWPD**), សីលការ(**SILAKA**), វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា(**CDRI**), គណៈកម្មាធិការអព្យាក្រឹត្យ និងយុត្តិធម៌ដើម្បីបោះឆ្នោតដោយសេរី និងត្រឹមត្រូវនៅកម្ពុជា(**NECFFEC**), គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងត្រឹមត្រូវនៅកម្ពុជា (**COMFREL**) ។ គណៈកម្មាធិការនេះ មានគោលបំណងដើម្បីរួមចំណែកក្នុងការបង្កើតបរិយាកាសជាវិជ្ជមានមួយសម្រាប់ការចូលរួមរបស់ស្ត្រីក្នុងវិស័យសាធារណៈ ។ ការអន្តរាគមន៍មានគោលដៅតម្រង់ទៅអ្នកគ្រប់គ្រងនៅថ្នាក់មូលដ្ឋាន ថ្នាក់ខេត្ត ថ្នាក់ជាតិ និងថ្នាក់ដឹកនាំគណៈបក្សនយោបាយនានា បេក្ខជនជាស្ត្រីដែលមានសក្តានុពល និងអ្នកបោះឆ្នោតរួមទាំងសាធារណៈជនទូទៅ ។ គណៈកម្មការលើកកម្ពស់សមត្ថភាពស្ត្រីក្នុងវិស័យនយោបាយ ត្រូវបានបង្កើតឡើង នៅខែវិច្ឆិកា ឆ្នាំ២០០៥ នៅពេលដែលក្រុមនៃអង្គការក្នុងស្រុកទាំង៧ បានជួបគ្នា និងពិភាក្សាពីរបៀបដោះស្រាយផលប៉ះពាល់សំខាន់ៗ និងរបៀបធ្វើឱ្យសម្រេចនូវកិច្ចការរបស់ខ្លួន ។ ក្នុងចំណោមសកម្មភាពជាច្រើននេះ គណៈកម្មការលើកកម្ពស់សមត្ថភាពស្ត្រីក្នុងវិស័យនយោបាយ បានផ្តល់វគ្គបណ្តុះបណ្តាលដល់ក្រុមប្រឹក្សាឃុំ សង្កាត់ជាស្ត្រី ដែលទើបនឹងជាប់ឆ្នោតដើម្បីប្រើប្រាស់វិធីសាស្ត្រដែលផ្តល់ការបណ្តុះបណ្តាលជំនាញក្នុងការអនុវត្តការងារ និងការធ្វើការងារ ដោយមានទំនុកចិត្ត និងការគោរពខ្លួនឯង(**CPWP,2008**) ។ វិធីសាស្ត្រនេះ អាចអនុវត្តបានក្នុងការកសាងទំនុកចិត្ត និងសមត្ថភាព ហើយបញ្ចូលគ្នារវាងការបង្ហាត់បង្ហាញ និងការណែនាំ ។ មានភស្តុតាងបញ្ជាក់ថា វគ្គបណ្តុះបណ្តាលរបស់គណៈកម្មការលើកកម្ពស់សមត្ថភាពស្ត្រីក្នុងវិស័យនយោបាយ កសាងបាននូវទំនុកចិត្ត និងភាពជោគជ័យចំពោះស្ត្រីដែលជាបេក្ខជន (**Storer,2007**) ។

ការគាំទ្រ ការកសាងសមត្ថភាព និងការណែនាំ ដែលផ្តល់ដោយគណៈកម្មការលើកកម្ពស់សមត្ថភាពស្ត្រីក្នុងវិស័យនយោបាយដល់ស្ត្រីជាបេក្ខជនបានជួយឱ្យមានការអភិវឌ្ឍសក្តានុពលរបស់ពួកគេ ។ លើសពីនេះទៅទៀត វេទិកាសាធារណៈ ដែលរៀបចំឡើងដោយគណៈកម្មការលើកកម្ពស់សមត្ថភាពស្ត្រីក្នុងវិស័យនយោបាយ បានបង្កើនការយល់

ដឹង និងគាំទ្រចំពោះស្ត្រីដែលធ្វើការនៅតាមការិយាល័យ ។ វេទិកាទាំងនេះ ត្រូវបានរៀបចំជារចនាសម្ព័ន្ធឡើងដើម្បីភ្ជាប់ទំនាក់ទំនងជាមួយសាធារណៈជនសំខាន់ពីរប្រភេទ : សាធារណៈជនដែលមានការចាប់អារម្មណ៍ជាក់លាក់នៅក្នុងការពិភាក្សាពីការចូលរួមរបស់ស្ត្រីក្នុងវិស័យនយោបាយព្រមទាំងការចូលរួមរបស់សហគមន៍ទូទៅផងដែរ ។ ការធ្វើតាមរបៀបជាវេទិកានេះ អាចជួយបង្កើនឱ្យមានការទទួលស្គាល់ទូលាយក្នុងចំណោមសហគមន៍ ចំពោះការចូលរួមរបស់ស្ត្រី នៅក្នុងវិស័យនយោបាយ ។

## ៤.២.៣.កិច្ចសន្ទនាសហគមន៍

នៅខណៈពេលដែលកិច្ចសន្ទនាសហគមន៍ ពុំទាន់មានលក្ខណៈជាការខិតខំប្រឹងប្រែងក្នុងការកសាងសមត្ថភាពសម្រាប់ គ.ក.ន.ក ប៉ុន្តែវាជាការទំនាក់ទំនងគ្នា ពីព្រោះវិធីសាស្ត្រនេះជួយពង្រឹងនូវទំនាក់ទំនងសង្គមឱ្យកាន់តែរឹងមាំឡើងតាមរយៈដំណើរការពិគ្រោះយោបល់ដែលនាំឱ្យមានការផ្លាស់ប្តូរនូវគំនិតផ្សេងៗគ្នា ដែលអ្នកចូលរួមបានស្តាប់ និងរៀនសូត្រពីគ្នាទៅវិញទៅមក ព្រោះកិច្ចសន្ទនាសហគមន៍ប្រើប្រាស់ចំណេះដឹងមូលដ្ឋានដែលមានស្រាប់ដើម្បីបង្កើននូវទំនុកចិត្ត និងភាពជាម្ចាស់ ។

អង្គការចំរើនស្ត្រី បានរៀបចំកិច្ចសន្ទនាប្រចាំឆ្នាំជាមួយសហគមន៍តាំងពីឆ្នាំ២០០៧មកម្លេះ(VBNK,2009) ។ កិច្ចសន្ទនានីមួយៗបានធ្វើឡើងដោយមានក្រុមយុវជន និងមនុស្សចាស់ចំរុះគ្នាមកពីសហគមន៍ ព្រមទាំងមន្ត្រីរដ្ឋាភិបាល និងបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការគាំទ្រកិច្ចអភិវឌ្ឍផ្នែកសង្គម ។ អង្គការចំរើនស្ត្រីបានរកឃើញថា កិច្ចសន្ទនាសហគមន៍អនុញ្ញាតឱ្យអ្នកដែលមិនអាចធ្វើការទំនាក់ទំនងបានពីមុនមក អាចធ្វើការទំនាក់ទំនងគ្នាបាន ។ វិធីសាស្ត្រចូលរួមជួយជំរុញឱ្យមានទំនុកចិត្ត និងធ្វើឱ្យសហគមន៍អាចកំណត់គោលដៅផ្ទាល់ខ្លួន ចំពោះអ្វីដែលត្រូវធ្វើឱ្យសម្រេចបានជោគជ័យ ។ កត្តាទាំងនេះ ជំរុញឱ្យមានផែនការជាបន្តបន្ទាប់ដើម្បីធ្វើឱ្យសង្គមមានការផ្លាស់ប្តូរ ។

វិធីសាស្ត្រដែលគាំទ្រដល់កិច្ចសន្ទនាសហគមន៍នេះ ផ្អែកលើគោលការណ៍ដំណើរការសន្ទនាដូចខាងក្រោម:

**-ការបង្កើតទំនាក់ទំនងដោយមានទំនុកចិត្តគ្នាទៅវិញទៅមក** ការយោគយល់គ្នា និងការគោរពចំពោះសហគមន៍គឺជាមូលដ្ឋានគ្រឹះនៃកិច្ចសន្ទនាសហគមន៍ ។ កត្តាជោគជ័យដ៏សំខាន់នោះ គឺអ្នកសម្របសម្រួល បង្កើតការទទួលស្គាល់តម្លៃសហគមន៍តាមរយៈការស្តាប់ដោយយកចិត្តទុកដាក់ ជំនាញក្នុងការសួរសំណួរ និងធ្វើសកម្មភាពដែលអនុញ្ញាតឱ្យមានការចូលរួម និងការបញ្ចេញមតិយោបល់ ។

**-ការកំណត់ពីការព្រួយបារម្ភរបស់សហគមន៍** មានន័យថា សហគមន៍អាចកំណត់ពីតម្រូវការ និងការព្រួយបារម្ភផ្ទាល់ខ្លួនបាន ហើយអ្នកសម្របសម្រួលដើរតួនាទីជាអ្នកប្រាប់ផ្លូវពួកគេតាមរយៈការសួរសំណួរ ដោយមិនកាត់យោបល់របស់ពួកគេឡើយ ។

**-ការព្រួយបារម្ភដែលបានកំណត់** ត្រូវបានធ្វើតាមរយៈការស្វែងរកដោយហ្មត់ចត់ ដែលនាំឱ្យមានការយល់ដឹងកាន់តែស៊ីជម្រៅអំពីកត្តានៅពីក្រោយបញ្ហាដែលរួមចំណែកក្នុងការកំណត់ពីការព្រួយបារម្ភ ។

**-ការធ្វើសេចក្តីសម្រេចចិត្ត និងការធ្វើផែនការ** ត្រូវបានធ្វើតាមរយៈការសួរសំណួរមូលដ្ឋាន ដូចជា"ធ្វើអ្វីខ្លះ? ធ្វើរបៀបណា? ពេលណា? កន្លែងណា? នរណាខ្លះ?"នៅក្នុងការសម្រេចនីមួយៗ ។

-**ការឆ្លុះបញ្ចាំង និងការពិនិត្យមើលឡើងវិញ**ត្រូវបានរៀបចំលំអិតនៅក្នុងដំណើរការទាំងមូល។ រាល់កិច្ចប្រជុំសហគមន៍បញ្ចប់ដោយធ្វើការឆ្លុះបញ្ចាំង និងសង្ខេបលទ្ធផល។ តួយ៉ាងការប្រជុំចាប់ផ្តើមជាមួយការសរុបលទ្ធផលដែលព្រមព្រៀងនៅក្នុងកិច្ចប្រជុំលើកមុនជាដើម។

កិច្ចសន្ទនាសហគមន៍បានបង្ហាញឱ្យឃើញថាមានការអនុវត្តជាសកលមួយទៅតាមលំដាប់នៃប្រធានបទ ហើយមានអង្គការមិនមែនរដ្ឋាភិបាលជាច្រើននៅកម្ពុជាបានប្រើប្រាស់កិច្ចសន្ទនាសហគមន៍នេះ។ កម្មវិធីអភិវឌ្ឍអង្គការសហប្រជាជាតិ បានប្រើប្រាស់កិច្ចសន្ទនាសហគមន៍ពាក់ព័ន្ធនឹងការរីករាលដាលនៃជំងឺអេដស៍។ សមាគមយុវជនខ្មែរបានដឹកនាំក្រុមយុវជនមកពីឃុំផ្សេងៗដើម្បីពិភាក្សា និងដោះស្រាយឧបសគ្គក្នុងការកសាងសាមគ្គីភាពនៅក្នុងក្រុមយុវជន។ ក្រុមអ្នកគ្រប់គ្រងធនធានធម្មជាតិ ដែលមានមូលដ្ឋាននៅក្នុងខេត្តនានា បានប្រើប្រាស់កិច្ចសន្ទនាសហគមន៍នេះផងដែរ សម្រាប់ធ្វើជាមធ្យោបាយក្នុងការប្រមូលផ្តុំសហគមន៍ដើម្បីបង្កើតគំនិត និងរៀបចំផែនការសកម្មភាពស្តីពីការគ្រប់គ្រងធនធានធម្មជាតិ។

## ៤.២.៤.ការបង្កើតផែនទីសេវាសង្គម និងកិច្ចការពារសង្គម

ការធ្វើផែនទីសេវាសង្គមជាផ្នែកមួយនៃដំណើរការខិតខំប្រឹងប្រែងជួយឱ្យសមាជិក គ.ក.ន.ក ធ្វើការវិភាគទិន្នន័យជាលក្ខណៈប្រព័ន្ធ និងប្រើប្រាស់ព័ត៌មានប្រកបដោយតម្លាភាពដើម្បីអន្តរាគមន៍ចំពោះជនងាយរងគ្រោះបំផុត នៅក្នុងសហគមន៍។ អង្គការយូនីសេហ្វបានចាប់ផ្តួចផ្តើមសាកល្បងបង្កើតផែនទីសេវាសង្គមក្នុងឆ្នាំ២០០៩ជាមួយតំណាងមកពីមន្ទីរវិស័យនានា(មន្ទីរសុខាភិបាល, មន្ទីរអប់រំ យុវជន និងកីឡា, មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា, និងមន្ទីរអភិវឌ្ឍន៍ជនបទ) និងមន្ត្រីបង្គោលកម្មវិធីសិទ្ធិកុមារខេត្ត ស្រុកនៅក្នុងអង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត។ ក្រុមនេះបានផ្តល់វគ្គបណ្តុះបណ្តាលដល់ គ.ក.ន.ក ដែលជាអ្នកធ្វើការជាមួយសហគមន៍ដើម្បីប្រើប្រាស់ផែនទីភូមិដែលមានស្រាប់ ឬបង្កើតផែនទីថ្មី។

ផែនទីសេវាសង្គមមិនត្រឹមតែកំណត់ធនធាននៅក្នុងភូមិទេ ប៉ុន្តែថែមទាំងកំណត់បានពីភាពខុសគ្នាដែលគ្រួសារទាំងនោះមិនទាន់បានទទួលសេវាសំខាន់ៗ(ដូចជា ការចាក់ថ្នាំបង្ការ ការថែទាំសុខភាពមាតាមុនពេលសម្រាល និងកម្មវិធីអប់រំកុមារតូច) ឬគ្រួសារដែលត្រូវការសេវាពិសេស(ដូចជា អ្នកថែទាំមនុស្សចាស់ កុមារពិការ និងកុមារដែលមិនបានរស់នៅជាមួយឪពុកម្តាយបង្កើត)។

គ.ក.ន.ក អាចប្រើប្រាស់ផែនទីនេះនៅក្នុងកិច្ចប្រជុំប្រចាំខែដើម្បីធ្វើអន្តរាគមន៍ដល់ក្រុមគោលដៅរបស់ពួកគេឱ្យកាន់តែប្រសើរឡើង និងបង្កើនប្រសិទ្ធភាពក្នុងការអនុវត្តការងារតាមលក្ខណៈ ដែលមានការចូលរួម និងតម្លាភាព។ ដំណើរការធ្វើផែនទីនេះ ក៏ផ្តល់ជាមូលដ្ឋានមួយផងដែរសម្រាប់តាមដានត្រួតពិនិត្យសកម្មភាព។

ដូច្នេះដំណើរការធ្វើផែនទីនេះ គឺជាឧបករណ៍មួយដ៏មានប្រសិទ្ធភាពក្នុងការបំពេញកង្វះចន្លោះ ដូចជា តម្រូវការក្នុងការសិក្សាវាយតម្លៃពីតម្រូវការរបស់សហគមន៍ដើម្បីបង្កើនការវិភាគ និងការធ្វើផែនការសកម្មភាព។ ឧបករណ៍ផែនទីសេវាសង្គមនេះ ជួយឱ្យយើងកំណត់ពីគ្រួសារដែលងាយរងគ្រោះ និងការផ្លាស់ប្តូរស្ថានភាពក្រីក្រនៃគ្រួសារនីមួយៗ។

ការធ្វើផែនទីនេះអាចប្រាប់អ្នកទទួលផលពីកម្មវិធីកិច្ចការពារសង្គម អ្នកផ្តល់សេវា និងអ្នកពាក់ព័ន្ធផ្សេងទៀត ឱ្យបានដឹងផងដែរ។ ផ្ទុយមកវិញ ការធ្វើផែនទីនេះ អាចជួយកំណត់គោលដៅគ្រួសារនីមួយៗ ព្រមទាំងភូមិអាទិភាពជាច្រើននៅក្នុងឃុំ សង្កាត់ និងផ្តល់ជាភស្តុតាងសម្រាប់ការធ្វើផែនការទាំងនៅថ្នាក់ភូមិ និងឃុំ។ ជាចុងក្រោយ បទពិសោធន៍ដែលទទួលបានពីការប្រើប្រាស់ផែនទីសេវាសង្គម ដែលជាឧបករណ៍វិភាគមួយអាចពង្រឹងតួនាទីរបស់ គ.ក.ន.ក ក្នុងការលើកតម្កល់សិទ្ធិរបស់គ្រួសារក្រីក្រ និងគ្រួសារងាយរងគ្រោះ ព្រមទាំងបង្កើតមេរៀនបទពិសោធន៍សម្រាប់ការពិភាក្សាកម្រិតគោលនយោបាយជាមួយរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធផ្សេងៗ នាពេលអនាគត។

### ៣.២.៥.ការបណ្តុះបណ្តាលដល់អ្នកធ្វើការងារសង្គម

ការងារសង្គមគឺនៅតែឱ្យតម្លៃទាប និងនៅតែជាជំនាញ ដែលពិបាករកមនុស្សមកធ្វើការនៅប្រទេសកម្ពុជា។ មានអ្នកធ្វើការងារសង្គម ឬអ្នកពិគ្រោះយោបល់តិចតួចដែលបានទទួលការបណ្តុះបណ្តាល ហើយមានអ្នកគ្រប់គ្រងតិចតួចដែលមានបទពិសោធន៍ និងមានការបណ្តុះបណ្តាលផ្តល់បច្ចេកទេស និងផ្តល់ការណែនាំបែបគាំទ្រ ឬការពិគ្រោះយោបល់ទៅដល់បុគ្គលិកធ្វើការនៅសហគមន៍ ដែលមានតម្រូវក្នុងការអនុវត្តការងារច្រើនជាងគេ។

នៅក្នុងឆ្នាំ២០០៨ សកលវិទ្យាល័យភូមិន្ទភ្នំពេញ បានបង្កើតឱ្យមានកម្មវិធីសិក្សាថ្នាក់បរិញ្ញាប័ត្រផ្នែកការងារសង្គម។ បច្ចុប្បន្ន សកលវិទ្យាល័យនេះ បានបង្កើតកម្មវិធីសិក្សាថ្នាក់អនុបណ្ឌិតផ្នែកសង្គមវិទ្យា។ សកលវិទ្យាល័យឯកជនខ្លះបានប្រកាសផ្សាយអំពីកម្មវិធីសិក្សាការងារសង្គម ប៉ុន្តែតាមការពិត មានតែមួយ ឬពីរថ្នាក់តែប៉ុណ្ណោះដែលបានដំណើរការបង្រៀន។ មិនមានបទដ្ឋានជំនាញការងារសង្គមដើម្បីធានាគុណភាពតាមរយៈការផ្តល់កម្មវិធីសិក្សាទាំងនេះ។

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មានកម្មវិធីបណ្តុះបណ្តាលអ្នកធ្វើការងារសង្គម ដែលកម្មវិធីនេះឆ្លើយតបទៅនឹងតម្រូវការចាំបាច់ក្នុងការកសាងសមត្ថភាពជំនាញរបស់មន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាក្នុងការផ្តល់សេវាទៅដល់ជនងាយរងគ្រោះនៅប្រទេសកម្ពុជា។ ការវាយតម្លៃនៅឆ្នាំ២០០៥ (Harknett, 2005) បានបង្ហាញថា តម្រូវការបន្ថែមលើជំនាញក្នុងការអនុវត្តការងារ (ដូចជា ការពិគ្រោះយោបល់ ការបង្កើនការយល់ដឹង និងការអប់រំឱ្យមានឥរិយាបថសមរម្យ) និងដើម្បីផ្តល់ឱកាសសម្រាប់ការធ្វើកម្មសិក្សា។ ការវាយតម្លៃនេះបានកត់សំគាល់ផងដែរថា អ្នកបណ្តុះបណ្តាលរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នឹងទទួលបានផលប្រយោជន៍បន្ថែមពីវគ្គបណ្តុះបណ្តាលនេះ ដូចជា វិធីសាស្ត្របណ្តុះបណ្តាលតាមបែបចូលរួម ព្រមទាំងកាន់តែទទួលបានបទពិសោធន៍ពីការអនុវត្តការងារជាក់ស្តែងនៅទីកន្លែងផងដែរ។

សេវាសង្គមនៅក្នុងប្រទេសកម្ពុជា ផ្តល់ការបណ្តុះបណ្តាលដល់អ្នកធ្វើការងារសង្គម នៅក្រៅប្រព័ន្ធអប់រំរបស់រដ្ឋាភិបាល។ សេវាសង្គមនេះ ផ្តល់វគ្គរៀនសូត្រនៅតាមផ្ទះជាមួយការអនុវត្តជាក់ស្តែងនៅទីកន្លែងការងារ និងផ្តល់ឱ្យការគាំទ្រជាបន្តនៅក្នុងពេលបំពេញកម្មសិក្សាផងដែរ ( Roberts, 2007 )។ នេះគឺជាកម្មវិធីគំរូមួយសម្រាប់អ្នកផ្សេងទៀតដែលត្រូវការធ្វើតាមវិធីសាស្ត្រអតិថិជនជាចម្បងក្នុងការផ្តល់សេវាពិគ្រោះយោបល់។

### ៤.២.៦.កម្មវិធីសិលាជាករណីសិក្សាមួយក្នុងការផ្លាស់ប្តូរឱ្យមានការអភិវឌ្ឍប្រកបដោយយេនឌ័រភាព

មេរៀនសំខាន់អាចទទួលយកបានតាមរយៈកម្មវិធីសិលា បានធ្វើជាមូលដ្ឋានគ្រឹះដែលនាំឱ្យមានការផ្លាស់ប្តូរជាបន្តបន្ទាប់។ គោលការណ៍ និងការអនុវត្តដែលបានបង្កើតឡើងដោយកម្មវិធីសិលា និងអ្នកដែលបានទទួលការបណ្តុះបណ្តាលនៅក្រោមកម្មវិធីសិលា គឺជាធនធានដ៏សំខាន់សម្រាប់កម្មវិធីបណ្តុះបណ្តាលនៅពេលខាងមុខទៀត ដែលកំពុងតែដោះស្រាយជាមួយការប្រកួតប្រជែងប្រព័ន្ធនៃការឱ្យតម្លៃ និងការស្វែងរកការងារនៅថ្នាក់ឃុំ សង្កាត់ ស្រុក ខណ្ឌ ខេត្ត និងថ្នាក់ជាតិ។

ការស្រាវជ្រាវ(Knowles,2009)បានបង្ហាញថា ការផ្លាស់ប្តូរនេះ បានទទួលការណែនាំពីភ្នាក់ងារផ្លាស់ប្តូរថ្នាក់ជាតិដែលបានធ្វើការ និងបានបណ្តុះបណ្តាលពីកម្មវិធីសិលាដែលប្រែក្លាយទៅជា"អន្តរការីវប្បធម៌"ដោយដើរតួជាស្ពានចម្លងរវាងម្ខាងជាការរំពឹងទុកនៃដំណើរការវិមជ្ឈការ និងវិសហមជ្ឈការជាមួយនឹងម្ចាស់ជំនួយដែលតាមមើលសកម្មភាពទាំងនោះ និងម្ខាងទៀតជាអ្នកគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ ក្រុមប្រឹក្សាឃុំ សង្កាត់ និងសហគមន៍។ កម្មវិធីនេះត្រូវបានរៀបចំបង្កើតឡើងដើម្បីបង្ហាញពីភាពផ្ទុយគ្នារវាងវប្បធម៌ និងការឱ្យតម្លៃ។ កម្មវិធីនេះរៀបចំឡើងដោយទីប្រឹក្សាជាន់ខ្ពស់គម្រោងភាពជាដៃគូដើម្បីអភិបាលកិច្ចមូលដ្ឋានប្រចាំខេត្ត(SPPAs) ដែលពួកគេធ្វើការងារដើម្បីគាំទ្រការងាររបស់អភិបាលខេត្ត និងគណៈកម្មាធិការប្រតិបត្តិខេត្ត ព្រមទាំងដើរតួម្ខាងជាអ្នកបកស្រាយនូវការរំពឹងទុករបស់រាជរដ្ឋាភិបាល និងម្ចាស់ជំនួយ និងម្ខាងទៀតជាអ្នកបកស្រាយនូវការរំពឹងទុករបស់រដ្ឋាភិបាលមូលដ្ឋាន និងសហគមន៍។

នៅក្នុងការធ្វើការងារនេះ ទីប្រឹក្សាជាន់ខ្ពស់គម្រោងភាពជាដៃគូដើម្បីអភិបាលកិច្ចមូលដ្ឋានប្រចាំខេត្តបានជួបការប្រឈមជាច្រើនជាមួយនឹងទំនាស់ផ្ទាល់ខ្លួន និងវិជ្ជាជីវៈជំនាញ។ ទំនាស់ទាំងនេះកើតឡើងដោយសារតែការពិបាកនៅក្នុងការចាប់យកទស្សនៈថ្មី និងការឱ្យតម្លៃនៅពីក្រោយការងារនេះ។ ទស្សនៈទាំងនេះ រួមបញ្ចូលនូវទស្សនៈស្តីពីលទ្ធិប្រជាធិបតេយ្យ, វិមជ្ឈការ និងការធ្វើសេចក្តីសំរេចចិត្តដោយមានការចូលរួម។ វិធីមួយដែលទទួលបានផលល្អនោះគឺថា អ្នកជំនាញការអន្តរជាតិក្នុងកម្មវិធីសិលាបានផ្តល់ការគាំទ្របែបបង្ហាត់បង្ហាញ ដើម្បីជួយដល់ទីប្រឹក្សាប្រចាំខេត្តក្នុងការធ្វើការងារដែលមានភាពច្របូកច្របល់របស់ពួកគេ។ លើសពីនេះទៅទៀត ការខិតខំប្រឹងប្រែងជាច្រើនត្រូវបានផ្តល់ឱ្យដើម្បីការបង្កើតទីប្រឹក្សាគម្រោងប្រចាំខេត្តទៅជាក្រុមមួយ និងអភិវឌ្ឍនូវភាពជឿជាក់ និងទំនុកចិត្ត ដូច្នេះ ពួកគេអាចធ្វើការគាំទ្រគ្នាទៅវិញទៅមក។ គោលការណ៍បួនបានណែនាំសម្រាប់បំពេញការងារនោះគឺៈ ពិភាក្សា, ច្បាស់លាស់, ព្រមព្រៀង, និងគោរពប្រតិបត្តិ។ គោលការណ៍ទាំងបួននេះ ផ្តល់ឱ្យបុគ្គលិកក្នុងស្រុកនូវឥរិយាបទគំរូមួយសម្រាប់ធ្វើជាគំរូនៃការអភិវឌ្ឍដោយមានការចូលរួមទៅអ្នកដទៃទៀត។ ជាឧទាហរណ៍គោលការណ៍នេះត្រូវបានប្រើប្រាស់ដើម្បីដឹកនាំកម្មវិធីនៃកិច្ចប្រជុំ និងការផ្ទេរនូវក្តីសង្ឃឹមថាមានឥរិយាបទប្រកបដោយសីលធម៌។ ពួកគេ ក៏បានអនុវត្តគោលការណ៍នេះផងដែរនៅក្នុងវគ្គបណ្តុះបណ្តាល។

ផ្នែកផ្សេងទៀតនៃវិធីសាស្ត្រនេះទាក់ទងទៅនឹងការបង្កើតរចនាសម្ព័ន្ធរៀនសូត្រ។ ប្រការនេះរួមមាន ការធ្វើជាគំរូ (ពេលដែលអ្នកបណ្តុះបណ្តាលប្រតិបត្តិខ្លួនតាមគោលការណ៍ដែលបានប្រកាន់យក ហើយសិក្ខាកាមក៏អាចមើលឃើញនូវឥរិយាបថថ្មីនៅក្នុងសកម្មភាពនោះផងដែរ)។ សកម្មភាពទាំងនេះ ពង្រឹងឡើងវិញបានចំពោះគំនិតដែលថា

ការឆ្លុះបញ្ចាំងពីបទពិសោធន៍ គឺជាផ្នែកដ៏សំខាន់មួយនៃការរៀនសូត្រ។ សកម្មភាពទាំងនេះ មិនត្រឹមតែបានអភិវឌ្ឍការយល់ដឹងប៉ុណ្ណោះទេ តែថែមទាំងបានលើកទឹកចិត្តឱ្យមានការពិសោធន៍ និងគំនិតច្នៃប្រឌិតថ្មីៗផងដែរ។

## ៤.៣.គោលការណ៍ណែនាំអំពីយុទ្ធសាស្ត្រអភិវឌ្ឍន៍សមត្ថភាព

ផ្អែកទៅលើការវិភាគនៅផ្នែកខាងដើម និងឧទាហរណ៍នៃការអនុវត្តល្អ ដែលបានរៀបរាប់រួចមកហើយនោះ យើងរៀបចំជាគោលការណ៍ណែនាំដូចខាងក្រោមសម្រាប់ធ្វើជាយុទ្ធសាស្ត្រអភិវឌ្ឍន៍សមត្ថភាព គ.ក.ន.ក/អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ពេលបច្ចុប្បន្ន។

យុទ្ធសាស្ត្រអភិវឌ្ឍសមត្ថភាពរយៈពេលវែងគួរតែ ៖

-បង្កើនការសម្របសម្រួល សុខដុមនីយកម្ម និងការបន្សីុនូវការផ្តួចផ្តើមក្នុងការកសាងសមត្ថភាពដែលផ្តល់ដោយរដ្ឋាភិបាល ម្ចាស់ជំនួយ ឬតាមរយៈអង្គការមិនមែនរដ្ឋាភិបាលនានា

-បង្កើនប្រសិទ្ធផល និងកាត់បន្ថយនូវផលប៉ះពាល់

-តម្រង់ទៅរករៀនសូត្រឱ្យមានការផ្លាស់ប្តូរដែលប្រឈមទៅនឹងការមិនយកចិត្តទុកដាក់ ឋានានុក្រម និងបន្សីុជាមួយបែបបទប្រពៃណី និងការឱ្យតម្លៃ ដែលបញ្ជាក់ពីវិមជ្ឈការ សិទ្ធិស្ត្រី និងកុមារ

-បង្កើនគុណភាពនៃកម្មវិធីការកសាងសមត្ថភាពដោយ ៖

- ផ្តោតទៅលើការរៀនសូត្រដោយតម្រង់ទិសលើសកម្មភាព
- ជំរុញឱ្យមានវិធីសាស្ត្រសមស្របសម្រាប់ការរៀនសូត្ររបស់មនុស្សពេញវ័យ
- កុំព្យាយាមផ្តល់ទ្រឹស្តីច្រើន តែព្យាយាមបញ្ជ្រាបក្នុងការអនុវត្ត
- ធានាថា អ្នកសម្របសម្រួល អាចកាត់ជាចំណែកៗនូវអ្វីដែលគួរដាក់ទៅក្នុងវគ្គបណ្តុះបណ្តាលតាមតម្រូវការខុសៗគ្នារបស់អ្នករៀនសូត្រ
- ធានាថា រាល់សំណើរសុំការបណ្តុះបណ្តាលត្រូវបានលើកឡើង ដោយផ្អែកទៅលើការសិក្សាវាយតម្លៃជាបឋមលើសមត្ថភាព និងតម្រូវការបណ្តុះបណ្តាល ហើយត្រូវធ្វើការតាមដានដោយការវាយតម្លៃ

-ពង្រឹងសមត្ថភាពជាមូលដ្ឋានសម្រាប់អ្នកសម្របសម្រួលខេត្ត ស្រុក ដើម្បីឱ្យសម្រេចបានលទ្ធផលតាមការណែនាំពីថ្នាក់ជាតិ ៖

- លើកទឹកចិត្តឱ្យក្រុមសម្របសម្រួលអន្តរវិស័យគាំទ្រដល់វិធីសាស្ត្រនៃការអនុវត្ត
- ជំរុញឱ្យមានការបង្ហាត់បង្ហាញជាបន្ត និងគាំទ្រទៅដល់គ្រូបណ្តុះបណ្តាល ដើម្បីឱ្យពួកគេមានលទ្ធភាពគ្រប់គ្រាន់ក្នុងការតាមដាន និងគាំទ្រសិក្ខាកាម
- ធានាថា អ្នកបណ្តុះបណ្តាល/អ្នកសម្របសម្រួលបង្ហាញពីចរិកលក្ខណៈនៃការគោរពដល់សិក្ខាកាម ព្រមទាំងមានភាពស្ទាត់ជំនាញក្នុងការបង្ហាញមាតិការឿង និងមានភាពបត់បែននៅក្នុងវិធីសាស្ត្ររបស់ខ្លួន។

## ៤.៤.អនុសាសន៍សម្រាប់យុទ្ធសាស្ត្រអភិវឌ្ឍន៍សមត្ថភាពរយៈពេលវែង

យុទ្ធសាស្ត្រអភិវឌ្ឍន៍សមត្ថភាព គ.ក.ន.ក ដែលបានស្នើឡើង ត្រូវបានបង្ហាញឱ្យឃើញនៅក្នុងគំនូសតាងទី៣ ដូចខាងក្រោម។ លក្ខណៈសំគាល់នៃយុទ្ធសាស្ត្រអភិវឌ្ឍន៍សមត្ថភាពមានដូចខាងក្រោម ៖

-ផ្តោតការយកចិត្តទុកដាក់លើការរៀនសូត្រឱ្យបានស៊ីជម្រៅតាមរយៈតាមដានការគាំទ្រ និងការឆ្លុះបញ្ចាំង

-គំរូវគ្គបណ្តុះបណ្តាលបន្ត (គំរូមួយដែលផ្តល់ឱ្យសម្រាប់ទូទាំងប្រទេស) ត្រូវបានពង្រីក ដើម្បីដាក់បញ្ចូលគ្នាសម្រាប់ក្រុមសម្របសម្រួលពហុវិស័យ (ធ្វើដូច្នេះដើម្បីលើកកម្ពស់កិច្ចសហការ និងការសម្របសម្រួលអន្តរវិស័យ)។

-បង្កើតឱ្យមានក្រុមសម្របសម្រួលពហុវិស័យស្នូលមួយ ដើម្បីបង្កើតកម្មវិធីសិក្សា និងវិធីសាស្ត្របណ្តុះបណ្តាលរួមគ្នាមួយ និងផ្តល់ការបណ្តុះបណ្តាលទៅអ្នកសម្របសម្រួលថ្នាក់ខេត្ត ស្រុក។ ក្រុមស្នូលនេះ នឹងផ្តល់ការគាំទ្រដល់អ្នកសម្របសម្រួលថ្នាក់ខេត្ត និងស្រុក ព្រមទាំងជំរុញឱ្យក្រុមនេះធ្វើការឆ្លុះបញ្ចាំងខ្លួនឯងផងដែរ។

# គំនូសតាងទី៣: ក្រុមសម្របសម្រួលពហុវិស័យ និងការបណ្តុះបណ្តាលបន្ត



ដំណាក់ការទី១ នៃយុទ្ធសាស្ត្រដែលបានស្នើឡើងនេះ គឺធ្វើឱ្យប្រាកដថាមានភាពម្ចាស់ការ និងការប្តេជ្ញាចិត្តរួមគ្នា សម្រាប់យុទ្ធសាស្ត្រអភិវឌ្ឍន៍សមត្ថភាពដែលមានការយោគយល់គ្នា និងមានការឯកភាពរួមគ្នាមួយ ។

### ក.បង្កើតភាពជាអ្នកដឹកនាំដោយសម្របសម្រួលឱ្យមានយុទ្ធសាស្ត្ររួមគ្នាមួយ

គ.ជ.អ.ប នឹងត្រូវសម្របសម្រួលកិច្ចប្រជុំមួយជាមួយតំណាងមកពីក្រសួងនានា (ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងផែនការ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងកិច្ចការនារី ក្រសួងសុខាភិបាល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ) ម្ចាស់ជំនួយ និងអ្នកផ្តល់ការបណ្តុះបណ្តាលនានា ។

កិច្ចប្រជុំនេះ គួរតែព្រមព្រៀងគ្នាទៅលើ :

-យោបល់រួមមួយសម្រាប់ធ្វើការជាមួយគ្នា ដើម្បីអភិវឌ្ឍសមត្ថភាព គ.ក.ន.ក/អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់នៅទូទាំងប្រទេសដែលការងារនេះតម្រូវឱ្យមានការព្រមព្រៀងទៅលើគោលដៅ (អ្វីដែលយើងចង់ឱ្យសម្រេច និងភាពជោគជ័យអ្វីដែលយើងចង់ឃើញ) ព្រមទាំងគោលការណ៍ណែនាំមួយចំនួនដែលនឹងគាំទ្រដល់កិច្ចអន្តរាគមន៍ក្នុងការណ្តុះបណ្តាល

-ផែនការសកម្មភាពកម្រិតទូលាយមួយដែលមានកាលកំណត់ច្បាស់លាស់(Milestones)

### ខ.ធ្វើឱ្យសម្រេចបានភាពជាដៃគូដែលមានកិច្ចសហការគ្នា

ភាពជាដៃគូដែលមានកិច្ចសហការគ្នារវាងអ្នកផ្តល់ការបណ្តុះបណ្តាលរបស់ក្រសួង និងអង្គការមិនមែនរដ្ឋាភិបាល ព្រមទាំងម្ចាស់ជំនួយមានសារៈសំខាន់ណាស់ក្នុងការធ្វើឱ្យសម្រេចគោលបំណងនៅទូទាំងប្រទេស ។ ទោះបីជាយ៉ាងណាក៏ដោយ ការសិក្សាស្រាវជ្រាវបានគូសសំគាល់ថា (ក).តម្រូវការឱ្យមានការជជែកពិភាក្សាថែមទៀតរវាងអ្នកផ្តល់ការបណ្តុះបណ្តាលនានាដើម្បីជៀសវាងធ្វើការងារជាន់គ្នា ព្រមទាំងឆ្លើយតបទៅនឹងគម្លាតក្នុងការបណ្តុះបណ្តាល ។ និង (ខ). សារៈសំខាន់នៃការអូសទាញភ្ជាក់ងារអង្គការមិនមែនរដ្ឋាភិបាល ។ ដូច្នេះ ការជជែកពិភាក្សាគួរតែផ្តោតការចាប់អារម្មណ៍មិនត្រឹមតែផ្តោតលើហេតុអ្វីភាពជាដៃគូមានសារៈសំខាន់ប៉ុណ្ណោះទេ (អ្នកណាម្នាក់ដែលអះអាងថាយល់ដឹងរួចហើយ) ប៉ុន្តែត្រូវគិតថា តើអ្វីដែលធ្វើឱ្យរារាំង និងតើអ្វីដែលនឹងត្រូវការដើម្បីផ្លាស់ប្តូរទៅជារបៀបធ្វើការរួមគ្នា?[១០២] ។

➢ លទ្ធផលសំខាន់មួយនៃកិច្ចប្រជុំដែលដឹកនាំដោយ គ.ជ.អ.ប នោះ(ចំណុច**ក**ខាងលើ) គួរតែជាការព្រមព្រៀងរួមមួយនៃគោលការណ៍ភាពជាដៃគូដែលលើកកម្ពស់ដល់កិច្ចសហការពហុវិស័យ និងជាសេចក្តីណែនាំមួយដែលផ្តល់ព័ត៌មានដល់មន្ទីរខ្សែបណ្តោយរបស់ក្រសួងអំពីការងារដែលត្រូវធ្វើជាមួយ គ.ក.ន.ក ។

[102] កំណត់សំគាល់: ធនធានដ៏សំខាន់សម្រាប់ការគ្រប់គ្រងភាពជាដៃគូពហុវិស័យ អាចរកមើលបាននៅក្នុងសៀវភៅការកសាងភាពជាដៃគូ ( The Partnering Toolbook, 2009 )

## គ.បង្កើតក្រុមសម្របសម្រួលពហុវិស័យនៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

ដូចបានរៀបរាប់នៅក្នុងផ្នែកទី២.៥ គ.ក.ន.ក/អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់មិនអនុវត្តគម្រោងទេ ប៉ុន្តែអនុវត្តមុខងាររបស់ពួកគេ។ មុខងារមួយត្រូវបានឱ្យអត្ថន័យដូចជាចង្កោមសកម្មភាពដាច់ៗពីគ្នានៅក្នុងវិស័យដោយឡែកមួយ។ ការបំពេញមុខងាររបស់ គ.ក.ន.ក ឬ អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ខុសគ្នាពីការបំពេញមុខងាររបស់មន្ត្រីក្រសួង និងអ្នកផ្តល់សេវាដទៃទៀត ដូចបានបង្ហាញនៅក្នុងគំនូសតាងទី៤នេះ។

### គំនូសតាងទី៤: ការអនុវត្តមុខងាររបស់ គ.ក.ន.ក និងការគាំទ្ររបស់អ្នកផ្តល់សេវា




ដើម្បីអនុវត្តនូវមុខងារទាំងនេះបាន គ.ក.ន.ក/អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ត្រូវការយល់ពីបញ្ហាបច្ចេកទេសដែលទាក់ទងទៅនឹងស្ត្រី និងកុមារដែលមាននៅតាមវិស័យផ្សេងៗ។ ហេតុនេះ អ្នកសម្របសម្រួលត្រូវមានការយល់ដឹងពីខ្លឹមសារបច្ចេកទេស និងមានសមត្ថភាពក្នុងការនិយាយឱ្យបានច្បាស់ និងជាក់លាក់អំពីការងារនីមួយៗ។

លក្ខណៈគន្លឹះនៃយុទ្ធសាស្ត្រនេះគឺបង្កើតក្រុមអ្នកបណ្តុះបណ្តាលពហុវិស័យនៅថ្នាក់រាជធានី, ខេត្ត, ក្រុង, ស្រុក ខណ្ឌ ឧទាហរណ៍ គ្រូបណ្តុះបណ្តាលមកពី គ.ជ.អ.ប និងរួមបញ្ចូលគ្រូបណ្តុះបណ្តាលមកពីក្រសួងកិច្ចការនារី, ក្រសួងអប់រំ

យុវជន និងកីឡា និងក្រសួងសុខាភិបាលផងដែរ។ ការធ្វើបែបនេះ អាចឱ្យអាទិភាពរបស់ក្រសួងនីមួយៗ ត្រូវបានដាក់បញ្ចូលទៅក្នុងកម្មវិធីបណ្តុះបណ្តាលណាមួយឱ្យមានលក្ខណៈសង្គតភាព។

- ជំហានដំបូង ត្រូវបង្កើតក្រុមអ្នកសម្របសម្រួលស្នូលថ្នាក់ជាតិមួយ ដែលអាចប្រើប្រាស់ជំនាញមានលក្ខណៈអន្តរវិស័យតាមរយៈភ្នាក់ងាររបស់រដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលនានា។ ក្រុមអ្នកសម្របសម្រួលស្នូលនេះគួរតែធ្វើការជាមួយគ្នាដើម្បីបង្កើត"សារគន្លឹះ៧" និងវិធីសាស្ត្របណ្តុះបណ្តាលរួមមួយ ដើម្បីគាំទ្រដល់ការអភិវឌ្ឍសមត្ថភាពរបស់ គ.ក.ន.ក ។
- ការងារនេះ គួរតែពិនិត្យមើលឡើងវិញពីកម្មវិធីបណ្តុះបណ្តាល/វិធីសាស្ត្របណ្តុះបណ្តាល ដែលមានបច្ចុប្បន្នរបស់ភ្នាក់ងារផ្សេងៗ ហើយដាក់បញ្ចូលគ្នានូវវិធីសាស្ត្រល្អៗទៅក្នុងកម្មវិធីបណ្តុះបណ្តាលរបស់ គ.ក.ន.ក និងអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់, ឧទាហរណ៍ចំណុចដែលត្រូវយកចិត្តទុកដាក់ :
  - ការបន្សុីការឱ្យតម្លៃ ដូចជារបៀបទទួលយក និងបន្សុីកង្វះចន្លោះរវាងគោលគំនិតនៃការអភិវឌ្ឍថ្មីៗ និងបែបបទនៃការឱ្យតម្លៃ ព្រមទាំងវប្បធម៌សង្គមដែលមានលក្ខណៈជាប្រពៃណីទំនៀមទំលាប់
  - វិធីសាស្ត្រសម្របសម្រួលដែលលើកទឹកចិត្តឱ្យមានការចូលរួម និងការរៀនសូត្រដែលតម្រង់ទិសទៅលើការធ្វើសកម្មភាព (ឧទាហរណ៍ វេទិការៀនសូត្រ កិច្ចសន្ទនាសហគមន៍ និងការអនុវត្តបែបឆ្លុះបញ្ចាំង)
  - បច្ចេកទេសសិក្សាវាយតម្លៃរហ័សដោយមានការចូលរួមក្នុងការធ្វើការជាមួយទិន្នន័យ និងការផ្លាស់ប្តូរសំខាន់ ព្រមទាំងវិធីសាស្ត្រសួរសំណួរដោយមានការលើកសរសើរដើម្បីធ្វើការវាយតម្លៃ
  - ផ្តល់ព័ត៌មានសម្រាប់គាំទ្រលើអ្វីដែលត្រូវធ្វើបន្តមកទៀតដើម្បីឱ្យមានការរៀនសូត្រកាន់តែស៊ីជម្រៅ
  - បញ្ចូលបច្ចេកទេសផ្សេងៗ ដែលពាក់ព័ន្ធស្ត្រី និងកុមារ
  - ផ្តល់ព័ត៌មានអំពីរបៀបជ្រើសយកកម្មវិធីសិក្សាឱ្យស្របទៅនឹងបរិបទផ្សេងៗគ្នា
- ក្រុមអ្នកសម្របសម្រួលស្នូលថ្នាក់ជាតិគួរតែផ្តល់ការបណ្តុះបណ្តាលដល់អ្នកសម្របសម្រួលរាជធានី និងខេត្ត ដែលអាចបណ្តុះបណ្តាលបន្តដល់អ្នកសម្របសម្រួលក្រុង ស្រុក ខណ្ឌ និងគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារថ្នាក់រាជធានី/ខេត្ត (PCWC) ដែលនឹងបង្កើតឡើងនៅឆ្នាំ២០១០។ បន្ទាប់មកទៀត ពួកគេគួរពង្រីកទៅតាមស្ថានភាពភូមិសាស្ត្រ ដើម្បីការគាំទ្រទៅដល់ក្រុមអ្នកសម្របសម្រួលក្រុង/ស្រុក/ខណ្ឌ និងគណៈកម្មាធិការពិគ្រោះយោបល់កិច្ច ការស្ត្រី និងកុមារថ្នាក់រាជធានី/ខេត្តផងដែរ។
- អ្នកសម្របសម្រួលក្រុង/ស្រុក/ខណ្ឌ គួរផ្តល់វគ្គបណ្តុះបណ្តាលដល់ គ.ក.ន.ក និងអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ និងគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារថ្នាក់ក្រុង ស្រុក ខណ្ឌ និងគាំទ្រលើអ្វីដែលត្រូវធ្វើបន្តមកទៀត។ វគ្គបណ្តុះបណ្តាលទាំងនេះអាចរួមបញ្ចូលទាំង ដូចជា ការជួយមេឃុំ/ចៅសង្កាត់ ជំទប់ទី២/ចៅសង្កាត់រងទី២ និងអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ដើម្បីរៀបចំកិច្ចប្រជុំ។ ហើយពួកគេអាចចូលរួមកិច្ចប្រជុំ គ.ក.ន.ក និងអាចផ្តល់ជាធនធានបច្ចេកទេសប្រសិនបើមានតម្រូវការ ឬជួយធ្វើយ៉ាងណាឱ្យកិច្ចប្រជុំប្រព្រឹត្តទៅតាមរបៀបវារៈដែលត្រូវពិភាក្សា។ បន្ទាប់ពីកិច្ចប្រជុំ ពួកគេអាចសង្ខេបឡើង

វិញជាមួយមេឃុំ/ចៅសង្កាត់ ជំទប់ទី២/ចៅសង្កាត់រងទី២ និងអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ : អ្វីដែលធ្វើបានល្អ ? អ្វីដែលចង់ធ្វើឱ្យប្លែកពីមុន ? សកម្មភាពគន្លឹះអ្វីខ្លះដែលបានទទួលពីកិច្ចប្រជុំនេះ? ។ ពួកគេ អាចសម្របសម្រួលកិច្ចសន្ទនាផងដែរអំពីរបៀបប្រមូល និងគ្រប់គ្រងទិន្នន័យដោយការសួរសំណួរ ដូចជា តើអ្វីដែលសំខាន់បំផុត? ហេតុអ្វីបានជាអញ្ចឹង? តើយើងអាចធ្វើអ្វីបានខ្លះ? តើសកម្មភាពអ្វីខ្លះដែលយើងបានលើកសំណើឡើង? ស្រដៀងនេះដែរ អ្នកសម្របសម្រួល អាចជួយអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំពេលដែលគាត់ចុះបំពេញការងារជាមួយសហគមន៍ ជួយគាត់ក្នុងការរៀបចំវេទិកាសាធារណៈ និងសង្ខេបនូវអ្វីដែលធ្វើបានល្អនៅក្នុងពេលបំពេញការងារនៅមូលដ្ឋាន ។

- នៅក្នុងពេលបំពេញការងារនៅមូលដ្ឋាន អ្នកសម្របសម្រួលអាចប្រមូលផងដែរនូវទិន្នន័យដើម្បីប្រាប់ឱ្យដឹងពីការតាមដាន និងវាយតម្លៃរបស់ពួកគេ តាមរយៈការកត់សំគាល់នូវអ្វីដែលវគ្គបណ្តុះបណ្តាលកំពុងចាក់ឬសគល់នៅមូលដ្ឋាន និងអ្វីដែលកំពុងជួបប្រទះការលំបាក ។ ពេលត្រលប់មកប្រជុំឆ្លុះបញ្ចាំងការងារជាមួយក្រុមសម្របសម្រួលវិញ ពួកគេអាចប្រៀបធៀបជាមួយការកត់សំគាល់ផ្សេងៗ និងកំណត់យុទ្ធសាស្ត្រក្នុងការផ្លាស់ប្តូរវិធីសាស្ត្ររបស់ខ្លួន ។

ពាក់ព័ន្ធនឹងការងារនេះ គឺថា គ្រប់អ្នកសម្របសម្រួល ឬ គ្រូបង្គោលទាំងអស់ នឹងត្រូវការដាក់បញ្ចូលឱ្យបានជាក់លាក់ពីរបៀបដឹកនាំការបង្រៀន ការតាមដាន និងការប្រជុំឆ្លុះបញ្ចាំង ព្រមទាំងរបៀបទាញយកនូវរឿងរ៉ាវនៃការផ្លាស់ប្តូរសំខាន់បំផុត ដូចជាឧបករណ៍វាយតម្លៃ និងក៏ជាប្រភពមួយសម្រាប់ធ្វើជាករណីសិក្សាផងដែរដែលអាចត្រូវបានប្រើប្រាស់ជាធនធានក្នុងការបណ្តុះបណ្តាល ។

គុណសម្បត្តិមួយដែលបានមកពីវិធីសាស្ត្រនេះ គឺថា អ្វីដែលត្រូវដាក់បញ្ចូលស្រដៀងគ្នានេះ នឹងត្រូវផ្តល់ឱ្យជាខ្លឹមសារបច្ចេកទេស និងវិធីសាស្ត្រ ទៅឱ្យថ្នាក់រាជធានី ខេត្ត ស្រុក និងឃុំ សង្កាត់ ។ អ្វីដែលត្រូវដាក់បញ្ចូលផ្សេងទៀត គឺថា សមាជិកក្រុមអ្នកសម្របសម្រួល នឹងត្រូវបានផ្តល់ឱ្យនូវធនធានបច្ចេកទេសសម្រាប់គ្រប់ផ្នែក ដូចជា សមាជិកក្រុមមកពីផ្នែកសុខភាព អាចត្រូវបានអញ្ជើញឱ្យមកធ្វើជាធនធានក្នុងការផ្តល់ធាតុចូលពាក់ព័ន្ធបញ្ហាសុខភាព អប់រំ កិច្ចការពារសង្គម និងប្រជាជន ជាដើម ។ល ។ នៅក្នុងវិធីនេះ ឃើញថាការផ្សារភ្ជាប់ទំនាក់ទំនង គួរត្រូវបានពង្រឹងបន្ថែមតាំងពីថ្នាក់លើរហូតដល់ថ្នាក់ក្រោម និងផ្នែកអន្តរវិស័យផ្សេងៗ ។

- អនុសាស្ត្រមួយដែលបានលើកឡើងនៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់មួយសម្រាប់ផ្តល់ឱ្យ គ.ក.ន.ក នោះគឺ ក). បោះពុម្ពផ្សាយបញ្ជីសារពើភ័ណ្ឌគណៈកម្មាធិការទាំងអស់ដែលមានស្រាប់ និងតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន ។ (ខ).បន្ទាប់មកដឹងនាំគណៈកម្មាធិការផ្សេងៗទៀតមកជុំគ្នា ដើម្បីធ្វើការឆ្លុះបញ្ចាំងពីកាលានុវត្តភាពដែលមានឥទ្ធិពលទៅវិញទៅមក ឬ និងចំណុចណាដែលសមស្របដើម្បីដាក់បញ្ចូលគ្នា ធ្វើដូច្នេះគឺដើម្បីកាត់បន្ថយបាននូវការងារដែលជាន់គ្នា ។

## ឃ.ពង្រឹងគុណភាពកម្មវិធីសិក្សា និងការរៀនសូត្រ

ដូចបានរៀបរាប់នៅក្នុងផ្នែកទី២ វគ្គបណ្តុះបណ្តាលបន្តផ្តល់ជាយន្តការមួយដើម្បីពង្រីកឱ្យបានទូទាំងប្រទេស។ ប៉ុន្តែនៅពេលជាមួយគ្នានេះដែរ វាមានការពិបាកដើម្បីធានានូវគុណភាពជាមួយវិធីសាស្ត្របណ្តុះបណ្តាលបន្តនេះ នៅខណៈដែលវគ្គបណ្តុះបណ្តាលបន្តពីថ្នាក់មួយទៅថ្នាក់មួយទៀតអាចធ្វើឱ្យផ្នែកណាមួយនៃវគ្គបណ្តុះបណ្តាលត្រូវបាត់បង់។ ខ្លឹមសារបច្ចេកទេសដែលដាក់បញ្ចូលក្នុងវគ្គបណ្តុះបណ្តាល អាចត្រូវមានការយកចិត្តទុកដាក់ច្រើនជាងដំណើរការរៀនសូត្រ។ រីឯខ្លឹមសារមេរៀន អាចជាមិនចាំបាច់សម្របទៅតាមបរិបទដោយឡែកដែលរារាំងដល់ការរៀនសូត្រ និងការប្រតិបត្តិនោះទេ។ អ្នកបណ្តុះបណ្តាលអាចត្រឡប់ទៅប្រើវិធីសាស្ត្រនិយាយប្រាប់វិញក៏បាន។

ហេតុដូចនេះ វាមានសារៈសំខាន់ណាស់ដែលថា ការវាយតម្លៃ និងការរៀនសូត្រ ត្រូវបានរៀបចំចងឱ្យមានជារចនាសម្ព័ន្ធនៅក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍សមត្ថភាព៖

- គ្រប់វគ្គបណ្តុះបណ្តាលត្រូវផ្អែកលើការវាយតម្លៃពីតម្រូវការបឋម ហើយក្រុមអ្នកសម្របសម្រួល ត្រូវយល់ពីរបៀបបន្ថែមបន្ថយអ្វីដែលត្រូវដាក់បញ្ចូលក្នុងវគ្គបណ្តុះបណ្តាល ដើម្បីឱ្យឆ្លើយតបទៅនឹងតម្រូវការជាក់លាក់របស់អ្នករៀនសូត្រផ្សេងៗគ្នា។ ការងារនេះរាប់បញ្ចូលនូវការយល់ដឹងដែលថា គ.ក.ន.ក ដែលដឹងការងារច្រើននឹងមិនត្រូវការវគ្គបណ្តុះបណ្តាលដូច គ.ក.ន.ក ដែលទើបនឹងចាប់ផ្តើមការងារនោះទេ ឬថា ការប្រើប្រាស់ភាសា និងវិធីសាស្ត្របណ្តុះបណ្តាល នឹងត្រូវសម្របទៅតាមតម្រូវការជនជាតិដើមភាគតិចជាដើម។
- កម្មវិធីបណ្តុះបណ្តាលនីមួយៗ គួររាប់បញ្ចូលនូវការវាយតម្លៃអំពីប្រតិកម្មរបស់សិក្ខាកាមនៅពេលបញ្ចប់វគ្គ (អ្វីដែលពួកគេបានគិត និងចាប់អារម្មណ៍អំពីវគ្គបណ្តុះបណ្តាលនេះ) ព្រមទាំងអ្វីខ្លះដែលពួកគេបានរៀនសូត្រ (ឧទាហរណ៍បង្កើនសមត្ថភាពឱ្យចេះនិយាយឱ្យបានត្រឹមត្រូវអំពីបញ្ហាពាក់ព័ន្ធសុខភាពមាតា)។
- ក្នុងអំឡុងពេលចុះតាមដានការងារ អ្នកបណ្តុះបណ្តាល/អ្នកសម្របសម្រួល គួរស្វែងរកឧទាហរណ៍អំពីរបៀបនៃការរៀនសូត្រដែលនាំឱ្យមានការផ្លាស់ប្តូរឥរិយាបថ។ អ្នកបណ្តុះបណ្តាល/អ្នកសម្របសម្រួល គួរសង្កេតមើលនូវអ្វីដែលសិក្ខាកាមកំពុងធ្វើ និងចេះឆ្លុះបញ្ចាំងអំពី ៖ តើផ្នែកណានៃវគ្គបណ្តុះបណ្តាលនេះទំនងជាមានប្រយោជន៍ច្រើនជាងគេ? ហើយអ្វីដែលអាចយកទៅអនុវត្តបានជាមួយការងាររបស់ខ្លួន? អ្វីដែលសិក្ខាកាមបានយល់ច្បាស់ ឬមិនទាន់បានយល់ច្បាស់? ហើយនាពេលអនាគត តើ គ.ក.ន.ក នឹងធ្វើការងារអ្វីខ្លះ ដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃការប្រើប្រាស់សេវាសង្គម និងគុណភាពសេវា ដែលចេះតែកើនឡើង?[១១]
- ចំណុចគន្លឹះនៅក្នុងវិធីសាស្ត្រទាំងនេះ នឹងត្រូវធ្វើឱ្យមានលក្ខណៈសាមញ្ញ ហើយអ្នកសម្របសម្រួល មិនត្រូវទទួលបន្ទុកច្រើនក្នុងការប្រមូលឯកសារសម្រាប់បង្ហាញនោះទេ។ វិធីសាស្ត្រវាយតម្លៃ ជាវិធីសាស្ត្រមួយដែលលើកទឹកចិត្តឱ្យមានការនិយាយរឿងរ៉ាវប្រាប់ (ដូចជា រឿងរ៉ាវនៃការផ្លាស់ប្តូរសំខាន់ជាងគេ) និងការអនុវត្តមានដោយការឆ្លុះបញ្ចាំង ពិតជាអាចប្រើជាភស្តុតាងដែលមានប្រយោជន៍។

[១២] យកលំនាំតាម Kirkpatrick, ២០០៤

- ធាតុសំខាន់មួយនៅក្នុងយុទ្ធសាស្ត្រនេះ គឺក្រុមអ្នកសម្របសម្រួលនឹងមានតម្រូវការបណ្តុះបណ្តាលពីរបៀបនៃដឹកនាំការចុះពិនិត្យអ្វីដែលបានអនុវត្ត និងរបៀបធ្វើការវាយតម្លៃកម្មវិធីសិក្សារបស់ពួកគេ។ អ្នកសម្របសម្រួលត្រូវជួបប្រជុំជាប្រចាំនៅក្នុងក្រុមរបស់ពួកគេ ដើម្បីឆ្លុះបញ្ចាំងពីអ្វីដែលបានធ្វើ និងអ្វីដែលមិនទាន់បានធ្វើ ព្រមទាំងពីរបៀបដែលពួកគេអាចកែលំអកម្មវិធីបណ្តុះបណ្តាលរបស់ខ្លួនឱ្យកាន់តែប្រសើរឡើង។

### ខ.ជំរុញឱ្យមានវេទិកាសៀនសូត្រនៅថ្នាក់ស្រុក និងថ្នាក់ខេត្ត

ដូចគ្នានេះដែរ ការជួបប្រជុំគ្នានៅថ្នាក់ស្រុក និងខេត្ត ក៏អាចផ្តល់ឱកាសសម្រាប់ការរៀនសូត្រផងដែរ ដោយ :

- ពេលវេលានៅក្នុងកិច្ចប្រជុំ អាចត្រូវបានបែងចែក ដើម្បីសម្របសម្រួលការពិភាក្សាអំពីភាពជោគជ័យ បញ្ហាប្រឈម និងការកំណត់ពីមេរៀន។ ការជួបប្រជុំគ្នានេះអាចជាការរៀនសូត្រសម្រាប់មនុស្សពេញវ័យផងដែរ។ ហើយវាក៏អនុញ្ញាតឱ្យអ្នកសម្របសម្រួលអាចទាញចេញជាគំរូជាច្រើនដូចជា: តើមានបញ្ហាសង្គមជាក់លាក់ណាខ្លះនៅក្នុងស្រុកនេះ? ហេតុអ្វីបានជាមានបញ្ហានេះកើតឡើងដូច្នេះ? ហើយតើត្រូវធ្វើដូចម្តេចដើម្បីដោះស្រាយបញ្ហាទាំងនេះ?
- ប្រសិនបើបញ្ហាមួយត្រូវបានលើកឡើងនៅក្នុងគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារថ្នាក់ស្រុក ហើយគណៈកម្មាធិការនេះមិនអាចដោះស្រាយបញ្ហាបាន ដូច្នេះបញ្ហានេះ នឹងត្រូវបញ្ជូនទៅថ្នាក់លើបន្ទាប់ទៀតដើម្បីដោះស្រាយ។ ការធ្វើដូចនេះ ដើម្បីធានាឱ្យមានគណនេយ្យភាពចំពោះផែនការរបស់ថ្នាក់លើ។
- អង្គការមិនមែនរដ្ឋាភិបាល និងក្រសួងពាក់ព័ន្ធនានា គួរត្រូវបានអញ្ជើញឱ្យចូលរួមក្នុងវេទិកាទាំងនេះដើម្បីជំរុញឱ្យមានការធ្វើសមាហរណកម្មបន្ថែមទៀត។ ក្រុមអ្នកសម្របសម្រួលស្នូល អាចធ្វើសំយោគនូវមេរៀន ដែលជាបទពិសោធន៍ និងឧទាហរណ៍នៃការអនុវត្តល្អៗ ដែលបានលើកឡើងនៅក្នុងវេទិកាទាំងនេះ។

### ច.យកចិត្តទុកដាក់ និងបង្កើតស្ថាប័នការងារតាមរយៈមូលនិធិមានលក្ខខណ្ឌកំណត់

ម្ចាស់មូលនិធិ និងភ្នាក់ងារជាច្រើនទៀត ត្រូវការឱ្យមានការព្រមព្រៀងរួមគ្នាមួយស្តីពីរបៀបចាត់អាទិភាពការងារនៅក្នុងដំណាក់កាលចាប់ផ្តើម និងដំណាក់កាលដែលកំពុងអភិវឌ្ឍន៍ ហើយពួកគេ ក៏ត្រូវការឱ្យមានការព្រមព្រៀងគ្នាផងដែរទៅលើបញ្ហាថាតើត្រូវផ្តល់ ឬមិនត្រូវផ្តល់មូលនិធិមានគ្មានលក្ខខណ្ឌកំណត់ (នេះមានន័យថា គ.ក.ន.ក ធ្វើការសម្រេចថាតើមូលនិធិនេះត្រូវចំណាយយ៉ាងដូចម្តេច) ឬមូលនិធិមានលក្ខខណ្ឌកំណត់ (នេះមានន័យថា មូលនិធិដែលបានផ្តល់ឱ្យ ត្រូវចំណាយតែទៅលើអាទិភាពដែលបានកំណត់រួចហើយ។

- ផ្អែកលើការវិភាគដែលបានផ្តល់នៅក្នុងផ្នែកទី ២.៣ គឺជាយោបល់របស់អ្នកសរសេររបាយការណ៍នេះ ដោយលើកឡើងថា មូលនិធិទាំងនេះ គួរត្រូវបានកំណត់លក្ខខណ្ឌជាពិសេសនៅក្នុងឆ្នាំទី១ ហើយមូលនិធិមានលក្ខខណ្ឌកំណត់នេះ គួរត្រូវបានភ្ជាប់ទៅនឹងអាទិភាពខ្ពស់ដែលតាមមិនទាន់គោលដៅអភិវឌ្ឍន៍សហសវត្សរ៍ ដូចជាការកាត់បន្ថយអត្រាមរណៈភាពមាតា។ ការកាត់បន្ថយអត្រាមរណៈភាពមាតានេះក៏ជាចំណុចដែលឃុំ សង្កាត់ត្រូវធ្វើភាពជាដៃគូជាមួយមណ្ឌលសុខភាព មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត និងការិយាល័យអភិវឌ្ឍន៍ជនបទស្រុក

ផងដែរ។ ការអនុវត្តបែបនេះ អាចធ្វើឱ្យឃុំ សង្កាត់ មានភាពជោគជ័យទៅលើការវិនិយោគគម្រោងតូច។ ដូចនេះ គ.ក.ន.ក ត្រូវចាប់ផ្តើមបង្កើនសមត្ថភាពរបស់ខ្លួនដើម្បីកំណត់ និងយល់ដឹងអំពីបញ្ហាស្ត្រី និងកុមារ នៅមូលដ្ឋាន ហើយការបែងចែងមូលនិធិ អាចផ្លាស់ប្តូរទៅជាការផ្តល់មូលនិធិធំរុំមួយ ដោយរួមបញ្ចូលគ្នារវាងមូលនិធិមានលក្ខខណ្ឌកំណត់ និងមូលនិធិគ្មានលក្ខខណ្ឌកំណត់ ។ នៅឆ្នាំទី៤ និងទី៥ យើងរំពឹងថានឹងឃើញ គ.ក.ន.ក គ្រប់គ្រងមូលនិធិគ្មានលក្ខខណ្ឌកំណត់នេះបាន។

"មធ្យោបាយកណ្តាល"មួយ គួរត្រូវបានផ្តល់ឱ្យនូវមូលនិធិ និងតារាងជម្រើសមួយដែល គ.ក.ន.ក ពិសេសណាមួយអាចប្រើប្រាស់ ដើម្បីចាត់អាទិភាពតម្រូវការរបស់មូលដ្ឋាន។

| **សកម្មភាព** | **ការណែនាំដែលអាចមើលសម្រាប់ធ្វើជាឧទាហរណ៍** |
|---|---|
| -សុខភាពមាតា និងអាហារបំប៉ន<br>-ការអប់រំកម្រិតមត្តេយ្យសិក្សា<br>-ទឹកស្អាត និងអនាម័យ<br>-ប្រជាជន និងយេនឌ័រ<br>-ហ៊ីវ/អេដស៍... ។ល។ | ▪ គ.ក.ន.ក ទាំងអស់ ត្រូវផ្តល់ធនធាន និងរបាយការណ៍ស្តីពីសកម្មភាព ដែលទាក់ទងទៅនឹងសុខភាពមាតា (ដោយសារតែវាមានសារៈសំខាន់ក្នុងការធ្វើឱ្យបានសម្រេចគោលដៅអភិវឌ្ឍន៍សហសវត្សរ៍)<br>▪ ពួកគេក៏ត្រូវតែនិយាយផងដែរអំពីការលើកកម្ពស់ការប្រើប្រាស់ទឹកស្អាត និងអនាម័យ (ពីព្រោះ វាមានសារៈសំខាន់ក្នុងការធ្វើឱ្យបានសម្រេចគោលដៅអភិវឌ្ឍន៍សហសវត្សរ៍ផងដែរ)<br>▪ គ.ក.ន.ក អាចជ្រើសរើសយ៉ាងហោចណាស់ពីរសកម្មភាពផ្សេងទៀត ដោយផ្អែកលើតម្រូវការរបស់មូលដ្ឋាន |

## ច.ធានាឱ្យមានការត្រៀមខ្លួនជាស្រេច

អនុសាសន៍មួយចំនួនត្រូវបានស្នើឡើងនៅខណៈពេលពិគ្រោះយោបល់ដើម្បីធានាឱ្យ សមាជិក គ.ក.ន.ក ជាពិសេស អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ កំពុងធ្វើការងារនៅក្នុងបរិយាកាសមួយ ដែលអាចដំណើរការការងាររបស់ខ្លួនទៅបាន (មិនមែនមនុស្សម្នាក់ អាចតស៊ូទៅនឹងការប្រឈមរបស់ គ.ក.ន.ក នោះទេ) ៖

- ទីមួយ គ.ជ.អ.ប គួរតែបង្កើត និងចេញសេចក្តីណែនាំពីស្តីពីអាណត្តិរបស់ គ.ក.ន.ក ទៅគ្រប់ក្រសួងទាំងអស់ ធ្វើដូច្នេះដើម្បីបង្កើតនូវការរំពឹងទុកមួយដែលរាល់កិច្ចប្រជុំនៅថ្នាក់ស្រុក និងថ្នាក់ខេត្ត ត្រូវបញ្ចូលសេចក្តីរាយការណ៍ដែលទាក់ទងទៅនឹង គ.ក.ន.ក ទៅក្នុងរបៀបវារៈនៃកិច្ចប្រជុំ។
- ទីពីរ ក្រសួងដែលពាក់ព័ន្ធ ត្រូវផ្សព្វផ្សាយព័ត៌មានអំពី គ.ក.ន.ក ទៅដៃគូអភិវឌ្ឍន៍របស់ខ្លួនទាំងអស់ ដើម្បីឱ្យដៃគូអភិវឌ្ឍន៍ទាំងនោះ ធ្វើការទាក់ទងគ្នារវាងកម្មវិធីនានារបស់ពួកគេជាមួយនឹងអាណត្តិរបស់ គ.ក.ន.ក ដោយផ្តោតសំខាន់ទៅលើបញ្ហាស្ត្រី និងកុមារ (រាប់បញ្ចូលទាំងបញ្ហាយុវជនផងដែរ)។

- ទីបី ដោយសារ គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារថ្នាក់រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ ត្រូវបានបង្កើតថ្មី វានឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការធានាថា លក្ខខណ្ឌការងារសម្រាប់ថ្នាក់ឃុំ សង្កាត់ ថ្នាក់ក្រុង ស្រុក ខណ្ឌ និងថ្នាក់រាជធានី ខេត្ត បំពេញបន្ថែម និងគាំទ្រគ្នាទៅវិញទៅមក ហើយវាមានទំហំធំទូលាយសម្រាប់ការរៀនសូត្រពីគ្នាទៅវិញទៅមក។
- ជាចុងក្រោយ នៅក្នុងការបង្កើត គ.ក.ន.ក ថ្មី វាជារឿងសំខាន់នៅក្នុងការផ្សព្វផ្សាយការងាររបស់ គ.ក.ន.ក និងអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ តាមរយៈកម្មវិធីវិទ្យុ និងទូរទស្សន៍ ដែលអាចធ្វើឱ្យសហគមន៍ និងរដ្ឋាភិបាល ព្រមទាំងភ្នាក់ងារមិនមែនរដ្ឋាភិបាលទាំងអស់ រៀបចំខ្លួនជាស្រេច និងចង់ធ្វើកិច្ចសហការជាមួយ គ.ក.ន.ក។

## ឆ.សមត្ថភាព និងការទុកចិត្ត

ដូចដែលបានកត់សំគាល់ពីខាងដើម តួនាទីរបស់អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ខុសពីសមាជិកផ្សេងៗទៀតរបស់ គ.ក.ន.ក។ អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់តំណាងឱ្យសហគមន៍ដោយកំណត់ និងធ្វើសកម្មភាពលើបញ្ហាស្ត្រី និងកុមារ ព្រមទាំងនាំសហគមន៍ឱ្យយកចិត្តទុកដាក់ទៅលើ គ.ក.ន.ក។ អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ក៏ធ្វើការតស៊ូមតិផងដែរក្នុងនាមស្ត្រី និងកុមារ ព្រមទាំងផ្តល់នូវវិធីផ្សេងៗដើម្បីធ្វើឱ្យបានជោគជ័យលើការផ្តល់សេវាដែលមានភាពខ្វះចន្លោះ។ តួនាទីរបស់ គ.ក.ន.ក គឺធ្វើការពិភាក្សា និងវិភាគបញ្ហាដែលបានកំណត់ ព្រមទាំងលើកជាអនុសាសន៍ដោយផ្អែកទៅលើការវិភាគ។ បន្ទាប់មកក្រុមប្រឹក្សាឃុំ សង្កាត់ ពិនិត្យឡើងវិញលើការផ្តល់អនុសាសន៍ និងធ្វើសេចក្តីសម្រេច ព្រមទាំងធ្វើការបែងចែកធនធាន និងត្រួតពិនិត្យគុណភាពសេវាដែលបានផ្តល់។

យើងមើលឃើញថា អ្នកទទួលបន្ទុកិច្ចការនារី និងកុមារឃុំ សង្កាត់ បានទទួលទំនុកចិត្តពីអ្នករួមការងារ និងសហគមន៍ មុននឹងគាត់អាចធ្វើការមានប្រសិទ្ធភាព។ ចំពោះអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ខ្លះ ទំនុកចិត្តនេះ អាចជាការប្រឈមមួយ។ ដូចនេះ ជំនាញទំនាក់ទំនង ជំនាញសម្របសម្រួល និងជំនាញការប្រាស្រ័យទាក់ទង គឺជាសមត្ថភាពមូលដ្ឋានដ៏សំខាន់សម្រាប់អ្នកទទួលបន្ទុកកិច្ចាការនារី និងកុមារឃុំ សង្កាត់។ អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ក៏អាចត្រូវការដើម្បីឆ្លើយតបទៅនឹងឋានានុក្រម និងប្រឈមមុខនឹងទំនៀមទំលាប់ប្រពៃណី ព្រមទាំងការរំពឹងទុកជាច្រើនរបស់ស្ត្រី និងកុមារ។ អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ អាចដោះស្រាយបញ្ហានេះបានដោយបង្ហាញពីអំណះអំណាងក្នុងការបញ្ចុះបញ្ចូលនៅក្នុងរបាយការណ៍ជាលាយលក្ខណ៍អក្សរ និងរាយការណ៍ផ្ទាល់មាត់តាមរយៈការចរចារ និងការមានឥទ្ធិពលទៅលើអ្នកដទៃ និងតាមរយៈការគាំទ្រនូវខិតខំប្រឹងប្រែងតស៊ូមតិរបស់គាត់ភ្ជាប់ជាមួយភស្តុតាងដែលមានស្រាប់។

ការពិចារណាដ៏សំខាន់មួយ គឺទទួលស្គាល់ថា សមាជិកគណៈកម្មាធិការទាំងអស់ មានភាពចម្រើនលូតលាស់ នៅក្នុងល្បឿនផ្សេងៗគ្នា ប៉ុន្តែស្មាដៃបំពេញការងារ ពិតជារីកចម្រើនតាមរយៈការអនុវត្ត។ ឆ្នាំទី១ គឺជាឆ្នាំហាត់រៀនធ្វើការមួយយ៉ាងសំខាន់ និងមានពេលគ្រប់គ្រាន់សម្រាប់ឱ្យ គ.ក.ន.ក កសាង និងរៀបចំខ្លួន។ ការធ្វើការជាក្រុមដោយ

មានកិច្ចសហការគ្នា គឺជាមូលដ្ឋានគ្រឹះដើម្បីភាពជោគជ័យ។ ការអន្តរាគមន៍លើការអភិវឌ្ឍសមត្ថភាព គួរតែផ្តោតជាដំបូងទៅលើការតម្រង់ទិស និងផ្តល់ឱកាសសម្រាប់ គ.ក.ន.ក ថ្មី ដើម្បីអនុវត្តការងារជាមួយ គ.ក.ន.ក ដែលមានស្រាប់នៅមូលដ្ឋាន (ឧទាហរណ៍តាមរយៈវេទិការៀនសូត្រថ្នាក់ស្រុក) និងបង្កើតឱកាដើម្បីធ្វើឱ្យសម្រេចបាន"ជ័យជំនះតូចៗ" ដែលជាការបង្កើតទំនុកចិត្តជាមួយអ្នកពាក់ព័ន្ធមកពីខាងក្រៅ។

ក្រុមបណ្តុះបណ្តាល ត្រូវការធ្វើការសិក្សាវាយតម្លៃពីតម្រូវការជាអាទិភាពបញ្ហាផ្សេងរបស់គណៈកម្មាធិការដូចជា ការកសាងផែនការ ការរៀបចំប្រជុំឱ្យមានប្រសិទ្ធភាព ការលើកកម្ពស់ការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការព្រមទាំងការកំណត់ និងដំណោះស្រាយបញ្ហាផ្សេងៗតាមរយៈផែនទីសេវាសង្គម និងការប្រើប្រាស់ព័ត៌មានដែលប្រមូលបានដើម្បីបង្កើតជាអនុសាសន៍។ ការខិតខំប្រឹងប្រែងអភិវឌ្ឍន៍សមត្ថភាពក៏ត្រូវការផងដែរដើម្បីធានាឱ្យមានតុល្យភាពជាក់លាក់ទៅលើសមត្ថភាពបែបឥរិយាបថ និងការទទួលបានជំនាញ និងចំណេះដឹងបច្ចេកទេស។

ចំពោះអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ និងសមាជិក គ.ក.ន.ក ផ្សេងទៀត ដែលធ្វើការជាមួយទិន្នន័យ ការវិភាគទិន្នន័យឱ្យបានស៊ីជម្រៅ អំណះអំណាងសម្រាប់បង្កើតសកម្មភាព និងចាត់អាទិភាពសកម្មភាពត្រូវទទួលស្គាល់ ដូចជាអាទិភាពមួយផ្តោតទៅលើតម្រូវការអន្តរាគមន៍បន្ថែម។

## Bibliography


Adams, L, 2007, *Gender analysis Training Manual*, Phnom Penh: Ministry of Women's Affairs (September, 2007)

Bloom, E, M Reeves, A Sunseri, and V Nyhan-Jones, 2008, Strengthening networks: Using Organisational Network Analysis to Promote Network Effectiveness, Scale and Accountability, *Capacity Development Briefs* (World Bank Institute), #28, August 2008

Committee for Participation of Women in Politics, 2008, *Empowerment of Women in Politics: Guidelines for Master Trainers*, UNDP/UNFPA/MoWA

DFID, 2005, *Reducing Poverty by Tackling Social Exclusion: A DFID policy paper*, Department for International Development (September 2005)

DIFID, 2005, *DFID Policy Paper: Reducing poverty by tackling social exclusion*, Department for International Development September 2005

Ferber, Natalie and Ek Puthy, 2008, *Administration Reform and Decentralisation Program: Assessment of the Sustainability of the Female Councillor forums*, GTZ/USAID/PACT/Oxfam/French Embassy (Phnom Penh, October 2008)

Gourley, Steve, 2009, *The Middle Way: Bridging the Gap between Cambodian Culture and Children's Rights*, NGO Committee on the Rights of the Child (NGOCRC)

Harknett, S, 2008 *Social Work Training Programme Evaluation Report*, UNICEF Cambodia (June 2005)

Horng, V and D Craig, 2008, *Accountability and Planning in Decentralised Cambodia,* Phnom Penh, Cambodia: Cambodia Development Resource Institute.

Horng, Vuthy, 2009, *UNFPA Review of 2008/2009 Commune Implementation Plans and Provincial Plans in UNFPA-supported Areas to Assess Integration and Implementation of Key Population, Reproductive Health, Gender, HIV/AIDS and Youth Issues*, UNFPA (Phnom Penh, August 2009)

Kirkpatrick, D.L. (1994). *Evaluating Training Programs: The Four Levels,* San Francisco, CA: Berrett-Koehler

Knowles, J, 2009, Constructing Participation: A Study of Cambodian Sensemaking of International Development Policies, Phnom Penh: VBNK

Land, Anthony and Peter Morgan, 2008, *Technical Cooperation for Capacity Development in Cambodia: Making the system Work better – final report*, CRDB/CDC in collaboration with the joint Technical Working Group on Partnership and Harmonisation (January 2008)

Fabienne Luco, 2002, *Between a Tiger and a Crocodile: Management of Local Conflicts in Cambodia, an Anthropological Approach to Traditional and New Practices*, Phnom Penh: UNESCO

Ministry of Women's Affairs, 2004, Guidelines on gender mainstreaming in the preparation process of the commune/sangkat 3-year rolling investment program (for trainers), Gender Mainstreaming Supporting Team in Seila Program

Ministry of Women's Affairs, 2004, *Guidelines on the use of tools and methods in mainstreaming gender in the 3-year rolling investment program*. Cambodia: MoWA

Ministry of Women's Affairs, 2006, *Monitoring and Advocacy for Women's Priorities and Evaluation*, Gender Mainstreaming in Local Governance Programme, MoWA

MOI/MoWA/UNICEF, 2008, *Commune Focal Point for Women and Children KAP (Knowledge, Attitudes and Practices) Study*, UNICEF Cambodia, Ministry of Women's Affairs, Ministry of Interior (March 2008)

McKay, E, 2009, *Capacity Building Framework for the Women's and Children's Consultative Committees and Related Institutions*, MoWA/UNICEF, November 2009

Moore, D. & McCabe, P. G, 1993, *Introduction to the practice of statistics* (2nd ed.). New York: W. H. Freeman and Company.

Morgan, P, 2005, *The Idea and Practice of Systems Thinking and their Relevance for Capacity Development*, Mimeo

Morgan, P, Land, T, Baser, H, 2005, Study on Capacity, change and performance, *ECDPM Discussion Paper 59A,* Maastricht: ECDPM, *http://www.ecdpm.org/dp59A*

MoWA, 1006, *Monitoring and Advocacy for Women's Priorities and Evaluation: Facilitators' Training Manual - Draft* (December 2006)

NCCD, 2007, Guideline on the organisation and establishment of the Committee for Women and Children for all Commune/Sangkat in Country, issued by the National Committee for the Management of Decentralisation and Deconcentration Reform (No. 082/NCDD, August 2007)

Nelson Mandela Foundation, 2007. *Youth Dialogue: Prevention is the key*. South Africa: Nelson Mandela Foundation. At: http://www.nelsonmandela.org/

O'Leary, Moira and Meas, Nee, 2001, *Learning for Transformation: A study of the relationship between culture, values, experience and development practice in Cambodia*. Phnom Penh: VBNK

O'Leary, Moira, 2007 *Values in Development Practice 3: The socio-cultural context and dilemmas in facilitating change,* VBNK

Pichara Leang, 2006, *Assessment of Commune Committees for Women and Children*, prepared by Dr Pichara Leang for UNICEF Cambodia, September 2006

Roberts, J, 2007, *Evaluation and Stakeholders Perceptions of the Training Centre for Counsellors and Social Workers*, GTZ/SSC (March 2007)

Rogers, C, 1969, *Freedom to Learn*, Columbus, Ohio: Merrill

Royal Government of Cambodia (2003). National population policy. Phnom Penh, Cambodia.

Royal Government of Cambodia, 2007, *Lessons Plan on Population and Development, Gender and Reproductive Health*, Secretariat for National Committee for Population and Development and Department of Local Administration

Secretariat for National Committee for Population and Development, 2007, *Reference Tool: National Population Policy*, Office of the Council of Ministers.

Seth Koma's Commune Committee for Women and Children and Commune Focal Points for Women and Children, Internal Document, 2006.

Storer, G, 2007, *Committee to Promote Women in Politics: Organisational Development Retreat (5-8 October, 2007)*, report prepared by Graeme Storer for the CPWP, with support from GTZ and the Heinrich Boll Foundation;

The Partnering Initiative, 2009, *The Partnering Toolbook: An essential guide to cross-sector partnering* (2nd edition). Available at: http://www.vbnk.org/publication.php

Copyright by The Partnering Initiative (2009) UNDP. 2005. Leadership for Results UNDP's response to HIV/AIDS: Community Capacity Enhancement Strategy Note. New York: UNDP. At; http://www.undp.org/HIV/docs/prog_guides/ldp_strategy_note.pdf

UNICEF Cambodia, 2006, *Seth Koma's Commune Committees for Women and Children and Commune Focal Points for Women and Children*, UNICEF Cambodia

UNICEF, 2008, Commune Women and Children Focal Point KAP Study, conducted in partnership with Ministry of Women's Affairs, Ministry of Interior and UNICEF (March 2008)

United Nations Population Fund (2006), Cambodia Country Programme Action Plan, Phnom Penh, Cambodia

United Nations Population Fund (2009), CPAP Planning and Tracking Tool – Based MTR 2008, Phnom Penh, Cambodia.

United Nations Population Fund, 2005, *Cambodia at a glance*, Phnom Penh, Cambodia

VBNK, 2008, *Transitions: Annual Report 2008*, available at: http://www.vbnk.org/Articles/Download/VBNK_2008_Annual_Report.pdf

VBNK, 2009, A Decade of Change: Community Conference 2009, available at: http://www.vbnk.org/Articles/A%20Community%20Conversation2009%20conference-english.pdf

World Bank, 2008, *Linking Citizens and the State,* Phnom Penh: World Bank.

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធទី១: លក្ខខណ្ឌការងារ

## ការសិក្សាវាយតម្លៃសមត្ថភាពគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ (គ.ក.ន.ក.), ឧបត្ថម្ភគាំទ្រដោយកម្មវិធីសិទ្ធិកុមារ នៃអង្គការយូនីសេហ្វ-កម្ពុជា

### ១. សាវតា

រាជរដ្ឋាភិបាលកម្ពុជាចាប់ផ្ដើមអាណត្តិរបស់ខ្លួននៅក្នុងឆ្នាំ១៩៩៣ តាមរយៈការបង្កើតស្ថាប័នប្រជាធិបតេយ្យ បន្ទាប់ពីការបញ្ចប់វិវាទដែលអូសបន្លាយរយៈពេលជាច្រើនឆ្នាំរួចមក។ រាជរដ្ឋាភិបាលកម្ពុជាមានការចាប់ផ្ដើមដ៏ល្អដើម្បីដោះស្រាយបញ្ហាប្រឈមនានារបស់ខ្លួន។ យុទ្ធសាស្ត្រស្ដីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាលកម្ពុជា កំពុងធ្វើឱ្យប្រជាពលរដ្ឋមានសម្លេងនៅក្នុងអភិបាលកិច្ច និងបានផ្ដល់សេវាសាធារណៈដល់ប្រជាពលរដ្ឋ នៅតាមមូលដ្ឋានកាន់តែមានលក្ខណៈល្អប្រសើរឡើងតាមរយៈការផ្ទេរសិទ្ធិអំណាច ការទទួលខុសត្រូវ និងធនធានពីរដ្ឋបាលថ្នាក់កណ្ដាលទៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

ក្របខ័ណ្ឌជំនួយអភិវឌ្ឍន៍របស់សហប្រជាជាតិ (២០០៦-២០១០) គូសបញ្ជាក់ថា មានការងារជាច្រើនទៀតដែលត្រូវធ្វើដើម្បីពង្រីកឱកាសឱ្យប្រជាពលរដ្ឋអាចមានឥទ្ធិពល និងចូលរួមនៅក្នុងអភិបាលកិច្ចមូលដ្ឋាន។

ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នៅក្នុងឆ្នាំ២០០២ បានធ្វើឱ្យឃុំ សង្កាត់ក្លាយជាស្ថាប័នសំខាន់មួយនៅក្នុងអភិបាលកិច្ចមូលដ្ឋាន។ ការបោះឆ្នោតនេះ បានផ្ដល់ឱកាសថ្មីសម្រាប់សហគមន៍ជនបទមានតួនាទីនៅក្នុងការធ្វើសេចក្ដីសម្រេចចិត្តដែលប៉ះពាល់ដល់ការរស់នៅរបស់ពួកគេ។ ឃុំ សង្កាត់ បានបង្កើនការចូលរួមនៅក្នុងការសម្រេចចិត្តក្នុងក្របខ័ណ្ឌនៃអាណត្តិរបស់ខ្លួនដើម្បីឱ្យប្រជាពលរដ្ឋទទួលបានសុខុមាលភាពល្អ។

ដំណើរការកំណែទម្រង់នេះ ផ្ដល់ឱកាសយ៉ាងល្អប្រសើរ ដើម្បីឱ្យមានការយកចិត្តទុកដាក់ចំពោះបញ្ហាធំៗដែលពាក់ព័ន្ធជាមួយនារី និងកុមារដើម្បីដាក់បញ្ចូលបញ្ហាទាំងនេះទៅក្នុងដំណើរការនយោបាយ និងការគ្រប់គ្រង។ អង្គការយូនីសេហ្វកំពុងធ្វើការជាមួយរដ្ឋាភិបាលដើម្បីធានាយ៉ាងណាឱ្យនារី និងកុមារមានតំណាងនៅក្នុងដំណើរការនេះ និងឱ្យមានការកំណត់តួនាទី និងមុខងារសំខាន់ៗរបស់រដ្ឋាភិបាលថ្នាក់ក្រោមជាតិក្នុងការផ្ដល់សេវាសាធារណៈជាមូលដ្ឋាន និងប្រែក្លាយតួនាទី និងមុខងារទាំងនេះឱ្យក្លាយជាឧបករណ៍ច្បាប់ ។ ដើម្បីសម្រេចបានគោលដៅនេះ អង្គការយូនីសេហ្វកំពុងធ្វើការដើម្បីពង្រឹងសមត្ថភាពរដ្ឋាភិបាលថ្នាក់ក្រោមជាតិ ជាពិសេសឃុំ សង្កាត់ លើផ្នែកកសាងផែនការ តាមបែបវិមជ្ឈការ ការគ្រប់គ្រង និងការផ្ដល់សេវាសាធារណៈសម្រាប់កុមារ។

ជាមួយធនធានថ្មីៗទាំងនេះ ក្រុមប្រឹក្សាឃុំ សង្កាត់ មានឱកាសធ្វើការសម្រេចចិត្តអំពីរបៀបចំណាយមូលនិធិទាំងនេះ។ ទោះបីជាយ៉ាងណា ដោយសារតែភាពចាំបាច់ ដើម្បីស្ដារឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធរបស់ប្រទេស បន្ទាប់ពីរយៈពេលនៃជំលោះ ដែលភាគច្រើននៃជំនួយអភិវឌ្ឍន៍នៅថ្នាក់ក្រោមជាតិក្នុងប្រទេសកម្ពុជា បានផ្ដោតលើគម្រោង

ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ដូចជា ការសាងសង់ផ្លូវថ្នល់ និងស្ពានថ្មីជាដើម។ សូចនាករបង្ហាញពីភាពរីកចម្រើនផ្នែកនារី និងកុមារនៅតែមានកម្រិតទាប ជាពិសេសនៅតំបន់ជនបទ ហើយសូចនាករខ្លះទៀត ដូចជាសូចនាករផ្នែកមរណៈភាពមាតា និងទារកទើបកើតនៅមិនទាន់មានភាពប្រសើរនៅឡើយ។ អង្គការយូនីសេហ្វ កំពុងធ្វើការងារជាមួយរដ្ឋបាលនៅថ្នាក់ខេត្ត និងថ្នាក់ស្រុក និងក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីធ្វើឱ្យមានតុល្យភាពនៃការលម្អៀងនេះ សំដៅទៅរកការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ ដោយបង្កើនការយល់ដឹងអំពីសារៈសំខាន់នៃការវិនិយោគលើសេវាសង្គម និងបង្កើនសមត្ថភាពដើម្បីបង្កលក្ខណៈឱ្យប្រជាពលរដ្ឋចូលរួមកាន់តែច្រើនជាងមុននៅក្នុងការទាមទារឱ្យមានសេវាចាំបាច់នានា។ ហើយក៏មានភាពចាំបាច់ផងដែរ ដើម្បីផ្តល់ការគាំទ្រដល់រដ្ឋបាលនៅថ្នាក់មូលដ្ឋាន និងសហគមន៍នៅក្នុងការធ្វើឱ្យមានគណនេយ្យភាពក្នុងការផ្តល់សេវាដែលផ្តល់ដោយកម្មវិធីតាមវិស័យនៃខ្សែបណ្តោយរបស់រដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល សហគមន៍ និងផ្នែកឯកជន។

## បទពិសោធន៍មកដល់ពេលបច្ចុប្បន្នរបស់ក្រុមប្រឹក្សាឃុំ សង្កាត់នៅក្នុងការធ្វើឱ្យប្រសើរឡើងការផ្តល់សេវានៅមូលដ្ឋាន

ក្រសួងមហាផ្ទៃ ដោយមានការគាំទ្រពីអង្គការយូនីសេហ្វ បានសាកល្បងបង្កើតគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់(គ.ក.ន.ក) ដើម្បីផ្តល់យោបល់ដល់ក្រុមប្រឹក្សាឃុំ សង្កាត់ និងមេឃុំ ចៅសង្កាត់ ដែលបានជ្រើសរើស លើបញ្ហានានាដែលពាក់ព័ន្ធនឹងនារី និងកុមារ។ នៅថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៤ ក្រសួងមហាផ្ទៃបានចេញសេចក្តីណែនាំលេខ ០០៥ ដើម្បីបង្កើតជាផ្លូវការនូវគណៈកម្មាធិការនៅឃុំមួយចំនួនក្នុងខេត្ត ដែលមានការគាំទ្រពីអង្គការយូនីសេហ្វ។

សមាជិករបស់គណៈកម្មាធិការនេះរួមមានតំណាងមកពីក្រុមប្រឹក្សាឃុំ សង្កាត់ ដូចជាមេឃុំ/ចៅសង្កាត់ ជំទប់ទី២/ចៅសង្កាត់រងទី២ តំណាងមណ្ឌលសុខភាព និងតំណាងសាលារៀនដែលផ្តល់សេវានៅក្នុងឃុំ សង្កាត់។ វត្តមានរបស់គ.ក.ន.ក គឺជួយផ្តល់ការគាំទ្រដល់អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ហើយធានាថាអ្វីដែលគាត់បានលើកឡើងត្រូវបានយកទៅធ្វើការពិចារណានៅក្នុងដំណើរការធ្វើការសម្រេចចិត្តរបស់ក្រុមប្រឹក្សាឃុំ សង្កាត់។ គ.ក.ន.ក ក៏មានតួនាទីសំខាន់នៅក្នុងការធានាឱ្យមានការសម្របសម្រួលឱ្យបានជិតស្និទ្ធបន្ថែមទៀតរវាងឃុំ សង្កាត់ និងអ្នកផ្តល់សេវាសង្គមសំខាន់ៗដល់កុមារ (ដូចជាទំនាក់ទំនងជាមួយសាលារៀន មណ្ឌលសុខភាព អ្នកធ្វើការងារសង្គម និងតុលាការ)។ គ.ក.ន.ក ជួយលើកទឹកចិត្តសហគមន៍ ជាពិសេសក្រុមដែលងាយរងគ្រោះនៅក្នុងសហគមន៍ទាំងនោះ ឱ្យដឹងពីតម្រូវការរបស់ពួកគេឱ្យបានច្បាស់លាស់ និងសំដៅឱ្យពួកគេទទួលបានសេវាសមស្របទៅនឹងតម្រូវការទាំងនោះ ហើយធានាឱ្យមានសមធម៌នៅក្នុងការទទួលបានសេវា និងតាមដានពិនិត្យការផ្តល់សេវា និងគុណភាពសេវារបស់គេ។

នៅចុងឆ្នាំ ២០០៤ គ,ក,ន,ក ចំនួន១៣០ ត្រូវបានបង្កើតឡើង។ នៅឆ្នាំ២០០៧ ក្រសួងមហាផ្ទៃសំណូមពរឱ្យមានការបង្កើតគណៈកម្មាធិការនេះនៅទូទាំងប្រទេស និងបន្ថែមសមាជិកភាពរបស់គណៈកម្មាធិការនេះដោយបញ្ចូលមេឃុំ ចៅសង្កាត់ ស្មៀនឃុំ សង្កាត់ តំណាងប៉ុស្តិ៍នគរបាលរដ្ឋបាល និងមេភូមិ។ នៅក្នុងកិច្ចប្រជុំប្រចាំឆ្នាំរបស់គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ (គ,ជ,វ,វ) ឆ្នាំ២០០៧ ក្រសួងមហាផ្ទៃ

បានស្នើឱ្យក្រុមប្រឹក្សាឃុំ សង្កាត់រ៉ាប់រងចំណាយប្រតិបត្តិការរដ្ឋបាលរបស់ គ.ក.ន.ក និងសម្រាប់ឧបត្ថម្ភគ្រូមត្តេយ្យសិក្សាសហគមន៍នៅក្នុងឃុំចំនួន៣១៧ដែល មានការគាំទ្រពីអង្គការយូនីសេហ្វ។ នៅឆ្នាំ២០០៧ គ.ជ.វ.វ បានចេញសេចក្តីណែនាំលេខ០៨២ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០០៧ ដើម្បីបង្កើត គ.ក.ន.ក នៅទូទាំងប្រទេស(១៦២១ឃុំ សង្កាត់)។ នៅឆ្នាំ ២០០៨ គ.ជ.វ.វ បានសៀវភៅណែនាំស្តីពីការអនុវត្តមុខងាររបស់ គ.ក.ន.ក និងបានរៀបចំសិក្ខាសាលាមួយនៅថ្នាក់ជាតិ និងបានផ្តល់វគ្គតម្រង់ទិសដល់គ្រប់អង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត នៅក្នុងខេត្ត ក្រុងទាំង២៤។

លទ្ធផលបឋមនៃការវាយតម្លៃ គ.ក.ន.ក ក្នុងឆ្នាំ២០០៦ និងការអង្កេតលើចំណេះដឹង ឥរិយាបថ និងការអនុវត្តរបស់អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ ក្នុងឆ្នាំ២០០៧ បង្ហាញថា ពួកគេកំពុងធ្វើឱ្យមានផលជាវិជ្ជមាន ហើយបញ្ហាពាក់ព័ន្ធនារី និងកុមារក្នុងវិស័យអប់រំ និងសុខភាពនៅក្នុងឃុំ ទទួលបានអាទិភាពខ្ពស់ជាង បើប្រៀបធៀបជាមួយឃុំ សង្កាត់ដែលគ្មានការគាំទ្រពីអង្គការយូនីសេហ្វ។ ការវាយតម្លៃឆ្នាំ២០០៦ បានបង្ហាញថា សកម្មភាពរបស់ គ.ក.ន.ក គឺជាកត្តាកំណត់ដ៏សំខាន់មួយនៃការដាក់បញ្ចូលបញ្ហារបស់នារី និងកុមារទៅក្នុងរបៀបវារៈនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងទៅក្នុងដំណើរការកសាងផែនការការអភិវឌ្ឍន៍របស់ឃុំ សង្កាត់។ ការពិភាក្សាជាមួយដៃគូនានាសម្រាប់ការពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិក៏បានរកឃើញផងដែរថាក្រុមប្រឹក្សាឃុំ សង្កាត់ កំពុងខិតខំបំពេញតួនាទីបច្ចុប្បន្នរបស់ពួកគេ ហើយក្នុងនាមជា គ.ក.ន.ក(គណៈកម្មាធិការផ្លូវការ) គឺកំពុងដើរតួនាទីយ៉ាងសំខាន់នៅក្នុងការជួយពង្រីកអាណត្តិការងាររបស់រដ្ឋាភិបាលមូលដ្ឋាន ដើម្បីធ្វើឱ្យប្រសើរឡើងនៃការផ្តល់សេវាសង្គម នៅក្នុងមូលដ្ឋាន។

គ.ក.ន.ក មានឱកាសបានចូលរួមនៅក្នុងវគ្គបណ្តុះបណ្តាលជាច្រើន ដែលជួយពួកគេឱ្យបំពេញតួនាទីរបស់ខ្លួនបាន។ ប៉ុន្តែវិធីសាស្ត្របែបនេះនៅមិនទាន់មានលក្ខណៈគ្រប់ជ្រុងជ្រោយ ឬជាលក្ខណៈយុទ្ធសាស្ត្រនៅឡើយទេ។ នៅពេលមានការពង្រីក គ.ក.ន.ក ឱ្យមាននៅទូទាំងប្រទេសក្នុងឆ្នាំ២០០៧ សមាជិក គ.ក.ន.ក នៅមានការយល់ដឹងតិចតួចអំពីតួនាទី និងការទទួលខុសត្រូវរបស់ខ្លួននៅឡើយ។ ការងាររបស់ គ.ក.ន.ក ច្រើនតែជាការងារដដែលៗ ហើយគំនិតច្នៃប្រឌិតនៅមានកម្រិត ជាពិសេសក្នុងការដោះស្រាយបញ្ហាដែលកើតមាននៅក្នុងឃុំ សង្កាត់ដូចជា សិទ្ធិរបស់អ្នកទទួលបានផលប្រយោជន៍តិចជាងគេជាដើម។ ការពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិ បានផ្តល់ជាអនុសាសន៍ថា គួរមានការផ្តោតការយកចិត្តទុកដាក់បន្ថែមទៀតលើការបង្កើនការគាំទ្រដល់កម្រិតឃុំ សង្កាត់។

ដោយសារតែមូលហេតុទាំងអស់នេះហើយ បានកម្មវិធីសិទ្ធិកុមារចង់ដឹកនាំការសិក្សាវាយតម្លៃសមត្ថភាព និងបង្កើតជាយុទ្ធសាស្ត្រអភិវឌ្ឍន៍សមត្ថភាពមួយ ហើយលទ្ធផលដែលបានរកឃើញពីការងារនេះ នឹងត្រូវបានចែករំលែកទៅឱ្យអង្គភាពរបស់រដ្ឋាភិបាលដែលធ្វើការពាក់ព័ន្ធវិមជ្ឈការ និងវិសហមជ្ឈការ ព្រមទាំងដៃគូអភិវឌ្ឍន៍នានា និងយកដាក់បន្ស៊ីជាមួយផែនការអភិវឌ្ឍន៍សមត្ថភាពរបស់គណៈកម្មាធិការជាតិ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)។

## ២.គោលបំណងនៃការសិក្សាវាយតម្លៃ

**ការសិក្សាវាយតម្លៃសមត្ថភាពនេះ មានគោលបំណង:**

១. សិក្សាវាយតម្លៃលើសមត្ថភាពបច្ចុប្បន្នរបស់ គ,ក,ន,កក្នុងការបំពេញភារៈកិច្ចនៅក្នុងអាណត្តិរបស់ពួកគេ (ដូចដែលបានចែងនៅក្នុងសេចក្តីណែនាំលេខ ០៨២ សណន ចុះថ្ងៃទី ៨ ខែសីហា ឆ្នាំ២០០៧ របស់ គ.ជ.វ.វ)

២. បង្កើតយុទ្ធសាស្ត្រអភិវឌ្ឍន៍សមត្ថភាពគ្រប់ជ្រុងជ្រោយមួយដើម្បីគាំទ្រការអភិវឌ្ឍស្ថាប័នរបស់ គ.ក.ន.ក ដើម្បីបំពេញភារៈកិច្ចនៅក្នុងអាណត្តិរបស់ខ្លួន។

វិសាលភាពនៃការសិក្សាវាយតម្លៃនេះ រួមមានដូចខាងក្រោម :

## <u>សមាសធាតុទី១</u>: ធ្វើការសិក្សាវាយតម្លៃលើសមត្ថភាពរបស់ គ.ក.ន.ក

ការវាយតម្លៃលើសមត្ថភាពបច្ចុប្បន្នរបស់ គ.ក.ន.ក គួរតែ : សិក្សាវាយតម្លៃលើចំណេះដឹង និងជំនាញ បញ្ហាប្រឈមផ្នែកហិរញ្ញវត្ថុ និងផ្នែកធនធានមនុស្ស និងកំណត់ការភ្ជាប់ទំនាក់ទំនងរវាង គ.ក.ន.ក ជាមួយអ្នកផ្សេងៗទៀតនៅក្នុងមូលដ្ឋាន។ ជាពិសេស ការសិក្សាវាយតម្លៃនេះ គួរពិនិត្យឡើងវិញលើការភ្ជាប់ទំនាក់ទំនងរវាង គ.ក.ន.ក ជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ គណៈកម្មាធិការគ្រប់គ្រងមណ្ឌលសុខភាព គណៈកម្មាធិការទ្រទ្រង់សាលារៀន គណៈកម្មការវត្ត ក្រុមទ្រទ្រង់សុខភាពភូមិ និងក្រុមអ្នកប្រើប្រាស់ទឹកស្អាត និងអនាម័យ។ ការសិក្សាវាយតម្លៃនេះ គួរសិក្សាពីការភ្ជាប់ទំនាក់ទំនងប្រកបដោយសក្តានុពលជាមួយគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារថ្នាក់ស្រុក និងថ្នាក់ខេត្តដែលនឹងបង្កើតក្នុងពេលឆាប់ៗខាងមុខ។ល។ ហើយគួរឆ្លើយទៅនឹងសំណួរថា តើត្រូវធ្វើយ៉ាងណាដើម្បីបញ្ជ្រាបការងាររបស់ គ.ក.ន.ក ឱ្យបានកាន់តែល្អជាងមុន ទៅក្នុងការងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់។

ផ្អែកតាមទិន្នន័យដែលមានស្រាប់ និងការសម្ភាសន៍ជាមួយអ្នកពាក់ព័ន្ធសំខាន់ៗ ទីប្រឹក្សាពិគ្រោះយោបល់ គួរបង្កើតឯកសារកម្រងសមត្ថភាពរយៈពេលវែងមួយសម្រាប់ធ្វើជាត្រីវិស័យក្នុងការអភិវឌ្ឍស្ថាប័នរយៈពេលវែងរបស់ គ.ក.ន.ក (រយៈពេលពី ៥-១០ ឆ្នាំ)។

របាយការណ៍ស្តីពីរកបកគំហើញលទ្ធផលដំបូងគួរដាក់ជូនក្រសួងមហាផ្ទៃ (នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន) ដើម្បីធ្វើការពិនិត្យឡើងវិញ និងពិភាក្សាជាមួយអ្នកពាក់ព័ន្ធសំខាន់ៗ បន្ទាប់ពីការបញ្ចប់សមាសធាតុទីមួយ។

## <u>សមាធាតុទី២</u>: បង្កើតយុទ្ធសាស្ត្រអភិវឌ្ឍន៍សមត្ថភាពសម្រាប់ គ.ក.ន.ក

ការងារនេះ គួរពិនិត្យឡើងវិញលើវិធីសាស្ត្រអភិវឌ្ឍន៍សមត្ថភាពដែលមានស្រាប់ និងផ្តល់អនុសាសន៍អំពីការប្រើប្រាស់សកម្មភាពរៀនសូត្រដែលមានស្រាប់, ការប្រើប្រាស់ធនធានមនុស្ស និងធនធានហិរញ្ញវត្ថុ, ការភ្ជាប់ទំនាក់ទំនងជាមួយគណៈកម្មាធិការដទៃទៀត រាប់បញ្ចូលទាំងសក្តានុពលសម្រាប់បង្កើតទំនាក់ទំនងជាមួយតួនាទីថ្មីៗរបស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារថ្នាក់ស្រុក និងថ្នាក់ខេត្ត ដែលនឹងបង្កើតឡើងនៅក្នុងខែឧសភា ឆ្នាំ២០០៩។

យុទ្ធសាស្ត្រអភិវឌ្ឍន៍សមត្ថភាពសម្រាប់ គ.ក.ន.ក នឹងត្រូវបង្ហាញដល់អង្គការយូនីសេហ្វ ក្រសួងមហាផ្ទៃ និងអ្នកដែលមានការពាក់ព័ន្ធនានា។

## ៣.លទ្ធផលការងារ

### សមាសធាតុទី១: ការសិក្សាវាយតម្លៃសមត្ថភាព គ.ក.ន.ក

ក. ផែនការការងារសម្រាប់រយៈពេលនៃការសិក្សា ដែលមានការយល់ព្រមពីអង្គការយូនីសេហ្វ

ខ. សម្របសម្រួលសិក្ខាសាលាជាមួយក្រសួងមហាផ្ទៃ អង្គការយូនីសេហ្វ និងដៃគូនានា

គ. របាយការណ៍បញ្ចប់ដែលកំណត់ពីគម្លាតនៃសមត្ថភាព

### សមាសធាតុទី២: យុទ្ធសាស្ត្រអភិវឌ្ឍន៍សមត្ថភាពដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ

ឃ. សេចក្តីព្រាងដំបូងនៃឯកសារស្តីពីការអភិវឌ្ឍសមត្ថភាពដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ (សកម្មភាព រៀនសូត្រ ការពង្រឹងធនធានមនុស្ស និងហិរញ្ញវត្ថុ ឱកាសចងក្រងបណ្តាញការងារ ឯកសារណែនាំ។ល។)

ង. បទបង្ហាញរបកគំហើញពីការសិក្សា សម្រាប់រដ្ឋាភិបាល និងអ្នកពាក់ព័ន្ធសំខាន់ៗនៅក្នុងការិយាល័យរបស់អង្គាការយូនីសេហ្វ

ច. របាយការណ៍សិក្សាវាយតម្លៃចុងក្រោយ រាប់បញ្ចូលទាំងគម្រោងលម្អិតនៃកម្មវិធីសិក្សា។

## ៤.ទំហំការងារនៃការសិក្សាវាយតម្លៃ

ទីប្រក្សាពិគ្រោះយោបល់ ត្រូវបំពេញការងារនេះឱ្យបានម៉ត់ចត់តាមដែលអាចធ្វើទៅបានដើម្បីផ្តល់ព័ត៌មាន និងអនុសាសន៍។ គេរំពឹងថាទីប្រឹក្សាដែលធ្វើការសិក្សាស្រាវជ្រាវនេះ នឹងដឹកនាំការសិក្សាវាយតម្លៃតាមបែបការចូលរួមមួយ ដោយមានការចូលរួមពីសំណាក់អ្នកពាក់ព័ន្ធសំខាន់នៅក្នុងគ្រប់ការងារសិក្សាវាយតម្លៃសំខាន់ៗទាំងអស់ ដែលរួមចំណែកដើម្បីពង្រឹងចំណេះដឹង និងជំនាញនៅក្នុងតំបន់គោលដៅរបស់គម្រោង។ អ្នកពាក់ព័ន្ធទាំងនេះ នឹងបង្កើតជាផ្នែកនៃក្រុមពិគ្រោះយោបល់មួយដែលនឹងជួយផ្តល់ដំបូន្មានលើការងារសិក្សាវាយតម្លៃនេះ និងផ្តល់ព័ត៌មានត្រឡប់លើសេចក្តីព្រាងលទ្ធផលការងារសំខាន់ៗ។ រាល់ឯកសារគម្រោងដែលមានស្រាប់ និងរបាយការណ៍រីកចម្រើន នឹងធ្វើការចែករំលែកជាមួយទីប្រឹក្សាពិគ្រោះយោបល់លើការសិក្សាវាតតម្លៃ ដើម្បីសម្របសម្រួលការបញ្ចប់កិច្ចការនេះ។

ការសិក្សាវាយតម្លៃនេះ នឹងធ្វើឡើងនៅក្នុងឃុំចំនួន១៥ នៅក្នុងខេត្តចំនួន៥ (១០ឃុំនៅក្នុងខេត្តគោលដៅចំនួន៣ដែលគាំទ្រដោយអង្គការយូនីសេហ្វ និង៥ឃុំនៅក្នុងខេត្ត២ផ្សេងទៀត)។ ការសិក្សាវាយតម្លៃនេះគួររាប់បញ្ចូលទាំងការពិភាក្សាជាមួយក្រុមគោលដៅ គ.ក.ន.ក, ក្រុមសម្របសម្រួល និងមន្ត្រីបង្គោលកម្មវិធីសិទ្ធិកុមារថ្នាក់ខេត្ត និងស្រុក, មន្ទីរពាក់ព័ន្ធ អ្នកផ្តល់សេវា ឪពុកម្តាយ និងសមាជិកផ្សេងទៀតនៅក្នុងសហគមន៍ដូចជាក្រុមទ្រទ្រង់សុខភាពភូមិ ក្រុមម៉ែបង្គោល ក្រុមអ្នកប្រើប្រាស់ទឹកស្អាត និងអនាម័យ ។ល។

**ធនធាន ៖**

ការពិគ្រោះយោបល់នេះ គួរប្រើប្រាស់ការងារដែលមានស្រាប់នៅក្នុងផ្នែកទាំងនេះ ៖

- ឯកសារបណ្តុះបណ្តាលអំពីសិទ្ធកុមារ សុខភាព អប់រំ កិច្ចការពារកុមារ និងទឹកស្អាត និងអនាម័យដែលគាំទ្រដោយ NCDD, PSDD, MOI, MOWA, MOH, MOEYS, MOSVY, MRD, UNFPA និង UNICEF
- វេទិកាតស៊ូមតិ ដែលសម្របសម្រួលដោយអង្គការចំរើនស្ត្រី (WfP)
- ការបណ្តុះបណ្តាលជំនាញ និចំណេះដឹងមូលដ្ឋានពាក់ព័ន្ធការងារសង្គមដល់ភ្នាក់ងារសង្គមកិច្ចស្រុក ដែលរៀបចំដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- កម្មវិធីសិក្សាសង្គម ដែលរៀបចំដោយ MOI, NAA, MOSVY
- ឧបករណ៍សិក្សាវាតតម្លៃរបស់ UNFPA ដែលគ្របដណ្តប់លើវិស័យចំនួន៣ រួមមាន ប្រជាជន យេនឌ័រ និងសុខភាពបន្តពូជ
- ការពិគ្រោះយោបល់ពីការសម្របសម្រួលប្រកបដោយសក្តានុពលរវាង គ.ក.ន.ក និងស្ថាប័នដែលធ្វើការងារពាក់ព័ន្ធនឹងសុខភាពនៅក្នុងខេត្តតាកែវ ដែលគាំទ្រដោយកាកបាទក្រហមស្វីស(Swiss Red Cross)
- ការពិគ្រោះយោបល់ពីការសិក្សាវាយតម្លៃសមត្ថភាពផ្នែកកិច្ចការពារសង្គម ដែលគាំទ្រដោ DFID

## ៥.ដៃគូនៃការវាយតម្លៃ

គម្រោងនេះមានភាពពាក់ព័ន្ធជាមួយវិស័យជំនាញរបស់ក្រសួង និងភ្នាក់ងារជាច្រើនដូចជាៈ NCDD, PSDD, UNDP, UNFPA, PACT, WB និងក្រសួងនានា (MOI, MOP, MRD, MOWA, MOEYS, MOH, MOSVY និងមន្ទីរខ្សែបណ្តាយរបស់ក្រសួងទាំងនេះ នៅក្នុងខេត្តចំនួន៥ ដែលបានជ្រើរើស ។

អង្គការយូនីសេហ្វ នឹងគ្រប់គ្រងការអនុវត្តក្នុងការសិក្សាវាយតម្លៃនេះដោយធ្វើការសម្របសម្រួលជាមួយអ្នកពាក់ព័ន្ធតាមវិស័យ ជាពិសេសក្រសួងមហាផ្ទៃ/នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន និង គ.ជ.អ.ប ។

## ៦.ការងារដែលត្រូវបំពេញ

ទីប្រឹក្សាម្នាក់ នឹងត្រូវជ្រើសរើសសម្រាប់ការងារនេះ ដើម្បីទំនាក់ទំនងជាមួយក្រុមផ្តល់យោបល់ ដែលមានសមាសភាពជាតំណាងមកពី MOI/DOLA និងដៃគូពាក់ព័ន្ធ ដើម្បីបង្កើតវិធីសាស្ត្រ និងឧបករណ៍សិក្សាវាយតម្លៃ, សម្របសម្រួលការសិក្សាបង្កើតកម្មវិធីសិក្សាដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងព្រាងរបាយការណ៍ នៃការសិក្សាវាយតម្លៃចុងក្រោយ, សម្របសម្រួលសិក្ខាសាលា និងធ្វើបទបង្ហាញ ។

## ៧.លក្ខណៈសម្បត្តិ ឬចំណេះដឹងបទពិសោធន៍ឯកទេសដែលត្រូវមាន

### លក្ខណៈសម្បត្តិ និងបទពិសោធន៍អប្បបរមា

- មានសញ្ញាបត្រអនុបណ្ឌិតដែលពាក់ព័ន្ធ នឹងកិច្ចការដែលត្រូវធ្វើ (រដ្ឋបាលសាធារណៈ គោលនយោបាយអំពីការអភិវឌ្ឍ ការធ្វើផែនការ ការអភិវឌ្ឍសមត្ថភាពក្រុមប្រឹក្សាឃុំ សង្កាត់ វិមជ្ឈការ ឬជំនាញពាក់ព័ន្ធ

- មានបទពិសោធន៍យ៉ាងតិច៧ឆ្នាំក្នុងការងារវិមជ្ឈការ វចនាសម្ព័ន្ធចាត់ចែង ប្រព័ន្ធត្រួតពិនិត្យនិងការគ្រប់គ្រងការងារ
- មានចំណេះដឹងអំពីបញ្ហារសុខភាព អប់រំ និងកិច្ចការពារសង្គមនៅថ្នាក់ក្រោមជាតិ
- មានចំណេះដឹងអំពីមុខងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងគណៈកម្មាធិការនានារបស់ឃុំ

**ជំនាញ/សមត្ថភាព**

- មានជំនាញស្រាវជ្រាវសង្គមតាមបែបវិភាគ និងជំនាញសម្របសម្រួល
- មានជំនាញវិភាគ ប្រាស្រ័យទាក់ទងជាភាសាអង់គ្លេស ធ្វើបទបង្ហាញ និងសរសេររបាយការណ៍ស្ទាត់ជំនាញ
- ចេះប្រើប្រាស់ឧបករណ៍វាយតម្លៃតាមបែបចូលរួម
- មានបទពិសោធន៍ធ្វើការងារនៅក្នុងប្រទេសកម្ពុជាយ៉ាងហោចណាស់រយៈពេល៥ឆ្នាំ

## ៨.រយៈពេលកិច្ចសន្យា (កាលបរិច្ឆេទ និងរយៈពេល)

-រយៈពេល១២សប្តាហ៍ រួមទាំងការបញ្ចប់របាយការណ៍ (ចាប់ពីខែសីហា ដល់ខែវិច្ឆិកា ឆ្នាំ២០០៩)។

## ៩.កាលវិភាគការងារ

ទីប្រឹក្សាត្រូវបង្កើតផែនការការងារដើម្បីបញ្ចប់សមាសធាតុទាំង២។ ទីប្រឹក្សានឹងធ្វើការក្នុងទីក្រុងភ្នំពេញ និងនៅក្នុងខេត្តដែលទទួលបាន និងមិនទទួលបានការគាំទ្រពីយូនីសេហ្វ ក្នុងរយៈពេលមួយ។ ចុងក្រោយ ទីប្រឹក្សាត្រូវរៀបចំរបាយការណ៍ និងផ្ញើររបាយការណ៍មកយូនីសេហ្វ ដើម្បីផ្តល់យោបល់ និងរៀបចំរបាយការណ៍ចុងក្រោយដើម្បីបញ្ចូលយោបល់ទាំងនេះ។

ការវាយតម្លៃនេះនឹងធ្វើឡើងក្នុងរយៈពេល១២សប្តាហ៍ សម្រាប់ការវាយតម្លៃសមត្ថភាពជារួម និងការបង្កើតកម្មវិធីសិក្សាដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយសម្រាប់ គ.ក.ន.ក ។ កាលវិភាគការងារមាននៅក្នុងចំណុចទី១០។

## ១០.លទ្ធផលការងារ រួមជាមួយនឹងការបរិច្ឆេតកំណត់

**១, ការវាយតម្លៃសមត្ថភាពរបស់ គ.ក.ន.ក : រយៈពេល៨សប្តាហ៍**

- ផែនការការងារដែលមានការឯកភាពពីយូនីសេហ្វ: ២សប្តាហ៍ បន្ទាប់ពីថ្ងៃចាប់ផ្តើម
- ឯកសារព្រាងដំបូងនៃលទ្ធផលរកឃើញពីសិក្សាវាយតម្លៃ: ៦សប្តាហ៍ បន្ទាប់ពីថ្ងៃចាប់ផ្តើម
- សម្របសម្រួលសិក្ខាសាលា: ៧សប្តាហ៍បន្ទាប់ពីថ្ងៃចាប់ផ្តើម
- បង្ហើយបញ្ចប់របាយការណ៍: ៨សប្តាហ៍បន្ទាប់ពីថ្ងៃចាប់ផ្តើម

**២, យុទ្ធសាស្ត្រអភិវឌ្ឍន៍សមត្ថភាពដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយរយៈពេល ៤សប្តាហ៍**

- ឯកសារព្រាងដំបូងនៃយុទ្ធសាស្ត្រអភិវឌ្ឍន៍សមត្ថភាព ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ: ១០សប្តាហ៍បន្ទាប់ពីថ្ងៃចាប់ផ្តើម
- ការបង្ហាញលទ្ធផលរកឃើញដល់រដ្ឋាភិបាល អ្នកពាក់ព័ន្ធ និងស្ថាប័នដទៃទៀតនៅ ការិយាល័យរបស់អង្គការយូនីសេហ្វ : ១១សប្តាហ៍

- របាយការណ៍វាយតម្លៃចុងក្រោយ ដែលរាប់បញ្ចូលកម្មវិធីសិក្សាដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងការធ្វើបទបង្ហាញដល់អង្គការយូនីសេហ្វ និងក្រសួងមហាផ្ទៃ (១២ សប្តាហ៍) មុនចុងខែវិច្ឆិកា ឆ្នាំ២០០៩ (សន្មត់ថាដៃគូនានានឹងផ្តល់ព័ត៌មានត្រឡប់ទាន់ពេលវេលា) ។ កាលបរិច្ឆេទចុងក្រោយសម្រាប់ផ្ញើររបាយការណ៍ទៅកាន់ក្រសួងមហាផ្ទៃ គឺមិនត្រូវលើសពី ១៤សប្តាហ៍ក្រោយពេលចាប់ផ្តើម ។

# ឧបសម្ព័ន្ធទី២: បញ្ជីឈ្មោះអ្នកចូលរួមសម្ភាសន៍សំខាន់ៗ

| Name | Contact information |
|---|---|
| Chnep Thy | CEO, LWF, Kampng Speu |
| Choun Ry | PFT, Kampng Speu |
| Elaine McKay | Independent consultant |
| Em Sreypov | Friend, Kampng Speu |
| Eng Chheanghong | Coordinator, Plan, chheanghong.eng@plan-international.org |
| Ha Chenda | PC, NAPA, Kampong Speu |
| Heng BounThoeun | Staff, Friend, Kampong Speu |
| Hilda Winarta | hwinarta@unicef.org |
| Jean-Yves Dekeister | Advisor, Swiss Red Cross, jykampot@mfone.com.kh 012 823 400 |
| Jes Sinat | Member, Kampong Speu |
| Jolanda Van Westering | Child Protection Specialist, UNICEF Cambodia |
| Julia Rees | Chief of Basic Services, Seth Koma, UNICEF Cambodia, jrees@unicef.org |
| Keo Borey | DFT, Kampng Speu |
| Keo Sarith | DFT, Kampng Speu |
| Kerstin Karlstrom | Education Specialist, UNICEF Cambodia, kkarlstrom@unicef.org |
| Khem Sarat | Assistant, Kampong Speu |
| Khem Vichet | PM, LWF, Kampng Speu |
| Kiean Socheat | CEO, LWF, Kampng Speu |
| Kim Vorn | DFT, Kampng Speu |
| Lam Vay | Capacity Building Officer, PSDD, MOI-DOLA, lamvay@ncdd.org.kh |
| Lam Vay | Capacity Building Officer, PSDD, MOI-DOLA, lamvay@ncdd.org.kh |
| Long Saky | Deput. Chief, Kampong Speu |
| Loum Las | Director, Kampong Speu |
| Malalay Ahmadzai | Child Survival Specialist, UNICEF Cambodia, mahmadzai@unicef.org |
| Mao Chinn | DFT, Kampng Speu |
| Mao Saroeun | Admin,WDC, Kampng Speu |
| Marc Vergara | Chief of Communications, UNICEF Cambodia, mvergara@unicef.org |
| Men Pom | DFT, Kampng Speu |
| Moeun Seak | District Chief, Kampong Speu |
| Mom Samnith | Planning Manager, Kampong Speu |
| Nanda Pok | Executive Director, WFP |
| Nhonh Sophea | Early Childhood Development Specialist, UNICEF,nsophea@unicef.org |
| Noub Phumara | Dept. of Economic Department, Kampong Speu |
| Nov Chanrotheany | DFP, Kampng Speu |
| Path Heang | Youth and Adolescent Specialist, UNICEF Cambodia, pheang@unicef.org |
| Penelope Campbell | HIV/AIDS Specialist, UNICEF Cambodia, pcampbell@unicef.org |
| Peter Leth | M&E Specialist, UNICEF Cambodia, pleth@unicef.org |
| Prak Thol | DFP, Kampong Speu |
| Ros Saly | PFT, Kampng Speu |
| Scott Leiper | PSDD Advisor – UNDP/MOI-DOLA, scott@ncdd.gov.kh |
| Seak Sokol | Official, Kampong speu |
| Sem Bunlip | DFT, Kampng Speu |
| Som Las | Deputy Director, Kampong Speu |
| Sours Samoul | PPC, RACC, Kampng Speu |
| Sreng Hai | DFP, Kampng Speu |
| Tann Kandol | DFP, Kampng Speu |
| Tem Yen | DFP, Kampong Speu |

| | |
|---|---|
| Thin Sarmek | PFP, Kampong Speu |
| Tong Savoeun | TL, RHAE, Kampng Speu |
| Tum May | UNFPA, may@unfpa.org |
| Vimol Hou | UNFPA, vimol@unfpa.org |
| Vong Sonat | PFT, Kampng Speu |
| យឹម ថៃ | ប្រជាពលរដ្ឋ កំពង់ស្ពឺ |
| កែវ សារឿន | អភិបាលរងខេត្តរតនៈគិរី |
| ឯក សុវណ្ណភារៈ | អភិបាលរងខេត្តឧត្តរមានជ័យ |
| អ៊ុត សំអន | អភិបាលរងខេត្តកំពង់ធំ |
| ទឹម សារ៉ាត | អភិបាលរងខេត្តកំពង់ស្ពឺ |
| ខុង ស៊ុនអេន | អភិបាលរងខេត្តកំពង់ចាម |
| សៅ ខាំឡៃ | ជនបង្គោលសង្កាត់ឡាបានសៀក ខេត្តរតនៈគិរី |
| ហុន ណារី | មន្ត្រីមណ្ឌលសុខភាពបានលុង ខេត្តរតនៈគិរី |
| ភា សុភ័ក្រ្ត | PFT, PLAU, Ratttanakiri |
| អ៊ុច បូ | អ្នកសម្របសម្រួល, ADHOC, Kampng Speu |
| អ៊ុច សារឿន | ឆ្មប កំពង់ស្ពឺ |
| អុន ប៉េង | ស្មៀន កំពង់ស្ពឺ |
| អ៊ុន នាង | ជំទប់ កំពង់ស្ពឺ |
| អាវ សារ៉ាន់ | ប្រជាពលរដ្ឋ កំពង់ស្ពឺ |
| ប៊ុល សុខលីម | ប្រធានខុទ្ធការល័យ កំពង់ស្ពឺ |
| ប៊ុល សុខលី | អនុប្រធានការិយាល័យ កំពង់ស្ពឺ |
| ប៊ូក សេដ្ឋា | អនុប្រធានសាសាឧទ្ធណ៍ កំពង់ស្ពឺ |
| ចៃ ខាវ | ប្រជាពលរដ្ឋ កំពង់ស្ពឺ |
| ជា សារុំ | មន្ត្រី កំពង់ស្ពឺ |
| ជា សុផា | ប្រជាពលរដ្ឋ កំពង់ស្ពឺ |
| ឈរ ប៊ុនណារ័ត្ន | Program coordinator, WFP, wfpnp@online.com.kh |
| ជិន សារិន | ប្រជាពលរដ្ឋ កំពង់ស្ពឺ |
| ជឹង សេង | PFT, Kampng Speu |
| ចន ឃឹម | ប្រជាពលរដ្ឋ កំពង់ស្ពឺ |
| អ៊ឹម សាម៉េត | អ្នកទទួលបន្ទុកកិច្ចការនារី និង កុមារឃុំ សង្កាត់ កំពង់ស្ពឺ |
| អេន សុខា | អនុប្រធានខុទ្ធការល័យ កំពង់ស្ពឺ |
| ង៉ែតសារិន | គ្រូ កំពង់ស្ពឺ |
| ចា សារឿន | ប្រជាពលរដ្ឋ កំពង់ស្ពឺ |
| ចាច់ សាម៉េត | ប្រជាពលរដ្ឋ កំពង់ស្ពឺ |
| ជិប ខន | ប្រជាពលរដ្ឋ កំពង់ស្ពឺ |

| | |
|---|---|
| កែវ សុខុម | ប្រជាពលរដ្ឋ កំពង់ស្ពឺ |
| ខឹម ស៊ីម៉ន | ប្រជាពលរដ្ឋ កំពង់ស្ពឺ |
| ផាន់ ចក | ប្រជាពលរដ្ឋ កំពង់ស្ពឺ |
| ពិន សារិម | ប្រជាពលរដ្ឋ កំពង់ស្ពឺ |
| ស្វាយ មាក | សមាជិក, កំពង់ស្ពឺ |
| អ៊ុម សុខខេង | ប្រជាពលរដ្ឋ កំពង់ស្ពឺ |
| សូ សៃ | ប្រជាពលរដ្ឋ កំពង់ស្ពឺ |
| ស៊ិន ប៊ុនណា | ប្រជាពលរដ្ឋ កំពង់ស្ពឺ |
| សឿង សុផាត | មេឃុំ កំពង់ស្ពឺ |
| សឿង យ៉ន | ប្រជាពលរដ្ឋ កំពង់ស្ពឺ |
| សុខ គឹម | មេឃុំ កំពង់ស្ពឺ |
| សុក លាន | ប្រជាពលរដ្ឋ កំពង់ស្ពឺ |
| សុខ នីន | ប្រជាពលរដ្ឋ កំពង់ស្ពឺ |
| សុខ សារ៉ែន | សមាជិកកំពង់ស្ពឺ |
| គីម ពុទ្ធា | អនុប្រធានការិយាល័យ កំពង់ស្ពឺ |
| ប្រាក់ នី | ប្រជាពលរដ្ឋ កំពង់ស្ពឺ |
| ម៉ុម ធន់ | ប្រជាពលរដ្ឋ កំពង់ស្ពឺ |
| នូ ហ៊ុន | ស្មៀន កំពង់ស្ពឺ |
| អក ទៀន | ប្រជាពលរដ្ឋ កំពង់ស្ពឺ |
| ក្រឹម មាត់ | បុគ្គលិកឱសថកំពង់ស្ពឺ |
| អ៊ុង សំអុល | DFT, Ochum District ,Rattanakiri |
| វៀត សំណាង | DFT, Ochum District ,Rattanakiri |
| នាង សំអាត | LAA, PSDD, Rattanakiri, n-samath@rat.ncdd.gov.kh |
| ប៊ុន ធឿត | SPPA, PSDD, Rattanakiri, bunthoeuth@rat.ncdd.gov.kh |
| សេក ហៃ | PM, Excom, Rattankiri, 16RATPM@ncdd.gov.kh |
| ស្រឹង វុទ្ធី | Clerk, Laak commune, Rattanakiri |
| ហាំប្រែង សាពី | Laak school director, Rattanakiri |
| អួន ចាំផៃ | មេភូមិល្អក់ រតនៈគិរី |
| ឃុន សាណយ | មេភូមិកាំ រតនៈគិរី |
| បៀន យ៉ែម | ជំទប់ទីពីរ ឃុំល្អក់ រតនៈគិរី |
| យ៉ាម ប៉ាន | មេឃុំល្អក់ រតនៈគិរី |
| វៀត សំណាង | DFT ឃុំល្អក់ រតនៈគិរី |
| ដាយ សុធី | ជនបង្គោល ឃុំល្អក់ រតនៈគិរី |
| ឡាំ ណាក់ | ប៉ូលីសប៉ុស្តិ៍ ឃុំល្អក់ រតនៈគិរី |

| | |
|---|---|
| មឿ្វន ម៉ាឡា | អភិបាលរងក្រុងបានលុង រតនៈគិរី |
| ជុំ នី | ប្រធានការិយាល័យកិច្ចការនារី រតនៈគិរី |
| សុខ សារិន | ប្រធានការិយាល័យអប់រំកីឡាក្រុងបានលុង រតនៈគិរី |
| ញ៉ឹម សំអឿន | PFT, PLAU, Rattanakiri |
| ញ ផានិត | PFT, PLAU, Rattanakiri |
| គីម ម៉ារុណ | DFT, សាលាក្រុងបានលុង រតនៈគិរី |
| វី សុខវង្ស | DFT, សាលាក្រុងបានលុង រតនៈគិរី |
| ច័ន្ទ ផល្លា | អនុប្រធានការិយាល័យសង្គមកិច្ចក្រុងបានលុង រតនៈគិរី |
| ម៉ៃ ភន | មន្រ្តីមន្ទីរអភិវឌ្ឍន៍ជនបទក្រុងបានលុង រតនៈគិរី |
| ង៉ែត សុភ័ក្រ្ត | អនុប្រធានការិយាល័យផែនការក្រុងបានលុង រតនៈគិរី |
| ណង ណូម | ប្រជាជនភូមិល្អក់ រតនៈគិរី |
| គ្រួន គ្រៀង | ប្រជាជនភូមិល្អក់ រតនៈគិរី |
| កំព្រៀង វែង | ប្រជាជនភូមិល្អក់ រតនៈគិរី |
| វែង ប៊ុនម៉ង | អ្នកស្ម័គ្រចិត្តសុខភាពភូមិល្អក់ រតនៈគិរី |
| ប៉ៀម ភ្លែម | អ្នកស្ម័គ្រចិត្តសុខភាពភូមិល្អក់ រតនៈគិរី |
| រាល សាលី | ជំនួយការភូមិ ភូមិល្អក់ រតនៈគិរី |
| ញូង យ៉ាម | ប្រជាជន ភូមិល្អក់ រតនៈគិរី |
| មាល ជើងខែ | ប្រជាជន ភូមិល្អក់ រតនៈគិរី |
| ថោង វាយ | អ្នកទទួលខុសត្រូវកសិកម្ម |
| ស៊ឹម សនឡៃ | ប្រធានមន្ទីរសុខាភិបាលខេត្តរតនៈគិរី |
| អៀម អឿន | អនុប្រធានមន្ទីរអភិវឌ្ឍន៍ជនបទខេត្តរតនៈគិរី |
| ស៊ុំ សុគន្ធា | អនុប្រធានការិយាល័យមន្ទីរកិច្ចការនារីខេត្តរតនៈគិរី |
| ហាក់ ផេងហ៊ុ | ប្រធានការិយាល័យមន្ទីរសង្គមកិច្ចខេត្តរតនៈគិរី |
| ច័ន្ទ ខាំឃឿ | ប្រធានមន្ទីរអប់រំខេត្តរតនៈគិរី |
| សាន់ កៀត | អ្នកទ្រទ្រង់ភូមិពីរខេត្តរតនៈគិរី |
| ស៊ឹម សុផាត | ពេទ្យសត្វភូមិខេត្តរតនៈគិរី |
| ថន ចាន់ផល្លា | អ្នកទ្រទ្រង់ភូមិ៥ ខេត្តរតនៈគិរី |
| ថុល សុផានី | អ្នកសំរបសំរួលភូមិ៣ខេត្តរតនៈគិរី |
| វ៉ា សុវណ្ណ | អ្នកសំរបសំរួលភូមិ៣ខេត្តរតនៈគិរី |
| សឹន សំអាត | អ្នកសំរបសំរួលភូមិ២ខេត្តរតនៈគិរី |
| រ័ត្នហាន់ ស៊ីម៉ូន | អ្នកទទួលខុសត្រូវគំរោងសន្តិសុខស្បៀង CARE, INGO, Rattanakiri |
| ថុល ថានី | ជំនួយការនាយកកម្មវិធី CARE, INGO, Rattanakiri |
| ឈឹម សាខន | ជំនួយការកម្មវិធី ICSO, NGO, Rattanakiri |
| លី ម៉េងលាង | Admin & Finance, HU, Rattanakiri |

| | |
|---|---|
| ចិន្តា រ៉ាវុឌ្ឍ | អ្នកសំរបសំរួលគំរោង CEDAC, Rattanakiri |
| រ៉ែន ចាន្ទា | ជំនួយការភូមិ៤ខេត្តរតនៈគិរី |
| វ៉ូន ណុង | អនុភូមិ៥ខេត្តរតនៈគិរី |
| អ៊ុល តាន់ | មេភូមិ៣ខេត្តរតនៈគិរី |
| ហ៊ូ ស្រួច | នាយរងប៉ុស្តិខេត្តរតនៈគិរី |
| សារិទ្ធ ស្រីពៅ | ជំនួយការភូមិ១ខេត្តរតនៈគិរី |
| តេង បុត្រទេពី | ចៅសង្កាត់រងទី២ខេត្តរតនៈគិរី |
| ញាណ តៃស៊ុ | ចៅសង្កាត់ឡាបានសៀកខេត្តរតនៈគិរី |
| ជា ដារី | អនុប្រធានភូមិ២ខេត្តរតនៈគិរី |
| ស៊ឹម សុភាព | ស្មៀនខេត្តរតនៈគិរី |
| នុត ប៊ុនថា | Provincial Finance Advisor, Kampong Cham |
| ទឹម ប៊ុនឈឿន | Finance Unit Director , Excom, Kampong Cham |
| អៀម ពិសិដ្ឋ | FMESA, Kampong Cham |
| គីម ច័ន្ទធារ៉ា | PLAU, Kampong Cham |
| សេង សុខជា | PFT, Kampong Cham |
| វ៉ាន់ ថេន | ទីប្រឹក្សា   កំពង់ចាម |
| ស្រី អួច | ក្រសួងកិច្ចការនារី ឃុំស្ពឺងជ័យ |
| ផុន សុខុម | មេភូមិប្របឹង |
| ឡាញ់ ឡូត | មេភូមិស្ពឺងជ័យ |
| ឃិន វន | នាយកសាលាក្កុយ |
| ផូ ភឿន | មេភូមិក្កុយ |
| ខុច ម៉ុន | មេភូមិដំណាក់អំពិល |
| ម៉ៅ សាយ | សហគមន៏ |
| សាង សុខលី | អនុភូមិពង្រ |
| តោម ស៊ឹម | អនុភូមិក្កុយ |
| ចេក វៃ | សមាជិកភូមិពង្រ |
| មន ពៅ | សមាជិកភូមិពង្រ |
| តែម ភី | សមាជិកភូមិពង្រ |
| ស៊ឿ ព្រឿន | អនុភូមិដំណាក់អំពិល |
| ហួ គួ | មេភូមិពង្រ |
| ឱក គួ | ប្រជាពលរដ្ឋភូមិពង្រ |
| ជិន សោភ័ណ្ឌ | ប្រជាពលរដ្ឋភូមិពង្រ |
| មុយ ចន្ទូ | ប្រជាពលរដ្ឋភូមិពង្រ |
| ចេ យ៉ុន | ប្រជាពលរដ្ឋភូមិពង្រ |

| | |
|---|---|
| ឈៀង ម៉េន | ប្រជាពលរដ្ឋភូមិពង្រ |
| ឈិត ឈឹម | ប្រជាពលរដ្ឋភូមិពង្រ |
| ឡេង លឹម | ប្រជាពលរដ្ឋភូមិពង្រ |
| ទី ស្រាង | ប្រជាពលរដ្ឋភូមិពង្រ |
| ជោក ហង់ | ប្រជាពលរដ្ឋភូមិប្របឹង |
| សូ ឡូញ | ប្រជាពលរដ្ឋភូមិប្របឹង |
| អែក នុត | ប្រជាពលរដ្ឋភូមិប្របឹង |
| អិ អួន | ប្រជាពលរដ្ឋភូមិប្របឹង |
| ព្រាប ព្រឿង | ប្រជាពលរដ្ឋភូមិប្របឹង |
| ខៀវ សឿន | ប្រជាពលរដ្ឋភូមិប្របឹង |
| រ៉ាយ ធឿង | ប្រជាពលរដ្ឋភូមិប្របឹង |
| ឃុន វុទ្ធី | ប្រជាពលរដ្ឋភូមិប្របឹង |
| ជិន ប៉ែត | ប្រជាពលរដ្ឋភូមិប្របឹង |
| សឿក គឿន | ប្រជាពលរដ្ឋភូមិខ្នា |
| ពក ពាញ | ប្រជាពលរដ្ឋភូមិខ្នា |
| ប៊ុត កាំង | ប្រជាពលរដ្ឋភូមិពង្រ |
| យឹម អៃ | ប្រជាពលរដ្ឋភូមិប្របឹង |
| ម៉ម ផារី | ប្រជាពលរដ្ឋភូមិដំណាក់អំពិល |
| មៀវ លឿ | ប្រជាពលរដ្ឋភូមិក្តុយ |
| ជឹម គឿន | ប្រជាពលរដ្ឋភូមិស្តើងជ័យ |
| ហែម តង | ប្រជាពលរដ្ឋភូមិខ្នា |
| ប៉ាន់ រឿង | បុគ្គលិក HE ខុនដំបង |
| ទី សុធី | អ្នកសំរបសំរួល |
| ស៊ុំ សេន | នាយប៉ុស្តិ៍ |
| ហាយ លុន | ប្រជាពលរដ្ឋ |
| ស្រេង គីមស្រីន | ប្រជាពលរដ្ឋ |
| អួង ស្រីន | ប្រជាពលរដ្ឋ |
| យេត វ៉ាន | ប្រជាពលរដ្ឋ |
| អួន ស្រីយួន | ប្រជាពលរដ្ឋ |
| ជា សឿន | ប្រជាពលរដ្ឋ |
| សា លឿន | ប្រជាពលរដ្ឋ |
| ពួ សុង | ប្រជាពលរដ្ឋ |
| សួន សុផល | ប្រជាពលរដ្ឋ |
| ចាន់ ធានី | ប្រជាពលរដ្ឋ |

| | |
|---|---|
| សំ អឿន | ប្រជាពលរដ្ឋ |
| ហួត ស៊ីណាត | Project Assistant |
| ជាប អេង | ប្រធានការិយាល័យអភិវឌ្ឍ |
| យូ គីមអាន | ប្រធានការិយាល័យ អ យ ក ស្រុកជើងព្រៃ |
| សេង សុគន្ធា | អភិបាលរង ស្រុកជើងព្រៃ |
| ឯម ចាន់ថុល | កិច្ចការនារីស្រុកជើងព្រៃ |
| សេង សុខជា | ផែនការ ស្រុកជើងព្រៃ |
| គីម សុខហេង | សុខាភិបាល ស្រុកជើងព្រៃ |
| មាស វណ្ណៈ | អនុប្រធាន ស អ យ |
| សេត សារឿន | អ្នកសម្របសម្រួល ស្រុកជើងព្រៃ |
| វ៉ាន់ ថេន | ទីប្រឹក្សា PSDD |
| អ៊ូ សុខា | មេភូមិ គោករវៀង |
| ទុយ តែម | មេភូមិ គោករវៀង |
| កុយ ស៊ុយ | មេភូមិ ឈូក |
| កាន់ សុកន | នាយកសាលា យូអ៊ុណា |
| សួន យូ | អនុភូមិ គោករវៀង |
| ណន សារឿន | ក្រុមប្រឹក្សាឃុំ គោករវៀង |
| ចក់ ឌួង | ស្មៀន គោករវៀង |
| តែម ផាត | មេឃុំ គោករវៀង |
| សាំង ស៊ីម | អនុឃុំ គោករវៀង |
| ហ៊ី គ្រុយ | ជំទប់២ គោករវៀង |
| សែម សឿង | មេភូមិ គោករវៀង |
| កៅ សោ | សមាជិក គោករវៀង |
| ស្រេង អួន | ក្រុមប្រឹក្សាឃុំ គោករវៀង |
| ស៊ូ សុភាព | នាយក គោករវៀង |
| លី ម៉េងសាន | ប្រធានការិយាល័យ POE |
| យី ផារី | អនុប្រធានការិយាល័យ SOC |
| ឡេង សុខា | ប្រធានមន្ទីរកិច្ចការនារី |
| ឡុង សុត្ថា | អនុប្រធានមន្ទីរ អភិវឌ្ឍជនបទ |
| ទូច ស៊ីថុល | ប្រធានមន្ទីរកិច្ចការនារី ខេត្តកំពង់ធំ |
| សួន ចិន្តាមុនី | អនុប្រធានការិយាល័យមន្ទីរអប់រំ ខេត្តកំពង់ធំ |
| មាស សុខា | អនុប្រធានមន្ទីរសុខាភិបាល ខេត្តកំពង់ធំ |
| ចាន់ សារឿន | សមាជិកអចិន្ត្រៃ |
| ស្វាយ រនាង | អនុប្រធានមន្ទីរ ស អ យ |

| | |
|---|---|
| ប៉ក់ ស៊ីងេន | មន្ត្រីបង្គោលសិទ្ធិកុមារស្រុកសន្ទុក |
| អ៊ឹម សុខឡេង | មន្ត្រី មន្ទីរផែនការ ខេត្តកំពង់ធំ |
| ថុង ប៊ុនតាង | មន្ទីរអភិវឌ្ឍន៍ ខេត្តកំពង់ធំ |
| ព្រាប មុនី | ស្មៀនឃុំត្បូងក្រពើ |
| យ៉ា យុនសេង | នាយករងប៉ូលីសត្បូងក្រពើ |
| ប្លង់ ចិត្រ | មេភូមិ សមាជិក |
| ម៉ែន សារុន | ស្ម័គ្រចិត្ត |
| គួច ឡូត | ប្រធានមេភូមិត្បូងក្រពើ |
| គៀង សេងគី | មេឃុំត្បូងក្រពើ ស្រុកសន្ទុក ខេត្តកំពង់ធំ |
| សោម ឃឹម | អ្នកទទួលបន្ទុកកិច្ចការនារីឃុំត្បូងក្រពើ ស្រុកសន្ទុក ខេត្តកំពង់ធំ |
| ស សេន | នាយករងសាលាបញ្ញើ |
| នង សុផាត | អនុប្រធានការិយាល័យកិច្ចការនារី ខេត្តកំពង់ធំ |
| អាំង ស្រ៊ី | ប្រធានការិយាល័យសង្គមកិច្ច |
| ហាន ខឿន | ប្រធានការិយាល័យផែនការ |
| លាស់ ចាន់ | ប្រធាន EPI OD |
| នៅ សមះ | ប្រធានការិយាល័យអប់រំស្រុក |
| ប្រាក់ សុវណ្ណា | អនុប្រធានការិយាល័យ អជប អភិវឌ្ឍន៍ស្រុក |
| ឱក សំណាង | អភិបាលរងស្រុកសន្ទុក |
| ជុន ហុងឈាន | អនុប្រធាន OD កំពង់ធំ |
| តែម ធន | មេឃុំកកោះ កំពង់ធំ |
| គង់ ស៊ីនឿន | សមាជិកអចិន្ត្រៃ កកោះ កំពង់ធំ |
| គីម ហៀង | គ ក ន ក ស្វាយកាល់ កំពង់ធំ |
| នៅ សំណោង | ជំទប់ទី២ កកោះ កំពង់ធំ |
| កុយ ស៊ីដន | ប្រធានមណ្ឌលសុខភាព កកោះ កំពង់ធំ |
| ភ្លង ខៀវ | គ គ ន ក សំណាក កំពង់ធំ |
| លន ស៊ីម | មេភូមិសន្ទុកក្រៅ កំពង់ធំ |
| ផ្លោក គាំ | មេភូមិធំ ជ័យជំនះ កំពង់ធំ |
| រឹម សុខា | តំណាងមាតាបិតា ឃុំកកោះ កំពង់ធំ |
| ឱត មឿន | អំពើហិង្សា ឃុំកកោះ |
| ព្រំ ស្រង់ | ប្រជាពលរដ្ឋ ឃុំកកោះ |
| យង់ ហៀង | មេភូមិស្វាយកាល់ ឃុំកកោះ |
| រស់ ផល់ | អនុភូមិ ឃុំកកោះ |
| ហេង ហ៊ន | មាតាបិតា ឃុំកកោះ |
| ហួន ធឿន | អនុភូមិ ជាយស្មៀ ឃុំកកោះ |

| | |
|---|---|
| ស្បៀង ស៊ីណន | ជំទប់ទី១ សហគមន៍ឃុំ ត្បូងក្រពើ |
| សេក សំអ៊ិន | ក្រុមប្រឹក្សាឃុំ សហគមន៍ឃុំ ត្បូងក្រពើ |
| ព្រាប មុនី | ស្មៀនឃុំ សហគមន៍ឃុំ ត្បូងក្រពើ |
| ហុង សាម៉ាប់ | បុគ្គលិកឃុំ សហគមន៍ឃុំ ត្បូងក្រពើ |
| អ៊ុត ចំរើន | គ្រូមត្តេយ្យ សហគមន៍ឃុំ ត្បូងក្រពើ |
| ស៊ឹម សារ៉េត | គ្រូមត្តេយ្យ សហគមន៍ឃុំ ត្បូងក្រពើ |
| នៅ ស៊ីណុំ | សមាជិកភូមិ សហគមន៍ឃុំ ត្បូងក្រពើ |
| ហេង ផល | អនុភូមិ សហគមន៍ឃុំ ត្បូងក្រពើ |
| ស្បៀង តាំងលី | យុវជនឃុំ សហគមន៍ឃុំ ត្បូងក្រពើ |
| យូង ប៊ូរី | យុវជនឃុំ សហគមន៍ឃុំ ត្បូងក្រពើ |
| សូ ភារ៉ាវុទ្ធ | យុវជនឃុំ សហគមន៍ឃុំ ត្បូងក្រពើ |
| សុក ហ៊ុម | យុវជនឃុំ សហគមន៍ឃុំ ត្បូងក្រពើ |
| ជា សុគន្ធារី | យុវជនឃុំ សហគមន៍ឃុំ ត្បូងក្រពើ |
| ជុន ស៊ីថាន់ | យុវជនឃុំ សហគមន៍ឃុំ ត្បូងក្រពើ |
| ខេ ច័ន្ទធន | អ្នកស្ម័គ្រចិត្តភូមិ |
| ទី ស៊ុមម៉ាណែត | ប្រជាពលរដ្ឋ |
| ឆេង យ៉ឹង | ប្រជាពលរដ្ឋ |
| ចាន់ នួ | ប្រជាពលរដ្ឋ |
| ចាយ សេងហ៊ាង | ប្រជាពលរដ្ឋ |
| ចាយ សេងហ៊ាន់ | ប្រជាពលរដ្ឋ |
| ហេង សារឹម | ប្រជាពលរដ្ឋ |
| កែវ ហ៊ាន់ | ប្រជាពលរដ្ឋ |
| ហៀន រុន | ប្រជាពលរដ្ឋ |
| អេង សុក | ប្រជាពលរដ្ឋ |
| ខំ សារំ | ប្រជាពលរដ្ឋ |
| ញឹក សឿន | ប្រជាពលរដ្ឋ |
| នង សាត | ប្រជាពលរដ្ឋ |
| មៀច អឿន | ប្រជាពលរដ្ឋ |
| ទុយ ចាន់នា | ប្រជាពលរដ្ឋ |
| ថេត សារឿន | មន្ត្រីសម្របសម្រួល អង្គភាពមូលដ្ឋាន |
| សោម ណៃថន | DFT អង្គភាពមូលដ្ឋាន |
| ប៉ក់ ស៊ីងេន | DFP សាលាស្រុកសន្ទុក |
| វ៉ន សាវុធ | LAA PSDD |
| អ៊ឹម នន | PFP PLAU |

| | |
|---|---|
| យស់ យូលីន | អនុប្រធាន PLAU |
| ជឹម សារ៉េន | SPPA, PSDD |
| ជីវ យាំង | មន្ត្រីត្រួតពិនិត្យ CAU |
| ភឿន ធារី | មន្ត្រីបង្គោលសិទ្ធិកុមារ DFP |
| ឡៃ ហុក | មន្ត្រីCAU excom |
| យ៉ាន់ សាវ៉ាន | ប្រធានកម្មវិធី Codee កំពង់ធំ |
| ឯក សុភាវី | ប្រធានមន្ទីរកិច្ចការនារី ខេត្តឧត្តរមានជ័យ |
| អ៊ឹង បូរ៉ាត់ | ប្រធានមន្ទីរអប់រំ ខេត្តឧត្តរមានជ័យ |
| សូ គឹមតន់ | ប្រធានមន្ទីរផែនការ ខេត្តឧត្តរមានជ័យ |
| ប្រិច រ៉ាមី | អនុប្រធានមន្ទីរអភិវឌ្ឍជនបទ ខេត្តឧត្តរមានជ័យ |
| លាង ហ៊ុន | អនុប្រធានមន្ទីរសង្គមកិច្ច ខេត្តឧត្តរមានជ័យ |
| បូ សុខហេង | PFT, LAU |
| រិទ្ធី ប៉ាក់ | ប្រធាន PLAU |
| ទូត វាសនា | DFP ស្រុកបន្ទាយអំពិល |
| ថាច់ ណារិរិច័ន្ទ | ទីប្រឹក្សារដ្ឋបាលមូលដ្ឋាន PSDD/OMC |
| ឈូក អឿត | PFT, សំលាង |
| សាន់ ឆេង | DFT, អន្លង់វែង |
| ឡុង វ៉ុន | DFT, អន្លង់វែង |
| សរ សាម៉េត | PFT, LAU ស្រុកអន្លង់វែង |
| គង់ មុំ | អភិបាលរង ស្រុកអន្លង់វែង |
| គឹម សំណាង | DFT ស្រុកអន្លង់វែង |
| រឿន គឹម | ប្រធានកិច្ចការនារី អន្លង់វែង |
| ខុម សុខុន | មន្ត្រីការិយាល័យ អ យ ក ស អន្លង់វែង |
| សាន់ ឆេង | DFT ស្រុកអន្លង់វែង |
| កែវ សុខខេង | សង្គមកិច្ច ស្រុកអន្លង់វែង |
| នៅ សំអន | អនុប្រធាន មន្ទីរពេទ្យ បង្អែកអន្លង់វែង |
| ជន រ៉ះ | មេឃុំ លំទង |
| ហ៊ឹម ហាក់ | គ្រូពេទ្យ ឃុំលំទង |
| ឈឹម លី | នាយកសាលា ឃុំលំទង |
| អន សុភាព | គកនក ឃុំលំទង |
| អ៊ុច ផា | មេឃុំ ឃុំថ្លាត |
| អឿ សុផាត | ជំទប់ទី២ ឃុំថ្លាត |
| ខេង ផា | មេភូមិ ស្វាយចេក |
| ស័ក្ក មាន | មេភូមិ ទួលក្រឡាញ់ |

| | |
|---|---|
| សោ គន្ធា | ប្រធានកំរង ឃុំថ្លាត |
| ញឹម សឿន | ស្មៀនឃុំ ឃុំថ្លាត |
| អួន រី | ក្រុមប្រឹក្សាឃុំ ឃុំថ្លាត |
| គុយ ស្អាង | ប៉ុស្តិ៍ ថ្លាត |
| ម៉ា អឿ | មេភូមិថ្មី ឃុំថ្លាត |
| ស៊ុយ ធារី | នាយប៉ុស្តិ៍ ន ប |
| ទោម លឿ | គ ក ន ក លំទងសស់ |
| សាំង ថាញ់ | គ ក ន ក លំទងថ្មី |
| មាស ពៅ | គ ក ន ក អូរ គគីលើ |
| សែម ប៊ុនធឿន | ស្មៀនឃុំ លំទង |
| ម៉ែន សុភា | ប្រជាពលរដ្ឋ ឃុំថ្លាត |
| ប៉ាន់ គឹមលុយ | ប្រជាពលរដ្ឋ ឃុំថ្លាត |
| នៅ វ៉ាន | ប្រជាពលរដ្ឋ ឃុំថ្លាត |
| ប៊ី សុខឿន | ប្រជាពលរដ្ឋ ឃុំថ្លាត |
| លួន ឡោត | ប្រជាពលរដ្ឋ ឃុំថ្លាត |
| ជួន សុខ | ប្រជាពលរដ្ឋ ឃុំថ្លាត |
| វ៉ន ខេន | ប្រជាពលរដ្ឋ ឃុំថ្លាត |
| ជិន ស្រីរ័ត្ន | ប្រជាពលរដ្ឋ ឃុំថ្លាត |
| អិន ហ៊ី | ប្រជាពលរដ្ឋ ឃុំថ្លាត |
| ស៊ិន វុឌ្ឍី | អនុប្រធានភូមិ |
| ឡាច ធឿន | សមាជិកភូមិ |
| ហ៊ឹម គឹមយ៉ា | អនុប្រធានភូមិ ទួល ព្រេច |
| យស់ សាដាត | ប្រជាពលរដ្ឋ ទួលព្រេច |
| សំ សេង | ប្រជាពលរដ្ឋ ទួលព្រេច |
| ជា អំ | ប្រជាពលរដ្ឋ ទួលព្រេច |
| ពយ សុខា | ប្រជាពលរដ្ឋ ទួលព្រេច |
| រឿន ផាស៊ី | ប្រជាពលរដ្ឋទួលព្រេច |
| វង់ រឿន | ប្រជាពលរដ្ឋទួលព្រេច |
| សឹម ថន | ប្រជាពលរដ្ឋទួលព្រេច |
| មាន នី | ប្រជាពលរដ្ឋទួលព្រេច |
| ម៉ន រ៉ាវី | សម្របសម្រួលឃុំអូស្វាយ ZOA |
| តុំ សំនិត | DRM facilitator, ZOA |
| ឡុង វ៉ាន់ដា | Project Manager, ZOA |
| យិន ដានី | DRM facilitator, ZOA |

| | |
|---|---|
| ឯម វណ្ណៈ | ប្រធានផ្នែកកសិកម្ម, ZOA |
| ទ្រា ធិន | DRM facilitator, ZOA |
| Phon Ra | Administrative Officer, ODM5 |
| មា សុភឿន | គ អ ក ភូមិទួលទ្រាស |
| ឃឹម ខុន | គ្រូមត្តេយ្យ លំទងថ្មី |
| ជួន សំណាង | ប្រជាពលរដ្ឋ លំទងថ្មី |
| ចាំង ចាន់ថេង | ប្រជាពលរដ្ឋ លំទងថ្មី |
| វ៉ិត នាង | គ អ ក លំទងថ្មី |
| អន សុភាព | គ ក ន ក លំទងថ្មី |
| ជន រះ | មេឃុំ លំទងថ្មី |
| អុន សុត | គ ក ន ក |
| ណុប សម្បត្តិ | គ ក ន ក |
| សៀង ហ៊ាង | គ កន ក ទួលទ្រាស |

## ឧបសម្ព័ន្ធទី៣: អត្ថន័យនៃពាក្យ "សមត្ថភាព"

### ការគ្រប់គ្រងខ្លួនឯង

#### ១. ការគោរព

- សំដែងឥរិយាបថ ដែលឆ្លុះបញ្ចាំងទៅលើជំនឿអំពីសិទ្ធិស្ត្រី និងកុមារ
- បង្កើនឱ្យអ្នកដទៃមានជំនឿចិត្ត ដោយបង្កើតឱ្យមានបរិយាកាសបើកចំហ និងភាពជឿជាក់
- ប្រាស្រ័យទាក់ទងដោយបើកចំហ និងបង្ហាញពីការយល់ចិត្តពីគ្នាទៅវិញទៅមក :

  - ស្តាប់ដោយប្រុងប្រយ័ត្ន (ឧ. ផ្តល់ការផ្តោតអារម្មណ៍ទាំងស្រុង ត្រូវដឹងអំពីភាសាកាយវិការរបស់ខ្លួន ព្រមទាំងស្តាប់ដោយមិនមានការវិនិច្ឆ័យ)
  - សុំឱ្យអ្នកដទៃនិយាយ និងចូលរួមចែករំលែកមតិក្នុងការពិភាក្សាក្រុម
  - មិនត្រូវត្រួតត្រាលើកិច្ចសន្ទនា ឬការប្រជុំនោះទេ
  - បំពេញបន្ថែមលើគំនិតនៃការចូលរួមយោបល់របស់គាត់
  - សួរសំណួរគាំទ្រដើម្បីបញ្ជាក់បន្ថែមក្នុងន័យមិនមែន "មើលស្រាល" ឬ ស្តីបន្ទោសនោះទេ

- ឱ្យតម្លៃទៅលើចំណេះដឹង ជំនាញ និងតួនាទីដែលអ្នកផ្សេងទៀតទទួលខុសត្រូវ :

  - ឱ្យគាត់ចូលរួមធ្វើសេចក្តីសម្រេចចិត្តដែលទាក់ទងនឹងខ្លួនគាត់ និងកិច្ចការដែលគាត់ទទួលខុសត្រូវ
  - គាំទ្រគំនិតអ្នកផ្សេងទៀតដែលបង្ហាញការចំណាប់អារម្មណ៍ និងតម្រូវការ ហើយធ្វើឱ្យពួកគាត់ទទួលបានអ្វីដែលគាត់ត្រូវការ
  - ដើរតួជាអ្នកពន្យល់ពីហេតុផល នៅពេលណាដែលតម្រូវការរបស់ពួកគាត់មិនសម្រេចបានលទ្ធផល
  - ស្តាប់ដោយយកចិត្តទុកដាក់ និងធ្វើការពិចារណាទៅលើទស្សនៈផ្សេងៗ

#### ២. ការប្តេជ្ញាចិត្ត

- បង្ហាញពីការតាំងចិត្តតាមរយៈសកម្មភាព ព្រមទាំងធ្វើឱ្យឃើញពីការតស៊ូក្នុងការនិយាយ និងការធ្វើសកម្មភាព
- រៀបចំឱ្យមានគោលបំណងជាក់លាក់ដែលអាចសម្រេចបានលទ្ធផល បង្កើតសូចនាករដែលអាចវាស់វែង និងអាចអនុវត្តបាន
- បង្កើតស្នាដៃការងារក្នុងន័យថាជា "ករណីយកិច្ច" ដើម្បីធ្វើឱ្យគណៈកម្មាធិការទទួលបានជោគជ័យ :

- បន្តយ៉ាងស្វាហាប់ក្នុងការរៀនសូត្រពីតួនាទី និងការទទួលខុសត្រូវរបស់គណៈកម្មាធិការ

- ដោះស្រាយការប្រឈមមុខ ដោយសេចក្តីសប្បាយរីករាយ និងមិនមានការស្តីបន្ទោស

- បង្ហាញពីការសារទរចំពោះការងារដែលល្អ ដោយផ្តល់ព័ត៌មានត្រឡប់បែបស្ថាបនា

- ជួយសមាជិកក្នុងគណៈកម្មាធិការ និងចែករំលែកបន្ទុកការងារពីសមាជិកផ្សេងៗទៀត

- ចែករំលែកព័ត៌មានដោយសេរី ព្រមទាំងផ្តល់ព័ត៌មានឱ្យគ្នាទៅវិញទៅមកជាប្រចាំ

- សកម្មក្នុងការស្វែងរកព័ត៌មាន និងលទ្ធផលពីសហគមន៍ដែលមានសាវតាផ្សេងៗគ្នាដោយឱ្យគាត់ចូលរួមក្នុងការដោះស្រាយបញ្ហា និងការធ្វើសេចក្តីសម្រេចចិត្ត
- ធ្វើការជាមួយអ្នកពាក់ព័ន្ធទាំងអស់ដើម្បីកសាងការប្តេជ្ញាចិត្តសម្រាប់ធ្វើសកម្មភាព :

- ធ្វើឱ្យប្រាកដថា មានការចែករំលែកការយល់ដឹងរួមលើបញ្ហាសំខាន់ៗ

- សម្របសម្រួលការពិភាក្សាដើម្បីបង្កើតការព្រមព្រៀង ឬការសម្រេចការយល់ព្រមពីអ្នកពាក់ព័ន្ធផ្សេងៗទៀត

- ប្រមើលមើលប្រតិកម្ម និងការជំទាស់ព្រមទាំងរៀបចំវិធីសាស្ត្រផ្សេងៗសម្រាប់ជំនះប្រតិកម្ម និងការជំទាស់ទាំងនោះ

## ៣. ជំនាញក្នុងការប្រាស្រ័យទាក់ទងដែលមានប្រសិទ្ធភាព(ការនិយាយដោយសង្ខេប ការស្តាប់ដោយយកចិត្តទុកដាក់ និងការសរសេររបាយការណ៍)

- ប្រើជំនាញស្តាប់ដែលមានឥទ្ធិពលរួមមាន :

- អបអរចំពោះការចូលរួមមតិយោបល់ពីអ្នកដទៃ

- សួរសំនួរដើម្បីទទួលបានព័ត៌មានថ្មីៗ ឬស្វែងរកការបញ្ជាក់បន្ថែម

- ផ្តោតការយកចិត្តទុកដាក់ទៅលើការប្រាស្រ័យទាក់ទងដោយកាយវិការ

-អធិប្បាយសាររបស់អ្នកដទៃឱ្យបានត្រឹមត្រូវ និងឆ្លើយតបឱ្យបានសមរម្យ

- ប្រើសេចក្តីវាងវៃ និងការយល់ដឹង នៅពេលដែលមានការប្រាស្រ័យទាក់ទងព័ត៌មានពីគ្នាទៅវិញទៅមក (សូមមើលលើការគោរព) :

- សុំឱ្យអ្នកដទៃផ្តល់ព័ត៌មានត្រលប់

- ផ្តល់ព័ត៌មានត្រលប់ និងផ្តល់យោបល់នៅក្នុងលក្ខណៈដែលមិនបង្កើនការការពារខ្លួន ឬការស្តីបន្ទោស

- សម្រួលភាសានិយាយឱ្យត្រូវតាមតម្រូវការនៃក្រុមផ្សេងៗគ្នា (ឧ. ក្រុមមនុស្សចាស់ ក្រុមជនពិការ ក្រុមជនក្រីក្រ និងក្រុមស្ត្រីមេម៉ាយ)

- ផ្តល់យោបល់ និងព័ត៌មានឱ្យច្បាស់លាស់ និងត្រឹមត្រូវមានហេតុផលសមស្រប :

<u>ការប្រាស្រ័យទាក់ទងដោយការនិយាយ</u>

- រៀបចំ និងបង្ហាញគំនិតយោបល់ឱ្យបានច្បាស់ សង្ខេបឱ្យបានត្រឹមត្រូវដោយមានហេតុផលសមស្រប
- ប្រាស្រ័យទាក់ទងក្នុងលក្ខណៈផ្សារភ្ជាប់គ្នាទាំងក្នុងករណីរវាងពីម្នាក់ទៅម្នាក់ និងក្នុងបរិបទនៃក្រុម
- បង្ហាញពីការយល់ពីអារម្មណ៍របស់អ្នកដទៃ
- សម្រួលការប្រើប្រាស់ភាសារបស់អ្នក (ជៀសវាងការប្រើពាក្យបច្ចេកទេស) សម្រាប់ក្រុមផ្សេងៗ ដើម្បីឱ្យប្រាកដថាអ្នកស្តាប់អាចយល់បាន
- ប្រើវិធីនិយាយដើម្បីលើកទឹកចិត្តឱ្យអ្នកស្តាប់បើកចិត្តទទួលយក

<u>ការប្រាស្រ័យទាក់ទងដោយការសរសេរ</u>

- ផ្តល់សារជាអក្សរឱ្យបានច្បាស់លាស់ និងត្រឹមត្រូវតាមតក្កៈ
- រក្សាសៀវភៅវាយឈ្មោះ និងអាស័យដ្ឋាន (នៃការអប់រំ កិច្ចការសង្គម វេជ្ជសាស្ត្រ នីត្យានុកូល វិជ្ជាជីវៈ)
- រក្សា និងតាមដានជាប្រចាំនូវរចនាសម្ព័ន្ធគាំទ្រដែលអាចមានដូចជាអាហារូបករណ៍មូលនិធិឃុំ សង្កាត់ មូលនិធិគណៈកម្មាធិការវត្ត មូលនិធិសង្គ្រោះបន្ទាន់សម្រាប់ថ្នាក់ខេត្ត និងស្រុក ធនធានឥណទានខ្នាតតូចដែលអាចប្រើប្រាស់បាននៅថ្នាក់ឃុំ ស្រុក និងខេត្ត
- រក្សា និងផ្សព្វផ្សាយឯកសារជាសារធារណៈ

## ៤. ការសម្របសម្រួល

- រៀបចំអោយមានការប្រជុំដោយជោគជ័យ :

- រៀបចំរបៀបវារៈ ព្រមទាំងកំណត់គោលបំណង និងការរំពឹងទុកពីលទ្ធផលនៃការប្រជុំ
- ដាក់ផែនការថាតើគួរប្រើអស់រយៈពេលប៉ុន្មានក្នុងការប្រជុំ ហើយត្រូវតែឧប្រាកដថាបញ្ហាសំខាន់ៗត្រូវផ្តល់ជាអាទិភាពក្នុងពេលប្រជុំនោះ
- ផ្តល់ការសង្ខេបយ៉ាងខ្លីទៅលើការសម្រេចចិត្ត និងអ្វីត្រូវធ្វើបន្តបន្ទាប់ក្រោយពេលចប់ការពិភាក្សានៅក្នុងរបៀបវារៈនីមួយៗ

- បង្កើតវិន័យសាមញ្ញៗ បី ឬ បួន
- ជួយឱ្យមានលំហូរព័ត៌មាន និងត្រូវអោយប្រាកដថាការចូលរួមមានភាពពេញលេញ និងមានតុល្យភាព ធ្វើឱ្យច្បាស់ថាអ្នកចូលរួមទាំងអស់អាចមានឱកាសចូលរួមគំនិតយោបល់( មិនមែនតែមនុស្សម្នាក់ត្រួតត្រាលើការពិភាក្សានោះទេ) បង្ហាញពីការអត់ធ្មត់ និងឆន្ទៈក្នុងការស្តាប់ទៅលើទស្សនៈគ្រប់ៗគ្នា

- ការចាត់ចែងដំណើរការក្រុម :
  - ព្យាយាមយល់ពីថាមពលក្រុម និងការបង្កើតក្រុម
  - រៀបចំ និងចាត់ចែងរបៀបរាយការណ៍ការងារតាមក្រុម និងជាលក្ខណៈបុគ្គល
  - កំណត់ និងធ្វើការជាមួយយុទ្ធសាស្ត្រដែលរារាំង ( ឧទាហរណ៍ ការស្តីបន្ទោស បក្សពួក និងសម្ព័ន្ធមិត្ត)
  - ធ្វើឱ្យការចូលរួមមានភាពស្មើគ្នាឱ្យបានច្រើនបំផុត
  - ធ្វើឱ្យមានតុល្យភាពរវាងតម្រូវការបុគ្គល និងក្រុមជាមួយការបំពេញការងារ
  - រំលេចឡើងនូវមតិផ្សេងៗគ្នាក្នុងលក្ខណៈស្ថាបនា និងស្វែងរកដំណោះស្រាយ ឈ្នះ-ឈ្នះ
- បង្កើនឱ្យមានការចូលរួម និងផ្តល់យោបល់ :
  - ចាត់ចែងការប្រជុំក្នុងបរិយាកាសមួយដែលមិនមានបុគ្គល ឬក្រុមណាមួយត្រួតត្រា
  - បង្កើនការចូលរួមក្នុងក្រុមជនដែលងាយរងគ្រោះ( កុមារ យុវជន ស្ត្រី ជនពិការ ក្រុមគ្រួសារ) ដែលឆ្លងមេរោគហ៊ីវ/អេដស៍ និងជនទីទាល់ក្រ ទោះបីជានៅក្នុងការប្រជុំជាសារធារណៈ ឬការងារឃុំ សង្កាត់ ។
  - និយាយក្នុងនាម ឬតស៊ូមតិសម្រាប់តម្រូវការរបស់ក្រុមជនងាយរងគ្រោះពេលចាំបាច់
  - ធ្វើឱ្យប្រាកដថាមានតុល្យភាពនៅក្នុងការប្រើប្រាស់សេវា ព្រមទាំងគុណភាពនៃការផ្តល់សេវាសំខាន់ៗ
- បង្កើនការរៀនសូត្របែបឆ្លុះបញ្ចាំងដែលបញ្ជាក់ពីសកម្មភាពទៅអនាគត :
  - សុំឱ្យគេផ្តល់ព័ត៌មានត្រលប់
  - លើកទឹកចិត្តសិក្ខាកាមឱ្យកំណត់រកភាពជោគជ័យ និងបញ្ហាប្រឈម
  - ផ្តល់ពេលឱ្យគ្រប់គ្រាន់ក្នុងការឆ្លុះបញ្ចាំងដើម្បីសំយោគមេរៀន និងធ្វើផែនការសកម្មភាព

## ការគ្រប់គ្រងទំនាក់ទំនង

## ៥. ការងារជាក្រុម

**<u>កំណត់ចំណាំ</u>**: សមត្ថកិច្ចនេះទាក់ទងជាពិសេសចំពោះមេឃុំ សង្កាត់នៅក្នុងការបង្កើត គ.ក.ន.ក

- កសាងការយល់ដឹង និងការប្តេជ្ញាចិត្តក្នុងចំណោមសមាជិក គ.ក.ន.ក ដើម្បីពង្រឹងតួនាទី និងការទទួលខុសត្រូវរបស់ពួកគាត់ ព្រមទាំងធ្វើឱ្យពួកគាត់យល់ដឹងពីរបៀប គ.ក.ន.ក ទាក់ទង ឬ រាយការណ៍ទៅក្រុមប្រឹក្សាឃុំ សង្កាត់
- បង្កើតទំនាក់ទំនងដែលគួរឱ្យទុកចិត្តជាមួយសមាជិក គ.ក.ន.ក ទាំងអស់ ដោយផ្អែកលើការគោរពគ្នាទៅវិញទៅមក :
  - ពន្យល់ឱ្យបានក្បោះក្បាយអំពីតួនាទីរបស់សមាជិកម្នាក់ៗអាចធ្វើដើម្បីគាំទ្រ គ.ក.ន.ក
  - សុំឱ្យសមាជិក គ.ក.ន.ក ទាំងអស់ផ្តល់ជាសំណូមពរ និងអនុសាសន៍
  - បញ្ជាក់ពីគំនិត និងអារម្មណ៍របស់អ្នកផ្សេងទៀត និងផ្តល់ការគាំទ្រនៅខណៈពេលដែលមានការចែករំលែកនូវគំនិត និងអារម្មណ៍ផ្ទាល់ខ្លួនផងដែរ
- ធ្វើការជាមួយសមាជិក គ.ក.ន.ក ទាំងអស់ ដើម្បីរៀបចំផែនការសកម្មភាពដឹកនាំសហគមន៍ ដែលឆ្លុះបញ្ចាំងពីការប្រឈមរបស់ស្ត្រី និងកុមារ ព្រមទាំងកំណត់រកសកម្មភាពដែលសមស្របបំផុត សម្រាប់ឆ្លើយតបចំពោះការប្រឈមទាំងនេះ
- បង្កើតគោលដៅជាក់លាក់សម្រាប់សមាជិកគណៈកម្មាធិការផ្សេងៗគ្នា ព្រមទាំងបង្កើតកាលវិភាគសម្រាប់ធ្វើរបាយការណ៍
- តម្រង់ទិសសមាជិកថ្មីអំពីតួនាទី និងការទទួលខុសត្រូវរបស់ គ.ក.ន.ក  ព្រមទាំងការរំពឹងទុកក្នុងការបំពេញការងារជាមួយគ្នា
- តាមដានត្រួតពិនិត្យ និងវាយតម្លៃស្នាដៃការងារនៅក្នុងការអនុវត្តកម្មវិធីវិនិយោគរបស់ឃុំ សង្កាត់ :
  - ពិនិត្យមើលជាប្រចាំចំពោះសកម្មភាពដែលបានគ្រោងទុក ត្រូវបានអនុវត្តទាន់ពេលវេលា និងត្រូវតាមខ្ទង់ថវិកា

- នៅពេលសកម្មភាពណាមួយមិនអាចសម្រេចបាន សួររកមូលហេតុនៃការខកខាននោះ ព្រមទាំងធ្វើការជាមួយសមាជិកគណៈកម្មាធិការពាក់ព័ន្ធ ដើម្បីចាត់វិធានការបង្ការ ឬ ដោះស្រាយ
- មានឆន្ទៈក្នុងការផ្តល់ ឬចែករំលែកកិត្តិយសចំពោះស្នាដៃការងារជាមួយសមាជិក គ.ក.ន.ក ផ្សេងទៀត
- បង្កើតបរិយាកាសបើកចំហរ ដែលជួយឱ្យសមាជិកគណៈកម្មាធិការទាំងអស់មានអារម្មណ៍រីករាយក្នុងការផ្តល់ព័ត៌មានត្រឡប់ និងលើកឡើងពីការបារម្ភណ៍ និងបញ្ហាដោយបើកចំហរ

## ៦. ជំរុញឱ្យមានការសម្របសម្រួល និងកិច្ចសហការ (ពីផ្នែកខាងក្រៅ)

- បង្កើតទំនាក់ទំនងដោយមានកិច្ចសហការជាមួយអង្គការពីខាងក្រៅដើម្បីធ្វើឱ្យសម្រេចគោលដៅរបស់ គ.ក.ន.ក
- បង្ហាញឱ្យគេដឹងតាមរយៈការធ្វើសកម្មភាព (អនុវត្តផែនការសកម្មភាព) ៖
  - សិក្សាវាយតម្លៃ និងបកស្រាយតម្រូវការរបស់សហគមន៍ និងអង្គការផ្សេងៗទៀត
  - ឱ្យអ្នកពាក់ព័ន្ធទាំងអស់ចូលរួមនៅក្នុងដំណើរការពិគ្រោះយោបល់ និងការធ្វើសេចក្តីសម្រេចចិត្ត
  - សហការក្នុងការកំណត់រកមធ្យោបាយអនុវត្តឱ្យសម្រេចបានលទ្ធផល ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់អ្នកផ្សេងទៀត
  - សម្របសម្រួលឱ្យមានការព្រមព្រៀងលើការទទួលខុសត្រូវ និងការគាំទ្រតម្រូវការ
- ស្វែងរកឱកាសបង្កើតការគាំទ្រគ្នាទៅវិញទៅមកដើម្បីធ្វើឱ្យសម្រេចគោលបំណងរបស់ គ.ក.ន.ក ៖
  - ជួយកសាងការយល់ដឹង និងការព្រមព្រៀងលើផែនការការងារ (អ្វីខ្លះ និងហេតុអ្វី)
  - ស្គាល់ឱកាសដើម្បីបង្កើតទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព និងសហការជាមួយអង្គការខាងក្រៅ
  - នៅពេលដែលចង់ធ្វើឱ្យមានឥទ្ធិពលលើបញ្ហាគន្លឹះ ត្រូវរកមើលសម្ព័ន្ធមិត្តសំខាន់ៗ និងធ្វើឱ្យអ្នកផ្សេងទៀតចូលរួម
- បង្ហាញពីទំនុកចិត្តក្នុងការភ្ជាប់ទំនាក់ទំនងនៅក្នុងបរិបថសង្គម និងបរិបថការងារ (បណ្តាញការងារ) ៖
  - ទទួលស្គាល់ឱកាសក្នុងការបង្កើតទំនាក់ទំនងជាមួយគណៈកម្មាធិការផ្សេងទៀត មន្ទីរខ្សែបណ្តោយរបស់ក្រសួង និងអង្គការផ្សេងទៀត ព្រមទាំងធ្វើការជាមួយពួកគេ
  - បង្កើន និងពង្រឹងទំនាក់ទំនង កិច្ចសហការ និងការសម្របសម្រួលក្នុងចំណោមក្រុមប្រឹក្សាឃុំ សង្កាត់ អ្នកផ្តល់សេវាផ្សេងៗ និងប្រជាពលរដ្ឋ
  - ដឹងពីរបៀបបង្រួបបង្រួមរវាងអង្គការ និងប្រជាពលរដ្ឋ ហើយនាំឱ្យពួកគេធ្វើការជាមួយគ្នា។

## ៧. ការចរចា និងការធ្វើឱ្យមានឥទ្ធិពល

- ធ្វើការយ៉ាងសកម្មដើម្បីកសាង និងរក្សាទំនាក់ទំនងរវាងបុគ្គលដែលគួរឱ្យគោរព
- ដឹងពីពេលវេលាដែលចាំបាច់ និងសមស្របដើម្បីចរចារជាមួយភាគីផ្សេងៗទៀត :

 - ប្រើប្រាស់ការព្រមព្រៀង ដើម្បីបង្កើតគោលការណ៍រួម

 - ប្រើប្រាស់ការជំទាស់ក្នុងលក្ខណៈស្ថាបនា ដើម្បីផ្តោតទៅលើការពិភាក្សា

 - ពិភាក្សាដោយស្មោះត្រង់ និងតាមការយល់ដឹងរបស់ខ្លួនឯង ព្រមទាំងពិភាក្សាលើព័ត៌មានពិត

- បញ្ជាក់ឱ្យច្បាស់ពីស្ថានភាពបច្ចុប្បន្ន :

 - ស្វែងរកឱ្យឃើញពីតម្រូវការ កង្វល់ និងស្ថានភាពដើមដំបូងរបស់ភាគីទាំងអស់

 - ធ្វើឱ្យប្រាកដថា អ្នកពាក់ព័ន្ធទាំងអស់ បានយល់ដឹងច្បាស់ពីឱកាស និងកត្តារាំងស្ទះ

 - បញ្ជាក់ពីចំណុចយល់ព្រម និងចំណុចមិនយល់ព្រម

 - ស្វែងរកឱ្យឃើញភាពលំអៀងយេនឌ័រដែលអាចកើតមានឡើង

- អភិវឌ្ឍន៏រាល់គំនិតយោបល់ :

 - ផ្សារភ្ជាប់ការដោះស្រាយបញ្ហាទាំងសងខាង ដោយឱ្យគ្រប់ភាគីរីះរកដំណោះស្រាយម្តងម្នាក់

 - ធ្វើការរួមគ្នាដើម្បីវាយតំលៃ និងចាត់អាទិភាពជម្រើសទាំងឡាយ

- សម្របសម្រួលឱ្យមានការព្រមព្រៀង :

 - ធ្វើការរួមគ្នាដោយអញ្ជើញសិក្ខាកាមចូលរួមយោបល់ និងរក្សាការពិភាក្សាលើទស្សនៈផ្សេងៗដោយបើកចំហរ

 - គោរពតាមគំនិតយោបល់ទាំងឡាយរបស់ពួកគាត់ ដោយមិនធ្វើការវិនិច្ឆ័យ

 - ធ្វើឱ្យប្រាកដថា គំនិតខុសគ្នា មិនមែនដើម្បីប្រយោជន៏បុគ្គលទេ

 - បូកសរុបការរីកចម្រើននៃការពិភាក្សាជាដំណាក់ៗ និងបញ្ជាក់ពីចំណុចពិភាក្សាដែលនៅសល់ និងការធ្វើសេចក្តីសម្រេចចិត្ត

 - ពង្រឹងការប្តេជ្ញាចិត្ត និងគោរពចំពោះការសម្រេចចិត្តដែលបានធ្វើឡើង

 - ស្វែងរកដំណោះស្រាយ "ឈ្នះ-ឈ្នះ" (ផ្លូវកណ្តាល) ដែលទទួលស្គាល់ថាជាតម្រូវការរបស់ភាគីនីមួយៗ

 - មានការប្តេជ្ញាចិត្ត ពីអ្នកផ្សេងទៀតក្នុងការធ្វើការជាមួយដំណោះស្រាយដែលស្នើឡើង

## ៨. ការតស៊ូមតិ (ការជួយគាំទ្រ)

- បង្កើនការយល់ដឹងអំពីច្បាប់ និងគោលនយោបាយផ្សេងៗទៀតដែលទាក់ទងដល់សិទ្ធិស្ត្រី និងកុមារនៅក្នុងចំណោមប្រជាពលរដ្ឋនៅក្នុងឃុំ សង្កាត់
- និយាយក្នុងនាម ឬ ជួយគាំទ្រលើតម្រូវការរបស់ក្រុមងាយរងគ្រោះនៅពេលមានតម្រូវការ និងធានាឱ្យមានសមភាពក្នុងការការប្រើប្រាស់សេវា និងការទទួលបានសេវាសំខាន់ៗប្រកបដោយគុណភាព
- កំណត់រកប្រភពមូលនិធិសម្រាប់គាំទ្រការផ្តល់សេវាពីផ្នែកឯកជន និងអង្គការនានា ដើម្បីបំពេញគម្លាត
- រកឱ្យឃើញមនុស្សដែលបានទទួលឥទ្ធិពល ព្រមទាំងការចាប់អារម្មណ៍ និងទស្សនៈរបស់ពួកគេ ដែលទាក់ទងទៅនឹងបញ្ហានោះ
- រៀបចំរឿងរ៉ាវដែលគាំទ្រដោយទិន្នន័យជាមួយចំណុចគន្លឹះមួយចំនួនដែលបានកំណត់
- បង្កើតគំនិតជាក់លាក់អំពីលទ្ធផលដែលអាចធ្វើបាន និងជាលទ្ធផលដែលគួរឱ្យចង់បាន, អាចទទួលយកបាន និងមិនអាចទទួលយកបានច្រើនជាងគេបំផុត
- បង្ហាញឆន្ទៈក្នុងការធ្វើឱ្យសម្រេចបានលទ្ធផល"ឈ្នះឈ្នះ" ដោយប្រើប្រាស់ការព្រមព្រៀងដើម្បីសម្រេចឱ្យបានគោលការណ៍រួមមួយ និងការមិនព្រមព្រៀងឱ្យបើកការពិភាក្សា
- បង្ហាញពីសមត្ថភាពក្នុងការធ្វើឱ្យមានការព្រមព្រៀង ហើយពង្រឹងការប្តេជ្ញាចិត្ត និងគោរពចំពោះការសម្រេចចិត្តដែលបានធ្វើឡើង

<u>សូមមើលបន្ថែម</u> : ការចរចារ ការធ្វើឱ្យមានឥទ្ធិពល ព្រមទាំងការសម្របសម្រួល

## ការគ្រប់គ្រងលទ្ធផល

## ៩. ការធ្វើផែនការ និងការចាត់ចែង

- ប្រមូលទិន្នន័យ (ដឹកនាំការវិភាគស្ថានភាព):
  - ធ្វើការពិគ្រោះយោបល់ជាមួយសមាជិកសហគមន៍ និងសមាជិកគណៈកម្មាធិការផ្សេងៗទៀត (ឧ. ក្រុមទ្រទ្រង់សុខភាពភូមិ គណៈកម្មការវត្ត ឬក្រុមយុវជន) មន្ទីរខ្សែបណ្តោយក្រសួង និងអង្គការនានាដែលធ្វើការយ៉ាវសកម្មនៅក្នុងតំបន់នោះ
  - យល់ដឹងពីគំរូផែនការមូលដ្ឋាន ថវិកា និងការចំណាយរបស់ឃុំ សង្កាត់ និងដឹងថាផែនការទាំងនេះប៉ះពាល់ទៅនឹងការផ្តល់សេវាយ៉ាងដូចម្តេចខ្លះ
  - រកឃើញកត្តារាំងស្ទះសំខាន់ៗ ដែលប៉ះពាល់ដល់ការផ្តល់សេវា

- រៀបចំផែនការ និងថវិកាប្រចាំឆ្នាំ :

  - ផ្អែកទៅលើការវិភាគស្ថានភាព រៀបចំផែនការសកម្មភាពប្រចាំឆ្នាំដែលវាស់វែង និងអាចសម្រេចបាន

  - រៀបចំថវិកាឱ្យច្បាស់លាស់សម្រាប់ការអនុវត្តផែនការប្រចាំឆ្នាំ

  - ដាក់ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ ជូនទៅក្រុមប្រឹក្សាឃុំ សង្កាត់ដើម្បីអនុម័ត

- អនុវត្ត និងតាមដានត្រួតពិនិត្យផែនការ :

  - ទទួលស្គាល់ និងចាត់អាទិភាពការងារចាំបាច់ដែលត្រូវធ្វើ (តើអ្វីដែលចាំបាច់ត្រូវធ្វើមុននៅក្នុងផែនការ ហើយអ្វីដែលត្រូវធ្វើបន្ទាប់?)

  - បំពេញកិច្ចការឱ្យទាន់ពេលវេលា និងត្រឹមត្រូវតាមខ្ទង់ថវិកា

  - រក្សារការកត់ត្រាសកម្មភាព និងលទ្ធផលសំខាន់ៗឱ្យបានត្រឹមត្រូវ និងទៀងទាត់ ហើយថវិកានោះត្រូវចំណាយយ៉ាងដូចម្ដេច

## ១០. ការដោះស្រាយបញ្ហា (ការវិភាគជំរើស និងការបង្កើតសកម្មភាពសម្រាប់អនុវត្ត)

- កំណត់រកចំណុចខ្លាំង ចំណុចខ្សោយ ឱកាស និងការប្រឈមទៅលើសកម្មភាពជាក់លាក់ណាមួយ
- វិភាគឱ្យបានស៊ីជម្រៅអំពីទំនាក់ទំនងរវាងតម្រូវការអភិវឌ្ឍផ្សេងៗគ្នានៅក្នុងភូមិ ឃុំ និងកំណត់នូវការឆ្លើយតបឱ្យបានសមរម្យ
- ប្រើប្រាស់វិធីសាស្ត្រចូលរួមដើម្បីជម្រុញសហគមន៍ឱ្យប្រមូល និងវិភាគទិន្នន័យ និងគូសផែនទីសកម្មភាព

## ១១. ការគិតដោយវិភាគ និងការធ្វើសេចក្ដីសម្រេចចិត្ត

- សិក្សាវាយតម្លៃសកម្មភាព និងសេវាអភិវឌ្ឍសង្គមនៅថ្នាក់ឃុំ សង្កាត់ និងស្រុក
- រៀបចំ និងដឹងនាំការសិក្សាវាយតម្លៃដោយមានការចូលរួមភ្លាមៗ ដើម្បីប្រមូលទិន្នន័យដែលពាក់ព័ន្ធបញ្ហា និងតម្រូវការរបស់ស្ត្រី និងកុមារ
- វិភាគ និងដកស្រង់អត្ថន័យចេញពីទិន្នន័យបែបបរិមាណ និងស្ថិតិសំខាន់ៗ ហើយធ្វើការពិភាក្សា និងវិភាគព័ត៌មានទាំងនេះជាមួយសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ និងបង្កើតជាអនុសាសន៍ ដើម្បីរៀបចំសកម្មភាពសម្រាប់អនុវត្ត
- ចាត់ចំណាត់ថ្នាក់, ចាត់អាទិភាព, វិភាគ និងសំយោគព័ត៌មានទាំងនេះ ដើម្បីដាក់ចេញជាគោលការណ៍
- ផ្ដល់អនុសាសន៍ដែលអាចយកទៅប្រើប្រាស់បានដើម្បីដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់

- គាំទ្រការរៀបចំផែនការសកម្មភាពដែលផ្តោតទៅលើសហគមន៍ដោយផ្តោតលើការប្រឈមរបស់ស្ត្រី និងកុមារ ព្រមទាំងកំណត់ពីសកម្មភាពល្អបំផុត សម្រាប់បង្ហាញ
- តស៊ូមតិដើម្បីឱ្យស្ត្រីចូលរួមនៅក្នុងការធ្វើសេចក្តីសម្រេចចិត្តដែលទាក់ទងទៅនឹងការអភិវឌ្ឍឃុំ សង្កាត់

## ១២. ត្រួតពិនិត្យ និងរាយការណ៍ពីការអនុវត្តផែនការសកម្មភាព

- ចូលរួមក្នុងការត្រួតពិនិត្យ និងវាយតម្លៃផែនការសកម្មភាពឃុំ សង្កាត់ដែលពាក់ព័ន្ធស្ត្រី និងកុមារ
- ប្រមូលទិន្នន័យតាមរយៈរបាយការណ៍របស់មន្ទីរអប់រំ យុវជន និងកីឡា និងការិយាល័យ អប់រំស្រុក មណ្ឌលសុខភាព ព្រមទាំងទិន្នន័យមកពីការពិគ្រោះយោបល់នៅសហគមន៍ និងការធ្វើផែនទីសេវាសង្គម
- ប្រើប្រាស់ទិន្នន័យដើម្បីតាមដានត្រួតពិនិត្យ និងកត់ត្រាសូចនាករវិកចំរើនសម្រាប់ស្ត្រី និងកុមារក្នុងឃុំ សង្កាត់ ដោយរាប់បញ្ចូល :

  - ចំនួនទារកបានចុះបញ្ជីកំណើត ចំនួនកុមារបានចុះឈ្មោះចូលរៀនតាមអាយុកំណត់ ចំនួនកុមារក្នុងឃុំបោះបង់ការសិក្សា ចំនួនគ្រួសារបានចូលរួមយុទ្ធនាការចាក់ថ្នាំបង្ការ ចំនួនស្ត្រីមានផ្ទៃពោះដែលរស់នៅក្នុងឃុំ និងបានទៅស្វែងរកសេវាថែរក្សាសុខភាពម្តាយ និងទារកនៅមណ្ឌលសុខភាព សារៈសំខាន់នៃការចិញ្ចឹមកូនដោយទឹកដោះម្តាយ ចំនួនអំពើហិង្សាក្នុងគ្រួសារដែលបានកើតឡើង ចំនួនគ្រួសារងាយរងគ្រោះដែលតម្រូវឱ្យមានជំនួយជាពិសេស ចំនួនកំណើតដែលបានសំរាលដោយពេទ្យឆ្មប ចំនួនមាតាដែលមិនចិញ្ចឹមកូនដោយទឹកដោះម្តាយក្នុងកំឡុងពេល៦ខែដំបូង ការសម្រុះសម្រួល និងផ្តល់ការគាំទ្រលើបញ្ហាសង្គមដែលទាក់ទងនៅក្នុងឃុំ ។

- តាមដានតាមការការចាំបាច់ ឧទាហរណ៍ :

  - តាមដានមាតាបិតាដែលមិនទាន់ចុះបញ្ជីកំណើតឱ្យកូន និងមាតាបិតាដែលមិនទាន់យកកូនទៅចាក់ថ្នាំបង្ការជំងឺ៧មុខ, បញ្ជូនជនរងគ្រោះដែលត្រូវគេរំលោភទៅរកសេវាសង្គម ឬទៅប៉ូលីស, រកមូលនិធិដែលអាចប្រើប្រាស់បាន ជាឧទាហរណ៍ ថវិកាសម្រាប់ទិញឯកសណ្ឋានសាលាឱ្យកុមារកំព្រា និងកុមារងាយរងគ្រោះ ឬថវិកាសម្រាប់ក្រុមគ្រួសារដែលរងគ្រោះដោយទឹកជំនន់ ។

- បង្កើត និងថែរក្សា(បីខែម្តង) សៀវភៅបញ្ជីឈ្មោះសេវាដែលពាក់ព័ន្ធ ដោយរាប់បញ្ចូលព័ត៌មានអំពី :

  - សេវាពិគ្រោះយោបល់ដល់ផ្ទះ មណ្ឌលសុខភាព សាលារៀន ។ល ។ ដែលអាចប្រើប្រាស់បាននៅក្នុងឃុំ សង្កាត់ ស្រុក និងខេត្ត, អ្នកធ្វើការងារសង្គមថ្នាក់ស្រុក និងមន្ទីរពេទ្យបង្អែកក្នុងឃុំ មូលនិធិ ឬយន្តការគាំទ្រនានាដែលអាចប្រើប្រាស់បានសម្រាប់ស្ត្រី និងកុមារដែលងាយរងគ្រោះនៅក្នុងឃុំ (ឧ. មូលនិធិសង្គមសម្រាប់ការសង្គ្រោះបន្ទាន់, ធនធានសម្រាប់ការផ្គត់ផ្គង់ស្ត្រីមានផ្ទៃពោះដែលទាមទារឱ្យមានបំប៉នអាហារបន្ថែម, ជំនួយលើគ្រោះទឹកជំនន់ជាដើម ។) ព្រមទាំងសោហ៊ុយផ្លូវការ ឬមិនផ្លូវការសម្រាប់គ្រួសារក្រីក្របំផុតក្នុងការប្រើប្រាស់សេវាដែលមានការបង់ថ្លៃ ។

- រាយការណ៍ផ្ទាល់មាត់ទៅក្រុមប្រឹក្សាឃុំ សង្កាត់ និងដឹកនាំការពិភាក្សាអំពីរបកគំហើញដែលជាប់ពាក់ព័ន្ធ (ឧ. តើអាទិភាពក្នុងផែនការងារ ចាំបាច់ត្រូវកែសម្រួលដើម្បីឆ្លើយតបទៅនឹងរបកគំហើញដែរឬទេ? តើគួរត្រូវជូនដំណឹងអំពីរបកគំហើញនេះទៅអ្នកណា?)
- ធានាថា រាល់ព័ត៌មានដែលបានតាមដានត្រួតពិនិត្យទាំងអស់ ត្រូវបានដាក់ចូលយ៉ាងច្បាស់លាស់ និងដាក់លាក់ទៅក្នុងរបាយការណ៍ឃុំ សង្កាត់៕